# សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
## មហាវិទ្យាល័យអប់រំ

កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន កម្រិតបរិញ្ញាបត្រ

# ការអនុវត្ត
# យុទ្ធសាស្ត្រសហគមន៍សាលារៀនសម្រាប់មធ្យមសិក្សា





## កញ្ចប់សមត្ថភាពទី១
## ចំណេះដឹងឯកទេសបរិញ្ញាបត្រ





# មុខវិជ្ជាៈ
# ការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀនសម្រាប់មធ្យមសិក្សា

កញ្ចប់សមត្ថភាពទី ២

ចំណេះដឹងវិធីសាស្ត្រដឹកនាំ និងការគ្រប់គ្រងតាមសាលារៀន

## ការពណ៌នាអំពីមុខវិជ្ជា

មុខវិជ្ជាការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀនសម្រាប់មធ្យមសិក្សានេះ នឹងជួយអ្នកសិក្សាឲ្យស្វែងយល់ពីគោលការណ៍ គោលនយោបាយ និងការអនុវត្តផ្ទាល់ក្របខណ្ឌយុទ្ធសាស្ត្រសហគមន៍សាលារៀនដែលដាក់ចេញដោយក្រសួងអប់រំ យុវជន និងកីឡា សម្រាប់សាលារៀនមធ្យមសិក្សាអនុវត្ត។ អ្នកសិក្សានឹងស្វែងយល់ពីសារៈសំខាន់នៃការជម្រុញភាពជាដៃគូរក្នុងការអភិវឌ្ឍសាលារៀនពីសំណាក់ អាណាព្យាបាលសិស្ស និងសហគមន៍មូលដ្ឋាន ក្នុងការធ្វើឲ្យប្រសើរឡើងជាលំដាប់នូវលទ្ធផលសិក្សារបស់សិស្ស។ មុខវិជ្ជានេះក៏នឹងបង្ហាញឲ្យអ្នកសិក្សាបានយល់ច្បាស់ពីតួនាទីរបស់គណៈគ្រប់គ្រងសាលារៀន និងការអភិវឌ្ឍសាលារៀន។ ក្រោយបញ្ចប់មុខវិជ្ជានេះ អ្នកសិក្សានឹងបានយល់ច្បាស់ពីគោលការណ៍ និងគោលនយោបាយពាក់ព័ន្ធនឹងកំណែទម្រង់អប់រំផ្សាភ្ជាប់នឹងក្របខណ្ឌយុទ្ធសាស្ត្រសហគមន៍សាលារៀនសម្រាប់សាលារៀនមធ្យមសិក្សា។

## លទ្ធផលសិក្សារំពឹងទុក៖

*ក្រោយពីបញ្ចប់ការសិក្សាមុខវិជ្ជានេះដោយជោគជ័យអ្នកសិក្សានឹង៖*

លទ្ធផលសិក្សារំពឹងទុក១៖ យល់ពីវត្ថុបំណង និងក្របខណ្ឌការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀនក្នុងបរិបទកំណែទម្រង់អប់រំបច្ចុប្បន្ន។

លទ្ធផលសិក្សារំពឹងទុក២៖ សិក្សា និងវិភាគតួនាទីរបស់គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងសហគមន៍ ក្នុងការធ្វើឲ្យប្រសើរឡើងលទ្ធផលសិក្សារបស់សិស្ស។

លទ្ធផលសិក្សារំពឹងទុក៣៖ បន្ស៊ី និងបង្កើតយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀនទៅតាមបរិបទសាលារៀនជាក់ស្តែងយោងតាម យុទ្ធសាស្ត្រសហគមន៍សាលារៀន ដើម្បីបង្កើនការចូលរួមរបស់សហគមន៍។

## របាយតម្លៃសិក្សា

*ដើម្បីបំពេញគ្រប់លក្ខខណ្ឌបញ្ចប់ការសិក្សាមុខវិជ្ជានេះ អ្នកសិក្សាត្រូវ*

១. វត្តមានចូលសិក្សា ១០%

២. ការចូលរួមសកម្មភាពសិក្សា ២០%

៣. ការវាយតម្លៃកំឡុងពេលសិក្សា ៣០%

៤. ការប្រឡងបញ្ចប់មុខវិជ្ជាសិក្សា ៤០%

# អារម្ភកថា

ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦ នៃរដ្ឋសភា យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក្នុងចំណុចចតុកោណទី១ បានកំណត់យក "ការអភិវឌ្ឍធនធានមនុស្ស" មុំទី១ជាវិស័យអាទិភាព។ សាកលវិទ្យាល័យ-ភូមិន្ទភ្នំពេញដើរតួនាទីយ៉ាងសំខាន់ជាចំណែកមួយនៃការកែទម្រង់វិស័យអប់រំក្នុងការស្តារប្រព័ន្ធអប់រំជាតិឡើងវិញ តាមរយៈការផលិតអ្នកអប់រំដែលមានគុណភាពខ្ពស់។

នៅដើមអាណត្តិទី៦នេះ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវយុទ្ធសាស្ត្រកំណែទម្រង់ វិស័យអប់រំ ២០១៨-២០២៣ ដែលមានចក្ខុវិស័យ "កសាង និងអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើនផ្អែកចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន"។ ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក៏បានលើកឡើងពីតួនាទីយ៉ាងសំខាន់របស់គ្រូបង្រៀនក្នុងវិស័យអប់រំ និងសង្គមជាតិ ដោយបញ្ជាក់ថា "គុណភាពគ្រូ ជាគុណភាពមូលធនមនុស្ស សម្រាប់ ការអភិវឌ្ឍប្រកបដោយចីរភាព" ដែលប្រែក្លាយប្រទេសមានប្រាក់ចំណូល មធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងប្រទេសអភិវឌ្ឍន៍ក្នុងឆ្នាំ២០៥០។

ដើម្បីឆ្លើយតបនឹងផែនការយុទ្ធសាស្ត្រ និងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា រួមជាមួយនឹងកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា សាកលវិទ្យាល័យភូមិន្ទភ្នំពេញបានទទួលភារកិច្ចបន្ថែមទៀត តាមរយៈការអនុវត្តគម្រោងកែលម្អការអប់រំនៅកម្រិតមធ្យមសិក្សា និងបន្តអនុវត្តគម្រោងកែលម្អការអប់រំចំណេះទូទៅរយៈពេលបួនឆ្នាំបន្តទៀត ចាប់ពីឆ្នាំ២០២២-២០២៦។ ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សាបានដឹកនាំ និងផ្តល់អនុសាសន៍យ៉ាងច្រើន ដែលធ្វើឱ្យគម្រោងប្រព្រឹត្តទៅដោយរលូន និង ជោគជ័យ។

គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សារៀបចំឡើង ដើម្បីលើកកម្ពស់គុណវុឌ្ឍិគ្រូឯកទេសលើមុខវិជ្ជាគោល៦ តាមគ្រឹះស្ថានមធ្យមសិក្សាគោលដៅ។ សាកលវិទ្យាល័យភូមិន្ទភ្នំពេញទទួលបណ្តុះបណ្តាលក្របខណ្ឌកម្មវិធីកម្រិតបរិញ្ញាបត្រអប់រំដល់នាយកសាលារៀន និងគ្រូឯកទេសដែលពុំទាន់មានសញ្ញាបត្របរិញ្ញាបត្រ ឬមានសញ្ញាបត្រខុសឯកទេសនៅតាមគ្រឹះស្ថានមធ្យមសិក្សាចំនួន១០០ នៅក្នុងគោលដៅគម្រោងនៅប្រទេសកម្ពុជា។ ដើម្បីពង្រីកវិសាលភាពនៃកំណែទម្រង់អប់រំ គម្រោងកែលម្អការអប់រំចំណេះទូទៅ ដែលប្រើប្រាស់យុទ្ធសាស្ត្រសហគមន៍សាលារៀនជាយុទ្ធសាស្ត្រស្នូលក្នុងការអនុវត្ត បានលេចរូបរាងឡើងក្នុងគោលបំណងបណ្តុះបណ្តាលនាយកសាលា និងគ្រូបង្រៀនចំនួនប្រមាណ ១៧០០០ នាក់ ដែលមកពី ១៧០០សាលា ក្នុងអនុវិស័យបី រួមមាន កុមារតូច បឋមសិក្សា និងមធ្យមសិក្សា។ មហាវិទ្យាល័យអប់រំក៏ត្រូវសហការផងដែរ ជាមួយស្ថាប័ន បណ្តុះបណ្តាលគ្រូទាំងអស់ ដើម្បីឈានទៅបង្កើតស្តង់ដាគុណភាពរួមមួយក្នុងការអប់រំគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលាឱ្យបានទូលំទូលាយ។ ដើម្បីឈានទៅសម្រេចបានការអនុវត្តគម្រោងថ្មីនេះ មហាវិទ្យាល័យត្រូវមានយុទ្ធសាស្ត្ររយៈពេលវែងមួយ សម្រាប់ឆ្នាំ ២០២១-២០៣០ ដើម្បីជាមគ្គុទេសបង្ហាញផ្លូវ។

សៀវភៅសិក្សាគោលយុទ្ធសាស្ត្រសហគមន៍សាលារៀននេះ បានរៀបចំឡើងជាការឆ្លើយតបជាមួយតម្រូវការដែលអ្នកសិក្សាជានាយក និងគ្រូបង្រៀនក្នុងគម្រោងកែលម្អការអប់រំចំណេះទូទៅដើម្បីធ្វើការស្វ័យសិក្សាលើខ្លឹមសារសំខាន់ៗ នៃយុទ្ធសាស្ត្រសហគមន៍សាលារៀន ដែលការស្វ័យសិក្សានេះបានភ្ជាប់មកជាមួយសំណួរស្វ័យសិក្សា ដែល

បញ្ជាក់ពីកម្រិតយល់ដឹងពីខ្លឹមសារគោលនីមួយៗនៃយុទ្ធសាស្ត្រសហគមន៍សាលារៀន។ តាមរយៈសៀវភៅសិក្សាគោលនេះ អ្នកសិក្សាក្នុងគម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP) និងគ្រឹះស្ថានបណ្តុះបណ្តាលឯទៀតអាចយកជាប្រយោជន៍ក្នុងការអនុវត្តកំណែទម្រង់សាលារៀន ដែលយកសហគមន៍ជាធនធានគោល ដើម្បីអភិវឌ្ឍន៍សាលារៀនឱ្យឈានទៅរកសាលារៀនជាប់ស្តង់ដាសហគមន៍សាលារៀន។

ទន្ទឹមនឹងនេះ វាជាឯកសារដែលឆ្លុះបញ្ចាំងពីមេរៀន បទពិសោធន៍នៃការអនុវត្ត និងផលសម្រេចជាក់ស្តែង និងជាឯកសាររស់ដែលមានលក្ខណៈបើកទូលាយឱ្យមានការកែលម្អបន្ថែមផ្អែកលើការរៀនពីការអនុវត្ត ដែលនាំមកនូវលទ្ធផលវិជ្ជមាន។ ឯកសារនេះមានខ្លឹមសារ ដែលជាអត្ថប្រយោជន៍សម្រាប់ប្រើប្រាស់ក្នុងពេល ដែលបានអនុវត្តន៍កន្លងមក និងបន្តប្រើប្រាស់ក្នុងពេលបច្ចុប្បន្ន ហើយអាចនឹងប្រើប្រាស់សម្រាប់អនាគត ឬអាចនឹងកែសម្រួលបន្ថែមឱ្យសមស្របតាមកាលៈទេសៈ និងល្បឿននៃការអភិវឌ្ឍក្នុងសង្គមជាតិ។

សាកលវិទ្យាល័យភូមិន្ទភ្នំពេញមានជំនឿយ៉ាងមុតមាំ ក្នុងការរៀបចំក្របខណ្ឌកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ក្រោមគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សាពិតជាដើរតួនាទីយ៉ាងសំខាន់ និងឆ្លើយតបទៅនឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា និងបេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងការកសាងធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព និងក្រមសីលធម៌។ យើងនឹងបន្តការខិតខំប្រឹងប្រែងក្នុងការអនុវត្តគម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP) ឱ្យបានកាន់តែប្រសើរជាមួយនឹងសៀវភៅសិក្សាគោលយុទ្ធសាស្ត្រសហគមន៍សាលារៀន និងឧត្តមានុវត្តន៍ផ្សេងៗដែលបានចងក្រង។

ខ្ញុំសូមថ្លែងអំណរគុណ និងសូមកោតសរសើរចំពោះក្រុមការងារដែលបានខិតខំកសាងក្របខណ្ឌកម្មវិធីឱ្យទទួលបានលទ្ធផលល្អ។

ថ្ងៃ ពុធ [illegible] ខែ [illegible] ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កក្កដា ឆ្នាំ២០២២

**សាកលវិទ្យាធិការ**

**បណ្ឌិត ជេត ជាលី**

## រចនាសម្ព័ន្ធកម្មវិធីសិក្សា

កម្មវិធីសិក្សាកម្រិតបរិញ្ញាបត្រអប់រំមានចំនួន ៦៣ ក្រេឌីត ដោយបញ្ចូលការសិក្សាលើមុខវិជ្ជាសិក្សា ការចូលរួមវគ្គសិក្ខាសាលាជាបន្តបន្ទាប់ ការអនុវត្តផ្ទាល់ និងការចងក្រងរបាយការណ៍ស្រាវជ្រាវ។ ដោយសារអ្នកសិក្សាក្នុង កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនបានបំពេញគុណវុឌ្ឍិចំនួន ៦៣ ក្រេឌីត។ (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៣៦ ក្រេឌីត) (២)ចំណេះដឹងវិធីសាស្ត្រដឹកនាំ និងការគ្រប់គ្រងតាមសាលារៀន (១២ (+៣) ក្រេឌីត) (៣)ហ្វឹកហាត់កម្មសិក្សា និងការអនុវត្តជាក់ស្តែង (១២ ក្រេឌីត)។

ការចូលរួមសិក្ខាសាលាតម្រូវឱ្យនិស្សិត/អ្នកសិក្សារៀនបន្ថែម និងចែករំលែកបទពិសោធអំពីការអនុវត្តការងារនៅសាលារៀន។ ការអនុវត្តផ្ទាល់ គឺភ្ជាប់និស្សិត/អ្នកសិក្សាទៅនឹងការបំពេញកិច្ចការអនុវត្ត ដើម្បីចងក្រងបទពិសោធនៃការបំពេញការងារផ្អែកលើលទ្ធផល។ របាយការណ៍ស្រាវជ្រាវតម្រូវឱ្យនិស្សិត/អ្នកសិក្សាចងក្រងនូវបទពិសោធដែលអនុវត្តការងារប្រកបដោយផលសម្រេច។

| កញ្ចប់សមត្ថភាព | ចំនួនមុខវិជ្ជា | ចំនួនក្រេឌីត |
|---|---|---|
| (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៦០%) | ១២ មុខវិជ្ជា | ៣៦ |
| (២)ចំណេះដឹងវិធីសាស្ត្រដឹកនាំ និងការគ្រប់គ្រងតាមសាលារៀន (២០%) | ៤(+១) មុខវិជ្ជា | ១២ (+៣) |
| (៣)ហ្វឹកហាត់កម្មសិក្សានិងការអនុវត្តជាក់ស្តែង (២០%) | ៣ មុខវិជ្ជា | ១២ |
| សរុប | ២០ | ៦៣ |

## ក្របខណ្ឌកម្មវិធីសិក្សាបរិញ្ញាបត្រអប់រំ

មុខវិជ្ជាសិក្សាសម្រាប់កម្រិតបរិញ្ញាបត្រអប់រំនេះនឹងជួយឱ្យនិស្សិត/អ្នកសិក្សាបំពេញកញ្ចប់សមត្ថភាពដូចខាងក្រោមដើម្បីឆ្លើយតបនឹងលទ្ធផលសិក្សាកម្មវិធីអប់រំហើយឱ្យនិស្សិត/អ្នកសិក្សាមានសមត្ថភាពសម្រាប់បំពេញការងារប្រកបដោយវិជ្ជាជីវៈ។

| កញ្ចប់សមត្ថភាព | មុខវិជ្ជាសិក្សា | ចំនួនក្រេឌីត |
|---|---|---|
| (១)ចំណេះដឹងឯកទេស កម្រិតបរិញ្ញាបត្រ ៣៦ ក្រេឌីត(៦០%) | ចិត្តវិទ្យាអប់រំ | ៣ |
| | មូលដ្ឋានគ្រឹះអប់រំ | ៣ |
| | ការប្រើប្រាស់កុំព្យូទ័រ និងបច្ចេកវិទ្យាឌីជីថលសម្រាប់ការអប់រំ | ៣ |
| | ភាសាអង់គ្លេសសម្រាប់ការអប់រំ | ៣ |
| | មូលដ្ឋានគ្រឹះនៃវង្វាយតម្លៃអប់រំ | ៣ |
| | មូលដ្ឋានគ្រឹះការស្រាវជ្រាវប្រតិបត្តិ | ៣ |
| | វិធីសាស្ត្រស្រាវជ្រាវ | ៣ |
| | ការគ្រប់គ្រងការរៀន និងបង្រៀន | ៣ |

| | | |
|---|---|---|
| | ភាពជាអ្នកដឹកនាំក្នុងការគ្រប់គ្រងសាលារៀននិងរដ្ឋបាលសាលារៀន | ៣ |
| | ការសិក្សាពហុវិន័យនៅមធ្យមសិក្សា | ៣ |
| | ការអប់រំអំពីបម្រែបម្រួលអាកាសធាតុនៅមធ្យមសិក្សា | ៣ |
| | បញ្ញត្តិ និងគោលការណ៍ការអនុវត្តការគ្រប់គ្រងតាមសាលារៀន | ៣ |
| (២)ចំណេះដឹងវិធីសាស្ត្រដឹកនាំ និងការគ្រប់គ្រងតាមសាលារៀន ១២ (+៣) ក្រេឌីត (២០%) | ការគ្រប់គ្រង និងការវិភាគទិន្នន័យអប់រំ | ៣ |
| | ការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ការអប់រំ | ៣ |
| | ការគ្រប់គ្រង និងការអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំ | ៣ |
| | ដំណើរការ ការគ្រប់គ្រងសាលារៀននៅមធ្យមសិក្សា | ៣ |
| | ការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀនសម្រាប់មធ្យមសិក្សា | ៣ |
| (៣)ហ្វឹកហាត់កម្មសិក្សា និងការអនុវត្តជាក់ស្តែង ១២ ក្រឌីត (២០%) | ការពិនិត្យតាមដាន និងការវាយតម្លៃគ្រឹះស្ថានសិក្សា | ៣ |
| | ការធ្វើអធិការកិច្ចផ្ទៃក្នុងតាមសាលារៀន | ៣ |
| | ការសរសេររបាយការណ៍ស្រាវជ្រាវ | ៦ |
| សរុប | | ៦៣ |

## លំហូរបង្រៀន និងរៀន

**លំហូរបង្រៀននិងរៀន ១មេរៀន ឬកិច្ចការមួយ រួមជាមួយបំណិនមួយ និងចរិយាមួយ**



**ស្តង់ដាស្តង់ដាគណៈគ្រប់គ្រងសាលារៀននៃយុទ្ធសាស្ត្រសហគមន៍សាលារៀន**

**ស្តង់ដាទី១ និង ៤** សាលារៀនដំណើរការសម្រាប់ផលសម្រេចការអប់រំនិងការសិក្សារបស់សិស្ស និង ដំណើរការរដ្ឋបាល និងប្រតិបត្តិការសហគមន៍សាលារៀន។ក្នុងការបណ្តុះបណ្តាលលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលារៀនទាំងអស់ត្រូវបានណែនាំឱ្យអនុវត្តកិច្ចការដូចតទៅៈ

| | |
|---|---|
| ១ | កែលម្អការសិក្សារៀនសូត្ររបស់សិស្សពីថ្នាក់ទី៧ ដល់ទី១២ នាំឱ្យសិស្សអាចទទួលបានកម្រិតល្អ និងល្អប្រសើរលើមុខវិជ្ជាគោល។ |
| ២ | ផ្តោតការសិក្សារបស់សិស្សលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាជាអទិភាព ពិសេសនៅមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា។ |
| ៣ | អនុវត្តអនុសាសន៍របាយការណ៍ការគ្រប់គ្រងហិរញ្ញវត្ថុ និងសវនកម្ម។ |
| ៤ | ធ្វើឱ្យការសិក្សាមានភាពបន្សុីគ្នារវាងសាលាមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាដើម្បីឈានឆ្ពោះទៅឧត្តមសិក្សា។ |
| ៥ | បង្កើនប្រសិទ្ធផល និងកំណត់មុខសញ្ញាប្រើប្រាស់ធនធាន ដោយផ្តោតលើអទិភាពរបស់សាលារៀនដែលមានមូលដ្ឋានលើយុទ្ធសាស្ត្រ វប្បធម៌ និងគុណតម្លៃ។ |

**ការវាយតម្លៃលើការសិក្សា**

ការវាយតម្លៃលើការសិក្សារបស់និស្សិត/អ្នកសិក្សាគឺផ្តោតលើលទ្ធផលសិក្សាជាគោល។ ការវាយតម្លៃលើការសិក្សាមានបីដំណាក់កាលធំៗ គឺ (១) ការវាយតម្លៃលើការសិក្សាមុខវិជ្ជា (២) ការវាយតម្លៃលើការសរសេររបាយការណ៍ស្រាវជ្រាវ និង (៣) ការវាយតម្លៃសរុបដោយពិនិត្យលើការបំពេញគ្រប់លក្ខខណ្ឌសម្រាប់បញ្ចប់ការសិក្សា។

**គោលការណ៍វាយតម្លៃ**

គោលការណ៍រួមសម្រាប់ការវាយតម្លៃលើការសិក្សារបស់និស្សិត/អ្នកសិក្សាមានដូចតទៅៈ

១) និស្សិត/អ្នកសិក្សាតម្រូវឱ្យមានវត្តមានក្នុងការសិក្សាតាមមុខវិជ្ជានីមួយៗ មិនតិចជាង៧០%។ ក្នុងករណីអ្នកសិក្សាមានវត្តមានតិចជាង៧០% នឹងមិនត្រូវបានអនុញ្ញាតឱ្យប្រឡងបញ្ចប់មុខវិជ្ជានោះទេ។

២) ក្នុងករណីដែលនិស្សិត/អ្នកសិក្សាធ្លាក់មុខវិជ្ជាណាមួយក្នុងឆមាស នឹងមិនអនុញ្ញាតឱ្យបន្តការសិក្សាទៅឆ្នាំបន្ទាប់ និងប្រឡងបញ្ចប់ឡើយ។

៣) និស្សិត/អ្នកសិក្សាទាំងអស់ត្រូវធ្វើកិច្ចការស្រាវជ្រាវសំខាន់ៗតាមមុខវិជ្ជានីមួយៗ និងប្រគល់ជូនគ្រូឧទ្ទេសតាមមុខវិជ្ជាដែលបានកំណត់។

៤) និស្សិត/អ្នកសិក្សាត្រូវប្រឡងបញ្ចប់ការសិក្សាដែលធ្វើឡើងបន្ទាប់ពីចប់ឆមាសនីមួយៗ តាមការកំណត់ក្នុងកម្មវិធីសិក្សា។

៥) និស្សិត/អ្នកសិក្សាត្រូវចងក្រងឯកសារវឌ្ឍនភាពនៃកិច្ចការស្លួលរួមមានការហាត់ការ និងកម្មសិក្សាដែលផ្តោតលើ (ក) សកម្មភាពប្រតិបត្តិ (ខ) លទ្ធផលដែលសម្រេចបាន និង (គ) ការឆ្លុះបញ្ចាំង និងមេរៀនបទពិសោធន៍។

៦) និស្សិត/អ្នកសិក្សាត្រូវតែជាប់មធ្យមភាគនៃការសិក្សាមុខវិជ្ជានិងការធ្វើកម្មសិក្សា ដើម្បីទទួលការអនុញ្ញាតឱ្យការពាររបាយការណ៍ស្រាវជ្រាវ។

### ការផ្តល់ពិន្ទុ និងប្រព័ន្ធចំណាត់ថ្នាក់

និស្សិត/អ្នកសិក្សាអាចទទួលពិន្ទុចាប់ពី 00 ដល់ 100 ទៅតាមការវាយតម្លៃផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានកំណត់ក្នុងការសិក្សាមុខវិជ្ជា ការបំពេញកម្មសិក្សា និងការសរសេរនិងការការពាររបាយការណ៍។ ពិន្ទុដែលជាប់ត្រូវចាប់ផ្តើមពីមធ្យមភាគពិន្ទុ 50% ឬពិន្ទុនិទ្ទេស 2.00 ឡើងទៅ។

ពិន្ទុគឺកំណត់ពី 00.00 ដល់ 100 (មធ្យមភាគនៃពិន្ទុនិទ្ទេសសរុប ឬ Grade Point Average – GPA)។ រូបមន្តគណនារកមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) គឺមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) ស្មើផលបូកសរុបរវាងផលគុណនៃពិន្ទុនិទ្ទេស (Grade Point – P) និងតម្លៃក្រេឌីតដែលត្រូវយកនៃមុខវិជ្ជានីមួយៗ (Attempted Credit Value – C) ចែកនឹងផលបូកសរុបនៃតម្លៃក្រេឌីតដែលត្រូវយកគ្រប់មុខវិជ្ជា។

ប្រព័ន្ធចំណាត់ថ្នាក់កម្មវិធី គឺផ្អែកទៅលើតម្លៃនៃពិន្ទុអតិបរមា 100% និង 50% នៃពិន្ទុអប្បបរមា។ ប្រព័ន្ធដាក់ពិន្ទុនេះ ត្រូវបានបកប្រែទៅជា "ពិន្ទុជានិទ្ទេស" និង "ពិន្ទុជាតម្លៃលេខ" ដូចដែលពិពណ៌នាដូចខាងក្រោម៖

| ពិន្ទុជាភាគរយ% | និទ្ទេស | ពិន្ទុនិទ្ទេស | មូលវិចារណ៍ |
|---|---|---|---|
| 85%-100% | A | 4.00 | ល្អប្រសើរ |
| 80%-84% | B+ | 3.50 | ល្អណាស់ |
| 70%-79% | B | 3.00 | ល្អ |
| 65%-69% | C+ | 2.50 | ល្អបង្គួរ |
| 50%-64% | C | 2.00 | មធ្យម |
| <49% | F | 1.50 | ធ្លាក់ |

## គោលការណ៍ប្រតិបត្តិ

ដើម្បីធានានូវការផ្តល់សេវាអប់រំប្រកបដោយគុណភាព និងភាពស័ក្តសិទ្ធ មហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញអនុវត្តតាមគោលការណ៍ បទបញ្ញត្តិ និងបទដ្ឋានគតិយុត្តិរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងគោលការណ៍ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ជាមួយគ្នានេះដែរ និស្សិត/អ្នកសិក្សាម្នាក់ៗ ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងឈរលើស្មារតីស្មោះត្រង់ ទទួលខុសត្រូវខ្ពស់ និងភាពម្ចាស់ការ និងគោលការណ៍សុចរិតភាពនៃការសិក្សា។ សម្រាប់គោលការណ៍សុចរិតភាពនៃការសិក្សា និស្សិត/អ្នកសិក្សាម្នាក់ៗ ត្រូវបានវាយតម្លៃលើចំណុចសំខាន់ៗដូចខាងក្រោម៖

**ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយា**

ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់និស្សិត/អ្នកសិក្សាម្នាក់ៗ ត្រូវបានប្រមូលផ្តុំលើការគោរពវិន័យចាត់តាំង ការមករៀនទៀងទាត់ ការយកចិត្តទុកដាក់ក្នុងការសិក្សា ការខិតខំស្រាវជ្រាវ ការអនុវត្ត ភារកិច្ច និងស្មារតីសាមគ្គីភាពនៅក្នុងថ្នាក់ ក្នុងសាលារៀន និងក្រៅសាលារៀន។ ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់និស្សិតម្នាក់ៗ ត្រូវបានធ្វើឡើងតាមរយៈយោបល់ឯកភាពពីមតិភាគច្រើនដាច់ខាតរបស់ក្រុមប្រឹក្សាវិន័យ ដោយផ្អែកលើលក្ខណសម្បត្តិជាក់ស្តែងរបស់និស្សិត/អ្នកសិក្សាម្នាក់ៗ និងបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

**ការក្លែងបន្លំឯកសារ**

និស្សិត/អ្នកសិក្សាដែលក្លែងបន្លំឯកសារ នឹងត្រូវលុបឈ្មោះចេញពីបញ្ជីនិស្សិតដោយស្វ័យប្រវត្តិ ព្រមទាំងទទួលទោសតាមច្បាប់ជាធរមាន។ និស្សិតត្រូវចាំថា ការលួចចម្លងស្នាដៃ ការលួចកម្មសិទ្ធិបញ្ញា និងគំនិតរបស់អ្នកដទៃគឺជាបទល្មើសសិក្សាធ្ងន់ធ្ងរដែលអាចឈានដល់ការបញ្ឈប់និស្សិតដែលប្រព្រឹត្តបទល្មើសពីកម្មវិធី។ និស្សិត/អ្នកសិក្សានឹងត្រូវធ្លាក់ជាស្ថាពរ បើនិស្សិត/អ្នកសិក្សារូបណាចម្លងដោយផ្ទាល់ពីនិស្សិតដទៃទៀត ឬប្រភពផ្សេងៗ ឬការប្រើសម្ភារៈ ឬឯកសារផ្សេងទៀត ដែលមិនត្រូវបានអនុញ្ញាតក្នុងការប្រឡង។

**របាយការណ៍/កិច្ចការស្រាវជ្រាវ**

និស្សិត/អ្នកសិក្សាត្រូវបង្ហាញនូវសុចរិតភាពនៃការស្រាវជ្រាវរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួនចាប់តាំងពីពេលចូលរៀនរហូតដល់ចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាល។ រាល់សំណេរការងារសិក្សាទាំងអស់ មិនត្រូវដកស្រង់គំនិត សរសេរ ឬចម្លងស្នាដៃផ្សេងៗរបស់អ្នកដទៃមកធ្វើជាគំនិតជាស្នាដៃ ឬជាកម្មសិទ្ធិរបស់ខ្លួនដោយគ្មានការបញ្ជាក់ពីប្រភពច្បាស់លាស់នៃឯកសារយោង ឯកសារពិគ្រោះ ឬការអនុញ្ញាតពីម្ចាស់ប្រភព។

ក្នុងករណីរកឃើញមានការលួចចម្លងស្នាដៃអ្នកដទៃ និស្សិត/អ្នកសិក្សានឹងត្រូវប្រឈមមុខចំពោះក្រុមប្រឹក្សា បច្ចេកទេស និងក្រុមប្រឹក្សាវិន័យរបស់មហាវិទ្យាល័យអប់រំ ឬសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដោយត្រូវទទួលពិន័យឱ្យរៀនត្រួតថ្នាក់ ឬអាចត្រូវបញ្ឈប់ពីកម្មវិធីដោយគ្មានសំណងប្រាក់សិក្សាដែលបានបង់រួចហើយទេ និងមិនមានការចេញលិខិតស្នាមបញ្ជាក់ការសិក្សាអ្វីដែរ។

**សំគាល់៖** កម្មវិធីបណ្តុះបណ្តាលសូមរក្សាសិទ្ធិក្នុងការកែប្រែការអនុវត្តជាក់ស្តែងដើម្បីឆ្លើយតបនឹងភាពការរៀននិងបង្រៀន សមត្ថភាពរៀន និងអនុវត្តជាក់ស្តែង ស្ថានភាពរៀននិងបង្រៀនជាក់ស្តែង ដើម្បីសម្រេចបានលទ្ធផលសិក្សាល្អបំផុត និងសម្រេចស្តង់ដាសហគមន៍សាលារៀននៃគម្រោង GEIP។

តើអ្នកចង់បាន អ្វីពីសិក្ខាសាលា ?

ប្រើពេលវេលា កសាងចំណេះដឹង ដែលចេញពី ពិសោធន៍ តាមការ អនុវត្តជាក់ស្តែង

នាំអ្នកមានឋាមពលមិន ចេះអស់ ព្រោះអ្នកក សាងបាននូវការភ្ញាក់ ដឹងខ្លួន និងការភ្ញាក់ ស្វែងយល់ពីការពិត របស់អ្នកនិងមនុស្សជុំ វិញ

13

តើអ្នកចង់បាន អ្វីពីសិក្ខាសាលា ?

តើគ្រួសារអាចឈប់ ក្រីក្រឬទេ៖ បើមានចំណេះដឹង បើមានលុយ និង មានសុខភាពផ្លូវចិត្ត

តើសាលារៀននិងសហ គមន៍អាចជួយគ្រួសារ ក្នុងសហគមន៍ឲ្យឈប់ ក្រីក្របានទេ ?

14


តើអ្នកចង់បាន
អ្វីពីសិក្ខា
សាលា ?
តើគ្រួសារអាចឈប់
ក្រីក្របានទេ
បើមានចំណេះដឹង
បើមានលុយ និង
មានសុខភាពផ្លូវចិត្ត
រស់ពេញលេញ
ដោយរីករាយ
តើសាលារៀននិងសហ
គមន៍អាចជួយគ្រួសារ
ក្នុងសហគមន៍ឲ្យឈប់
ក្រីក្របានទេ ?
តើនេះជាអ្វីអ្នកចង់បាន
ពីសិក្ខាសាលានេះ
ឬទេ ?

15


លុះណាអ្នក
គ្រប់គ្រងសតិ
អ្នកបាន
ភ្នែកនៅមើលឃើញ
ត្រចៀកនៅស្តាប់ឮ
ច្រមុះនៅដឹងខ្លិន
មាត់នៅដឹងរស់ជាតិ
ស្បែកនៅដឹងត្រជាក់ក្តៅ
នាំអ្នកប្រើពេល
វេលា
ប្រកបដោយ
ប៉ាមពលបាន

16


តែបើអ្នកគ្រប់គ្រងសតិមិនបាននោះអ្នកនឹងមាន៖
▪ ភ្នែកតែមើលមិនឃើញ
▪ ត្រចៀកតែស្តាប់មិនឮ
▪ ច្រមុះតែមិនដឹងក្លិន
▪ អណ្តាតតែមិនដឹងរស់ជាតិ
▪ ស្បែកមិនដឹងត្រជាក់ក្តៅ
ហើយនាំអ្នកធុញទ្រាន់នឹងពេលវេលានៃជីវិត ហើយរស់ជាមួយកាយឈឺ និងចិត្តឈឺ

17


តែបើអ្នកគ្រប់គ្រងសតិមិនបាននោះអ្នកនឹងមាន៖
វត្តមានរបស់អ្នកនៅទីនេះ មិនមែនដើម្បីអ្នកទេ តែដើម្បីកូនចៅរបស់អ្នក និងដើម្បីសង្គម និងប្រទេសជាតិរបស់អ្នក តើមែនទេ?

18


លំនាំនៃសិក្ខាសាលា
អនុវត្តប្រព័ន្ធគ្រប់គ្រង
ការអនុវត្តការងារ
សិក្សាស្វែងយល់ពីការងារ
2017
2018
2019
2020
រៀបចំផែនការអនុវត្តការងារ
អនុវត្តប្រព័ន្ធពិនិត្យតាមដាន វាយតម្លៃ
និងរាយការ

21

# កិច្ចព្រមព្រៀងផ្លូវការ គម្រោងGEIP និងយុទ្ធសាស្ត្រសហគមន៍សាលារៀន

1

***អាសន្ន?***

***ឬ***

***មិនអាសន្ន?***

2

*បើអាសន្ន ?*

*ប្តេជ្ញាចិត្តជួយសិស្សឲ្យរៀនចេះឬទេ ?*

3

*បើអាសន្ន ?*

*ប្តេជ្ញាចិត្តជួយសិស្សឲ្យរៀនចេះឬទេ ?*

*តើអាចធ្វើបានទេ ?*

*បើបានមានឧទាហរណ៍ជាក់ស្តែងថាធ្វើបាន ឬទេ ?*

4

## ១. បង្ហាញពីកិច្ចព្រមព្រៀងផ្លូវការ យុទ្ធសាស្ត្រចតុកោណ និងទំនាក់ទំនងកម្មវិធីកំណែទម្រង់

5



Kingdom of Cambodia
Nation Religion King

Royal Government
N° 41 OFP

Phnom Penh, 10 November 2021

**DELEGATION OF FULL POWERS**

- Having seen the Constitution of the Kingdom of Cambodia
- Having seen the Royal Decree No. NS/RKT/0918/925 dated September 06, 2018 on the Appointment of the Royal Government of the Kingdom Cambodia
- Having seen the Royal Decree No. NS/RKT/0320/421 dated March 30, 2020 on the Reorganization of the Royal Government of the Kingdom Cambodia
- Having seen the Royal Kram No. NS/RKM/0618/012 dated June 28, 2018 promulgating the law on the Organization and the Functioning of the Council of Ministers
- Having seen the Royal Kram No. NS/RKM/0196/18 dated January 24, 1996 promulgating the law on the Establishment of the Ministry of Economy and Finance
- Having seen the Royal Kram No. [illegible]016 dated May 13, 2008 promulgating the law on Public Financial System
- Having seen the Royal Kram No. NS/RKM/1220/038 dated December 25, 2020 on the 2021 Financial Management Law
- Referring to the request of the Ministry of Economy and Finance

**THE GOVERNMENT OF THE KINGDOM OF CAMBODIA**

Delegate herewith full powers to H.E. Dr. AUN PORNMONIROTH, Deputy Prime Minister, Minister of Economy and Finance, to negotiate, sign and deliver the Financing Agreement for "Cambodia General Education Improvement Project" between the Government of the Kingdom of Cambodia and the International Development Association. This power includes the power of delegation.

In witness whereof the undersigned, Samdech Akka Moha Sena Padei Techo HUN SEN, Prime Minister of the Government of the Kingdom of C[illegible] full powers duly entrusted to him, have signed this delegation of full power

Prime Minister

Samdech Akka Moha Sena Padei Techo HUN SEN

6

CREDIT NUMBER 7034-KH

**Financing Agreement**

(Cambodia General Education Improvement Project)

between

KINGDOM OF CAMBODIA

and

INTERNATIONAL DEVELOPMENT ASSOCIATION

AGREED as of the Signature Date.

KINGDOM OF CAMBODIA

By

Authorized Representative

Name: AUN PORN MONIROTH, Ph.D

Title: Deputy Prime Minister
Minister of Economy and Finance

Date: 01 - March - 2022

INTERNATIONAL DEVELOPMENT ASSOCIATION

By

Authorized Representative

Name: MIRYAM SALIM

Title: COUNTRY MANAGER

Date: 01 - March - 2022

7

«យុទ្ធសាស្ត្រចតុកោណ»

ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព ៖

កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០

ដំណាក់កាលទី ៤

របស់រាជរដ្ឋាភិបាល នីតិកាលទី ៦ នៃរដ្ឋសភា

8

<table>
<tr><td colspan="4">ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធិភាព<br>កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ២០២៥០</td></tr>
<tr><td colspan="4">យុទ្ធសាស្ត្រទី១ ការពង្រឹងគុណភាពអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា<br>ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ការកែលម្អរយេនឌ័រ សមធម៌ និងការពារសង្គម<br>ការពង្រីកសុខភាពសាធារណៈ និងអាហារូបត្ថម្ភ</td></tr>
<tr><td></td><td colspan="2">សន្តិភាព ស្ថេរភាពនយោបាយ<br>និងសណ្ដាប់ធ្នាប់សាធារណៈ</td><td></td></tr>
<tr><td rowspan="3">បរិយាកាសអំណោយផលសម្រេចធុរៈកិច្ច ការវិនិយោគ និងការអភិវឌ្ឍ</td><td>ការកែទម្រង់និងការលើកកម្ពស់សមត្ថភាពស្ថាបន</td><td>ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ</td><td rowspan="3">ការពង្រឹងភាពជាម្ចាស់ ភាពជាដៃគូក្នុងកិច្ចការអភិវឌ្ឍ និងសហប្រតិបត្តិការណ៍អន្តរជាតិ</td></tr>
<tr><td colspan="2">ការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ច</td></tr>
<tr><td>ការពង្រឹងប្រសិទ្ធភាពកអនុវត្តការងារ</td><td>ការពង្រឹងអភិបាលកិច្ចវិស័យឯកជន</td></tr>
<tr><td></td><td colspan="2">ការពង្រឹងសមត្ថភាពកម្ពុជាដើម្បីបន្តរជំរុញសមាហរណកម្មខ្លួនចូលក្នុងសេដ្ឋកិច្ចតំបន់ និងអន្តរជាតិ</td><td></td></tr>
</table>

**កម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដំណោះស្រាយតាមដំណាក់ការ**

ដំណាក់ទី៤
អន្តរសកម្មនៃគណនេយ្យភាព និងដំណើរនៃការពិនិត្យឡើងវិញ ទាំងហិរញ្ញវត្ថុ និងការអនុវត្ត

ផ្តល់លទ្ធភាព
គណនេយ្យភាពអនុវត្ត

រដ្ឋបាលៈ វាយតម្លៃពាក់កណ្តាលនិងចុងឆ្នាំ ចំណាយនិងលទ្ធផល

ដំណាក់ទី៣
ការផ្សារភ្ជាប់កាន់តែប្រសើររវាង អទិភាព និងក្រុមគោលដៅសេវា ជាមួយថវិកា និងការអនុវត្ត

ផ្តល់លទ្ធភាព
ផ្តោតលើអ្វីត្រូវធ្វើជាមួយលុយ

រដ្ឋបាលៈ កិច្ចព្រមព្រៀងលទ្ធផលឆ្នាំ ធ្វើកិច្ចការត្រូវធ្វើបានត្រឹមត្រូវ

ដំណាក់ទី២
ការចាប់ផ្តើមកែលម្អ ការត្រួតពិនិត្យផ្ទៃក្នុង និងការចាត់ឱ្យអ្នកគ្រប់គ្រងមានគណនេយ្យភាព

ផ្តលលទ្ធភាព
មូលដ្ឋានគណនេយ្យភាព

វិមជ្ឈការៈ ផ្តល់អំណាច ធ្វើកិច្ចការត្រូវធ្វើ

ដំណាក់ទី១
ថវិកាជឿជាក់បាន ដោយសារធនធានទាយទុកនិងផ្តល់ឱ្យទៅអ្នកគ្រប់គ្រងថវិកា

11

***សិស្សមានសិទ្ធិសួរថា តើរៀនធ្វើអីៈ***

***បើរៀនចប់ថ្នាក់ទី៦ នៅក្រៅក្រដដែល???***
***បើរៀនចប់ថ្នាក់ទី៩ នៅក្រក្រដដែល???***
***ចុះទ្រាំចប់ថ្នាក់ទី១២ នៅតែក្រក្រ???***
***ឬចប់បរិញ្ញាបត្រ ហើយនៅតែក្រក្រ ???***

***ចឹងហើយបានសិស្សមិនរៀន និងមិនចង់រៀន***

12

*មេរៀនថ្ងៃនាំអាចជួយអ្នកឲ្យអាចឆ្លើយសំនួរសិស្សថា «រៀនធ្វើអី ?»*

*តើអ្នកយល់ស្របទេថាសិស្សត្រូវរៀន ដើម្បី*

*បំបាត់ភាពក្រីក្រសង្គម ?*

*បំបាត់ភាពក្រីក្រសិក្សារៀនសូត្រ ?*

*បំបាត់ភាពក្រីក្រូបិយវត្ថុ (លុយ) ?*

*ហើយដែលនាំឱ្យគេ កសាងបាននូវបំណិនសតវត្សទី២១ រស់ជាមនុស្សពេញលេញនិងរីករាយ នៅកម្រិតមធ្យមសិក្សា ?*

13

**គម្រោងកែលម្អគុណភាពអប់រំចំណេះទូទៅ**

ប្រាក់កម្ចី៦០លានដុល្លា ពីធនាគារពិភពលោក និង

ជំនួយឥតសំណង១០លានដុល្លា ពីដៃគូសកលលោក

សម្រាប់អប់រំ

14

# ការជ្រើសរើសសាលាគោលដៅ

| ប្រភេទគ្រឹះស្ថានសិក្សារដ្ឋ | ចំនួនសាលាសរុប | ចំនួនសាលាគោលដៅ | ភាគរយសាលាគោលដៅ |
|---|---|---|---|
| ចំនួនមត្តេយ្យសិក្សារដ្ឋ | 213 | 213 | 100 |
| ចំនួនសាលាបឋមសិក្សា | 7,282 | 1,000 | 13.7 |
| ចំនួនសាលាមធ្យមសិក្សា | 1,791 | 420 | 23.5 |




15

# វត្ថុបំណងអភិវឌ្ឍន៍គម្រោង

- កែលម្អ គុណភាព និងសមធម៌ការអប់រំចំណេះទូទៅឲ្យសម្រេចបានស្តង់ដាអប្បបរិមានៅតំបន់គោលដៅ និងផ្តល់ជំនួយបន្ទាន់និងមានប្រសិទ្ធភាពដើម្បីឆ្លើយតបនឹងករណីមានបញ្ហាសមស្រប ឬ បន្ទាន់ដែលកើតឡើង។

16

## សូចនាករវត្ថុបំណងអភិវឌ្ឍន៍គម្រោង

១. លទ្ធផលសិក្សារបស់សិស្សដែលទទួលប្រយោជន៍ពីគម្រោងត្រូវបានកែលម្អ និងយកចិត្តទុកដាក់សមធម៌យេនឌ័រ

២. ភាគរយនៃសាលាគោលដៅនឹងទទួលបានស្តង់ដារអប្បបរិមាទៅតាមអនុវិស័យនីមួយៗ

- ភាគរយគ្រូបឋមសិក្សាអនុវត្តការបង្រៀនមានប្រសិទ្ធភាពលើមុខវិជ្ជាអំណាន និងគណិតវិទ្យា និងយកចិត្តទុកដាក់សមធម៌យេនឌ័រ

៣. កែលម្អបរិស្ថានសិក្សា សាងសង់ បន្ទប់សិក្សា បន្ទប់ពិសោធន៍ អគារសិក្សាសាលាគរុកោសល្យ អគារសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមណ្ឌល អគារសិក្សាអប់រំពិសេសពង្រីកសមធម៌ក្នុងការចូលរៀន និងជួសជុលបន្ទប់សិក្សា។

17

## លក្ខ័ណ្ឌហិរញ្ញប្បទានផ្អែកលើលទ្ធផល

18

## សូមប្រុងប្រយ័ត្នពី លក្ខខណ្ឌហិរញ្ញប្បទានផ្អែកលើលទ្ធផល
(Program Based Condition)

១. បើកលុយពីធនាគារពិភពលោក
២. ចាយលុយសម្រាប់អនុវត្តសកម្មភាព
៣. ផលិតផលសម្រេចតាមចំនួនក្រុមគោលដៅឆ្នាំ
៤. រាយការណ៍មកធនាគារពិភពលោក
៥. វាយតម្លៃលើរបាយការផលសម្រេច បើពិតមែន WB and GPE ផ្តល់លុយបន្ថែម
៦. តែបើមិនពិត ត្រូវសងលុយមកធនាគារពិភពលោក និងGPE វិញ

19

តារាងប្រព្រឹត្តផលសម្រាប់ពន្ធPBC

| PBC 1 | ភាគរយសាលារៀនបង្ហាញលទ្ធផលសិក្សាមុខវិជ្ជាគោលបានកើនឡើង |
|---|---|
| អធិប្បាយ | • សូចនាករនេះជាសូចនាករគុណភាព។ លទ្ធផលសិក្សាសិស្សកើនឡើងត្រូវបានវាស់ស្ទង់ដោយតេស្តស្តង់ដា ដោយសាលារៀនគោលដៅ មានសហគមន៍ និងរដ្ឋអំណាចចូលរួម។<br>• *គ្រូបង្រៀនមិនធ្វើតេស្ត និងផ្តល់ពិន្ទុដល់សិស្សរបស់ខ្លួនទេ គ្រូធ្វើតេស្តសិស្សដែលខ្លួនមិនបង្រៀនដោយមិនដឹងថាសិស្សណាទេ ដោយសារក្បាលក្រដាសតេស្តត្រូវបានកាច់ផ្តាច់។*<br>• *សំនួរតេស្តគឺជាសំនួរតេស្តដែលបានរៀបចំនៅក្នុងសន្លឹកកិច្ចការ ដែលបានចែកឱ្យសិស្សនៅឆ្នាំ២០២០ និង ២០២១ និងសំនួរតេស្តល្អៗដែលផលិតដោយគ្រូបង្រៀនបានចូលរួមផលិត ដោយមានការជួយពីនាយកដ្ឋានធានាគុណភាព និងគ្រូបង្គោលថ្នាក់ជាតិ នៅពេលគេទទួលការបំប៉ន ឬបង្កើនគុណវុឌ្ឍិ។ ធ្វើបែបនេះ ធានានូវលទ្ធផលសិក្សាជាក់ស្តែងរបស់សិស្ស ទៅតាមកម្មវិធីសិក្សាដែលបានផលិតនៅឆ្នាំ២០១៩។*<br>• *ឧបករណ៍តេស្តមាន (១) ឧបករណ៍តេស្តថ្នាក់ជាតិ (មុខវិជ្ជាគោលៈ ភាសាខ្មែរ និងគណិតវិទ្យា) ថ្នាក់ទី៦ សម្រាប់បឋមសិក្សា ឧបករណ៍តេស្តថ្នាក់ជាតិ (មុខវិជ្ជាគោលៈ ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ) ថ្នាក់ទី៨ សម្រាប់មធ្យមសិក្សា និងសៀវភៅតេស្តកុមារអាយុ៥ឆ្នាំ សម្រាប់សិស្សមត្តេយ្យសិក្សា។ សូចនាករនេះនឹងអាចរីកចម្រើនទៅតាមភាគរយសាលារៀនដែលបង្ហាញការកើនឡើងលទ្ធផលសិក្សាសិស្ស។* |

20

| តារាងប្រូតូកូលសម្រាប់ពិនិត្យ PBC | |
|---|---|
| PBC២ | ភាគរយសាលារៀនទទួលការគាំទ្រដោយការបង្វិក ដើម្បីកែលម្អដំណើរប្រតិបត្តិការណ៍សាលារៀន និងទទួលការគាំទ្រពីសហគមន៍ |
| អធិប្បាយ | • សូចនាករប្រសិទ្ធផលនេះជួយដល់សាលារៀនមានសមត្ថភាពប្រសើរជួយដល់សាលាទន់ខ្សោយ ប្រឹងប្រែងកែលម្អដំណើរប្រតិបត្តិការណ៍សាលារៀន បង្កើនការចូលរួម និងការជួយគាំទ្រពីសហគមន៍។<br>• *សកម្មភាពសម្រេចសូចនាករនេះជាការរៀបចំយុទ្ធសាស្ត្រជួយក្រសួងពង្រីកវិសាលភាពអនុវត្តដោយមានប្រសិទ្ធិផល និងរក្សាចីរភាពក្រោមគម្រោង។*<br>• *ដើម្បីអាចទទួល មូលនីធិ ជួយដល់សាលារៀនដ៏ទៃ សាលារៀនអនុវត្តកិច្ចការបង្វិកត្រូវតែបំពេញបាននូវ ស្តង់ដាសាលារៀនមានប្រសិទ្ធិភាព និងមានការប្តេជ្ញាចិត្តរំលែកបទពិសោធន៍ និងឧត្តមានុវត្តដល់សាលារៀនទន់ខ្សោយ។*<br>• *កិច្ចព្រមព្រៀងមូលនិធីនឹងត្រូវបានរៀបចំដោយសាលារៀនមានតួនាទីអនុវត្តកិច្ចការបង្វិក។* |

21

| តារាងប្រូតូកូលសម្រាប់ពិនិត្យ PBC | |
|---|---|
| PBC៣ | ភាគរយសាលារៀនមានផែនការជួយសិស្សរៀនយឺត និងសិស្សមានពិការភាព |
| អធិប្បាយ | • *សូចនាករសមធម៌នេះគាំទ្រដល់ការបង្រៀនពីការស្វែងរកសិស្សអាចមានពិការភាពនៅឆ្នាំទី២ និងតម្លៃចំណាយធ្វើដំណើរដល់គ្រូឧទ្ទេសថ្នាក់ជាតិ និងមន្ទីរអប់រំផ្តល់ការបង្វិកដល់សាលារៀន ដើម្បីធានាថានៅក្នុងផែនការសាលារៀនមានបញ្ចូលការជួយ និងការអនុវត្តនៅសាលារៀនបានជួយសិស្សរៀនយឺត និងកុមារមានពិការភាព។*<br>• *ដើម្បីសម្រេចបាននូវសូចនាករ ផែនការសាលារៀនត្រូវមានបញ្ចូលសកម្មភាព ជួយដល់សិស្សដែលរៀនយឺត និងកុមារមានមានពិការភាព មានអាយុចូលសាលារៀនបានទទួលនូវការអប់រំមានគុណភាព។* |

22

| សូចនាករ | ឆ្នាំ២០២២ | ក្រុមគោលដៅ ២០២៣ |
| --- | --- | --- |
| ១. ភាគរយសាលារៀនបង្ហាញលទ្ធផលសិក្សាមុខវិជ្ជាគោលបានកើនឡើង | | ១៥ |
| *សាលាមត្តេយ្យសិក្សា២១៣* | | *៣២* |
| *សាលាបឋមសិក្សា១,000* | | *១៥0* |
| *សាលាមធ្យមសិក្សា៤៣0* | | *៦៦* |
| ២. ភាគរយសាលារៀនទទួលការគាំទ្រដោយការបង្វឹក ដើម្បីកែលម្អដំណើរប្រតិបត្តិការណ៍សាលារៀន និងទទួលការគាំទ្រពីសហគមន៍ | | ៤០ |
| *សាលាមត្តេយ្យសិក្សា២១៣* | | *៨៦* |
| *សាលាបឋមសិក្សា១,000* | | *៤00* |
| *សាលាមធ្យមសិក្សា៤៣0* | | *១៧២* |
| ៣. ភាគរយសាលារៀនមានផែនការជួយសិស្សរៀនយឺត និងសិស្សមានពិការភាព | | ៤០ |
| *សាលាមត្តេយ្យសិក្សា២១៣* | | *៨៦* |
| *សាលាបឋមសិក្សា១,000* | | *៤00* |
| *សាលាមធ្យមសិក្សា៤៣0* | | *១៧២* |

23

# ពីការគ្រប់គ្រងតាមសាលារៀនមកជា យុទ្ធសាស្ត្រសហគមន៍សាលារៀន

១០៣០/១២០០

24


ពិសោធន៍សាកលលោក និងអ្វីដែលយើងយល់ស្រប
ថ្នាក់មូលដ្ឋានដឹងច្បាស់ពីតម្រូវការរបស់គេ
ថ្នាក់មូលដ្ឋានមានអំណាច និងសមត្ថភាពសម្រេចចិត្ត និងអនុវត្តនូវការសម្រេចចិត្តនោះ
រដ្ឋមានប្រសិទ្ធភាព ដោយសារសេវាសាធារណៈមានប្រសិទ្ធិភាព

25


ផលិតសិស្សមានបំណិនខ្ពស់សម្រាប់ជីវិតនិងការងារ និងត្រៀមត្រូវច្បាស់ចូលរៀននៅគ្រឹះស្ថានឧត្តមសិក្សាឬ ចូលរួមក្នុងទីផ្សារការងារ និង
កែលម្អការអនុវត្តរបស់សាលារៀនបំពេញបាននូវស្តង់ដាសាលារៀនមានប្រសិទ្ធិភាព។ សាលារៀននឹងជួយដល់សិស្សទាំងអស់ដោយគ្មានការរើសអើងលើភាពក្រីក្រ យេនឌ័រ ពិការភាព ឬជនជាតិភាគតិច។
បេសកកម្មសាលារៀន
គោលបំណង
សិស្ស៨០ទៅ៨៥% មានបំណិនខ្ពស់សម្រាប់ជីវិតនិងការងារ និងត្រៀមត្រូវច្បាស់ចូលរៀននៅតាមគ្រឹះស្ថានឧត្តមសិក្សា ឬ ចូលរួមក្នុងទីផ្សារការងារ នៅមុនឆ្នាំ ២០៣០(៥ឆ្នាំក្រោយ)
សាលារៀនបំពេញបាននូវស្តង់ដាយុទ្ធសាស្ត្រសហគមន៍សាលារៀននៅ៥ឆ្នាំក្រោយ។ សាលារៀននឹងជួយដល់សិស្សទាំងអស់ដោយគ្មានការរើសអើងលើភាពក្រីក្រ យេនឌ័រ ពិការភាព ឬជនជាតិភាគតិច។

26


ចរិយាស្ងប់សុខ
របស់បុគ្គល
ដែលមិនទារ
ទារអ្វីទាំងអស់
សមត្ថភាពគេច
ចេញផុតពីការប៉ះ
ទង្គិចអារម្មណ៍
ញាណថៃរក្សាខ្លួន
ដោយខ្លួនឯង
ញាណថាត្រូវមាន
ចំណែកទទួល
ខុសត្រូវសង្គម
ញាណប្រាកដថា
មិនគប្បីរស់នៅ
ដើម្បីតែខ្លួនឯង
នោះទេ
ញាណទាំងអស់
នេះនាំឲ្យអ្នកមាន
ក្តីសុខ

27


ការដឹកនាំ
ដោយមិន
ច្បាច់ដឹកនាំ
រៀនរស់ក្រោមច្បាប់
ព្រោះថាវាជា
អភិបាលកិច្ច
គិតនិងជួយមនុស្សនិង
សង្គម ដែលការពិតវា
លើសពីច្បាប់
កែលម្អច្បាប់ដើម្បីជួយ
សង្គមនិងមនុស្សច្រើន
ឲ្យទាន់ពេលវេលា
បើបុគ្គលគ្រប់រូបជាអ្នក
ដឹកនាំ នោះមិនត្រូវការ
ការដឹកនាំឡើយ តែអ្វី
មួយគត់ដែលត្រូវការគឺ
ការកំណត់ទិស

28

## អនុវត្តយុទ្ធសាស្ត្រនាំឱ្យមានការផ្លាស់ប្តូរ

ការធ្វើតេស្តស្តង់ដាវាស់សមត្ថភាពសិស្ស និងបិទផ្សាយលទ្ធផលជាសាធារណៈ នាំបង្កើតការទាមទារពីអតិថិជននូវសេវាសាធារណៈនិងការបង្រៀនមានគុណភាព

សហគមន៍ប្រើអំណាចសម្រេចចិត្តលើផែនការ ថវិកា និងកិច្ចការសាលារៀន នាំឱ្យ សហគមន៍ជាម្ចាស់សាលារៀន និងជួយដល់សាលារៀន

នាយកសាលាប្រើសិទ្ធិប្រតិបត្តិជានាកិច្ចការរដ្ឋបាលសាលារៀន និងបង្ហាញលទ្ធផលសិក្សា ចំណូលចំណាយ និងការរីកចម្រើនស្តង់ដាសាលារៀនជាសាធារណៈ ដែលនាំឱ្យសហគមន៍ជឿជាក់លើសាលារៀន នាយកសាលារៀន និងគ្រូបង្រៀន

29

## អនុវត្តយុទ្ធសាស្ត្រនាំឱ្យមានការផ្លាស់ប្តូរ

យកចិត្តទុកដាក់ថែរក្សាគ្រូបង្រៀន ទាំងសមត្ថភាពនិងការរស់នៅ ដែលជាគន្លឹះក្នុងការកសាងកិច្ចសន្យាសង្គមរវាងគ្រូបង្រៀន មាតាបិតាសិស្សនិងសិស្ស និងសហគមន៍ ហើយវានាំឱ្យមនុស្សទាំងអស់ធ្វើកិច្ចការរបស់ខ្លួនដើម្បីគាំទ្រការសិក្សារបស់សិស្ស

ការអនុវត្តវប្បធម៌គឺ នាំឱ្យបុគ្គលិកទាំងអស់ក្នុងសាលារៀនគោរពគ្នាដោយប្រើអំណាចសម្រាប់ធ្វើតែកិច្ចការត្រូវធ្វើ មិនប្រើអំណាចខុសគោលដៅឬប្រើសម្បត្តិសាលាសម្រាប់ប្រយោជន៍បុគ្គល ហើយការអនុវត្តគុណតម្លៃជាកត្តានាំឱ្យមនុស្សម្នាក់ៗក្លាយជាមនុស្សល្អ ដោយសារមនុស្សម្នាក់ៗធ្វើតែអ្វីដែលត្រូវ និងជួយមនុស្សទាំងអស់ក្នុងសហគមន៍

ការយកចិត្តទុកដាក់លើការអប់រំថែទាំកុមារតូចជាកត្តាគន្លឹះនាំឱ្យកុមារមានសមត្ថភាពគ្រឹះដូចជាមានសមត្ថភាពទំនាក់ទំនង អាហារូបត្ថម្ភល្អនិងខួរក្បាលពេញលេញ អក្ខរកម្ម និងចិត្តសង្គម ហើយសមត្ថភាពទាំងនេះនាំឱ្យកុមារម្នាក់ៗនឹងក្លាយជាធនធានមនុស្សសំខាន់សម្រាប់អនាគត។

30


គ្រប់ការផ្លាស់ប្តូរតែងចាប់ផ្តើមពីមួយ ឥឡូវហ្នឹងហើយ
ការផ្លាស់ប្តូរគឺដោយសារវាមានគ្រឹះមួយដែលរឹងមាំ គ្រឹះនោះគឺ ពុំមានអ្នកណាម្នាក់ចង់ក្រទេ ហើយមនុស្សម្នាក់ៗចង់ក្លាយជាមនុស្សល្អ
ពីនាំសិស្សម្នាក់ផ្លាស់ប្តូរនឹងនាំសិស្សទាំងអស់ក្នុងថ្នាក់ផ្លាស់ប្តូរ
ពីថ្នាក់រៀនមួយផ្លាស់ប្តូរទៅថ្នាក់រៀនទាំងអស់ក្នុងសាលាលរៀនមួយផ្លាស់ប្តូរ
ពីសាលារៀនមួយផ្លាស់ប្តូរឆ្ពោះទៅសាលារៀនទាំងអស់ក្នុងស្រុកផ្លាស់ប្តូរ
ពីស្រុកមួយផ្លាស់ប្តូរទៅស្រុកទាំងអស់ក្នុងខេត្តផ្លាស់ប្តូរ
ពីខេត្តមួយផ្លាស់ប្តូរទៅខេត្តទាំងអស់ក្នុងប្រទេសផ្លាស់ប្តូរ
ពីខេត្តមួយផ្លាស់ប្តូរទៅខេត្តទាំងអស់ក្នុងប្រទេសផ្លាស់ប្តូរ

31


វប្បធម៌សាលារៀន
អត្តសញ្ញាណរបស់សាលារៀន
ជារបៀបធ្វើកិច្ចការតាមបែបវិមជ្ឈការអំណាចទៅសហគមន៍
នាយកសាលារៀន គ្រូបង្រៀន និងសិស្ស នាំឱ្យម្នាក់ៗមានកិច្ចការច្បាស់លាស់
ការអភិវឌ្ឍមានលក្ខណៈគ្រប់ដណ្តប់
នាយកសាលារៀន គ្រូបង្រៀន និងសិស្សទទួលខុសត្រូវជាមួយនឹងកិច្ចការរបស់ខ្លួន

32




33

# ក្របខណ្ឌនិងលំដាប់អនុវត្តយុទ្ធសាស្រ្តសហគមន៍សាលារៀន

| ដំណាក់កាលអភិវឌ្ឍសហគមន៍សាលារៀន |
|---|
| ឆ្នាំទី១៖ ការធ្វើឱ្យសាលារៀននិងថ្នាក់រៀនមានដំណើរការសម្រាប់ការសិក្សារៀនសូត្រ |
| ឆ្នាំទី២៖ ការធ្វើឱ្យសាលារៀនបំពេញបានស្តង់ដាអប្បបរមាសាលារៀនមានប្រសិទ្ធភាព |
| ឆ្នាំទី៣៖ ឆ្ពោះទៅរកការរក្សានិរន្តរភាពសាលារៀនជាមួយកម្មវិធីបំណិនរកចំណូល |
| ឆ្នាំទី៤៖ សាលារៀនមានដំណើរការប្រកបដោយនិរន្តរភាព និងច្រើនជាងនេះ |

34

# បទបង្ហាញ
# ស្តីពី
# កំណែទម្រង់ក្នុងវិស័យអប់រំឈានទៅសម្រេចស្តង់ដាសាលារៀន

*បង្ហាញដោយ: ឯកឧត្តម ឡោ ឆវណ្ណា*
*អនុរដ្ឋលេខាធិការ*

## មាតិកា

១-ចក្ខុវិស័យ និងយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល៖

២-បរិបទប្រទេស និងបញ្ហាប្រឈមក្នុងបរិបទ វិស័យអប់រំនៅកម្ពុជា

៣.កម្មវិធីកំណែទម្រង់វិស័យអប់រំ៖

៤- ការផ្សាភ្ជាប់កម្មវិធីកំណែទម្រង់ និងកិច្ចសហការហិរញ្ញប្បទាន៖

៥.កំណែទម្រង់សាលារៀនការសម្រួចអាទិភាពកំណែទម្រង់ វិស័យអប់រំយុវជន និងកីឡាឆ្នាំ២០២៤-២០២៨

# ១.ចក្ខុវិស័យ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី ១ របស់រាជរដ្ឋាភិបាល៖

A. កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យ ឆ្នាំ ២០៣០ និងឆ្នាំ ២០៥០




អាទិភាពគន្លឹះ
១ មនុស្ស
២ ផ្លូវ
៣ ទឹក
៤ ភ្លើង
៥ បច្ចេកវិទ្យា
បាវចនា ៥
-កំណើន -ការងារ -សមធម៌ -ប្រសិទ្ធភាព -ចីរភាព
គោលដៅយុទ្ធសាស្ត្រ
១ កំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ
២ បង្កើតឱកាសការងារ និងពង្រឹងគុណភាពអប់រំ
៣ កាត់បន្ថយភាពក្រីក្រ ឱ្យនៅក្រោមអត្រា ១០%
៤ ពង្រឹងសមត្ថភាពអភិបាលកិច្ច និងលើកកម្ពស់គុណភាពស្ថាប័ន
៥ ធានាឱ្យបាននូវចីរភាពនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងកសាងភាពធន់នឹងបម្រែបម្រួលអាកាសធាតុ
#កម្ពុជា២០៥០
#CAMBODIA2050
មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center


គោលនយោបាយអាទិភាព ៦ចំណុច ក្នុងដំណាក់ឆ្នាំ២០២៣
១៖ ពង្រីកសេវាថែទាំសុខភាពឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកល
២៖ បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសសម្រាប់យុវជនដែលមានស្ថានភាពខ្វះខាត
៣៖ ធ្វើស្ថាបនូបនីយកម្មកម្មវិធីជំនួយសង្គមជូនដល់គ្រួសារក្រីក្រ និងរងហានិភ័យនៃវិបត្តិសេដ្ឋកិច្ច
៤៖ ដាក់ចេញ យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឱ្យមានលទ្ធភាពចូលរួមក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ
៥៖ យន្តការសម្របសម្រួល និងកម្មវិធីហិរញ្ញប្បទាន សំដៅលើកស្ទួយវិស័យកសិកម្មសម្រាប់ការនាំចេញ និងបំពេញតម្រូវការក្នុងស្រុក
៦៖ ដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មទៅជួយកសិករនៅតាមមូលដ្ឋាន
#កម្ពុជា២០៥០
#CAMBODIA2050
មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

## បញ្ហាគោលណទី១ ÷ ការអភិវឌ្ឍមូលធនមនុស្ស

1) ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
2) ការបណ្តុះបណ្តាលជំនាញបច្ចេកទេស
3) ការលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជន
4) ការពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធស្បៀង
5) ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គមដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន

## បញ្ហាគោលណទី១ ÷ ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

1) ការបន្តពង្រឹងគុណភាពអប់រំ និងការបណ្តុះបណ្តាលគ្រប់កម្រិត, ការធ្វើបច្ចុប្បន្នកម្មកម្មវិធីសិក្សានៅគ្រប់កម្រិត, និង ការបង្កើតបរិយាកាសល្អសម្រាប់ការសិក្សាពេញមួយជីវិត

២) ការបន្តកែទម្រង់សាលារៀន ដោយផ្តោតលើការពង្រឹងសមិទ្ធផលដែលមានស្រាប់, ការជំរុញការបង្កើតសាលារៀនជំនាន់ថ្មី និងសាលាគំរូ, ការពង្រឹងអភិបាលកិច្ច និងប្រសិទ្ធភាពគ្រប់គ្រងនៅមន្ទីរអប់រំ យុវជន និងកីឡា, ព្រមទាំងការជំរុញការចូលរួម និងភាពជាម្ចាស់របស់មាតាបិតា, សហគមន៍ និងវិស័យឯកជន។

៣) ការពង្រឹងគុណភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀន និងវិធីសាស្ត្របង្រៀន ព្រមទាំងការបន្តលើកកម្ពស់ ជីវភាព និង គុណតម្លៃ បុគ្គលិកសិក្សាគ្រប់កម្រិត។

## បញ្ញត្តិគោលការណ៍ទី១ ÷ ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

៤) ការបន្តលើកកម្ពស់ការអប់រំឌីជីថល, ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល តាមសាលារៀន, និងការជំរុញនូវការចាប់យកមុខវិជ្ជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា (STEAM)

៥) ការលើកកម្ពស់សុខភាពសិក្សា និង ការបង្កើនអាហារូបករណ៍សម្រាប់សិស្ស-និស្សិតក្រីក្រ និងរងគ្រោះ។

៦) ការពង្រឹងអភិបាលកិច្ចគ្រឹះស្ថានឧត្តមសិក្សា; ការលើកកម្ពស់ការស្រាវជ្រាវ, ការអភិវឌ្ឍ និងការនវានុវត្តន៍; និង ការជំរុញភាពជាដៃគូរវាងរដ្ឋ និង ឯកជន

៧) ការលើកកម្ពស់វិស័យកីឡាផ្សារភ្ជាប់នឹងការអប់រំ និង ការបន្តជំរុញចលនា "យុវជនម្នាក់ចេះកីឡាមួយប្រភេទយ៉ាងតិចប្រចាំជីវិត"។

## ២-បរិបទប្រទេស និងបញ្ហាប្រឈមក្នុងបរិបទវិស័យអប់រំនៅកម្ពុជា

## វិស័យអាទិភាព ៖

- កសិកម្ម កសិឧស្សាហកម្ម (ការកែច្នៃផលិតផលកសិកម្ម)
- ឧស្សាហកម្ម ដែលមានតម្លៃបន្ថែមខ្ពស់ (អេឡិត្រូនិក យានយន្ត)
- វាយនភ័ណ្ឌ និងសំលៀកបំពាក់
- កង់ និងគ្រឿងបង្គុំ
- គ្រឿងសង្ហារិម ឈើ និងផលិតផលធ្វើពីឈើ
- ទេសចរណ៍ និងសេវាកម្ម
- សំណង់
- សិប្បកម្ម
- ឧស្សាហកម្មច្នៃប្រឌិត

## បរិបទប្រទេស និងបញ្ហាប្រឈមក្នុងបរិបទអប់រំនៅកម្ពុជា ៖

- អត្រាគង់វង្សនៃសិស្សកំពុងសិក្សានៅមធ្យមសិក្សាទុតិយភូមិនៅទាប(25.19%)
- និស្សិតអាយុ១៨-២២ឆ្នាំ កំពុងសិក្សានៅឧត្តមសិក្សាកម្ពុជាមានប្រមាណ១៨% ប៉ុណ្ណោះ
- និស្សិតកំពុងសិក្សាលើជំនាញពាក់ព័ន្ធនឹងស្តែម មានប្រមាណ៣០%
- និស្សិតបញ្ចប់ការសិក្សាទទួលបានការងារមិនត្រូវជំនាញ (skill mismatch) ឬមិនស្រប នឹងគុណវុឌ្ឍិ (under-employment ) និងកង្វះខាតនៃជំនាញសំខាន់ៗ (skill shortage) ដូចជា ជំនាញបច្ចេកទេស និងអនុវត្តផ្ទាល់ ភាសាបរទេស កំព្យូទ័រ និងបច្ចេកវិទ្យា ទំនាក់ទំនង ជំនាញសរសេរ ដោះស្រាយបញ្ហា ធ្វើការជាក្រុម និងជំនាញរៀបចំផែនការ និងគ្រប់គ្រង ជាដើម។

## បរិបទប្រទេស និងបញ្ហាប្រឈមក្នុងបរិបទអប់រំនៅកម្ពុជា ÷

- ការចុះឈ្មោះចូលរៀនក្នុងកម្មវិធីអប់រំបច្ចេកទេស និងវិជ្ជាជីវៈ (អ.ប.វ) ទាំងនៅកម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១, ២ និង៣, កម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស (Diploma), និងកម្រិតបរិញ្ញាបត្របច្ចេកទេស គឺនៅមានកម្រិតនៅឡើយ
- ប្រព័ន្ធអប់រំនៅកម្ពុជាមិនទាន់កំណត់ពីតម្រូវការនៃការសិក្សារបស់សិស្សតាមទេពកោសល្យ និងការអភិវឌ្ឍរបស់កុមារម្នាក់ៗពីថ្នាក់ក្រោមមក
- ការរៀបចំគន្លងអប់រំនាពេលបច្ចុប្បន្នមិនទាន់មានភាពទូលំទូលាយ ច្រើនជម្រើស និងផ្អែកលើសមត្ថភាពសិស្ស។

## ៣.កម្មវិធីកំណែទម្រង់វិស័យអប់រំ៖

ការផ្សារភ្ជាប់យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលទៅកម្មវិធីកំណែទម្រង់អប់រំ ៤ ដំណាក់កាលសំខាន់ៗ

# ១. សាវតានៃកំណែទម្រង់វិស័យអប់រំស្របតាមយុទ្ធសាស្ត្រចតុកោណ

- **កំណែទម្រង់ដំណាក់កាលទី១ ៖** នៅក្នុងឆ្នាំ២០១៣ ដើមអាណត្តិទី៥ នៃរាជរដ្ឋាភិបាលកម្ពុជា ក្រសួងបាន ដាក់ចេញនូវកម្មវិធីកំណែទម្រង់ ៨ចំណុច រួមមាន៖
  - *១.ការបង្កើនគុណភាពអប់រំ,*
  - *២.ការពង្រឹងការគ្រប់គ្រងបុគ្គលិកអប់រំ,*
  - *៣.ការពង្រឹងការប្រឡងគ្រប់ប្រភេទ,*
  - *៤.កំណែទម្រង់ឧត្តមសិក្សា,*
  - *៥.ការអភិវឌ្ឍយុវជននូវជំនាញបច្ចេកទេស និង ជំនាញទន់,*
  - *៦.កំណែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*
  - *៧.កំណែទម្រង់ការអប់រំកាយនិងកីឡា, និង*
  - *៨.ការបង្កើតអង្គភាពស្រាវជ្រាវគោលនយោបាយ អប់រំ។*

# ១. សាវតានៃកំណែទម្រង់វិស័យអប់រំស្របតាមយុទ្ធសាស្ត្រចតុកោណ

- **កំណែទម្រង់ដំណាក់កាលទី២ ៖** ការដាក់ចេញនូវ សកម្មភាពអាទិភាពកំណែទម្រង់អប់រំនៅឆ្នាំ ២០១៥ ដោយផ្តោតលើសសរស្តម្ភប្រាំ រួមមាន៖
  - *១.ការអនុវត្តផែនការសកម្មភាពគោល នយោបាយគ្រូបង្រៀន,*
  - *២. ការធ្វើអធិការកិច្ច,*
  - *៣. វាយតម្លៃការសិក្សា,*
  - *៤. ការកែលម្អកម្មវិធីសិក្សា,*
  - *៥. កំណែទម្រង់ឧត្តមសិក្សា*
- *បំផ្លែងជាអាទិភាពកំណែទម្រង់ចំនួន ១៥ ចំណុច។*

## ១. សាវតានៃកំណែទម្រង់វិស័យអប់រំស្របតាមយុទ្ធសាស្ត្រចតុកោណ

- **កំណែទម្រង់ដំណាក់កាលទី៣ ៖** នៅឆ្នាំ ២០១៧ ក្រសួងបានដាក់ចេញនូវកំណែទម្រង់ដំណាក់កាលទី៣ ដោយផ្តោតលើកំណែទម្រង់ សាលារៀន ដែលរួមមាន៖ន សាលារៀនជំនាន់ថ្មី សាលារៀនធនធាន និងសាលារៀនគំរូ (ការគ្រប់គ្រងសាលារៀន/សាលារៀនមានប្រសិទ្ធភាព/សាលា SBM/សាលារៀនគោលដៅ/សាលារៀន ១០០) និងកំណែទម្រង់សាលាគរុកោសល្យ៖

- *១) វាយតម្លៃសមត្ថភាពរបស់សិស្សតាមរយៈការធ្វើ តេស្តដោយតម្លាភាព,*
- *២) ការបង្កើនគណនេយ្យភាពរបស់សាលារៀន,*
- *៣) ការបង្កើនស្វ័យភាព និងសិទ្ធិអំណាច ក្នុងការសម្រេចចិត្តនៅកម្រិតសាលារៀន តាមរយៈគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន*

## ១. សាវតានៃកំណែទម្រង់វិស័យអប់រំស្របតាមយុទ្ធសាស្ត្រចតុកោណ

- **កំណែទម្រង់ដំណាក់កាលទី៤ ៖** ក្នុងសន្និបាតអប់រំឆ្នាំ ២០២២ ក្រសួងបានដាក់ចេញវិធានការកែទម្រង់វិស័យអប់រំ ដំណាក់កាលទី៤ គឺ "ការកសាងប្រព័ន្ធ និងការអភិវឌ្ឍសមត្ថភាព" ដោយដាក់ឱ្យអនុវត្តអភិក្រមស្តីពីការគ្រប់គ្រងផ្តោតលើលទ្ធផលឆ្ពោះទៅរកការដោះស្រាយបញ្ហាជាលក្ខណៈប្រព័ន្ធ និងតាមបែបអនុវិស័យ៖
- *១. ការពង្រឹងប្រព័ន្ធគ្រប់គ្រងអប់រំ ដោយត្រូវរួមបញ្ចូលគ្នានូវការពិនិត្យឡើងវិញមុខងារនិងភារកិច្ច,*
- *២. ការរៀបចំផែនការប្រចាំឆ្នាំ,*
- *៣. ការអនុវត្តគន្លងអាជីព,*
- *៤. ការអភិវឌ្ឍសមត្ថភាព និង*
- *៥. ការពិនិត្យតាមដាននិងវាយតម្លៃ។*

# ការផ្សារភ្ជាប់គោលនយោបាយ និងការអនុវត្តជាក់ស្តែង៖

## ការផ្សារភ្ជាប់យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី ១ ទៅនឹងយុទ្ធសាស្ត្រសហគមន៍សាលារៀន (ស្តង់ដាសាលារៀនគំរូ)

| រចនាសម្ព័ន្ធយុទ្ធសាស្ត្របញ្ចកោណ | រចនាសម្ព័ន្ធយុទ្ធសាស្ត្រសហគមន៍សាលារៀន |
|---|---|
| *ចក្ខុវិស័យ* | *ចក្ខុវិស័យ* |
| • *បេសកកម្ម៖ សម្រេចចក្ខុវិស័យ ២០៣០ និង២០៥០* | • *បេសកកម្ម៖ សមត្ថភាពសិស្សសម្រាប់ជីវិតនិងការងារ និង សមត្ថភាពដឹកនាំរបស់សាលារៀនបំពេញស្តង់ដា* |
| • *គោលដៅ៖ កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព* | • *គោលដៅ៖ សិស្សមានសមត្ថភាព៨០ទៅ៨៥% និង សហគមន៍សាលារៀនបំពេញស្តង់ដា ដោយពុំទុកចោលអ្នកណាម្នាក់* |
| • *យុទ្ធសាស្ត្រ៖ ចំនួន៥ បញ្ចកោណទី១ មូលធនមនុស្ស* | • *យុទ្ធសាស្ត្រ៖ 6A បូកជាមួយវប្បធម៌ និងគុណតម្លៃ* |
| *រចនាសម្ព័ន្ធអនុវត្តយុទ្ធសាស្ត្រ៖ ចូលរួមដោយគ្រប់ភាគីពាក់ព័ន្ធ ១៦ស្ថាប័ន*<br>• *យុទ្ធសាស្ត្រស្នូល អភិបាលកិច្ច* | *រចនាសម្ព័ន្ធអនុវត្តយុទ្ធសាស្ត្រ៖ ចូលរួមដោយគ្រប់ភាគីពាក់ព័ន្ធ កម្រិតក្រុង ស្រុក ខណ្ឌ ខេត្ត ទូទាំងប្រទេស*<br>• *អភិបាលកិច្ចស្ថាប័ន និង អភិបាលកិច្ចសហគមន៍សាលារៀនបំពេញស្តង់ដាសហគមន៍សាលារៀន* |
| *រចនាសម្ព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ៖ ភស្តុតាងនៃការប្តេជ្ញាចិត្ត*<br>• *រាល់ខែ រាល់៣ខែ និងចុងឆ្នាំ កម្រិតថ្នាក់ជាតិ និងរដ្ឋបាលក្រុងស្រុកខណ្ឌ* | *រចនាសម្ព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ៖ ភស្តុតាងនៃការប្តេជ្ញាចិត្ត*<br>• *ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ វាស់ស្ទង់ការរីកចម្រើនស្តង់ដា ជាមួយផែនការសង់បន្ត កម្រិតជាតិ មន្ទីរអប់រំ ការិយាល័យអប់រំ សហគមន៍សាលារៀន* |

## ការកសាងប្រព័ន្ធធានាបានចីរភាព

### ភាពចន់ (ប្រព័ន្ធ) គ្រប់គម្រោង និងទូទាំងប្រទេស

ការងារ និងកំណើន

**៦អា** (6As)

ការវាយតម្លៃ → គណនេយ្យភាព → ស្វ័យភាព → យកចិត្តទុកដាក់លើនាយក/គ្រូ → យកចិត្តទុកដាក់លើការអប់រំកុមារតូច/បឋម → យកចិត្តទុកដាក់លើវប្បធម៌/គុណតម្លៃសាលា

ការរៀន (លទ្ធផល) → ការបង្រៀន (លទ្ធផល) → ប្រសិទ្ធភាព → ស័ក្តិសិទ្ធភាព

អប់រំកុមារតូច | បឋមសិក្សា | មធ្យមសិក្សា | ឧត្តមសិក្សា

21

## ទំនាក់ទំនងបញ្ញកោណស្តង់ដាសាលាគំរូ និងយុទ្ធសាស្ត្របញ្ញកោណដំណាក់កាលទី ១






# ៨- ការផ្សាភ្ជាប់កម្មវិធីកំណែទម្រង់ និងកិច្ចសហការហិរញ្ញប្បទាន៖

## កំណែទម្រង់អនុវិស័យ ÷

### កិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលជាមួយធនាគារពិភពលោក៖

ក) គម្រោងកែលម្អការអប់រំមធ្យមសិក្សា (២០១៧- ២០២២) ជួយសាលាមធ្យមសិក្សា១០០ ។

ទឹកប្រាក់សរុប ៖ ៤០លានដុល្លារ

ខ) គម្រោងកែលម្អការអប់រំចំណេះទូទៅ ២០២២ដល់២០២៦ ទឹកប្រាក់ចំនួន៦៩.២៥លាន ដុល្លារជួយសាលាមត្តេយ្យសិក្សាទាំងអស់២១៣ សាលាបឋមសិក្សា១០០០ និងសាលា មធ្យមសិក្សា៤៣៥ ។

គ)គម្រោងកែលម្អការអប់រំចំណេះទូទៅ ២០២៤ដល់២០២៩ ទឹកប្រាក់ចំនួន៧៩.៥០លាន ដុល្លារជួយសាលាមត្តេយ្យសិក្សា៨០សាលាបឋមសិក្សា១០០០ និងវិទ្យា ល័យទាំងអស់ និង សាលាមធ្យមសិក្សា៥០០ ។

# បេសកកម្ម និងគោលបំណងគម្រោង ÷

**បេសកកម្ម៖**

*១) ផលិតសិស្សមានគុណភាព សមត្ថភាព និងបំណិនខ្ពស់សម្រាប់ត្រៀមជាស្រេចចូលរៀនកម្រិតឧត្តមសិក្សា ឆ្លើយតបតាមតម្រូវការទីផ្សារការងារ។*

**គោលបំណង៖**

*១) ផ្តល់ឲ្យសិស្សទទួលបាននូវសម្បទារ ទាំង ៤ វិជ្ជាសម្បទារ បំនិនសម្បាទារ ចរិយាសម្បាទារ និងកាយសម្បាទារប្រកបដោយសមធម៌ សម្រាប់ជីវិតនិងការងារ និងត្រៀមគេរួចស្រេចចូលរៀននៅមហាវិទ្យាល័យ ឬ ចូលរួមក្នុង ទីផ្សារការងារ ។*

# ៤.កំណែទម្រង់សាលារៀនការសម្រួចអាទិភាព
# កំណែទម្រង់វិស័យអប់រំយុវជន និងកីឡាឆ្នាំ២០២៤-២០២៨

## អាទិភាពវិស័យអប់រំយុវជន និងកីឡា ៨ចំនុច ÷

- ១) ការពង្រឹងអភិបាលកិច្ចសាលារៀន
- ២) ការពិនិត្យកែសម្រួលនិងរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សាឲ្យស្របទៅតាម តម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបទរបស់សិស្ស
- ៣) ការលើកកម្ពស់សុខភាពសិក្សា ដោយយកចិត្តទុកដាក់លើសុខភាពរបស់សិស្ស តាមរយៈកម្មវិធីអាហារូបត្ថម្ភដល់កុមារ និងការ ត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលា
- ៤) ការជំរុញ និងការលើកទឹកចិត្តការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ ក្នុងការអប់រំស្របតាមពាក្យស្លោក ភាពជាដៃគូរដ្ឋ និងសហគមន៍ដើម្បីការអប់រំ
- ៥) ការអប់រំឌីជីថល
- ៦) ការបង្កើតមជ្ឈមណ្ឌលឧត្តមភាពនៅគ្រឹះស្ថានឧត្តមសិក្សា
- ៧) ការកសាងប្រព័ន្ធ និងការកសាងសមត្ថភាព
- ៨) ការអភិវឌ្ឍការអប់រំកាយ និងកីឡា

## កំណែទម្រង់ថ្នាក់ជាតិ ÷

- ១) ផ្តោតលើ "ការពង្រឹងសមត្ថភាពចំណេះដឹង, សុខភាព និងឥរិយាបទដល់សិស្សគ្រប់រូប" លើការអប់រំចាប់ពីមត្តេយ្យសិក្សារហូតដល់មធ្យមសិក្សាទុតិយភូមិ
- ២) រៀបចំ "យន្តការថ្នាក់ជាតិដើម្បីជំរុញកំណែទម្រង់" តាមរយៈការកំណត់អាទិភាព បញ្ហាប្រឈម យុទ្ធសាស្ត្រ និងពង្រឹងការពិនិត្យតាមដាននិងវាយតម្លៃ
- ៣) រៀបចំ "ក្រុមការងារបច្ចេកទេសកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា" និង និង "ក្រុមចុះជួយ coaching team" រួមជាមួយនាយកសាលាល្អចូលនិវត្តន៍ ដើម្បីចុះជួយគាំទ្រនៅតាមសាលារៀន
- ៤) ផ្សព្វផ្សាយ "ឧត្តមមានុវត្តន៍នៃកំណែទម្រង់សាលារៀន" ដូចជាសាលារៀនជំនាន់ថ្មី និងសាលារៀនគំរូ ឱ្យបានទូលំទូលាយទូទាំងប្រទេស
- ៥) គាំទ្រចំពោះការចូលរួមក្នុង "វង្វាយតម្លៃការសិក្សាកម្រិតអន្តរជាតិ (PISA)" ដើម្បីលើកកម្ពស់ស្តង់ដានៃការអប់រំនៅកម្ពុជា និងរិះរកវិធានការកែលម្អ

# កំណែទម្រង់ថ្នាក់ជាតិ ÷

- ៦) ប្រើប្រាស់លទ្ធផលវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិ នៅថ្នាក់ទី៣, ទី៦, ទី៨, និងទី១១ ដើម្បីកែលម្អប្រព័ន្ធអប់រំ
- ៧) រៀបចំ"សេចក្តីណែនាំស្តីពី ការអនុវត្តតេស្តស្តង់ដានៅតាមសាលាបឋមសិក្សា និងមធ្យមសិក្សា" និង "ឯកសារស្តីពី ការធ្វើតេស្តស្តង់ដាប្រចាំខែ ត្រីមាស ឆមាស" ។
- ៨) ពិនិត្យឡើងវិញ និងរៀបចំ "ស្តង់ដាសាលារៀន ស្តង់ដាសាលាគំរូ និងសាលារៀនជំនាន់ថ្មី"
- ៩) រៀបចំ "ព្រឹតិបត្រព័ត៌មានសាលារៀន/School Profile" ដើម្បីគ្រប់គ្រងព័ត៌មានគ្រូបង្រៀន ព័ត៌មានសិស្ស និងការងារគ្រប់គ្រងសាលារៀនជាទូទៅ។
- ១០) ជំរុញការអនុវត្តការបង្រៀនពេញមួយថ្ងៃ

# កំណែទម្រង់កម្រិតសាលារៀន ÷

- ១) ផ្តោតជាសំខាន់លើ “សាលារៀនគំរូ” ដោយពង្រឹងសាលារៀនគំរូដែលមានស្រាប់ និងពង្រីកសាលារៀនធម្មតាឱ្យក្លាយជាសាលារៀនគំរូ តាមរយៈការដាក់ឱ្យអនុវត្តទូទៅសម្រាប់សាលារៀនទាំងអស់ទូទាំងប្រទេស
- ២) អនុវត្ត “វិធីសាស្ត្របង្រៀនថ្មី” ដូចជាការបង្រៀនតាមបែបគម្រោង ការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀន ។ល។ ដែលបានដាក់ឱ្យអនុវត្តនៅសាលារៀនជំនាន់ថ្មី
- ៣) ជំរុញ និងលើកទឹកចិត្តដល់ “ការ
- ៤) រៀបចំ “បណ្ណាល័យស្តង់ដា” ដោយសហការជាមួយអង្គការដៃគូ និងផ្តោតលើសាលារៀនគំរូ
- ៥) ពង្រឹង “ការបណ្តុះបណ្តាលនាយក និងការតែងតាំងនាយក” ព្រមទាំងការត្រួតពិនិត្យ និងការវាយតម្លៃការងាររបស់នាយក ផ្អែកតាមស្តង់ដាអប្បបរមា និងការលើកទឹកចិត្តនាយកមានស្នាដៃ និងការអនុវត្តគន្លងអាជីពនាយក
- ៦) រៀបចំ “យន្តការចុះកិច្ចសន្យាការងារប្រចាំឆ្នាំរវាងនាយក និងគណៈកម្មការគ្រប់គ្រងសាលារៀន”

# កំណែទម្រង់កម្រិតសាលារៀន ÷

- ៧) ត្រួតពិនិត្យវត្តមានសិស្ស និងវត្តមានគ្រូបង្រៀន ព្រមទាំងការពង្រឹងការអនុវត្តម៉ោងសិក្សា
- ៨) រៀបចំ "វិធានការ និងយន្តការដើម្បីជួយសិស្សរៀនយឺត"
- ៩) រៀបចំផែនការ "អធិការកិច្ចថ្នាក់រៀន" ប្រចាំខែ និងចុះអធិការកិច្ចជួយគ្រូឱ្យបានច្បាស់លាស់
- ១០) ធ្វើ "អធិការកិច្ចតាមមុខវិជ្ជា និងធ្វើអធិការកិច្ចតាមប្រធានបទ" ដោយផ្តោតលើការអនុវត្តកម្មវិធីសិក្សានៅតាមសាលារៀន និងផ្តោតលើមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា

# ស្តង់ដាសាលារៀនគំរូ ÷

- ស្តង់ដាទី១ ៖ លទ្ធផលសិក្សារបស់សិស្ស
- ស្តង់ដាទី២ ៖ ដំណើរការបង្រៀន និងរៀន
- ស្តង់ដាទី៣ ៖ ការចូលរួមរបស់សហគមន៍
- ស្តង់ដាទី៤ ៖ ដំណើរការប្រតិបត្តិ និងរដ្ឋបាលសាលារៀន
- ស្តង់ដាទី៥ ៖ គណនេយ្យភាព



## លទ្ធផលស្តង់ដាសាលារៀនគំរូ ឆ្នាំ២០២៣ ÷

| ល.រ | អនុវិស័យ | ចំនួនសាលាគោលដៅ | សាលាគំរូ ២០២៣ | សាលាគំរូ GEIP | ភាគរយ |
|---|---|---|---|---|---|
| ១ | កុមារតូច | 213 | 10 | 9 | 90 |
| ២ | បឋមសិក្សា | 1000 | 40 | 17 | 42.5 |
| ៣ | មធ្យមសិក្សា | 435 | 70 | 30 | 43 |
| សរុប | | 1648 | 120 | 57 | |

## ស្តង់ដាសាលារៀនគំរូគ្រោង ឆ្នាំ២០២៤ ÷

| ល.រ | អនុវិស័យ | ចំនួនគ្រោង | ចំនួនសាលាគោលដៅ | សាលា GEIP | ភាគរយ | ចំនួនជាប់ |
|---|---|---|---|---|---|---|
| ១ | កុមារតូច | 39 | 213 | 36 | 92.30 | ? |
| ២ | បឋមសិក្សា | 175 | 1000 | 68 | 38.85 | ? |
| ៣ | មធ្យមសិក្សា | 152 | 435 | 77 | 50.65 | ??? |
| សរុប | | 366 | 1648 | 181 | | ? |

# សំណួរ និងចម្លើយ




សូមអរគុណ!



# ការលេខភាគ

# សម្រាប់គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន ក្នុងការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន

ក្នុងឆ្នាំសិក្សា២០២៣-២០២៤

| ខែ | កិច្ចការគ្រូបន្ទុកថ្នាក់ និងគ្រូមុខវិជ្ជា | កិច្ចការរបស់គណៈគ្រប់គ្រងសាលារៀន |
|---|---|---|
| | **ធ្វើផែនការរៀនសូត្រសិស្ស និងផែនការបង្រៀន១ឆ្នាំ និង៣ខែ** | **ធ្វើតេស្តវិនិច្ឆ័យសម្រាប់ រៀបចំថ្នាក់រៀនជួយសិស្សរៀនយឺត និង សិស្សរៀនលឿន** |
| ១២ ធ្នូ<br>(ពេលវេលាអាចបត់បែនតាមសាលារៀន) | ១ គ្រូបន្ទុកថ្នាក់ដឹកនាំសកម្មភាពសិស្សធ្វើ៖<br>*(ក) ផែនការរៀនសូត្រឆ្នាំ ផ្អែកលើលទ្ធផលតេស្តដើមឆ្នាំ ដោយមានការចូលរួមពីអ្នកអាណាព្យាបាលផ្ទាល់*<br>*និង*<br>*(ខ) ការបោះឆ្នោតជ្រើសរើសគណៈកម្មការថ្នាក់រៀនក្នុងពេលជាមួយគ្នាតែម្តងក៏បានដែរ*<br>*(គ) ជួយសិស្សធ្វើបច្ចុប្បន្នភាពផែនការរៀនសូត្ររៀង*<br>*រាល់ ខែ ផ្អែកលើលទ្ធផលតេស្តស្តង់ដាប្រចាំខែ*<br>**សម្គាល់៖**<br>*សកម្មភាពនេះបន្តអនុវត្ត និងតាមដានលទ្ធផល*<br>*រៀង រាល់រៀងរាល់ចុងខែ ដោយយកលទ្ធផលរៀនសូត្រប្រចាំខែ ពិសេសសិស្សរៀនយឺត និងរៀនលឿន សម្រាប់ពិគ្រោះយោបល់ជាមួយគណៈកម្មការគ្រប់គ្រងថ្នាក់រៀន ជារៀងរាល់ខែ*<br><br>២ ប្រធានក្រុមមុខវិជ្ជា តាមកម្រិតថ្នាក់ដឹកនាំគ្រូបង្រៀនមុខវិជ្ជាដូចគ្នា មានកម្រិតថ្នាក់ដូចគ្នា តែសិស្សមានកម្រិតសមត្ថភាពខុសគ្នា ដើម្បីរួមគ្នា<br>*(ក) ធ្វើផែនការបង្រៀន៣ឆ្នាំ*<br>*(ខ) ១ឆ្នាំ និង៣ខែ (ជៀសវាងការកំណត់សូចនាកមិនសមស្របជាមួយសមត្ថភាពសិស្សតាមថ្នាក់)*<br>**សម្គាល់៖**<br>*សកម្មភាពនេះបន្តអនុវត្ត និងតាមដានលទ្ធផល*<br>*រៀង រាល់រៀងរាល់ចុងខែ គ្រូមុខវិជ្ជាត្រូវធ្វើបច្ចុប្បន្នភាពផែនការបង្រៀន ផ្អែកលើលទ្ធផលសិក្សារបស់*<br>*សិស្ស ពីការធ្វើតេស្តស្តង់ដាប្រចាំខែខែរហូតដាច់ឆ្នាំ* | *០ នាយកសាលាដឹកនាំការធ្វើតេស្តស្តង់ដាដើមឆ្នាំ ឱ្យបានគ្រប់កម្រិតថ្នាក់ទាំងអស់ ដើម្បីយកលទ្ធផលមក៖*<br>*(ក) រៀបចំថ្នាក់រៀន តាមកម្រិតសមត្ថភាពសិស្ស និង រៀបចំគ្រូដែលមានជំនាញ និងទេពកោសល្យដោយឡែកៗពីគ្នាក្នុងការជួយសិស្សរៀនយឺត ឬសិស្ស*<br>*រៀន លឿន*<br>*(ខ) សម្រាប់ឱ្យសិស្ស និងមាតាបិតាសិស្សប្រើជាមូល ដ្ឋាន ធ្វើផែនការរៀនសូត្រឆ្នាំរបស់កូន ដែល*<br>*សម្របសម្រួល ដោយគ្រូបន្ទុកថ្នាក់ ដឹងឮពីអ្នកអាណាព្យាបាលសិស្ស*<br>*(គ) សម្រាប់ប្រធានក្រុមបច្ចេកទេស ឬនាយករង បច្ចេកទេសដឹកនាំគ្រូបង្រៀនតាមក្រុមបច្ចេកទេស*<br>*ធ្វើ ផែនការបង្រៀន៣ឆ្នាំ ១ឆ្នាំ និង៣ខែ ផ្តោតលើការជួយសិស្សរៀនយឺត និងរៀនលឿន* |
| | **បង្កើតក្រុមប្រឹក្សាសិស្សតាមថ្នាក់ សម្រាប់ដំណើរការរៀនសូត្រ និង គ្រប់គ្រងវិន័យរដ្ឋបាលថ្នាក់រៀន** | **បង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន សម្រាប់ដឹកនាំការធ្វើផែនការកែលម្អ សាលារៀន ៣ឆ្នាំ និង៦ឆ្នាំ** |

| | | |
|---|---|---|
| ១ មករា<br>(ពេលវេលាអាចបត់បែនតាមសាលារៀន) | **១ គ្រូបន្ទុកថ្នាក់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាកុមារយុវជនថ្នាក់រៀន និងរៀបចំសិស្សទាំងអស់ក្នុងថ្នាក់ទៅជាក្រុមតូចៗ សម្រាប់ដឹកនាំ និងគ្រប់គ្រងការកត់ត្រា សរុបរាយការណ៍ទិន្នន័យ និងព័ត៌មានអំពី៖**<br>*(ក) សកម្មភាពសិក្សា និងលទ្ធផលសិក្សារបស់សិស្សម្នាក់ៗ ផ្អែកលើផែនការរៀនសូត្រឆ្នាំរបស់សិស្ស*<br>*(ខ) សកម្មភាពបង្រៀនរបស់គ្រូម្នាក់ៗ និងលទ្ធផលសម្រេចបានសិស្សសរុបABCDEនិងFប្រចាំខែ*<br>*(គ) សកម្មភាពសន្សំលុយ កម្មវិធីឥណទាន រួមជាមួយបំណិនរកចំណូលពីកសិកម្ម និងកម្មន្តសាលកម្ម*<br>*(ឃ) សកម្មភាពគ្រប់គ្រងរដ្ឋបាលថ្នាក់រៀន និងការកែលម្អថ្នាក់រៀន*<br>*<u>សម្គាល់៖</u>*<br>*<u>សកម្មភាពនេះបន្តអនុវត្ត និងតាមដានលទ្ធផលរៀងរាល់ខែរហូតដាច់ឆ្នាំ ដោយមានការបូកសរុបលទ្ធផលនៅចុងឆមាសទី១ និងដំណាច់ឆ្នាំ</u>*<br><br>**២ គ្រូមុខវិជ្ជាសហការណ៍ជាមួយគ្រូបន្ទុកថ្នាក់ និងក្រុមប្រឹក្សាកុមារយុវជនថ្នាក់រៀនផ្ដល់ឱ្យសិស្សទាំងអស់នូវ៖**<br>*(ក) សន្លឹកកិច្ចការទី១ ដល់សិស្សទាំងអស់ដើម្បីសិស្សអាចស្វ័យសិក្សាតាមរយៈការអានមេរៀនក្នុងសៀវភៅសិក្សាគោលមុនពេលរៀនជាមួយគ្រូ*<br>*(ខ) សន្លឹកកិច្ចការទី២ ដល់សិស្សទាំងអស់ដើម្បីសិស្សអាចស្វ័យសិក្សាអំពីបញ្ញត្តិមេរៀន / មេរៀនសង្ខេបមុនពេលរៀនជាមួយគ្រូ*<br>*(គ) សន្លឹកកិច្ចការទី៣ ដល់សិស្សទាំងអស់ដើម្បីសិស្សអាចស្វ័យហ្វឹកហាត់សំណួរ លំហាត់ និងចំណោទដើម្បីអាចយល់កាន់តែស៊ីជម្រៅ អំពីបញ្ញត្តិមេរៀន / មេរៀនសង្ខេប មុនពេលរៀនជាមួយគ្រូ*<br>*(ឃ) សន្លឹកកិច្ចការទី៤ ដល់សិស្សទាំងអស់ដើម្បីសិស្សអាចស្វ័យវាយតម្លៃសមត្ថភាព ឬចំណេះដឹងមួយមេរៀនដោយខ្លួនឯង ដើម្បីសិស្សអាចទំនាក់ទំនងផ្ទាល់ជាមួយគ្រូដើម្បីគ្រូអាចជួយសិស្សអំពីការលំបាកមួយចំនួនក្នុងការស្វ័យសិក្សា និងជួយសិស្សពូកែឱ្យរៀនបានកាន់តែលឿនបន្ថែមទៀត ទៅតាមកម្រិតសមត្ថភាពសិស្ស*<br><br>**៣ គ្រូគ្រូបន្ទុកថ្នាក់ ដឹកនាំក្រុមប្រឹក្សាកុមារយុវជនថ្នាក់រៀនផ្ដល់ឱ្យសិស្សទាំងអស់នូវ៖**<br>*(ក) ចងក្រងក្រុមសន្សំប្រាក់តាមថ្នាក់រៀនប្រចាំថ្ងៃ*<br>*(ខ) ចងក្រងក្រុមដើម្បីធ្វើផែនការវិនិយោគ សម្រាប់អនុវត្តការងារកសិកម្ម និងឬកម្មន្តសាលកម្ម ដែលប្រព្រឹត្តិ* | ***0 នាយកសាលា និងគ្រូICTដឹកនាំសកម្មភាពតេស្តស្តង់ដាប្រចាំខែ ដោយម៉ត់ចត់ជាទីបំផុតដូចការប្រឡងថ្នាក់ជាតិ*** *(ក) ដោយព្យាយាមប្រើ Google Forms ឱ្យបានកាន់តែច្រើនពី១ខែ ទៅ១ខែ។*<br>*(ខ) សាលារៀនផ្ដល់សំណួរនិងចម្លើយឱ្យសិស្សបានដឹងមួយខែមុន ដើម្បីសិស្សអាចស្វ័យហ្វឹកហាត់ និងគ្រូអាចបង្រៀនបន្ថែមសម្រាប់សិស្សភាគច្រើនដែលរៀនយឺត និងសិស្សជួបការលំបាក*<br>*(គ) សាលារៀនរៀបចំកម្មវិធីប្រកួតល្បឿនអំណាន ធ្វើប្រមាណវិធីលេខ សរសេររឿង និងប្រវត្តិផ្សេងៗ សម្រាប់ដាក់ក្នុងបណ្ណាល័យ ទស្សនៈកិច្ចផ្ទះគ្រូ និងផ្ទះសិស្សបៃតងនៅតាមភូមិ*<br><br>**១ នាយកសាលាដឹកនាំសកម្មភាពបោះឆ្នោតជ្រើសរើសគណៈកម្មការគ្រប់គ្រងសាលារៀន និងបញ្ចូលសមាសភាពសំខាន់ៗខាងក្រោមជាសមាជិក៖**<br>*(ក) ប្រធានគណៈកម្មការគ្រប់គ្រងថ្នាក់រៀនទាំងអស់*<br>*(ខ) មេភូមិ និងអនុភូមិទាំងអស់*<br>*(គ) នគរបាលប៉ុស្តិ៍ មណ្ឌលសុខភាព និងអ្នកពាក់ព័ន្ធជាសមាសភាពសមាជិកអចិន្ត្រៃយ៍ ឬសមាជិកសកម្មរបស់គណៈកម្មការគ្រប់គ្រងសាលារៀន ក្នុងការជួយសិស្សរៀនយឺត សិស្សជួបការលំបាកក្នុងជីវភាព សិស្សមានបញ្ហាអំពើហឹង្សា សិស្សជាប់ពិការភាព សិស្សជនជាតិភាគតិច។ល។*<br><br>**២ នាយកសាលាដឹកនាំក្រុមប្រឹក្សាកុមារ គ្រូបង្រៀន គណៈកម្មការគ្រប់គ្រងថ្នាក់រៀន គណៈកម្មការគ្រប់គ្រងសាលារៀន និងអ្នកពាក់ព័ន្ធ៖**<br>*(ក) ធ្វើផែនការកែលម្អសាលារៀនឆ្នាំ*<br>*(ខ) ៣ឆ្នាំ និង*<br>*(គ) ៦ឆ្នាំ ផ្អែកលើលទ្ធផលតេស្តដើមឆ្នាំ*<br><br>**៣ គណៈគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងសាលារៀនផ្សព្វផ្សាយផែនការកែលម្អសាលារៀនឆ្នាំ ៣ឆ្នាំនិង៦ឆ្នាំដល់**<br>*(ក) សហគមន៍ និង*<br>*(ខ) ផ្អែកពាក់ព័ន្ធក្នុង និងក្រៅមូលដ្ឋាន ដើម្បីឱ្យគេបានដឹង និងអាចចូលរួមក្នុងការអនុវត្ត* |

| | | |
|---|---|---|
| | ទៅ នៅសាលារៀន ឬនិងនៅតាមផ្ទះ / កសិដ្ឋានរបស់សិស្ស<br>(គ) ចងក្រងក្រុមប្រវាស់ដៃ ក្នុងការរៀបចំលំនៅដ្ឋានឱ្យមានអនាម័យ សណ្ដាប់ធ្នាប់ សួនបន្លែគ្រួសារ និង ដាំ ដើមឈើច្រើនប្រភេទ ដើម្បីកែប្រែឱ្យទៅជាផ្ទះស្អាត ភូមិល្អ និងមានសុវត្ថិភាព<br>**សម្គាល់៖**<br>*សកម្មភាពនេះបន្តអនុវត្ត និងតាមដានលទ្ធផល រៀង រាល់ខែរហូតដាច់ឆ្នាំ ដោយមានការបូកសរុបលទ្ធ ផល នៅចុងឆមាសទី១ និងដំណាច់ឆ្នាំ* | |
| | **ធ្វើកិច្ចព្រមព្រៀង លទ្ធផលការងារប្រចាំឆ្នាំជាមួយគ្រូបង្រៀនក្នុងក្រុមបច្ចេកទេស ឬនាយករងបច្ចេកទេស** | **ធ្វើបច្ចុប្បន្នភាព ការពិពណ៌នាតួនាទី និងមុខតំណែង** (Job Description) **របស់គ្រូបង្រៀន ប្រធានក្រុមបច្ចេកទេស បុគ្គលិកទីចាត់ការ នាយករង និង នាយកសាលារៀន សម្រាប់ធ្វើកិច្ចព្រមព្រៀងលទ្ធផលការងារប្រចាំឆ្នាំ** (Annual Result Agreement) |
| ២ កុម្ភៈ (ពេលវេលាអាចបត់បែនតាមសាលារៀន) | ១ ប្រធានក្រុមបច្ចេកទេសដឹកនាំគ្រូបន្ទុកថ្នាក់ និងគ្រូមុខវិជ្ជាតាមកម្រិតថ្នាក់រួមគ្នា<br>(ក) ធ្វើកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ ផ្អែកលើផែនការបង្រៀន៣ខែ និង១ឆ្នាំ<br>(ខ) ដោយមានការឯកភាពពីប្រធានក្រុមបច្ចេកទេស និង<br>(គ) អនុម័តដោយគណៈគ្រប់គ្រងសាលារៀន<br><br>២ គ្រូបន្ទុកថ្នាក់ និងគ្រូមុខវិជ្ជាផ្សព្វផ្សាយកិច្ចព្រមព្រៀងដល់៖<br>(ក) សិស្សក្នុងថ្នាក់<br>(ខ) អ្នកអាណាព្យាបាលសិស្ស និង<br>(គ) គណៈកម្មការគ្រប់គ្រងថ្នាក់រៀន ដើម្បីឱ្យគាត់បានដឹង អំពីការប្ដេជ្ញាចិត្តរបស់លោកគ្រូ និងអ្នកគ្រូក្នុងការខំបង្រៀនសិស្សឱ្យសម្រេចបានលទ្ធផលដូចកូនគាត់កំណត់ក្នុងផែនការរៀនសូត្រ | ***០ នាយកសាលា និងគ្រូICTដឹកនាំសកម្មភាពតេស្តស្ដង់ដាប្រចាំខែ ដោយម៉ត់ចត់ជាទីបំផុតដូចការប្រឡងថ្នាក់ជាតិ*** (ក) ដោយព្យាយាមប្រើ Google Forms ឱ្យបានកាន់តែច្រើនពី១ខែ ទៅ១ខែ។<br>(ខ) សាលារៀនផ្ដល់សំណួរនិងចម្លើយឱ្យសិស្សបានដឹងមួយខែមុន ដើម្បីសិស្សអាចស្វ័យហ្វឹកហាត់ និងគ្រូអាចបង្រៀនបន្ថែមសម្រាប់សិស្សភាគច្រើនដែល រៀន យឺត និងសិស្សជួបការលំបាក<br>(គ) សាលារៀនរៀបចំកម្មវិធីប្រកួតល្បឿនអំណាន ធ្វើប្រមាណវិធីលេខ សរសេររឿង និងប្រវត្តិផ្សេងៗ សម្រាប់ដាក់ក្នុងបណ្ណាល័យ ទស្សនៈកិច្ចផ្ទះគ្រូ និងផ្ទះសិស្សបៃតងនៅតាមភូមិ<br><br>១ គណៈគ្រប់គ្រងសាលារៀន ពិភាក្សាជាមួយប្រធានក្រុមបច្ចេកទេស ដើម្បី៖<br>(ក) ធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និង<br>(ខ) កំណត់សកម្មភាពទទួលខុសត្រូវ របស់នាយក នាយករងទី១ ទី២ ឬទី៣ រួមជាមួយបុគ្គលិកទីចាត់ការផ្សេងទៀត<br><br>២ គណៈគ្រប់គ្រងសាលារៀនរួមគ្នាដើម្បី៖<br>(ក) ធ្វើកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំតាមការទទួល ខុស ត្រូវរៀងៗខ្លួន |

| | | |
|---|---|---|
| | | (ខ) បន្ទាប់មកប្រជុំឆ្លងជាមួយគណៈគ្រប់គ្រង និងគណៈ កម្មការគ្រប់គ្រងសាលារៀន ដើម្បីអនុម័ត។<br><br>៣ គណៈកម្មការគ្រប់គ្រងសាលារៀន ផ្សព្វផ្សាយកិច្ចព្រមព្រៀងដល់៖<br>(ក) គណៈគ្រប់គ្រងសាលា<br>(ខ) ប្រធានគណៈកម្មការគ្រប់គ្រងថ្នាក់រៀន<br>(គ) គ្រូបង្រៀន និងអ្នកពាក់ព័ន្ធក្នុងមូលដ្ឋាន |
| | **ធ្វើបច្ចុប្បន្នភាព បំណែងចែកកម្មវិធីសិក្សា និងគម្រោងបង្រៀនមួយមេរៀន មានច្រើនម៉ោងសិក្សា** | **ប្រជុំពិនិត្យតាមដានប្រចាំខែ និងត្រីមាស** |
| ៣ មីនា (ពេលវេលាអាចបត់បែនតាមសាលារៀន) | ១ ប្រធានក្រុមបច្ចេកទេសដឹកនាំគ្រូបន្ទុកថ្នាក់ និងគ្រូមុខវិជ្ជាតាមកម្រិតថ្នាក់រួមគ្នា<br>(ក) ធ្វើថ្មី ឬ<br>(ខ) ធ្វើបច្ចុប្បន្នភាពបំណែងចែកកម្មវិធីសិក្សាសម្រាប់បង្រៀនប្រចាំសប្ដាហ៍ សម្រាប់បង្រៀនផ្សារភ្ជាប់ការប្រើប្រាស់សន្លឹកកិច្ចការឱ្យសិស្សបានរៀនមុន ទាំង ៤ ប្រភេទ<br><br>២ ប្រធានក្រុមបច្ចេកទេសដឹកនាំគ្រូបន្ទុកថ្នាក់ និងគ្រូមុខវិជ្ជា៖<br>(ក) តាក់តែងថ្មី ឬ<br>(ខ) ធ្វើបច្ចុប្បន្នភាពគម្រោងបង្រៀនមួយមេរៀន មានច្រើនម៉ោងសិក្សា។ កិច្ចការនេះធ្វើរួមគ្នា សម្រាប់ បែក គ្នាប្រើប្រាស់តាមរបៀប និងវិធីផ្សេងៗរបស់លោក គ្រូ និងអ្នកគ្រូម្នាក់ៗ និងអាស្រ័យលើសមត្ថភាពសិស្សផងដែរ ដែលអាចឱ្យគ្រូបង្រៀនមានលទ្ធភាពបត់ បែន របៀបបង្រៀនតម្រូវតាមស្ថានភាពសមត្ថភាពរបស់គាត់ និងស្ថានភាពសិស្សរបស់គាត់<br>**សម្គាល់៖**<br>សកម្មភាពនេះបន្តអនុវត្ត និងតាមដានលទ្ធផល រៀង រាល់ខែ តាមការព្រមព្រៀងគ្នារបស់ក្រុមមុខវិជ្ជានីមួយៗជាអ្នកសម្រេច ដោយធ្វើយ៉ាងណាអាច ឱ្យគ្រូ ទាំងអស់មានគម្រោង បង្រៀនមួយមេរៀនគ្រប់មេរៀនទាំងអស់ និងបានធ្វើបច្ចុប្បន្នភាពជាប្រចាំ ឆ្លើយ តបទៅនឹងលទ្ធផលតេស្តកម្រិតអន្តរជាតិ | **០ នាយកសាលា និងគ្រូICTដឹកនាំសកម្មភាពតេស្តស្តង់ដាប្រចាំខែ ដោយម៉ត់ចត់ជាទីបំផុតដូចការប្រឡងថ្នាក់ជាតិ** (ក) ដោយព្យាយាមប្រើ Google Forms ឱ្យបានកាន់តែច្រើនពី១ខែ ទៅ១ខែ។<br>(ខ) សាលារៀនផ្តល់សំណួរនិងចម្លើយឱ្យសិស្សបានដឹងមួយខែមុន ដើម្បីសិស្សអាចស្វ័យហ្វឹកហាត់ និងគ្រូអាចបង្រៀនបន្ថែមសម្រាប់សិស្សភាគច្រើនដែល រៀន យឺត និងសិស្សជួបការលំបាក<br>(គ) សាលារៀនរៀបចំកម្មវិធីប្រកួតល្បឿនអំណាន ធ្វើប្រមាណវិធីលេខ សរសេររឿង និងប្រវត្តិផ្សេងៗសម្រាប់ដាក់ក្នុងបណ្ណាល័យ ទស្សនៈកិច្ចផ្ទះគ្រូ និងផ្ទះសិស្សបែតងនៅតាមភូមិ<br><br>**០ នាយកសាលាដឹកនាំការប្រជុំពិនិត្យតាមដានប្រចាំខែជាមួយគ្រូបង្រៀនដោយផ្អែកលើ៖**<br>(ក) ទិន្នន័យ និងព័ត៌មានបានពីការកត់ត្រា សរុប និង រាយ ការណ៍ប្រចាំខែ ពីក្រុមប្រឹក្សាកុមារយុវជនថ្នាក់រៀន និងគ្រូបន្ទុកថ្នាក់ជាអ្នកពិនិត្យផ្ទៀងផ្ទាត់បន្ថែម<br>(ខ) ដែលសរុបរួមប្រចាំខែកម្រិតសាលារៀន ដោយមានការបូកសរុប និងចងក្រងធ្វើជាបទបង្ហាដោយ នាយក រងកាន់រដ្ឋបាល (លទ្ធផលការអនុវត្តការងាររបស់ គ្រូ បង្រៀន) និងនាយករងកាន់បច្ចេកទេស (លទ្ធ ផល សិក្សារបស់សិស្សសរុបប្រចាំខែ ផ្អែកលើសូចនាកផែនការកែលម្អសាលារៀន)<br><br>២ គណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស និងគ្រូICTប្រចាំសាលារៀន រៀបចំឱ្យសិស្សបាននិទ្ទេស Aកម្រិតសាលារៀន បានចូលរួមប្រកួតវិញ្ញាសាអន្តរជាតិ ដឹកនាំដោយ បណ្តាញនាយកតំបន់/ ខេត្ត / ICTតំបន់ / ខេត្ត |
| ៤ មេសា | | **០ នាយកសាលា និងគ្រូICTដឹកនាំសកម្មភាពតេស្តស្តង់ដាប្រចាំខែ ដោយម៉ត់ចត់ជាទីបំផុតដូចការប្រឡងថ្នាក់** |

| | | |
|---|---|---|
| (ពេលវេលាអាចបត់បែនតាមសាលារៀន) | | ***ជាតិ*** *(ក) ដោយព្យាយាមប្រើ Google Forms ឱ្យបានកាន់តែច្រើនពី១ខែ ទៅ១ខែ។*<br>*(ខ) សាលារៀនផ្តល់សំណួរនិងចម្លើយឱ្យសិស្សបានដឹងមួយខែមុន ដើម្បីសិស្សអាចស្វ័យហ្វឹកហាត់ និងគ្រូអាចបង្រៀនបន្ថែមសម្រាប់សិស្សភាគច្រើនដែល រៀន យឺត និងសិស្សជួបការលំបាក*<br>*(គ) សាលារៀនរៀបចំកម្មវិធីប្រកួតល្បឿនអំណាន ធ្វើប្រមាណវិធីលេខ សរសេរឿង និងប្រវត្តិផ្សេងៗ សម្រាប់ដាក់ក្នុងបណ្ណាល័យ ទស្សនៈកិច្ចផ្ទះគ្រូ និងផ្ទះសិស្សបែតងនៅតាមភូមិ*<br><br>***o នាយកសាលាដឹកនាំការប្រជុំពិនិត្យតាមដានប្រចាំខែជាមួយគ្រូបង្រៀនដោយផ្អែកលើ៖***<br>*(ក) ទិន្នន័យ និងព័ត៌មានបានពីការកត់ត្រា សរុប និង រាយ ការណ៍ប្រចាំខែ ពីក្រុមប្រឹក្សាកុមារយុវជនថ្នាក់រៀន និងគ្រូបន្ទុកថ្នាក់ជាអ្នកពិនិត្យផ្ទៀងផ្ទាត់បន្ថែម*<br>*(ខ) ដែលសរុបរួមប្រចាំខែកម្រិតសាលារៀន ដោយមានការបូកសរុប និងចងក្រងធ្វើជាបទបង្ហាដោយ នាយក រងកាន់ផ្ទៃបាល (លទ្ធផលការអនុវត្តការងាររបស់ គ្រូ បង្រៀន) និងនាយករងកាន់បច្ចេកទេស (លទ្ធ ផល សិក្សារបស់សិស្សសរុបប្រចាំខែ ផ្អែកលើសូចនាករផែនការកែលម្អសាលារៀន)* |
| ៥ ឧសភា (ពេលវេលាអាចបត់បែនតាមសាលារៀន) | | ***o នាយកសាលា និងគ្រូICTដឹកនាំសកម្មភាពតេស្តស្ទង់ជាប្រចាំខែ ដោយម៉ត់ចត់ជាទីបំផុតដូចការប្រឡងថ្នាក់ជាតិ*** *(ក) ដោយព្យាយាមប្រើ Google Forms ឱ្យបានកាន់តែច្រើនពី១ខែ ទៅ១ខែ។*<br>*(ខ) សាលារៀនផ្តល់សំណួរនិងចម្លើយឱ្យសិស្សបានដឹងមួយខែមុន ដើម្បីសិស្សអាចស្វ័យហ្វឹកហាត់ និងគ្រូអាចបង្រៀនបន្ថែមសម្រាប់សិស្សភាគច្រើនដែល រៀន យឺត និងសិស្សជួបការលំបាក*<br>*(គ) សាលារៀនរៀបចំកម្មវិធីប្រកួតល្បឿនអំណាន ធ្វើប្រមាណវិធីលេខ សរសេរឿង និងប្រវត្តិផ្សេងៗ សម្រាប់ដាក់ក្នុងបណ្ណាល័យ ទស្សនៈកិច្ចផ្ទះគ្រូ និងផ្ទះសិស្សបែតងនៅតាមភូមិ*<br><br>***o នាយកសាលាដឹកនាំការប្រជុំពិនិត្យតាមដានប្រចាំខែជាមួយគ្រូបង្រៀនដោយផ្អែកលើ៖***<br>*(ក) ទិន្នន័យ និងព័ត៌មានបានពីការកត់ត្រា សរុប និង រាយ ការណ៍ប្រចាំខែ ពីក្រុមប្រឹក្សាកុមារយុវជនថ្នាក់រៀន និងគ្រូបន្ទុកថ្នាក់ជាអ្នកពិនិត្យផ្ទៀងផ្ទាត់បន្ថែម*<br>*(ខ) ដែលសរុបរួមប្រចាំខែកម្រិតសាលារៀន ដោយមានការបូកសរុប និងចងក្រងធ្វើជាបទបង្ហាដោយ នាយក រងកាន់ផ្ទៃបាល (លទ្ធផលការអនុវត្តការងាររបស់ គ្រូ បង្រៀន) និងនាយករងកាន់បច្ចេកទេស (លទ្ធ ផល សិក្សារបស់សិស្សសរុបប្រចាំខែ ផ្អែកលើសូចនាករផែនការកែលម្អសាលារៀន)* |

| | | |
|---|---|---|
| | **ស្វ័យវាយតម្លៃថ្នាក់រៀន<br>ពាក់កណ្តាលឆ្នាំ និងចុងឆ្នាំ** | **ស្វ័យវាយតម្លៃសាលារៀន<br>ពាក់កណ្តាលឆ្នាំ និងចុងឆ្នាំ** |
| ៦ មិថុនា (ពេលវេលាអាចបត់បែនតាមសាលារៀន) | ១ ប្រធានក្រុមបច្ចេកទេសដឹកនាំគ្រូបន្ទុកថ្នាក់ និងគ្រូមុខវិជ្ជាតាមកម្រិតថ្នាក់រួមគ្នា<br>*(ក) <u>ពិនិត្យឡើងវិញអំពីផលសម្រេចពាក់កណ្តាលឆ្នាំ</u>ក្នុង ការអនុវត្តកិច្ចព្រមព្រៀង លទ្ធផលប្រចាំឆ្នាំ ផ្អែកលើផែនការបង្រៀន៣ខែ និង១ឆ្នាំ*<br>*(ខ) ដោយមានការឯកភាពពីប្រធានក្រុមបច្ចេកទេស និង*<br>*(គ) អនុម័តដោយគណៈគ្រប់គ្រងសាលារៀន*<br><br>២ គ្រូបន្ទុកថ្នាក់ និងគ្រូមុខវិជ្ជាផ្សព្វផ្សាយ<u>ផលសម្រេចកិច្ចព្រមព្រៀងពាក់កណ្តាលឆ្នាំ</u>របស់គ្រូម្នាក់ៗដល់៖<br>*(ក) សិស្សក្នុងថ្នាក់*<br>*(ខ) អ្នកអាណាព្យាបាលសិស្ស និង*<br>*(គ) គណៈកម្មការគ្រប់គ្រងថ្នាក់រៀន ដើម្បីឱ្យគាត់បានដឹង អំពីការប្តេជ្ញាចិត្តរបស់លោកគ្រូ និងអ្នកគ្រូក្នុងការខំបង្រៀនសិស្សឱ្យសម្រេចបានលទ្ធផលដូចកូនគាត់កំណត់ក្នុងផែនការរៀនសូត្រ* | ***០ នាយកសាលា និងគ្រូICTដឹកនាំសកម្មភាពតេស្តស្តង់ដាប្រចាំខែ ដោយម៉ត់ចត់ជាទីបំផុតដូចការប្រឡងថ្នាក់ជាតិ*** *(ក) ដោយព្យាយាមប្រើ Google Forms ឱ្យបានកាន់តែច្រើនពី១ខែ ទៅ១ខែៗ **<u>និងចាប់ផ្តើមបញ្ចូលកម្រិតតេស្តអន្តរជាតិ</u>***<br>*(ខ) សាលារៀនផ្តល់សំណួរនិងចម្លើយឱ្យសិស្សបានដឹងមួយខែមុន ដើម្បីសិស្សអាចស្វ័យហ្វឹកហាត់ និងគ្រូអាចបង្រៀនបន្ថែមសម្រាប់សិស្សភាគច្រើនដែលរៀនយឺត និងសិស្សជួបការលំបាក*<br>*(គ) សាលារៀនរៀបចំកម្មវិធីប្រកួតល្បឿនអំណាន ធ្វើប្រមាណវិធីលេខ សរសេររឿង និងប្រវត្តិផ្សេងៗ សម្រាប់ដាក់ក្នុងបណ្ណាល័យ ទស្សនៈកិច្ចផ្ទះគ្រូ និងផ្ទះសិស្សបៃតងនៅតាមភូមិ*<br><br>***០ នាយកសាលាដឹកនាំការប្រជុំពិនិត្យតាមដានប្រចាំខែជាមួយគ្រូបង្រៀនដោយផ្អែកលើ៖***<br>*(ក) ទិន្នន័យ និងព័ត៌មានបានពីការកត់ត្រា សរុប និងរាយការណ៍ប្រចាំខែ ពីក្រុមប្រឹក្សាកុមារយុវជនថ្នាក់រៀន និងគ្រូបន្ទុកថ្នាក់ជាអ្នកពិនិត្យផ្ទៀងផ្ទាត់បន្ថែម*<br>*(ខ) ដែលសរុបរួមប្រចាំខែកម្រិតសាលារៀន ដោយមានការបូកសរុប និងចងក្រងធ្វើជាបទបង្ហាដោយនាយករងកាន់រដ្ឋបាល (លទ្ធផលការអនុវត្តការងាររបស់គ្រូបង្រៀន) និងនាយករងកាន់បច្ចេកទេស (លទ្ធផលសិក្សារបស់សិស្សសរុបប្រចាំខែ ផ្អែកលើសូចនាកផែនការកែលម្អសាលារៀន)*<br><br>*១ គណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស និងគ្រូICTប្រចាំសាលារៀន រៀបចំឱ្យសិស្សបាននិទ្ទេស Aកម្រិតសាលារៀន បានចូលរួមប្រកួតវិញ្ញាសាអន្តរជាតិ ដឹកនាំដោយ បណ្តាញនាយកតំបន់/ ខេត្ត / ICTតំបន់ / ខេត្ត*<br><br>២ នាយកសាលាដឹកនាំក្រុមប្រឹក្សាកុមារ គ្រូបង្រៀន គណៈកម្មការគ្រប់គ្រងថ្នាក់រៀន គណៈកម្មការគ្រប់គ្រងសាលារៀន និងអ្នកពាក់ព័ន្ធ៖<br>*(ក) <u>ធ្វើស្វ័យវាយតម្លៃការអនុវត្តពាក់កណ្តាលឆ្នាំ</u> អំពីផែនការកែលម្អសាលារៀនឆ្នាំ*<br>*(ខ) ៣ឆ្នាំ និង*<br>*(គ) ៦ឆ្នាំ ផ្អែកលើលទ្ធផលតេស្តដើមឆ្នាំ*<br><br>៣ គណៈគ្រប់គ្រងសាលារៀនរួមគ្នាដើម្បី៖ |

| | | |
|---|---|---|
| | | (ក) *<u>ស្វ័យវាយតម្លៃផលសម្រេចពាក់កណ្ដាលឆ្នាំ</u> អំពីកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំតាមការទទួលខុសត្រូវ រៀងៗខ្លួន*<br>(ខ) *បន្ទាប់មកប្រជុំឆ្លងជាមួយគណៈគ្រប់គ្រង និងគណៈ កម្មការគ្រប់គ្រងសាលារៀន ដើម្បីអនុម័ត។*<br><br>៤ គណៈកម្មការគ្រប់គ្រងសាលារៀន ផ្សព្វផ្សាយ<u>ផលសម្រេចរបស់គណៈគ្រប់គ្រង លើការអនុវត្តកិច្ចព្រមព្រៀងពាក់កណ្ដាលឆ្នាំដល់</u>៖<br>(ក) *គណៈគ្រប់គ្រងសាលា*<br>(ខ) *ប្រធានគណៈកម្មការគ្រប់គ្រងថ្នាក់រៀន*<br>(គ) *គ្រូបង្រៀន និងអ្នកពាក់ព័ន្ធក្នុងមូលដ្ឋាន* |
| ៧ កក្កដា (ពេលវេលាអាចបត់បែនតាមសាលារៀន) | | ***០ នាយកសាលា និងគ្រូICTដឹកនាំសកម្មភាពតេស្តស្តង់ដាប្រចាំខែ ដោយម៉ត់ចត់ជាទីបំផុតដូចការប្រឡងថ្នាក់ជាតិ*** *(ក) ដោយព្យាយាមប្រើ Google Forms ឱ្យបានកាន់តែច្រើនពី១ខែ ទៅ១ខែ។* ***<u>និងចាប់ផ្ដើមបញ្ចូលកម្រិតតេស្តអន្តរជាតិ</u>***<br>(ខ) *សាលារៀនផ្ដល់សំណួរនិងចម្លើយឱ្យសិស្សបានដឹងមួយខែមុន ដើម្បីសិស្សអាចស្វ័យហ្វឹកហាត់ និងគ្រូអាចបង្រៀនបន្ថែមសម្រាប់សិស្សភាគច្រើនដែលរៀនយឺត និងសិស្សជួបការលំបាក*<br>(គ) *សាលារៀនរៀបចំកម្មវិធីប្រកួតល្បឿនអំណាន ធ្វើប្រមាណវិធីលេខ សរសេររឿង និងប្រវត្តិផ្សេងៗ សម្រាប់ដាក់ក្នុងបណ្ណាល័យ ទស្សនៈកិច្ចផ្ទះគ្រូ និងផ្ទះសិស្សបែតងនៅតាមភូមិ*<br><br>***០ នាយកសាលាដឹកនាំការប្រជុំពិនិត្យតាមដានប្រចាំខែជាមួយគ្រូបង្រៀនដោយផ្អែកលើ៖***<br>(ក) *ទិន្នន័យ និងព័ត៌មានបានពីការកត់ត្រា សរុប និងរាយការណ៍ប្រចាំខែ ពីក្រុមប្រឹក្សាកុមារយុវជនថ្នាក់រៀន និងគ្រូបន្ទុកថ្នាក់ជាអ្នកពិនិត្យផ្ទៀងផ្ទាត់បន្ថែម*<br>(ខ) *ដែលសរុបរួមប្រចាំខែកម្រិតសាលារៀន ដោយមានការបូកសរុប និងចងក្រងធ្វើជាបទបង្ហាដោយនាយករងកាន់រដ្ឋបាល (លទ្ធផលការអនុវត្តការងាររបស់គ្រូបង្រៀន) និងនាយករងកាន់បច្ចេកទេស (លទ្ធផលសិក្សារបស់សិស្សសរុបប្រចាំខែ ផ្អែកលើសូចនាកផែនការកែលម្អសាលារៀន)* |
| ៨ សីហា (ពេលវេលាអាចបត់បែនតាម | | ***០ នាយកសាលា និងគ្រូICTដឹកនាំសកម្មភាពតេស្តស្តង់ដាប្រចាំខែ ដោយម៉ត់ចត់ជាទីបំផុតដូចការប្រឡងថ្នាក់ជាតិ*** *(ក) ដោយព្យាយាមប្រើ Google Forms ឱ្យបានកាន់តែច្រើនពី១ខែ ទៅ១ខែ។* ***<u>និងចាប់ផ្ដើមបញ្ចូលកម្រិតតេស្តអន្តរជាតិ</u>*** |

| | | |
|---|---|---|
| សាលា<br>រៀន) | | (ខ) សាលារៀនផ្តល់សំណួរនិងចម្លើយឱ្យសិស្សបានដឹង<br>មួយខែមុន ដើម្បីសិស្សអាចស្វ័យហ្វឹកហាត់ និងគ្រូ<br>អាចបង្រៀនបន្ថែមសម្រាប់សិស្សភាគច្រើនដែល<br>រៀន យឺត និងសិស្សជួបការលំបាក<br>(គ) សាលារៀនរៀបចំកម្មវិធីប្រកួតល្បឿនអំណាន ធ្វើ<br>ប្រមាណវិធីលេខ សរសេររឿង និងប្រវត្តិផ្សេងៗ<br>សម្រាប់ដាក់ក្នុងបណ្ណាល័យ ទស្សនៈកិច្ចផ្ទះគ្រូ និង<br>ផ្ទះសិស្សបែតងនៅតាមភូមិ<br><br>***០ នាយកសាលាដឹកនាំការប្រជុំពិនិត្យតាមដានប្រចាំខែ<br>ជាមួយគ្រូបង្រៀនដោយផ្អែកលើ៖***<br>(ក) ទិន្នន័យ និងព័ត៌មានបានពីការកត់ត្រា សរុប និង<br>រាយ ការណ៍ប្រចាំខែ ពីក្រុមប្រឹក្សាកុមារយុវជនថ្នាក់រៀន<br>និងគ្រូបន្ទុកថ្នាក់ជាអ្នកពិនិត្យផ្ទៀងផ្ទាត់បន្ថែម<br>(ខ) ដែលសរុបរួមប្រចាំខែកម្រិតសាលារៀន ដោយមាន<br>ការបូកសរុប និងចងក្រងធ្វើជាបទបង្ហាដោយ<br>នាយក រងកាន់រដ្ឋបាល (លទ្ធផលការអនុវត្តការងាររបស់<br>គ្រូ បង្រៀន) និងនាយករងកាន់បច្ចេកទេស (លទ្ធ<br>ផល សិក្សារបស់សិស្សសរុបប្រចាំខែ ផ្អែកលើសូចនាក<br>ផែនការកែលម្អសាលារៀន) |
| ៩ តុលា<br>(ពេលវេលា<br>អាចបត់<br>បែនតាម<br>សាលា<br>រៀន) | **១ ប្រធានក្រុមបច្ចេកទេសដឹកនាំគ្រូបន្ទុកថ្នាក់ និងគ្រូមុខ<br>វិជ្ជាតាមកម្រិតថ្នាក់រួមគ្នា**<br>(ក) *<u>ពិនិត្យឡើងវិញអំពីផលសម្រេចចុងឆ្នាំ</u>* ក្នុងកិច្ចព្រម<br>ព្រៀង លទ្ធផលប្រចាំឆ្នាំ ផ្អែកលើផែនការបង្រៀន<br>៣ ខែ និង១ ឆ្នាំ<br>(ខ) ដោយមានការឯកភាពពីប្រធានក្រុមបច្ចេកទេស<br>និង<br>(គ) អនុម័តដោយគណៈគ្រប់គ្រងសាលារៀន<br><br>**២ គ្រូបន្ទុកថ្នាក់ និងគ្រូមុខវិជ្ជាផ្សព្វផ្សាយ<u>ផលសម្រេច<br>កិច្ចព្រមព្រៀងដំណាច់ឆ្នាំ</u>របស់គ្រូម្នាក់ៗដល់៖**<br>(ក) សិស្សក្នុងថ្នាក់<br>(ខ) អ្នកអាណាព្យាបាលសិស្ស និង<br>(គ) គណៈកម្មការគ្រប់គ្រងថ្នាក់រៀន ដើម្បីឱ្យគាត់បាន<br>ដឹង អំពីការប្តេជ្ញាចិត្តរបស់លោកគ្រូ និងអ្នកគ្រូក្នុងការខំ<br>បង្រៀនសិស្សឱ្យសម្រេចបានលទ្ធផលដូចកូនគាត់<br>កំណត់ក្នុងផែនការរៀនសូត្រ | ***០ នាយកសាលា និងគ្រូICTដឹកនាំសកម្មភាពតេស្តស្តង់<br>ជាប្រចាំខែ ដោយម៉ត់ចត់ជាទីបំផុតដូចការប្រឡងថ្នាក់<br>ជាតិ*** (ក) ដោយព្យាយាមប្រើ Google Forms ឱ្យបានកាន់តែ<br>ច្រើនពី១ខែ ទៅ១ខែៗ ***<u>និងចាប់ផ្តើមបញ្ចូលកម្រិត<br>តេ ស្តអន្តរជាតិ</u>***<br>(ខ) សាលារៀនផ្តល់សំណួរនិងចម្លើយឱ្យសិស្សបានដឹង<br>មួយខែមុន ដើម្បីសិស្សអាចស្វ័យហ្វឹកហាត់ និងគ្រូ<br>អាចបង្រៀនបន្ថែមសម្រាប់សិស្សភាគច្រើនដែល<br>រៀន យឺត និងសិស្សជួបការលំបាក<br>(គ) សាលារៀនរៀបចំកម្មវិធីប្រកួតល្បឿនអំណាន ធ្វើ<br>ប្រមាណវិធីលេខ សរសេររឿង និងប្រវត្តិផ្សេងៗ<br>សម្រាប់ដាក់ក្នុងបណ្ណាល័យ ទស្សនៈកិច្ចផ្ទះគ្រូ និង<br>ផ្ទះសិស្សបែតងនៅតាមភូមិ<br><br>***០ នាយកសាលាដឹកនាំការប្រជុំពិនិត្យតាមដានប្រចាំខែ<br>ជាមួយគ្រូបង្រៀនដោយផ្អែកលើ៖***<br>(ក) ទិន្នន័យ និងព័ត៌មានបានពីការកត់ត្រា សរុប និង<br>រាយ ការណ៍ប្រចាំខែ ពីក្រុមប្រឹក្សាកុមារយុវជនថ្នាក់រៀន<br>និងគ្រូបន្ទុកថ្នាក់ជាអ្នកពិនិត្យផ្ទៀងផ្ទាត់បន្ថែម<br>(ខ) ដែលសរុបរួមប្រចាំខែកម្រិតសាលារៀន ដោយមាន<br>ការបូកសរុប និងចងក្រងធ្វើជាបទបង្ហាដោយ<br>នាយក រងកាន់រដ្ឋបាល (លទ្ធផលការអនុវត្តការងាររបស់<br>គ្រូ បង្រៀន) និងនាយករងកាន់បច្ចេកទេស (លទ្ធ<br>ផល សិក្សារបស់សិស្សសរុបប្រចាំខែ ផ្អែកលើសូចនាក<br>ផែនការកែលម្អសាលារៀន) |

| | | |
|---|---|---|
| | | *១ គណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស និងគ្រូICTប្រចាំសាលារៀន រៀបចំឱ្យសិស្សបាននិទ្ទេស A / BC កម្រិតសាលារៀន បានចូលរួមប្រកួតវិញ្ញាសាអន្តរជាតិ ដឹកនាំដោយ បណ្តាញនាយកតំបន់/ ខេត្ត / ICTតំបន់ / ខេត្ត*<br><br>២ នាយកសាលាដឹកនាំក្រុមប្រឹក្សាកុមារ គ្រូបង្រៀន គណៈកម្មការគ្រប់គ្រងថ្នាក់រៀន គណៈកម្មការគ្រប់គ្រងសាលារៀន និងអ្នកពាក់ព័ន្ធ៖<br>*(ក) ធ្វើស្វ័យវាយតម្លៃការអនុវត្តដំណាច់ឆ្នាំ អំពីផែនការកែលម្អសាលារៀនឆ្នាំ*<br>*(ខ) ៣ឆ្នាំ និង*<br>*(គ) ៦ឆ្នាំ ផ្អែកលើលទ្ធផលតេស្តដើមឆ្នាំ*<br><br>៣ គណៈគ្រប់គ្រងសាលារៀនរួមគ្នាដើម្បី៖<br>*(ក) ស្វ័យវាយតម្លៃផលសម្រេចដំណាច់ឆ្នាំ អំពីកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំតាមការទទួលខុសត្រូវរៀងៗខ្លួន*<br>*(ខ) បន្ទាប់មកប្រជុំឆ្លងជាមួយគណៈគ្រប់គ្រង និងគណៈកម្មការគ្រប់គ្រងសាលារៀន ដើម្បីអនុម័ត។*<br><br>៤ គណៈកម្មការគ្រប់គ្រងសាលារៀន ផ្សព្វផ្សាយផលសម្រេចរបស់គណៈគ្រប់គ្រង លើការអនុវត្តកិច្ចព្រមព្រៀងដំណាច់ឆ្នាំដល់៖<br>*(ក) គណៈគ្រប់គ្រងសាលា*<br>*(ខ) ប្រធានគណៈកម្មការគ្រប់គ្រងថ្នាក់រៀន*<br>*(គ) គ្រូបង្រៀន និងអ្នកពាក់ព័ន្ធក្នុងមូលដ្ឋាន* |
| ១០ កញ្ញា (ពេលវេលាអាចបត់បែនតាមសាលារៀន) | | ***o នាយកសាលា និងគ្រូICTដឹកនាំសកម្មភាពតេស្តស្តង់ដាប្រចាំខែ ដោយម៉ត់ចត់ជាទីបំផុតដូចការប្រឡងថ្នាក់ជាតិ***<br>*(ក) ដោយព្យាយាមប្រើ Google Forms ឱ្យបានកាន់តែច្រើនពី១ខែ ទៅ១ខែ។ **និងចាប់ផ្តើមបញ្ចូលកម្រិតតេស្តអន្តរជាតិ***<br>*(ខ) សាលារៀនផ្តល់សំណួរនិងចម្លើយឱ្យសិស្សបានដឹងមួយខែមុន ដើម្បីសិស្សអាចស្វ័យហ្វឹកហាត់ និងគ្រូអាចបង្រៀនបន្ថែមសម្រាប់សិស្សភាគច្រើនដែលរៀនយឺត និងសិស្សជួបការលំបាក*<br>*(គ) សាលារៀនរៀបចំកម្មវិធីប្រកួតល្បឿនអំណាន ធ្វើប្រមាណវិធីលេខ សរសេររឿង និងប្រវត្តិផ្សេងៗ សម្រាប់ដាក់ក្នុងបណ្ណាល័យ ទស្សនៈកិច្ចផ្ទះគ្រូ និងផ្ទះសិស្សបែតងនៅតាមភូមិ*<br><br>***o នាយកសាលាដឹកនាំការប្រជុំពិនិត្យតាមដានប្រចាំខែជាមួយគ្រូបង្រៀនដោយផ្អែកលើ៖*** |

| | | |
|---|---|---|
| | | *(ក) ទិន្នន័យ និងព័ត៌មានបានពីការកត់ត្រា សរុប និង<br>រាយ ការណ៍ប្រចាំខែ ពីក្រុមប្រឹក្សាកុមារយុវជនថ្នាក់រៀន<br>និងគ្រូបន្ទុកថ្នាក់ជាអ្នកពិនិត្យផ្ទៀងផ្ទាត់បន្ថែម<br>(ខ) ដែលសរុបរួមប្រចាំខែកម្រិតសាលារៀន ដោយមាន<br>ការបូកសរុប និងចងក្រងធ្វើជាបទបង្ហាដោយ<br>នាយក រងកាន់រដ្ឋបាល (លទ្ធផលការអនុវត្តការងាររបស់<br>គ្រូ បង្រៀន) និងនាយករងកាន់បច្ចេកទេស (លទ្ធ<br>ផល សិក្សារបស់សិស្សសរុបប្រចាំខែ ផ្អែកលើសូចនាក<br>ផែនការកែលម្អសាលារៀន)* |
| | **ការប្រកួតអំពីផលជះ<br>នៅតាមសាលារៀនក្នុងខេត្ត ពីការអនុវត្ត<br>យុទ្ធសាស្ត្រសហគមន៍សាលារៀន** | **ការប្រកួតអំពីផលជះ<br>នៅតាមសាលារៀនក្នុងខេត្ត ពីការអនុវត្ត<br>យុទ្ធសាស្ត្រសហគមន៍សាលារៀន** |
| ១១ វិច្ឆិកា (ពេលវេលាអាចបត់បែនតាមសាលារៀន) | ១ ប្រធានក្រុមមុខវិជ្ជា រួមជាមួយគ្រូបន្ទុកថ្នាក់ និងគ្រូមុខវិជ្ជា ដឹកនាំការប្រកួតសិស្សឆ្លាតវាងវៃសិស្សមកពីភូមិផ្សេងគ្នា ដើម្បីបង្កើនសកម្មភាពសិស្សនាំគ្នារៀនតាមភូមិ និងលប់បំបាត់សិស្សឈ្លោះប្រកែកគ្នា៖<br>*(ក) ល្បឿនអំណាន*<br>*(ខ) ប្រកបពាក្យពិបាក*<br>*(គ) សូត្រមេលេខបញ្ច្រាស*<br>*(ឃ) គូររូបភាព*<br>*(ង) សរសេររឿង*<br>*(ច) ច្រៀង / ស្មូត។ល។*<br>*(ឆ) លប់បំបាត់អំពើហឹង្សា*<br>*(ជ) ការប្រែប្រួលអាកាសធាតុ / ភូមិបៃតង*<br>ពិធីនេះអាចធ្វើនៅតាមវត្ត ដែលអាចប្រមូលផ្តុំអ្នកស្រុកចូលរួមបានច្រើន | ១ គណៈគ្រប់គ្រងធ្វើកិច្ចការជាមួយមេភូមិ វត្ត និងអ្នកពាក់ព័ន្ធរៀបចំកម្មវិធីនេះ ដោយផ្តល់ដំណឹង ឬផ្សព្វផ្សាយជាសាធារណៈឱ្យបានយ៉ាងតិច៥ខែមុនពេលដំណើរការ ពីព្រោះចង់ឱ្យសិស្សប្រមូលគ្នារៀន និងជួយគ្នាតាមភូមិ |

**កិច្ចការត្រូវអនុវត្តដើម្បីសម្រេចលទ្ធផលសិក្សារំពឹងទុក៖**

*ក្រោយពីបញ្ចប់ការសិក្សាមុខវិជ្ជានេះដោយជោគជ័យអ្នកសិក្សានឹង៖*

កិច្ចការទី ១៖ ចែករំលែកវត្ថុបំណង និងក្របខណ្ឌការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន ទៅកាន់បុគ្គលិកក្នុងអង្គភាពតាមរយៈបទបង្ហាញ/កិច្ចប្រជុំ

កិច្ចការទី ២៖ បែងចែកតួនាទី និងណែនាំបុគ្គលិកពីកិច្ចការដែលសាលាត្រូវអនុវត្ត។

កិច្ចការទី ៣៖ រៀបចំផែនការ និងយុទ្ធសាស្ត្រ ក្នុងការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន នៅក្នុងអង្គភាព។

# រាជរដ្ឋាភិបាលកម្ពុជា



# «យុទ្ធសាស្ត្រចតុកោណ»

## ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព :

## កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០

## ដំណាក់កាលទី ៤

## របស់រាជរដ្ឋាភិបាល នីតិកាលទី ៦ នៃរដ្ឋសភា

ខែ ស្រាពណ៍ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ខែ កញ្ញា ឆ្នាំ ២០១៨

# «យុទ្ធសាស្ត្រចតុកោណ»

## ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព :
## កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០

## ដំណាក់កាលទី ៤

### របស់រាជរដ្ឋាភិបាល នីតិកាលទី ៦ នៃរដ្ឋសភា

ខែ ស្រាពណ៍ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ខែ កញ្ញា ឆ្នាំ ២០១៨

# សេចក្តីផ្តើម

ឈ៚ឈ❀៙៚៙

រាជរដ្ឋាភិបាលកម្ពុជា បានអនុវត្តប្រកបដោយជោគជ័យនូវ**យុទ្ធសាស្ត្រចតុកោណ** ដើម្បី **កំណើន ការងារ សមធម៌** និង **ប្រសិទ្ធភាព** នៅកម្ពុជា, ៣ ជំណាក់កាលរួចមកហើយ, ដែលនាំឱ្យកម្ពុជាសម្រេចបាននូវការផ្លាស់ប្តូរមុខមាត់ថ្មីគួរជាទីមោទនៈបំផុត ។ ជាក់ស្តែង, បើប្រៀបធៀបកាលពីជាង ២០ ឆ្នាំមុន, កម្ពុជាបានប្រែក្លាយពីប្រទេសទទួលយកទាហានមួកខៀវរបស់អង្គការសហប្រជាជាតិដើម្បីមកធ្វើប្រតិបត្តិការរក្សាសន្តិភាព មកជាប្រទេសដែលបញ្ជូនកងកម្លាំងរបស់ខ្លួនឱ្យពាក់មួកខៀវទៅចូលរួមក្នុងប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិក្នុងប្រទេសមួយចំនួនដែលជាចំណុចក្តៅនៅលើសកលលោក ។ កម្ពុជាដែលពីមុនល្បីថា ជាវាលពិឃាត, ជាតំបន់អសន្តិសុខ, ជាចម្ការមីន ដែលគេភ័យខ្លាចគ្រប់គ្នា, ឥឡូវនេះ បានក្លាយទៅជាប្រទេសមួយដែលមានសន្តិភាពពេញលេញ និង ជាតំបន់ទេសចរណ៍ប្រកបដោយប្រជាប្រិយភាពនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលទទួលបានទេសចររាប់លាននាក់ក្នុងមួយឆ្នាំ ។ កម្ពុជាដែលពីមុនល្បីក្នុងការប្រើប្រាស់អាវុធដើម្បីដណ្តើមអំណាចគ្នា និង ក្នុងការផ្លាស់ប្តូររដ្ឋាភិបាល, ឥឡូវនេះ បានក្លាយទៅជាប្រទេសមួយ ដែលគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សតាមរយៈការរៀបចំយ៉ាងទៀងទាត់ នូវការបោះឆ្នោតដោយសេរី ត្រឹម-ត្រូវ និង យុត្តិធម៌ ដើម្បីឱ្យប្រជាពលរដ្ឋជ្រើសតាំងតំណាងដឹកនាំប្រទេស, ជានីតិរដ្ឋដែលគោរពគោលការណ៍ច្បាប់ដោយឥតងាករេ និង ជារដ្ឋអធិបតេយ្យ ដែលមានឯករាជ្យ និង បូរណភាពទឹកដីពេញលេញ ។ កម្ពុជា ដែលពីមុនជាប្រទេសត្រូវទទួលរងការហ៊ុមព័ទ្ធ និង ឯកោ, ទាំងខាងនយោបាយ និង សេដ្ឋកិច្ច ឥឡូវនេះ បានក្លាយ

ជាប្រទេស ដែលកំពុងសមាហរណខ្លួនយ៉ាងសកម្ម ទៅក្នុងរចនាសម្ព័ន្ធ និង និម្មាបនកម្មតំបន់ និង ពិភពលោក និង ជាប្រទេស ដែលកំពុងដើរតួនាទីយ៉ាងសកម្ម ដោយស្មើសិទ្ធិ និង ស្មើភាព ក្នុងគ្រប់កិច្ចការតំបន់ និង នៅលើឆាកអន្តរជាតិ ។ កម្ពុជាដែលពីមុនជាប្រទេសអន់ថយខាងផ្នែកសេដ្ឋកិច្ច, គ្របដណ្ដប់ទៅដោយភាពក្រីក្រ និង អសន្តិសុខស្បៀង, ឥឡូវនេះ បានក្លាយជាប្រទេសនាំស្បៀងចេញ ហើយស្ថិតនៅក្នុងចំណោមប្រទេសឯកទត្តលើពិភពលោក ែ ដលសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ និង ជាប្រទេស ដែលសម្រេចបាននូវវឌ្ឍនភាពដ៏ល្អប្រសើរ ក្នុងការកាត់បន្ថយភាពក្រីក្រ ក៏ដូចជាការកែលម្អសូចនាករផ្នែកសង្គមកិច្ច ហើយបានឆ្លងកាត់ដោយជោគជ័យ ពីចំណាត់ថ្នាក់នៃប្រទេសមានចំណូលទាប ក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប កាលពីពេលថ្មីៗកន្លងទៅ ។

ជារួម, យុទ្ធសាស្ត្រចតុកោណទាំង ៣ ដំណាក់កាល បានបំពេញតួនាទីយ៉ាងល្អប្រសើរ ជារបៀបវារៈអភិវឌ្ឍសង្គម- សេដ្ឋកិច្ចកម្ពុជា ។ ការអនុវត្តយុទ្ធសាស្ត្រចតុកោណ, ឆ្លងកាត់ដំណាក់កាលទាំង ៣ ជាបន្តបន្ទាប់, ជាលទ្ធផលបានផ្លាស់ប្ដូរស៊ីជម្រៅនូវរចនាសម្ព័ន្ធសេដ្ឋកិច្ច និង ការលើកកម្ពស់ជីវភាពប្រជ ាជនឱ្យកាន់តែប្រសើរឡើង, ទាំងខាងសម្ភារ និង ស្មារតី, តាមរយៈកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព, ការបង្កើតការងារជូនប្រជាជន, ការធានាសមធមិសង្គម, និង ការពង្រឹងប្រសិទ្ធភាពនៃអភិបាលកិច្ចរបស់ស្ថាប័នរដ្ឋ ។

សម្រាប់រយៈពេលមធ្យមខាងមុខ, ការអភិវឌ្ឍសង្គម- សេដ្ឋកិច្ចកម្ពុជានឹងឈានដល់ដំណាក់កាល«**ប្រែប្រួលថ្មី**» មួយទៀត ដែលជាអន្តរកាលឆ្ពោះទៅសម្រេចឋានៈប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ ។ ការណ៍នេះ, ទាមទារការយកចិត្តទុកដាក់ចំពោះការពង្រឹងថែមទៀត នូវស្ថា ប័នសាធារណៈ ដែលជារចនាសម្ព័ន្ធនៃ

យន្តការ, សំណុំវិធានច្បាប់, ធនធានមនុស្ស, មធ្យោបាយ និង ធនធានហិរញ្ញវត្ថុ ដែលកំណត់នូវគោលការណ៍ធំៗ និង តវិយាបថ ក្នុងការបំពេញមុខងារ, ទាំងក្នុងផ្នែកនយោបាយ សេដ្ឋកិច្ច និង សង្គម, នៅក្នុងក្របខណ្ឌនៃកិច្ចដំណើរការប្រជាធិបតេយ្យ និង នីតិរដ្ឋ ដែលមានធម្មានរូបភាពពេញលេញ ដើម្បីដំណើរការអភិវឌ្ឍទៅមុខទៀត ដោយបន្តរក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់; ជំរុញការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច- សង្គម; បង្កើតការងារប្រកបដោយគុណភាពសម្រាប់យុវជន; ឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះក្តីរំពឹងទុករបស់ប្រជាជន ជាពិសេសដោះស្រាយនូវសេចក្តីត្រូវការរបស់ប្រជាជនដែលចេះតែកើនឡើងជាលំដាប់ រួមបញ្ចូលនូវការទទួលបាននូវសេវាសាធារណៈសំខាន់ៗ ប្រកបដោយគុណភាព, ទាំងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សេវាអប់រំ សេវាសុខាភិបាល និង សេវាមូលដ្ឋានចាំបាច់ផ្សេងទៀត; ធានានូវសន្តិសុខសង្គម និង សុខុមាលភាពរបស់ប្រជាជនទូទៅ; ធានាសុវត្ថិភាពចំណូល ពិសេសសម្រាប់ប្រជាជនងាយរងគ្រោះ; ធានាតុល្យភាព និង កាត់បន្ថយគម្លាតរវាងទីក្រុង និង ជនបទ; រក្សាភាពបត់បែន និង តាមឱ្យទាន់សភាពការណ៍ប្រែប្រួល នៅក្នុងតំបន់ និង ពិភពលោក; ទាញយកផលប្រយោជន៍ជាអតិបរមាពីការរីកចម្រើនផ្នែកបច្ចេកវិទ្យា និង ឌីជីថលូបនីយកម្ម ជាពិសេសក្នុងបរិការណ៍នៃបដិវត្តឧស្សាហកម្មទី ៤; និងព្រមជាមួយនេះ, លើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចការពារ និង អភិរក្សបរិស្ថាន, ធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ីតំបន់ជីវចម្រុះ ព្រៃឈើ និង ជម្រកសត្វព្រៃ ព្រមទាំងការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ ។

លើមូលដ្ឋាននៃមហាសមិទ្ធផលដែលសម្រេចបាន តាមរយៈការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ** ៣ ដំណាក់កាលកន្លងមក ក៏ដូចជាតម្រូវការនៃការអភិវឌ្ឍ

ឈានទៅមុខទៀតរបស់កម្ពុជា ដូចបានគូសបញ្ជាក់ខាងលើ, រាជរដ្ឋាភិបាល បានដាក់ចេញ «**កម្មវិធីនយោបាយ**» របស់ខ្លួន ប្រកបដោយមហិច្ឆតា ហើយទទួលបាននូវការគាំទ្រដ៏ច្រើនលើសលប់ ពីសំណាក់ប្រជាពលរដ្ឋទូទាំងប្រទេស តាមរយៈការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និង យុត្តិធម៌ ដែលមានប្រជាពលរដ្ឋចូលរួមដ៏ច្រើនកុះករ រហូតដល់ទៅ ៨៣,០២% ។ **កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី ៦ នៃរដ្ឋសភា** បានកំណត់ដាក់ចេញនូវគោលដៅជាយុទ្ធសាស្ត្រ, គោលនយោបាយធំៗជាអាទិភាព, គោលនយោបាយអភិវឌ្ឍតាមវិស័យ និង វិធានការដាក់ស្តែងជាអាទិភាព សម្រាប់អនុវត្តចាប់ ពីឆ្នាំ ២០១៩ ទៅ, ដែលជាត្រីវិស័យសម្រាប់តម្រង់ទិសសកម្មភាពរបស់រាជរដ្ឋាភិបាល ក្នុងការបន្តបំពេញភារកិច្ចបម្រើជាតិ និង ប្រជាជន នៅក្នុងនីតិកាលទី ៦ នេះ ។

ហេតុនេះ, **យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី ៤**, ក្នុងតួនាទីជាឧបករណ៍គោលនយោបាយដ៏មានប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាល, នឹងធ្វើការប្រមូលសរុបនូវកិច្ចខិតខំប្រឹងប្រែងរយៈពេល ២០ ឆ្នាំ នៃបេសកកម្មកែប្រែមុខមាត់ ស្តារ និង អភិវឌ្ឍកម្ពុជា, ក្រោយពីបានបញ្ចប់សង្គ្រាមស៊ីវិល និង ទទួលបានសន្តិភាពពេញ-លេញ, ហើយជាមួយនេះ ក៏នឹងកំណត់ដាក់ចេញនូវវិធានការគោលនយោបាយជាយុទ្ធសាស្ត្រដាក់ស្តែង សម្រាប់អនុវត្ត **កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី ៦ នៃរដ្ឋសភា** សំដៅឆ្លើយតបទៅនឹងបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជា-ជនផង ព្រមទាំងសំដៅកសាងមូលដ្ឋានគ្រឹះចាំបាច់ទាំងឡាយ ឆ្ពោះទៅគោលដៅនៃចក្ខុវិស័យកម្ពុជា ២០៣០ និង ២០៥០ ផង ។ ក្នុងបរិការណ៍នេះ, រាជរដ្ឋាភិបាលយល់ឃើញថា **យុទ្ធសាស្ត្រចតុកោណ** ជាពិសេសគោលដៅសម្រាប់ **កំណើនការងារ សមធម៌** និង **ប្រសិទ្ធភាព** នៅតែចាំបាច់ និង សមស្រប សម្រាប់កម្ពុជា

អនុវត្ត ក្នុងនីតិកាលទី ៦ ឆ្នាំ ២០១៨-២០២៣ តទៅទៀត ដោយត្រូវពង្រឹងបន្ថែមទៀតលើសមិទ្ធផលសម្រេចបានកន្លងមក និង ផ្តោតសំខាន់លើរបៀបវារៈធានា «**ប្រសិទ្ធភាព**» តាមរយៈការអនុវត្តអភិក្រម «**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និង វះកាត់**» ។ ដូច្នេះ, រចនាសម្ព័ន្ធ «**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤**» នឹងត្រូវរក្សាទុកដដែល ដោយគ្រាន់តែពង្រីកវិសាលភាព សម្រិតសម្រាំងបន្ថែម និង ធ្វើអាទិភាវូបនីយកម្មមុំនីមួយៗនៃចតុកោណយុទ្ធសាស្ត្រទាំងបួន ព្រមទាំងកែលម្អរបៀបវារៈគោលនយោបាយ និង យន្តការអនុវត្ត ឱ្យកាន់តែល្អប្រសើរថែមទៀត ។

សរុបសេចក្តីមក, «**កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា**» និង «**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤**», នឹងរួមគ្នាបំពេញតួនាទីជាឯកសារក្របខណ្ឌគោលនយោបាយដែលគ្រប់ជ្រុងជ្រោយ សម្រាប់រៀបចំ «**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិឆ្នាំ ២០១៩-២០២៣**» ដែលនឹងមានកំណត់សូចនាករលទ្ធផល និង ពេលវេលាច្បាស់លាស់សម្រាប់អនុវត្ត និង ដែលត្រូវមានសង្គតិភាពជាមួយនឹងឯកសារគោលនយោបាយតាមវិស័យដទៃទៀត របស់រាជរដ្ឋាភិបាល ។ ដោយឡែក, « **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤**» នឹងក្លាយជាមគ្គុទេសក៍ច្បាស់លាស់ សម្រាប់តម្រែតម្រង់សកម្មភាពរបស់គ្រប់តួអង្គអភិវឌ្ឍទាំងអស់ ឱ្យស្ថិតនៅក្នុង«**ជវភាពនៃប្រព័ន្ធតួអង្គតែមួយ**»[1] (Dynamics of

[1] *ការសម្របសម្រួលគ្នាបានជាប្រព័ន្ធតួអង្គតែមួយ គឺនៅពេលដែលក្រសួង-ស្ថាប័នទាំងអស់ មិនត្រឹមតែត្រូវបំពេញតួនាទីរៀងៗខ្លួន ដោយមិនចោទប្រកាន់គ្នាទៅវិញទៅមកប៉ុណ្ណោះទេ, ប៉ុន្តែថែមទាំងសម្របសម្រួល និង សហការគ្នាជិតស្និទ ដើម្បីសម្រេចនូវបេសកកម្ម, គោលបំណងគោលនយោបាយរបស់រាជរដ្ឋាភិបាល និង ឆ្លើយតបទៅនឹងកង្វល់ ឬ សំណូមពររបស់ប្រជាជនបានដោយប្រសិទ្ធភាពទៀតផង ។*

Stakeholder System) ក្នុងគោលដៅបន្ត និង ពង្រឹងកិច្ចអភិវឌ្ឍប្រកបដោយចីរភាព សម្រាប់រយៈពេលមធ្យម និង វែងទៅមុខ ដោយធានាបាននូវប្រសិទ្ធភាពនៃស្ថាប័នសាធារណៈ និង ការគ្រប់គ្រងធនធានសរុបរបស់ប្រទេស ។

នៅក្នុងខ្លឹមសារនេះ **យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី៤** គឺជា «**របៀបវារៈគោលនយោបាយសង្គម - សេដ្ឋកិច្ច**» នៃ «**កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា**» នៅក្រោមដំបូលនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និង ម្លប់ដ៏ត្រជាក់នៃអង្គព្រះមហាក្សត្រជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតនៃជាតិកម្ពុជាយើង ។

# ផ្នែកទី ១

## ១.១. សមិទ្ធផលសំខាន់ៗរបស់រាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភា

កម្ពុជាសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើន, ទាំងខាងនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម, ទាំងខាងការអភិវឌ្ឍសង្គម- សេដ្ឋកិច្ច, ទោះបីជាត្រូវប្រឈមនឹងសភាពការណ៍ប្រែប្រួលផ្នែកនយោបាយ, ភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកល, ការគំរាមចំពោះអធិបតេយ្យជាតិ និង បូរណភាពទឹកដី, គ្រោះ-ធម្មជាតិផ្សេងៗ, និង តម្រូវការដោះស្រាយសំណូមពរថ្មីៗរបស់ប្រជាជនគ្រប់ស្រទាប់វណ្ណៈយ៉ាងណាក៏ដោយ ។ ក្នុងការអនុវត្តយ៉ាងប្ដូរផ្ដាច់នូវ «**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាល ទី ៣**» ក្នុងនីតិកាលទី ៥ នៃរដ្ឋសភាកន្លងមកនេះ, រាជរដ្ឋាភិបាលសម្រេចបានលទ្ធផលធំៗដូចតទៅ÷

ទី១- រក្សាបានពេញលេញនូវសន្តិភាព, បូរណភាពទឹកដី, និង ស្ថិរភាពនយោបាយ, ដោយប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍នីតិរដ្ឋ និង ប្រជាធិប-តេយ្យ; រារាំងទប់ស្កាត់បានប្រកបដោយប្រសិទ្ធភាពនូវឧបាយកលនៃការប្រើប្រាស់ចលនាបដិវត្តពណ៌ ដើម្បីប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ហើយការពារប្រទេសជាតិមិនឱ្យធ្លាក់ចូលក្នុងកលិយុគ ការបែកបាក់គ្នា និង សង្គ្រាមសាជាថ្មី ។ ទន្ទឹមនេះ, សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម កាន់តែត្រូវបានលើកកម្ពស់ តាមរយៈការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មគ្រប់ប្រភេទ, ជាអាទិ៍ អំពើជួញដូរមនុស្ស និង គ្រឿង-ញៀន, ដែលនឹងបង្កើតបាននូវបរិយាកាសអនុគ្រោះ សម្រាប់ការអភិវឌ្ឍប្រទេស និង ការវិនិយោគ និង សម្រាប់សុវត្ថិភាពរបស់សាធារណជនទូទៅ ។

ទី២- សេដ្ឋកិច្ចមានកំណើនខ្ពស់ ក្នុងអត្រាជាង ៧% ក្នុងមួយឆ្នាំ ដែលធ្វើ

ឱ្យកម្ពុជាសម្រេចបានឋានៈប្រទេសមានចំណូលមធ្យមកម្រិតទាប; មូលដ្ឋាននៃកំណើនសេដ្ឋកិច្ចកាន់តែមានពិពិធកម្មច្រើនឡើង; ភាពក្រីក្រត្រូវបានកាត់បន្ថយមកនៅត្រឹមក្រោម ១០%; និង គម្លាតនៃចំណូលក្នុងចំណោមប្រជាជន ស្ថិតក្នុងកម្រិតទាប តាមរយៈការបែងចែកផលនៃកំណើនសេដ្ឋកិច្ចដល់ប្រជាជនគ្រប់ស្រទាប់ ពិសេស គឺតាមរយៈការអនុវត្តគោលនយោបាយដំឡើងបៀវត្សមន្ត្រីរាជការ និង ប្រាក់ឈ្នួលអប្បបរមា ព្រមទាំងការគិតគូរពីសុខុមាលភាពរបស់កម្មករ តាមរយៈការតភ្ជាប់បណ្តាញអគ្គិសនី និង បណ្តាញទឹកស្អាតក្នុងតម្លៃទាប, ការពង្រីកវិសាល-ភាពបេឡាជាតិរបបសន្តិសុខសង្គម និង មូលនិធិសមធម៌, ការផ្តល់សេវាដឹកជញ្ជូនសាធារណៈ និង ការជំរុញអនុវត្តយន្តការដោះស្រាយវិវាទការងារ ។

ទី៣- វឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការកែទម្រង់អភិបាលកិច្ច, ទាំងការ-អនុវត្តការកែទម្រង់រដ្ឋបាលសាធារណៈ, កម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ, ការកែទម្រង់តាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ, ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ, ការកែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌, និង ការកែទម្រង់កងកម្លាំង-ប្រដាប់អាវុធ ។ ជាក់ស្តែង, រាជរដ្ឋាភិបាលបានដំឡើងបៀវត្សជូនមន្ត្រីរាជការ និង កងកម្លាំងប្រដាប់អាវុធ ដល់កម្រិតជាង ១ លានរៀល/ខែ នៅឆ្នាំ ២០១៨; ការ-បើកបៀវត្សត្រូវបានធ្វើទាន់ពេលវេលា ក្នុងសប្តាហ៍ទី ៤ នៃខែ ព្រមទាំងបានលើកកម្ពស់គុណភាព និង ប្រសិទ្ធភាពនៃសេវាសាធារណៈ, ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ។

ទី៤- សម្រេចបានលទ្ធផលគួរឱ្យកត់សម្គាល់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ បើគិតពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៨, ចំណូលចរន្តថវិការដ្ឋបានកើនឡើងជាង ២ ដង ពីប្រមាណ ២ ២៦៤ លានដុល្លារអាមេរិក ដល់ប្រមាណ៤ ៥៦០

លានដុល្លារអាមេរិក ។ លើមូលដ្ឋាននេះ, ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ, ចំណាយថវិការដ្ឋសរុប ត្រូវបានបង្កើនជិត ២ ដង ក្នុងនោះ, ចំណាយសរុបរបស់ក្រសួងអប់រំ យុវជន និង កីឡា ត្រូវបានបង្កើនជាង ៣ ដង, ចំណាយសរុបរបស់ក្រសួងសុខាភិបាល ត្រូវបានបង្កើនជិត ២ ដងកន្លះ, ចំណាយសរុបរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវបានបង្កើនជិត ៣ ដង ហើយចំណាយវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានក្នុងប្រទេស ត្រូវបានបង្កើនជិត ២ ដងកន្លះ ។ លើសពីនេះ, ប្រព័ន្ធថវិកាជាតិក៏ត្រូវបានកែលម្អកាន់តែប្រសើរជាងមុន តាមរយៈការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងថវិកា, ទាំងកម្រិតវិភាជ និង ទាំងកម្រិតប្រតិបត្តិការ ។

ទី៥- សម្រេចបាននូវគោលដៅនៃសូចនាករផ្នែកសង្គមសំខាន់ៗ, ទាំងក្នុងវិស័យអប់រំ និង សុខាភិបាល ។ ស្ថានភាពសុខភាពសាធារណៈត្រូវបានកែលម្អ ដោយសារការកាត់បន្ថយគួរឱ្យកត់សម្គាល់នៃអត្រាមរណភាពមាតា ទារក និង កុមារ, អត្រាប្រេវ៉ាឡង់នៃអ្នកផ្ទុកមេរោគអេដស៍ និង អត្រាស្លាប់ដោយជំងឺគ្រុនចាញ់ ក៏ត្រូវបានកាត់បន្ថយ ។**«មូលនិធិសមធម៌»** ត្រូវបានពង្រីកវិសាលភាពគ្របដណ្តប់បន្ថែម ដើម្បីជួយសម្រាលបន្ទុកចំណាយលើសុខភាពសម្រាប់ប្រជាជនក្រីក្រ ។ ការកែទម្រង់វិស័យអប់រំបង្កើតបាននូវបរិយាកាស និង ក្តីសង្ឃឹមថ្មី ក្នុងការបង្កើនគុណភាពធនធានមនុស្ស និង ជំនាញ សម្រាប់ផ្គត់ផ្គង់ទីផ្សារការងារ តាមរយៈការបង្កើតឱ្យមានសាលាជំនាន់ថ្មី, ការពង្រឹងគុណភាពនៃការបង្រៀន, ការលើកកម្ពស់សមត្ថភាពក្នុងការគ្រប់គ្រងសាលារៀន, ការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា, និង ការរៀបចំបរិយាកាសល្អ សម្រាប់ការរៀនសូត្រ ដែលត្រូវបានជំរុញឱ្យមានវឌ្ឍនភាពជាបណ្តើរៗ ។

ទី៦- បានចូលរួមកាន់តែសកម្មក្នុងកិច្ចការតំបន់ និង ពិភពលោក, ដោយស្មើមុខ និង ស្មើសិទ្ធិ, ទាំងផ្នែកសេដ្ឋកិច្ច និង នយោបាយ ។ក្នុងវិស័យពាណិជ្ជកម្ម,

កម្ពុជាបាននាំចេញទំនិញទៅកាន់ ១៤៧ ប្រទេស ក្នុងទំហំជាង ៦០% នៃ ផសស និង នាំចូលទំនិញពី ១៣៥ ប្រទេស ក្នុងទំហំប្រមាណ ៦៥% នៃ ផសស ។ ក្នុងក្របខណ្ឌអង្គការសហប្រជាជាតិ, គិតចាប់ពីឆ្នាំ ២០០៦ មក, កម្ពុជាបានបំពេញបេសកកម្មថែរក្សាសន្តិភាពនៅក្នុងប្រទេសចំនួន ៨ និង មានកម្លាំងចូលរួមចំនួន ៥ ៤៨៦ នាក់ ។ លើសពីនេះ, កិត្យានុភាពកម្ពុជា ក៏កាន់តែលេចខ្ពស់ឡើង តាមរយៈតួនាទីកាន់តែសកម្ម និង កាន់តែច្រើនរួមមាន : ក្នុងក្របខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក, កម្ពុជាបានបំពេញតួនាទីជាប្រធានសម្របសម្រួលនៃប្រទេសអភិវឌ្ឍតិចតួច ដោយជោគជ័យក្នុងឆ្នាំ ២០១៧-២០១៨ ដោយបានទាញយកអត្ថប្រយោជន៍ផ្នែកពាណិជ្ជកម្ម ពីសមាជិកភាពនៃអង្គការនេះ សម្រាប់កម្ពុជា; កម្ពុជាត្រូវបានជ្រើសរើសជាអនុប្រធាននៃមហាសន្និបាតអង្គការសហប្រជាជាតិលើកទី ៧៣ និង ត្រូវបានជ្រើសរើស ជាសមាជិកនៃក្រុមប្រឹក្សាសេដ្ឋកិច្ច-សង្គម នៃអង្គការសហប្រជាជាតិ; ក្នុងកិច្ចសហប្រតិបត្តិការក្នុងតំបន់, កម្ពុជាបានចូលរួមយ៉ាងសកម្ម ក្នុងក្របខណ្ឌអាស៊ាន និង គំនិតផ្តួចផ្តើមថ្មីៗក្នុងតំបន់ រួមបញ្ចូលនូវគំនិតផ្តួចផ្តើម **«ខ្សែក្រវាត់មួយ-ផ្លូវមួយ»**, ព្រមទាំងកិច្ចសហប្រតិបត្តិការទ្វេភាគី និង ពហុភាគីជាច្រើនទៀត ដែលក្នុងនោះ ក៏មានកិច្ចព្រមព្រៀងចៀសវាងការយកពន្ធត្រួតគ្នាជាដើម ។

ទី៧- កម្ពុជាបានប្រែក្លាយជាគោលដៅទេសចរណ៍ដ៏មានប្រជាប្រិយ ដែលនៅក្នុងឆ្នាំ ២០១៧ ទទួលបានទេសចរអន្តរជាតិសរុបចំនួន ៥,៦ លាននាក់, មកពី ១១០ ប្រទេសជុំវិញពិភពលោក ។ ការទទួលបានទេសចរកាន់តែច្រើនឡើងនេះ គឺជាលទ្ធផលនៃការសម្រេចបានការធ្វើសមាហរណកម្ម និង ការតភ្ជាប់ផ្នែកហេដ្ឋារចនាសម្ព័ន្ធទូទាំងផ្ទៃប្រទេស, ការផ្តត់ផ្គង់អគ្គិសនីមានស្ថិរភាព, ការធានាបាន

កាន់តែប្រសើរនូវសុវត្ថិភាពសម្រាប់ទេសចរ ព្រមទាំងការធ្វើពិពិធកម្មតំបន់ និង ផលិតផលទេសចរណ៍ ជាបណ្តើរៗ ។

ទី៨- កម្ពុជាបានក្លាយជាប្រទេសមួយ ក្នុងចំណោមប្រទេសនាំចេញអង្ករធំៗ ១០ ដែលក្នុងឆ្នាំ ២០១៧ បាននាំចេញអង្ករប្រមាណ ៦៣៥ ពាន់តោន, កើនឡើងជិតពីរដងធៀបនឹងឆ្នាំ ២០១៣ ។ លើសពីនេះ, កម្ពុជាបាននាំចេញផលិត-ផលកសិកម្មសរុប ក្នុងកំណើនពី ៣,៦៦ លានតោន ក្នុងឆ្នាំ ២០១៣ ដល់ ៥,១៤ លានតោន ក្នុងឆ្នាំ ២០១៧ ។ ក្នុងន័យនេះ, កម្ពុជាសម្រេចបានកំណើនវិជ្ជមានក្នុងវិស័យកសិកម្ម, ទោះបីវិស័យនេះ ទទួលរងនូវផលប៉ះពាល់ដោយសារថ្លៃកសិផលទាបលើទីផ្សារអន្តរជាតិ, ការបាត់បង់កម្លាំងពលកម្ម និង ភាពងាយរងគ្រោះដោយបាតុភូតធម្មជាតិក្តី ។

## ១.២. និន្នាការធំៗ បញ្ហាប្រឈម និង កាលានុវត្តភាពរបស់កម្ពុជា

### ១.២.១. និន្នាការធំៗ

ក្នុងរយៈពេលខាងមុខ, កម្ពុជានឹងប្រឈមជាមួយនិន្នាការវិវត្តធំៗមួយចំនួន, ទាំងក្នុង និង ក្រៅប្រទេស, ដែលជាកត្តាសត្យានុម័តកំណត់នូវបរិការណ៍ និង ទិសដៅនៃដំណើរការអភិវឌ្ឍប្រទេស ដែលអាចនឹងស្តែងឡើង ជាបញ្ហាប្រឈមផង និង ជាកាលានុវត្តភាពផង ។ ការណ៍នេះ, តម្រូវឱ្យកម្ពុជាពិនិត្យឡើងវិញនូវម៉ូដែល (Paradigm) នៃការអភិវឌ្ឍរបស់ខ្លួន សម្រាប់រយៈពេលមធ្យមទៅរយៈពេលវែងខាងមុខ ។ និន្នាការទាំងនោះ រួមមាន ÷

ទី១- ពិភពលោកកំពុងវិវត្តទៅរកក្របខណ្ឌពហុប៉ូលថ្មី ដោយសារការ-ប្រែប្រួលកម្លាំង និង ការកែតម្រូវតុល្យការ នៃអំណាចសកល ។ ការវិវត្តបែបនេះ នឹងនាំទៅរកការកែទម្រង់និម្មាបនកម្មនៃវិធាន និង ស្ថាប័នសកល, ទាំងនយោបាយ

និង សេដ្ឋកិច្ច, ដែលចំណុះឱ្យយថាភាព ឬ រចនាសម្ព័ន្ធនៃអំណាចដែលមានលក្ខណៈទ្វេប៉ូល និង ឯកប៉ូល ឬ ក៏ការបង្កើតនូវគំនិតផ្តួចផ្តើមថ្មីៗ នៅតាមតំបន់ និង ប៉ូលនៃអំណាចថ្មីៗ ។

ទី២- សេដ្ឋកិច្ចពិភពលោកដែលធ្លាប់តែនាំមុខដោយអាមេរិក និង អឺរ៉ុប, បច្ចុប្បន្នបាន និង កំពុងនាំមុខដោយអាស៊ី គឺ : ចិន និង ឥណ្ឌា ។ ជាមួយគ្នានេះ, សេដ្ឋកិច្ចសកលក៏កាន់តែប្រមូលផ្តុំខ្លាំងឡើងនៅទីក្រុង និង ទីប្រជុំជន ដែលតាមការប៉ាន់ស្មាន នឹងមានប្រជាជនរស់នៅជិតពាក់កណ្តាល នៅក្នុងឆ្នាំ ២០៥០ ។

ទី៣- ចរន្តនៃការរីកចម្រើនវិទ្យាសាស្ត្រ និង បច្ចេកវិទ្យា, ដែលត្រូវបានគេហៅថា **«បដិវត្តន៍ឧស្សាហកម្មទី ៤»** , បានក្លាយទៅជាកត្តាគន្លឹះចម្បងមួយកំណត់នូវនិន្នាការវិវត្តនៃសង្គម- សេដ្ឋកិច្ច ក្នុងគ្រប់ទិដ្ឋភាព ដែលបង្កើតឡើងទាំងកាលានុវត្តភាព, ទាំងបញ្ហាប្រឈម, សម្រាប់សកលលោកទាំងមូល ។ ការរីក-ចម្រើនផ្នែកបច្ចេកវិទ្យា នឹងជំរុញល្បឿន និង ជម្រៅ នៃស្វ័យប្រវត្តិកម្ម ដែលអាចជំនួសដល់កម្លាំង និង បញ្ញាមនុស្ស ។ ចរន្តនេះ មា នឥទ្ធិពលយ៉ាងខ្លាំងលើការ-កំណត់ឡើងវិញ នូវកត្តាផលិតកម្ម ទំនាក់ទំនងផលិតកម្ម ឥរិយាបថការប្រើប្រាស់ និង រចនាសម្ព័ន្ធសេដ្ឋកិច្ច ។

ទី៤- ការប្រែប្រួលអាកាសធាតុ និង ការបាត់បង់នូវជីវចម្រុះ ដែលនាំឱ្យកំដៅផែនដីកើនឡើងរយៈពេលវែង, នឹ ងបណ្តាលឱ្យបាតុភូតធម្មជាតិមានការ-ប្រែប្រួល ក្នុងលក្ខណៈគំហុកជាងសព្វដង និង មិនទៀងទាត់ដូចមុន, ទាំងភាពរាំងស្ងួត រលកកំដៅ និង ទឹកជំនន់ ។

### ១ . ២ . ២ . បញ្ហាប្រឈម

ក្នុងរយៈពេលមធ្យមខាងមុខ, កម្ពុជានឹងស្ថិតនៅលើដំណើរឆ្ពោះទៅជា

ប្រទេសចំណូលមធ្យមកម្រិតខ្ពស់ ជាមួយនឹងការប្រែប្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ច និង ការប្រែប្រួលរចនាសម្ព័ន្ធប្រជាសាស្ត្រ ។ ក្នុងបរិការណ៍នេះ, កម្ពុជានឹងជួបបញ្ហា-ប្រឈមសំខាន់ៗមួយចំនួន ដូចតទៅ ÷

ទី១- សេដ្ឋកិច្ចពិភពលោក និង តំបន់ បន្តស្ថិតនៅក្នុងភាពមិនប្រាកដ-ប្រជា ដោយសារ **«សង្គ្រាមពាណិជ្ជកម្ម»** ក្រោមគោលនយោបាយគាំពារនិយម, ប្រក្រតីកម្មនៃគោលនយោបាយរូបិយវត្ថុរបស់ប្រទេសអភិវឌ្ឍ, កំណើនឥណទានយ៉ាងឆាប់រហ័សក្នុងប្រទេសចិន, ការកើនឡើងវិញនូវថ្លៃប្រេង និង បញ្ហានានាពាក់ព័ន្ធនឹងភូមិសាស្ត្រនយោបាយ ភេរវកម្ម និង សន្តិសុខសកល ។ ស្ថានភាពបែបនេះ អាចនឹងបង្កផលប៉ះពាល់អាក្រក់ដល់សេដ្ឋកិច្ចកម្ពុជា ដែលពឹងផ្អែកខ្លាំងលើពាណិជ្ជកម្មអន្តរជាតិ សម្រាប់ជំរុញការអភិវឌ្ឍប្រទេស ។

ទី២- ការធានានូវសុខសន្តិភាព ស្ថិរភាពនយោបាយ និង សណ្តាប់ធ្នាប់សង្គម នៅតែជាបញ្ហាប្រឈមដ៏សំខាន់ ដោយសារភាពផុយស្រួយ បង្កឡើងដោយ-សារកត្តាផ្ទៃក្នុងផង និង កត្តាពីក្រៅប្រទេសផង ។

ទី៣- តម្រូវការក្នុងការអភិវឌ្ឍធនធានមនុស្ស ប្រកបដោយគុណភាព សមត្ថភាព និង ផលិតភាព ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការក្នុងការអភិវឌ្ឍសង្គម- សេដ្ឋកិច្ចកម្ពុជា ដែលជាកត្តាគន្លឹះ សម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច និង ភាពប្រកួតប្រជែងរបស់ប្រទេស, ទាំងក្នុងពេលចំពោះមុខ និង សម្រាប់អនាគតរយៈពេលវែង ។ ទោះបីកម្ពុជាសម្រេចបាន ការគ្របដណ្តប់ផ្នែកអប់រំកម្រិតបឋមសិក្សា ប៉ុន្តែនៅមានបញ្ហាប្រឈមផ្នែកលទ្ធផលនៃការរៀនសូត្រ, ការបន្តការសិក្សារហូតចប់មធ្យមសិក្សា ដែលជាមូលដ្ឋានសម្រាប់ឈោងចាប់ជំនាញ, និង ការលើកកម្ពស់គុណភាពឧត្តមសិក្សា ដើម្បីទាញយកផលប្រយោជន៍ពីភាពរីកចម្រើននៃ

បច្ចេកវិទ្យា និង ការធ្វើនវានុវត្តលើឧស្សាហកម្មមានស្រាប់ ។

ទី៤- បញ្ហាប្រឈមក្នុងការធ្វើពិពិធកម្ម និង ការបង្កើតតម្លៃបន្ថែម ក្នុងវិស័យឧស្សាហកម្ម និង វិស័យសេវាកម្ម រួមមាន ៖ សម្ពាធកើនឡើងនៃប្រាក់ឈ្នួល, បញ្ហាទំនាក់ទំនងវិជ្ជាជីវៈ, ថ្លៃដឹកជញ្ជូនខ្ពស់, ប្រព័ន្ធឡូជីស្ទីកមិនទាន់មានប្រសិទ្ធភាពគ្រប់គ្រាន់, ថ្លៃថាមពលអគ្គិសនីនៅខ្ពស់ធៀបនឹងប្រទេសជិតខាង, ចំណាយក្រៅផ្លូវការ, និង បរិយាកាសធុរកិច្ចនៅមានភាពស្មុគស្មាញ ។

ទី៥- ការជំរុញធ្វើពិពិធកម្ម និង លើកកម្ពស់ផលិតភាពនៃវិស័យកសិកម្ម គឺជាបញ្ហាប្រឈម ដែលត្រូវដោះស្រាយបន្ទាន់ នៅក្នុងល្បឿន និង ទំហំថ្មីមួយ ពីព្រោះថា វិស័យកសិកម្មនៅបន្តដើរតួនាទីសំខាន់នៅក្នុងសេដ្ឋកិច្ចជាតិ ជាពិសេស សម្រាប់ការកាត់បន្ថយភាពក្រីក្រ, ការកាត់បន្ថយចំណាយទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃ និង ការបង្កើតការងារជូនប្រជាជន ។ លើសពីនេះ, វិស័យនេះ អាចរួមចំណែកទប់ស្កាត់ការធ្លាក់ចូលក្នុងភាពក្រីក្រសាជាថ្មី និង បង្រួមគម្លាតចំណូលរបស់ប្រជាជន ក៏ដូចជាគម្លាតរវាងទីក្រុង និង ជនបទ ។ ម៉្យាងទៀត, ការវិនិយោគលើវិស័យកសិកម្មនឹងជួយធានានូវសន្តិសុខស្បៀងក្នុងរយៈពេលវែង ព្រមទាំងអាចរក្សាថ្លៃម្ហូបអាហារឱ្យនៅទាប ដែលជួយរក្សាកម្រិតបៀវត្សពិត ឱ្យបានល្អប្រសើរ ។

ទី៦- ការផ្តល់សេវាសាធារណៈ និង សេវាយុត្តិធម៌ នៅមិនទាន់ទទួលបានជំនឿទុកចិត្តគ្រប់គ្រាន់ពីសំណាក់មហាជន, ការងារកសាងស្ថាប័ន និង ក្របខណ្ឌច្បាប់ នៅមិនទាន់គ្រប់ជ្រុងជ្រោយ, ហើយការយល់ដឹងក្នុងការអនុវត្តច្បាប់ ក៏នៅតែមិនទាន់មានប្រសិទ្ធភាពពេញលេញតាមដែលរាជរដ្ឋាភិបាលចង់បាននៅឡើយ ។ ទន្ទឹមនេះ, ការរៀបចំ និង កំណត់រចនាសម្ព័ន្ធ ក៏ដូចជាការផ្ទេរមុខងារ និង ធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏នៅមិនទាន់អាចឆ្លើយតបបានទាំងស្រុង ទៅនឹង

តម្រូវការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិផងដែរ ។

ទី៧- គុណភាពនៃសេវាសុខាភិបាល នៅតែជាបញ្ហាប្រឈម, ទោះបីជាសេវាសុខភាពសាធារណៈ ត្រូវបានកែលម្អមួយកម្រិតធំហើយក៏ដោយ ។ ស្របពេលដែលជីវភាព និង លក្ខខណ្ឌរស់នៅរបស់ប្រជាជន មានការផ្លាស់ប្តូរ, គោលនយោបាយផ្នែកសុខាភិបាល ក៏ទាមទារឱ្យមាននូវក ារគិតគូរឡើងវិញក្នុងគ្រប់ទិដ្ឋភាព, ទាំងការផ្គត់ផ្គង់, ការផ្តល់សេវា, គុណភាពសេវា, ហិរញ្ញប្បទាន, និង ភាពគ្រប់ដណ្តប់នៃសេវា ។

ទី៨- បញ្ហាប្រឈមក្នុងវិស័យហិរញ្ញវត្ថុ គឺអត្រាការប្រាក់ខ្ពស់, ការសន្សំក្នុងស្រុកនៅទាប និង ការកើនឡើងបំណុលរបស់គេហជន ។ ខណៈដែលវិស័យធនាគារ និង ហិរញ្ញវត្ថុ សម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់, កំណើនឥណទាន និង អត្រាការប្រាក់ បន្តស្ថិតនៅក្នុងកម្រិតខ្ពស់នៅឡើយ ទោះបីជាបានថមថយជាលំដាប់ក៏ដោយ ។ លើសពីនេះ, ការសន្សំក្នុងស្រុកនៅមានកម្រិតទាប បានធ្វើឱ្យកម្ពុជាពឹងផ្អែកលើមូលធនខាងក្រៅសម្រាប់ការវិនិយោគ ។ ក្នុងស្ថានភាពដែលកម្ពុជាបានបាត់បង់ជាបណ្តើរៗនូវឱកាសខ្ចីបំណុលសម្បទាន, ការសន្សំក្នុងស្រុកនឹងផ្តល់នូវប្រភពទុនសំខាន់ សម្រាប់ការវិនិយោគ, ទាំងឯកជន និង សាធារណៈ ។

ទី៩- ថ្វីត្បិតតែការគ្រប់គ្រងបរិស្ថាន និង ធនធានធម្មជាតិ ត្រូវបានកែលម្អតាមរយៈការពង្រឹងការគ្រប់គ្រងធនធានរ៉ែ និង ការអនុវត្តការកែទម្រង់ ក្នុងវិស័យព្រៃឈើ និង វិស័យជលផល រួមទាំងការអភិរក្សមច្ឆជាតិផង, ក៏ដូចជាក្នុងវិស័យដីធ្លី, ព្រមទាំងក្នុងការគ្រប់គ្រងធនធានទឹក រួមបញ្ចូលការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីបឹងទន្លេសាប និង អាងទន្លេមេគង្គផងដែរ, បញ្ហាប្រឈមនៅតែមានច្រើននៅឡើយ ដែលការណ៍នេះ ទាមទារឱ្យមានការខិតខំប្រឹងប្រែង និង ការផ្តួចផ្តើមគំនិតបន្ថែម

ទៀត ដើម្បីធានាឱ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាព ។ បន្ថែមលើនេះ, ការ-ប្រែប្រួលអាកាសធាតុ ក៏បាន និង កំពុងជះឥទ្ធិពលអវិជ្ជមានលើប្រព័ន្ធអេកូឡូស៊ី និង លើការអភិវឌ្ឍសង្គម- សេដ្ឋកិច្ចកម្ពុជាផងដែរ ។

ទី១០- កម្ពុជាកំពុងតែធ្វើដំណើរឈានទៅចាកចេញពីឋានៈប្រទេសមានកម្រិតអភិវឌ្ឍតិចតួច (LDCs) ដែលការណ៍នេះ អាចនាំទៅដល់ការកាត់បន្ថយ ឬការបាត់បង់ទាំងស្រុងជាយថាហេតុ នូវការផ្តល់ភាពអនុគ្រោះខាងពាណិជ្ជកម្មពីដៃគូអភិវឌ្ឍសំខាន់ៗ ។ ដូច្នេះ, កម្ពុជាត្រូវខិតខំទាញប្រយោជន៍ពីកាលានុវត្តភាពដែលមានក្នុងបច្ចុប្បន្ននេះផង និង ចាំបាច់ត្រូវរៀបចំធានានូវភាពអំណោយផលខាងទីផ្សារថ្មីថែមទៀតផង ព្រមទាំងត្រូវពង្រឹងភាពប្រកួតប្រជែងរបស់ខ្លួនផង ដើម្បីបន្តជំរុញលើកកម្ពស់ និង ធ្វើពិពិធកម្មការនាំចេញផលិតផលរបស់ខ្លួន ។

### ១.២.៣. កាលានុវត្តភាព

បរិការណ៍សកល និង ក្នុងប្រទេស នាពេលបច្ចុប្បន្ន បានផ្តល់ឱ្យកម្ពុជានូវកាលានុវត្តភាពសំខាន់ៗ ដូចតទៅ ÷

ទី១- ក្នុងបរិការណ៍នៃការងើបឡើងវិញនៃសេដ្ឋកិច្ចសកល ដែលរំពឹងថានឹងល្អប្រសើរជាងបណ្តាឆ្នាំមុនៗ ពិសេសនៅបណ្តាប្រទេសជាដៃគូពាណិជ្ជកម្មសំខាន់ៗ, កម្ពុជាក៏នឹងបន្តរក្សាចលនាកំណើនដ៏រឹងមាំក្នុងរយៈពេលមធ្យម ដែលបង្ហាញពីភាពល្អូតលាស់នៃសកម្មភាពអាជីវកម្ម, ការបន្តកំណើននៃការវិនិយោគផ្ទាល់ពីបរទេស, ការបន្តកើនឡើងនៃសេចក្តីត្រូវការក្នុងស្រុក និង ភាពល្អប្រសើរនៃពាណិជ្ជកម្មអន្តរជាតិ ។

ទី២- ការផ្លាស់ប្តូរទីប្រជុំទម្ងន់នៃកំណើនសេដ្ឋកិច្ចមកទ្វីបអាស៊ី ពិសេសមកអាស៊ីបូព៌ា, បន្តនៅជា«**ឱកាសមាស**» សម្រាប់កម្ពុជា សម្រាប់ការអភិវឌ្ឍ និង ធ្វើ

ទំនើបកម្មឧស្សាហកម្ម, ផលិតកម្ម និង សេវាកម្ម, ជាមួយបណ្តាប្រទេសក្នុងតំបន់ ដោយសារកម្ពុជាស្ថិតនៅចំកណ្តាលនៃតំបន់ដែលកំពុងមានកំណើនប្រកបដោយជីវភាព និង មានសក្តានុពលក្លាយទៅជាផ្នែកសំខាន់មួយនៃខ្សែច្រវាក់ផលិតកម្មក្នុងតំបន់អាស៊ីបូព៌ា ។

ទី៣- ការកើនឡើងគួរឱ្យកត់សម្គាល់នៃការប្រកួតប្រជែង រវាងបណ្តាប្លុកពាណិជ្ជកម្មនៅអាស៊ី- ប៉ាស៊ីហ្វិក ជាអាទិ៍ : ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់, ភាពជាដៃគូអន្តរប៉ាស៊ីហ្វិក, ព្រមទាំងគំនិតផ្តួចផ្តើមសហប្រតិបត្តិការផ្សេងៗទៀត, នឹងបង្កើតឡើងនូវចលនការសេរីភាវូបនីយកម្មពាណិជ្ជកម្មទំនិញ សេវា និង ការវិនិយោគដ៏ធំសម្បើមនៅក្នុងតំបន់ ។ ការណ៍នេះ, នឹងផ្តល់ឱកាស ដល់កម្ពុជា ដែលជាសមាជិកអាស៊ាន ដើម្បីស្រូបយកការវិនិយោគ និង ពង្រីកទីផ្សារនាំចេញរបស់ខ្លួន ឱ្យកាន់តែធំទូលាយ ដោយសារការផ្សារភ្ជាប់ឧស្សាហកម្ម និង ពាណិជ្ជកម្ម ក៏ដូចជាការតភ្ជាប់, ទាំងផ្នែករូបវន្ត និង ស្ថាប័ន ជាមួយនឹងខ្សែច្រវាក់ផលិតកម្ម និង បណ្តាញផ្គត់ផ្គង់ នៅក្នុងតំបន់ និង អន្តរតំបន់នានា ។

ទី៤- កម្ពុជានៅមានសក្តានុពលយ៉ាងច្រើន ក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ រួមមាន ការបន្តបង្កើនភាពស៊ីជម្រៅនៃអន្តរការីយកម្មហិរញ្ញវត្ថុ, ការលើកកម្ពស់វិស័យធានារ៉ាប់រង និង ការអភិវឌ្ឍទីផ្សារមូលបត្រ ។

ទី៥- ផលលាភប្រជាសាស្ត្រ និង អត្រាទាបនៃអ្នករស់នៅក្នុងបន្ទុក គួបផ្សំនឹងការកើនឡើងនៃចំនួនប្រជាជន ដែលមានចំណូលមធ្យម និង ជាវណ្ណៈកណ្តាល នឹងបង្កើតកាលានុវត្តភាពសម្រាប់កម្ពុជា ក្នុងការសម្រេចនូវកំណើនសេដ្ឋកិច្ចខ្ពស់ សម្រាប់រយៈពេលប្រមាណ ៣ ទសវត្សរ៍ខាងមុខ ។

ទី៦- ការរីកចម្រើនផ្នែកបច្ចេកវិទ្យា ក្នុងដំណាក់កាលនៃបដិវត្តន៍ឧស្សា-

ហកម្មទី ៤ នេះ បានបង្កើតនូវមុខរបរ និង ធុរកិច្ចថ្មីៗជាច្រើន ដែលមិនធ្លាប់មានពីមុនមក ។ ចំពោះមុខនេះ, សេដ្ឋកិច្ចឌីជីថលកំពុងមានសន្ទុះកើនឡើង ដែលផ្តល់កាលានុវត្តភាពសម្រាប់កម្ពុជារៀបចំរចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់ខ្លួន ឱ្យកាន់តែប្រសើរ ក្នុងខណៈដែលកម្ពុជាមានអត្រាអ្នកប្រើប្រាស់ទូរស័ព្ទ និង អ៊ីនធឺណិតខ្ពស់ ។

## ១.៣. ភាពចាំបាច់ក្នុងការបន្តអនុវត្តយុទ្ធសាស្ត្រចតុកោណ

យោងតាមបទពិសោធន៍ក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណទាំង ៣ ដំណាក់-កាលកន្លងមក, រាជរដ្ឋាភិបាលអាចធ្វើការវាយតម្លៃបានត្រឹមត្រូវ ពីភាពខ្លាំង និង ភាពខ្សោយ ក៏ដូចជាបញ្ហាប្រឈម និង កាលានុវត្តភាព ។ ចំណុចខ្លាំងនៃយុទ្ធ-សាស្ត្រចតុកោណ គឺការផ្តល់ក្របខណ្ឌគោលនយោបាយប្រទាក់ក្រឡាគ្នា គ្រប់ជ្រុង-ជ្រោយ និង ប្រកបដោយសង្គតិភាព ព្រមទាំងគ្របដណ្តប់លើគ្រប់វិស័យសំខាន់ៗ សម្រាប់ការចូលរួមគាំទ្រអនុវត្តពីគ្រប់ក្រសួង- ស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលជាមូលដ្ឋានយ៉ាងសំខាន់ សម្រាប់ការវិភាជធនធាន ឆ្លុះទេ អាទិភាពគោល-នយោបាយ និង ជាក្របខណ្ឌមួយដ៏ល្អសម្រាប់កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍទាំងអស់ ដែលមានការពាក់ព័ន្ធ រួមទាំងវិស័យឯកជន និង សង្គមស៊ីវិល ផង ។ យ៉ាងណាមិញ, ចំណុចខ្សោយនៅក្នុងនេះ គឺបញ្ហាប្រសិទ្ធភាពនៃការអនុវត្ត ដែលពាក់ព័ន្ធទៅនឹងសមត្ថភាពស្ថាប័ន និង ប្រសិទ្ធភាពនៃការសម្របសម្រួលរវាងក្រសួង- ស្ថាប័ន ក្នុងការដាក់ចេញ និង អនុវត្តវិធានការគោលនយោបាយជាក់ស្តែង ។ ម្យ៉ាងទៀត, សកម្មភាពអនុវត្តប្រចាំថ្ងៃ ក៏នៅមានគម្លាត និង មិនបានផ្សារភ្ជាប់ល្អទៅនឹងគោលបំណងគោលនយោបាយរបស់រាជរដ្ឋាភិបាល និង របស់ក្រសួង- ស្ថាប័ន ។

ក្នុងន័យនេះ, ភាពចាំបាច់នៃការបន្តអនុវត្ត **យុទ្ធសាស្ត្រចតុកោណ** នៅក្នុងដំណាក់កាលទី ៤ តទៅមុខទៀតនេះ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងទិដ្ឋភាពសំខាន់ៗ

ដូចខាងក្រោម ÷

ទី១- ភាពចាំបាច់ក្នុងការបន្តពង្រឹង និង ពង្រីកសមិទ្ធផលនានា ដែលរាជរដ្ឋាភិបាលសម្រេចបាន ក្នុងនីតិកាលទី ៥ កន្លងមក ក៏ដូចជាក្នុងការបញ្ចប់ការងារសេសសល់ទាំងឡាយ នៅក្នុងក្របខណ្ឌ **យុទ្ធសាស្ត្រចតុកោណ** ទាំង ៣ ដំណាក់កាលមុន តាមរយៈការបន្តពង្រឹងសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម; ការលើកស្ទួយនីតិរដ្ឋ, សិទ្ធិសេរីភាព និង សេចក្តីថ្លៃថ្នូររបស់មនុស្ស, លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស; និង ការអនុវត្តវិធានការជាក់ស្តែងនានា សំដៅលើកកម្ពស់កម្រិតជីវភាព និង សុខុមាលភាពរបស់ប្រជាជន ពិសេសការដោះស្រាយបញ្ហា **«ប្រសិទ្ធភាព»** នៃអភិបាលកិច្ច និង បញ្ហាយុត្តិធម៌សង្គម ព្រមទាំងការពង្រឹងគុណភាពនៃសេវាសាធារណៈគ្រប់ប្រភេទ ។

ទី២- ភាពចាំបាច់ក្នុងការស្វែងរកប្រភពថ្មី ដើម្បីធានាកំណើនសេដ្ឋកិច្ចខ្ពស់ និង ប្រកបដោយចីរភាព ដោយទាញយកប្រយោជន៍ពីកាលានុវត្តភាពនៅក្នុងតំបន់, បង្កើតតម្លៃបន្ថែមក្នុងវិស័យចន្លល់សេដ្ឋកិច្ចដែលមានស្រាប់ និង អនុវិស័យពាក់ព័ន្ធ, ជំរុញការវិនិយោគក្នុងវិស័យកសិកម្ម, រៀបចំខ្លួនសម្រាប់ការឈោងចាប់យកបច្ចេកវិទ្យាថ្មីៗក្នុងយុគសម័យសេដ្ឋកិច្ចឌីជីថល និង ឈោងចាប់យកឱកាសក៏ដូចជាជំនះផលវិបាកពីបដិវត្តន៍ឧស្សាហកម្មទី ៤, ព្រមទាំងលើកកម្ពស់ភាព-ប្រកួតប្រជែងរបស់កម្ពុជា ក្នុងគោលដៅឆ្លើយតប និង ដោះស្រាយនូវកង្វល់ និងសំណូមពរថ្មីៗរបស់ប្រជាជនកម្ពុជា នៅក្នុងដំណាក់កាលថ្មីនៃការអភិវឌ្ឍ និង ក្នុងគោលដៅបម្រើឱ្យបេសកកម្មនៃការដឹកនាំកម្ពុជា ឈានទៅសម្រេចបានឋានៈជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និង ជាប្រទេសចំណូលខ្ពស់ នៅឆ្នាំ ២០៥០ ។

លើមូលដ្ឋាននេះ, រាជរដ្ឋាភិបាលបានកំណត់យក«**គោលដៅយុទ្ធសាស្ត្រ ៤**» និង«**វិស័យអាទិភាព ៤**» ជាការប្ដេជ្ញាចិត្តក្នុងការបន្តអនុវត្ត«**យុទ្ធសាស្ត្រចតុកោណ**» ក្នុងដំណាក់កាលទី ៤ នេះ ។

«**គោលដៅយុទ្ធសាស្ត្រ ៤**» គឺ ÷

ទី១- ធានាឱ្យបានកំណើនសេដ្ឋកិច្ច ក្នុងអត្រាមធ្យមប្រចាំឆ្នាំក្នុងរង្វង់ ៧% ប្រកបដោយចីរភាព និង ធន់នឹងវិបត្តិ តាមរយៈការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចថ្មីៗ ដោយទូលំទូលាយ និង មានភាពប្រកួតប្រជែង ជាមួយនឹងការថែរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការគ្រប់គ្រងអត្រាអតិផរណាឱ្យនៅទាប, ការធានាស្ថិរភាពអត្រាប្ដូរប្រាក់, ការខិតខំបង្កើនទុនបម្រុងជាប្រចាំ និង ការគ្រប់គ្រងបំណុលសាធារណៈដោយគត់មត់ ។

ទី២- បង្កើតការងារឱ្យបានកាន់តែច្រើន, ទាំងបរិមាណ និង គុណភាព, ជូនដល់ប្រជាជនកម្ពុជា ពិសេសសម្រាប់ស្រទាប់យុវជន តាមរយៈការផ្ដល់ជំនាញ, ព័ត៌មានទីផ្សារការងារ, ការកែលម្អលក្ខខណ្ឌការងារ, ការលើកកម្ពស់សកម្មភាពធុរកិច្ច, និង ការជំរុញការវិនិយោគ, ទាំងក្នុងប្រទេស និង ក្រៅប្រទេស ។

ទី៣- សម្រេចឱ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រ ឱ្យស្ថិតនៅក្នុងអត្រាទាបជាង ១០%, ការពារមិនឱ្យភាពក្រីក្រវិលត្រឡប់មកវិញ ដោយផ្ដោតលើការលើកកម្ពស់ការចូលរួមក្នុងយន្តការទីផ្សារ, ការអនុវត្តគោលនយោបាយគាំពារសង្គម, ការកាត់បន្ថយបន្ទុកជីវភាពរស់នៅ និង ការផ្ដល់សេវាសាធារណៈប្រកបដោយគុណភាព និង ការកាត់បន្ថយគម្លាតសង្គម ។

ទី៤- បន្តពង្រឹងសមត្ថភាព និង អភិបាលកិច្ចនៃស្ថាប័នរដ្ឋ, ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពនៃសេវាសាធារណៈ សំដៅ

បម្រើប្រជាជនឱ្យបានកាន់តែប្រសើរឡើង ក៏ដូចជាលើកកម្ពស់បរិយាកាសធុរកិច្ច និង បរិស្ថានអំណោយផលសម្រាប់ការវិនិយោគ ។

«**វិស័យអាទិភាព ៤**» គឺ ÷

ក្នុងនីតិកាលកន្លងមក, រាជរដ្ឋាភិបាលបានកំណត់យកអាទិភាពចំនួន ៤ រួមមាន **ផ្លូវ ទឹក ភ្លើង** និង **មនុស្ស** ដើម្បីជំរុញការអភិវឌ្ឍប្រទេស ដែលលំដាប់នៃសារៈសំខាន់របស់អាទិភាពទាំងនេះ ត្រូវបានផ្លាស់ប្តូរទៅតាមដំណាក់កាលនីមួយៗនៃការអភិវឌ្ឍ ។ ក្នុងដំណាក់កាល ២ ខាងដើម, **យុទ្ធសាស្រ្តចតុកោណ** បានផ្តោតអាទិភាពទី ១ លើ**ផ្លូវ** ហើយ **ទឹក ភ្លើង** និង **មនុស្ស** គឺជាអាទិភាពបន្តបន្ទាប់ ។ នៅក្នុង **យុទ្ធសាស្រ្តចតុកោណ-ដំណាក់កាលទី ៣, មនុស្ស** បានក្លាយជាអាទិភាពទី ១ វិញ ហើយ **ផ្លូវ ភ្លើង** និង **ទឹក** បានក្លាយជាអាទិភាពបន្តបន្ទាប់ ។ សម្រាប់នីតិកាលទី ៦ នេះ, **យុទ្ធសាស្រ្តចតុកោណ-ដំណាក់កាលទី ៤** នឹងបន្តផ្តោតការយកចិត្តទុកដាក់លើ«**វិស័យអាទិភាព ៤**» ដោយតម្កល់«**មនុស្ស**» ជាអាទិភាពទី ១ នៅលើគេ ។ ក្នុងគោលដៅនេះ, «**ចតុកោណយុទ្ធសាស្រ្ត**» ទាំង ៤ នៃ **យុទ្ធសាស្រ្តចតុកោណ** ត្រូវបានរៀបចំកែសម្រួលឡើងវិញ ឱ្យឆ្លុះបញ្ចាំង «**វិស័យអាទិភាព ៤**» និង កិច្ចការមួយចំនួនទៀត ដែលឆ្លើយតបនឹងតម្រូវការអភិវឌ្ឍកម្ពុជានៅក្នុងដំណាក់កាលថ្មី ដូចខាងក្រោម ÷

**ចតុកោណទី ១**- ការអភិវឌ្ឍធនធានមនុស្ស រួមមាន ៖ ១)• ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្រ្ត និង បច្ចេកវិទ្យា; ២)• ការបណ្តុះបណ្តាលជំនាញបច្ចេកទេស; ៣)• ការលើកកម្ពស់សេវាសុខភាពសាធារណៈ និង អាហារូបត្ថម្ភ; និង ៤)• ការពង្រឹងសមភាពយេនឌ័រ និង ការគាំពារសង្គម ។

**ចតុកោណទី ២**- ការធ្វើពិពិធកម្មសេដ្ឋកិច្ច រួមមាន ៖ ១)• ការកែលម្អ

ប្រព័ន្ធឡូជីស្ទីក, ការលើកកម្ពស់ការតភ្ជាប់ ផ្នែកដឹកជញ្ជូន ថាមពល និង ឌីជីថល; ២). ការអភិវឌ្ឍប្រភពនៃកំណើនសេដ្ឋកិច្ចគន្លឹះ និង ថ្មីៗ; ៣). ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និង ឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី ៤; និង ៤). ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និង ធនាគារ ។

**ចតុកោណទី ៣**- ការលើកស្ទួយវិស័យឯកជន និង ការងារ រួមមាន : ១). ការអភិវឌ្ឍទីផ្សារការងារ; ២). ការលើកស្ទួយសហគ្រាសធុនតូច និង មធ្យម និង សហគ្រិនភាព; ៣). ការរៀបចំ និង អនុវត្តភាពជាដៃគូវិស័យសាធារណៈ និង ឯកជន; និង ៤). ការពង្រឹងការប្រកួតប្រជែង ។

**ចតុកោណទី ៤**- ការអភិវឌ្ឍប្រកបដោយចីរភាព និង បរិយាប័ន្ន រួមមាន : ១). ការលើកស្ទួយវិស័យកសិកម្ម និង ការអភិវឌ្ឍជនបទ; ២). ការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ និង វប្បធម៌ដោយចីរភាព; ៣). ការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម; និង ៤). ការធានាចីរភាពបរិស្ថាន និង ការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ។

# ផ្នែកទី ២

## ២.១. រចនាសម្ព័ន្ធនៃយុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី ៤

ជោគជ័យក្នុងការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ** ដំណាក់កាលទី ១, ទី២, និង ទី ៣ កន្លងមកគឺជាសក្ខីភាពឆ្លុះបញ្ចាំងឱ្យឃើញភាពជាម្ចាស់ និង សមត្ថភាពដ៏រឹងមាំរបស់រាជរដ្ឋាភិបាល ក្នុងការដឹកនាំប្រទេស ។ ក្នុងបរិការណ៍បច្ចុប្បន្ន, ផ្អែកលើភាពចាំបាច់ ដូចបានបញ្ជាក់ពីខាងដើម កម្ពុជាបានត្រៀមលក្ខណៈសម្បត្តិយ៉ាងហ្មត់ចត់ និង គ្រប់ជ្រុងជ្រោយ ដើម្បីប្រើប្រាស់ឱ្យអស់នូវកាលានុវត្តភាព និងសក្តានុពលរបស់ខ្លួន សំដៅបន្តដោះស្រាយបញ្ហាប្រឈមនានា ក្នុងដំណាក់កាលបន្ទាប់នៃការអភិវឌ្ឍជាតិ ។

ដូចបានបញ្ជាក់ពីខាងដើម, **«យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី ៤»** នៅរក្សាជារួមនូវរចនាសម្ព័ន្ធដើមរបស់ខ្លួន ។ ទន្ទឹមនេះ, រាជរដ្ឋាភិបាលបានកែសម្រួលលំដាប់អាទិភាពតាមការដ្ឋាន និង មុំមួយចំនួននៃយុទ្ធសាស្ត្រនេះ ព្រមទាំងបញ្ចូលអាទិភាពថ្មីមួយចំនួន ហើយបានសម្រិតសម្រាំង និង សម្រួចសកម្មភាពមួយ-ចំនួនបន្ថែមទៀត ដើម្បី : ទី១). ឆ្លើយតបនឹងសេចក្តីត្រូវការជាក់ស្តែង និង បរិការណ៍ថ្មីៗរបស់កម្ពុជា ដូចបានគូសបញ្ជាក់ខាងលើ ហើយដែលត្រូវបានរំលេចក្នុង **«កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា»**; និង ទី២). លើកកម្ពស់កិច្ចអភិវឌ្ឍ តាមរយៈការពង្រឹងទំនាក់ទំនង ឬ អន្តរសកម្មរវាងបណ្តាទិសដៅទាំង ៤ នៃយុទ្ធសាស្ត្រគឺ **កំណើន ការងារ សមធម៌** និង **ប្រសិទ្ធភាព** ដែលជាកញ្ចប់នៃសមីការតែមួយ ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញច្បាស់អំពីការប្តេជ្ញារបស់រាជរដ្ឋាភិបាលក្នុងការលើកស្ទួយសុខុមាលភាពរបស់ប្រជាជន ។

លើមូលដ្ឋាននេះ, **«យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី ៤»** មាន

វចនាសម្ព័ន្ធដូចតទៅ : ១). ស្នូលនៃយុទ្ធសាស្រ្ត គឺការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ច; ២). បរិស្ថានគ្របដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្រ្តទាំងមូល; ៣). ចតុកោណយុទ្ធសាស្រ្តទាំង ៤; និង ៤). មុំយុទ្ធសាស្រ្តនៃចតុកោណនីមួយៗ ។

## ២.២. ស្នូល និង បរិស្ថានគ្របដណ្តប់នៃយុទ្ធសាស្រ្តចតុកោណ-ដំណាក់កាលទី ៤

### ២.២.១. ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ច

គោលដៅជាយុទ្ធសាស្រ្តនៃអភិបាលកិច្ច គឺការធ្វើទំនើបកម្មស្ថាប័នរដ្ឋ និងការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន, សមធម៌ និង យុត្តិធម៌ តាមរយៈការអនុវត្តសិទ្ធិ-អំណាចរដ្ឋខាងផ្នែកនយោបាយ សេដ្ឋកិច្ច និង រដ្ឋបាល ក្នុងការដឹកនាំ គ្រប់គ្រង និងចាត់ចែងកិច្ចការប្រទេសជាតិ ពិសេសការធានានិរន្តរភាពនៃតួនាទី និង ដំណើរការរដ្ឋបាលសាធារណៈ ដោយយកចិត្តទុកដាក់លើអត្ថប្រយោជ ន៍ប្រជាជនជាស្នូល (People-Centric) និង លើការកសាងជាតិ (Nation-state Building) ។

នៅក្នុងការអនុវត្តយុទ្ធសាស្រ្តចតុកោណទាំង ៣ ដំណាក់កាលកន្លងមក, រាជរដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពជាមូលដ្ឋាន នៅក្នុងការធ្វើទំនើបកម្មប្រព័ន្ធអភិបាលកិច្ច តាមរយៈការប្រយុទ្ធប្រឆាំងអំពើពុករលួយ, ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌, ការកែទម្រង់រដ្ឋបាលសា ធារណៈ, ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ, ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ការកែទម្រង់កងកម្លាំងប្រដាប់អាវុធ ។

ទន្ទឹមនេះ, រាជរដ្ឋាភិបាលនៅជួបប្រទះបញ្ហាប្រឈមមួយចំនួនពាក់ព័ន្ធនឹងការត្រួតមុខងារ និង ដែនសមត្ថកិច្ច; ការជ្រើសរើស និង ការលើកទឹកចិត្តមន្រ្តីរាជការ; ប្រព័ន្ធគណនេយ្យភាព រួមមានៈ យន្តការតាមដាន និង វាយតម្លៃការ

ផ្តល់សេវាសាធារណៈ, ការចែករំលែកព័ត៌មាន ទិន្នន័យ និង ក្រមប្រតិបត្តិការងារ; សមត្ថភាពជំនាញ និង វិជ្ជាជីវៈមន្ត្រីរាជការ; គម្លាតរវាងគោលនយោបាយ និង ការអនុវត្ត; ការពង្រឹងការអនុវត្តច្បាប់ ជាពិសេស ការផ្តល់សេវាយុត្តិធម៌; និង ការបង្កើនប្រសិទ្ធភាពនៃការកែទម្រង់កងកម្លាំងប្រដាប់អាវុធ ។

លើមូលដ្ឋាននេះ, ដើម្បីធានាធម្មានុរូបភាព និង ភាពជឿជាក់ពីសាធារណជន តាមរយៈការកសាងប្រព័ន្ធស្ថាប័នរដ្ឋ ឱ្យមានប្រសិទ្ធភាព ផលិតភាព ភាពឆ្លើយតប គណនេយ្យភាព និង តម្លាភាព, រាជរដ្ឋាភិបាលកម្ពុជា ក្នុងនីតិកាលទី ៦ នៃរដ្ឋសភានឹងអនុវត្តនូវ : ១)• ក ារកែទម្រង់ និង លើកកម្ពស់សមត្ថភាពស្ថាប័ន; ២)• ការពង្រឹងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ; ៣)• ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ; និង ៤)• ការពង្រឹងអភិបាលកិច្ចវិស័យឯកជន ។

### ទី១• ការកែទម្រង់ និង លើកកម្ពស់សមត្ថភាពស្ថាប័ន

ក្នុងនីតិកាលទី ៦ នៃរដ្ឋសភា, រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ÷

ទី១- ការធ្វើវិចារណកម្មមុខងារ និង ភារកិច្ច រចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័ន និង ការសម្របសម្រួលអន្តរស្ថាប័ន ដោយផ្តោតជាសំខាន់លើការពង្រឹងភាពជាម្ចាស់, ការទទួលខុសត្រូវ និង បន្ទាត់គណនេយ្យភាពច្បាស់លាស់របស់ក្រសួងស្ថាប័ននីមួយៗ ពិសេសតាមរយៈការអនុវត្តម៉ឺងម៉ាត់នូវច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។

ទី២- ការពង្រឹងភាពជាអ្នកដឹកនាំ, ស្មារតីម្ចាស់ការប្រកបដោយការទទួលខុសត្រូវខ្ពស់ និង សាមគ្គីភាពផ្ទៃក្នុងស្ថាប័ន; ការរៀបចំ និង អនុវត្តហ្មត់ចត់នូវក្រមប្រតិបត្តិសម្រាប់បំពេញការងារ; និង ការសម្រិតសម្រាំងរកមន្ត្រីមានសមត្ថភាពខ្ពស់ និង គុណវុឌ្ឍិល្អប្រសើរ សម្រាប់ការតែងតាំងមុខតំណែងដឹកនាំនៅក្នុង

មុខងារសាធារណៈ ។

ទី៣- ការលើកកម្ពស់គុណាធិបតេយ្យ ក្នុងការជ្រើសរើស ការតែងតាំង ការដំឡើងថ្នាក់ និង ឋានន្តរស័ក្តិ ព្រមទាំងការលើកទឹកចិត្ត និង ការផ្តល់អត្ថប្រយោជន៍ផ្សេងទៀតដល់មន្ត្រីសាធារណៈ និង អង្គភាពសាធារណៈ ជាពិសេស ការរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មក្នុងវិស័យសាធារណៈ ។

ទី៤- ការពង្រឹងសមត្ថភាពគ្រប់គ្រងវិស័យសាធារណៈ តាមរយៈការរៀបចំក្របខណ្ឌច្បាប់ និង លិខិតបទដ្ឋាន, ហេដ្ឋារចនាសម្ព័ន្ធការងារ, ក្របខណ្ឌអភិវឌ្ឍមូលធនមនុស្ស ដែលទាក់ទាញសមត្ថភាពជំនាញ និង ទេពកោសល្យ, និង ការជំរុញការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដើម្បីលើកកម្ពស់ការគ្រប់គ្រងព័ត៌មាន និង ទិន្នន័យមន្ត្រីសាធារណៈ ។

ទី៥- ការបន្តកែទម្រង់កងកម្លាំងប្រដាប់អាវុធ តាមរយៈ ១). ការពង្រឹងការដឹកនាំ ការគ្រប់គ្រង និង ខ្សែរយៈចាត់តាំង; ២). ការអភិវឌ្ឍធនធានមនុស្ស និង បង្កើនសមត្ថភាពកងកម្លាំងប្រដាប់អាវុធ ដោយបង្កើនគុណភាពហ្វឹកហ្វឺន បំពាក់បច្ចេកវិទ្យាសមស្រប និង កសាងជួរកងកម្លាំងបន្តវេន; ៣). ការលើកកម្ពស់សមត្ថភាពក្នុងការរក្សាសន្តិសុខ ការបន្តជំរុញកងទ័ព និង គ្រួសារកងទ័ពឱ្យរស់នៅតាមបណ្តោយព្រំដែន, ការប្រយុទ្ធប្រឆាំងនឹងភេរវកម្ម ដើម្បីធានាបាននូវព្រំដែនសន្តិភាព និង ការអភិវឌ្ឍ, សុវត្ថិភាពជាតិ និង គ្មានការគំរាមពីអំពើភេរវកម្ម; ៤). ការពង្រឹងសមត្ថភាពក្នុងការចូលរួមពង្រីក និង ពង្រឹងទំនាក់ទំនងសហប្រតិបត្តិការអន្តរជាតិ ពិសេសក្នុងការចូលរួមបំពេញបេសកកម្មរក្សាសន្តិភាពនៅក្នុងក្របខណ្ឌអង្គការសហប្រជាជាតិ; និង ៥). ការលើកកម្ពស់ស មត្ថភាពចូលរួមគាំទ្រដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ, ការការពារបរិស្ថាន និង ធនធាន

ធម្មជាតិ, ការឆ្លើយតបអន្តរាគមន៍ក្នុងពេលមានគ្រោះធម្មជាតិ, ការបំពេញប្រតិបត្តិការមនុស្សធម៌ និង ការជួយបង្កបង្កើនផលកសិកម្មដល់ប្រជាជន ។

### ទី២. ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ

ក្នុងនីតិកាលទី ៦ នៃរដ្ឋសភា, រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ÷

ទី១- ការសម្រេចយុទ្ធសាស្ត្រអប់រំ បង្ការ ទប់ស្កាត់ និង បង្ក្រាប ដោយផ្អែកលើផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ នៅក្នុងក្របខណ្ឌ **«មិនហ៊ាន មិនអាច និង មិនចង់»** ប្រព្រឹត្តអំពើពុករលួយ ។

ទី២- ការពង្រឹង និង ពង្រីកការផ្សព្វផ្សាយជាសាធារណៈ (Public Disclosure) នូវព័ត៌មានបច្ចុប្បន្នភាពស្តីពីសេវាសាធារណៈ លិខិតបទដ្ឋានគតិយុត្ត និង ឯកសារគោលនយោបាយជាតិ ។

ទី៣- ការជំរុញឱ្យមានការចូលរួមពីសំណាក់ប្រជាជន ក្នុងដំណើការនៃការអភិវឌ្ឍ, ការរៀបចំគោលនយោបាយ, និង ការអនុវត្ត ។

ទី៤- ការជំរុញការអនុវត្តយន្តការទទួលព័ត៌មានត្រឡប់ និង ដោះស្រាយបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវា រួមបញ្ចូលទាំងការពិនិត្យលទ្ធភាពប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដើម្បីគាំទ្រការអនុវត្ត ។

ទី៥- ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយន្តការអធិការកិច្ច និង សវនកម្មក្នុងវិស័យសាធារណៈ ។

ទី៦- ការពង្រឹងប្រសិទ្ធភាពរៀបចំ និង អនុវត្តក្រមសីលធម៌ការងារ ព្រមទាំងគោលការណ៍វិសមិតភាពមុខងារ និង ទំនាស់ផលប្រយោជន៍ នៅក្នុងការបំពេញការងាររបស់មន្ត្រីសាធារណៈ ។

## ទី៣. ការពង្រឹងប្រសិទ្ធភាពអនុវត្តការងារ

ក្នុងនីតិកាលទី ៦ នៃរដ្ឋសភា, រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ÷

ទី១- ការបន្តដំឡើងបៀវត្សជូនមន្ត្រីរាជការស៊ីវិល និង កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំងបង្កើនប្រាក់សោធនជូននិវត្តជន និង អតីតយុទ្ធជន ដោយរៀបចំបើកផ្តល់តាមប្រព័ន្ធធនាគារ ក្នុងរយៈពេល ២ សប្តាហ៍ម្តង ។

ទី២- ការពេ ្រប្រតិភូកម្មអំណាច ការផ្ទេរមុខងារ ការផ្ទេរធនធាន និង ការ-ចែករំលែកបច្ចេកទេស, តាមរយៈយន្តការវិមជ្ឈការ និង វិសហមជ្ឈការ, ដល់អង្គភាព រដ្ឋបាលគ្រប់កម្រិតក្រោមឱវាទក្រសួង- ស្ថាប័ន គ្រឹះស្ថានសាធារណៈ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីទទួលបានស្វ័យភាពសមស្រប, ទាំងការសម្រេចចិត្ត ការគ្រប់គ្រង និង ការចាត់ចែងធនធានមនុស្ស និង ហិរញ្ញវត្ថុ; ទន្ទឹមនឹងការ-កំណត់ឱ្យបានច្បាស់លាស់នូវគណនេយ្យភាព និង ការទទួលខុសត្រូវរបស់អង្គភាព សាធារណៈ និង មន្ត្រីសាធារណៈ ។

ទី៣- ការជំរុញនវានុវត្ត និង រដ្ឋបាលឯកភាព នៅក្នុងកម្រិតក្រុង ស្រុក-ខណ្ឌ ខេត្ត- រាជធានី ដើម្បីធានាប្រសិទ្ធភាព, ទាំងក្នុងការបំពេញមុខងារ និង ទាំងក្នុងការប្រើប្រាស់ធនធាន ។

ទ ី៤- ការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម ដោយប្រើប្រាស់សូចនាករសមិទ្ធកម្មគន្លឹះ (Key Performance Indicators) ជាពិសេសសម្រាប់មន្ត្រីក្នុងកម្រិតដឹកនាំ និង គ្រប់គ្រងស្ថាប័នសាធារណៈ ។

ទី៥- ការដាក់ឱ្យអនុវត្តយន្តការតាមដាន និង វាយតម្លៃ (M&E) ដើម្បីជំរុញការអនុវត្ត, កែលម្អវិធានការតម្រង់ទិសយុទ្ធសាស្ត្រ និង ពង្រឹងកិច្ចសហ-ប្រតិបត្តិការអន្តរក្រសួង, សម្រាប់ការកសាង រៀបចំ និង អនុវត្តគោលនយោបាយ

របស់រាជរដ្ឋាភិបាល ។

ទី៦- ការពង្រឹងយន្តការចែករំលែក និង ការផ្លាស់ប្តូរព័ត៌មាន ក្នុងរដ្ឋបាលសាធារណៈ នៅគ្រប់កម្រិត នៅទូទាំងប្រទេស ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការ-គ្រប់គ្រង និង ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់សេវាសាធារណៈ នៅក្នុងការវិវត្តដ៏ឆាប់រហ័សនៃបរិការណ៍ជាតិ និង អន្តរជាតិ ។

ទ ី៧- ការលើកកម្ពស់សេវាយុត្តិធមិ ដោយបង្កើនប្រសិទ្ធភាពការងាររបស់មន្ត្រីអនុវត្តច្បាប់, ពង្រឹងជំនឿទុកចិត្តពីសាធារណជនលើវិស័យយុត្តិធមិ, និង ប្រយុទ្ធប្រឆាំងអំពើបំពានដោយអយុត្តិធមិនៅក្នុងសង្គម, តាមរយៈ ១)• ការពង្រឹងការ-អនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ, ២)• ការពង្រឹងភាពស្អាតស្អំ និង ក្រមសីលធមិវិជ្ជាជីវៈរបស់មន្ត្រីក្នុងការអនុវត្តច្បាប់, ៣)• ការពង្រឹងយន្តការវិន័យការងារ និង ការធ្វើទំនើបកម្មរដ្ឋបាលយុត្តិធមិ, ៤)• ការលើកកម្ពស់ការផ្តល់សេវាច្បាប់, និង ៥)• ការពង្រឹង និង កែលម្អយន្តការដោះស្រាយវិវាទ ដែលអាចឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងរបស់សង្គមប្រកបដោយប្រសិទ្ធភាព ។

### ទី៤• ការពង្រឹងអភិបាលកិច្ចវិស័យឯកជន

ក្នុងនីតិកាលទី ៦ នៃរដ្ឋសភា, រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ÷

ទី១- ការសិក្សា និង ការរៀបចំក្របខណ្ឌគោលនយោបាយលើកកម្ពស់អភិបាលកិច្ច ក្នុងវិស័យឯកជន (Corporate Governance) ដែលជាគោលការណ៍រួម ដើម្បីធានាការគ្រប់គ្រង និង ការអនុវត្តល្អក្នុងវិស័យឯកជន ។

ទី២- ការសិក្សា និង រៀបចំក្របខណ្ឌគោលនយោបាយលើកកម្ពស់ការទទួលខុសត្រូវផ្នែកសង្គម និង បរិស្ថាន (Corporate Social and Environmental Responsibility) ដើម្បីជំរុញការចូលរួមដោះស្រាយបញ្ហាសង្គម និង លើកកម្ពស់

ការថែរក្សាបរិស្ថាន តម្លៃសីលធម៌សង្គម និង វប្បធម៌ជាតិ ព្រមទាំងពង្រឹងការ-ការពារសិទ្ធិ និង សុវត្ថិភាពអតិថិជន តាមរយៈការជំរុញរៀបចំ និង អនុម័តច្បាប់ស្តីពីការការពារអតិថិជន (Consumer Protection Law) ។

ទី៣- ការបន្តអនុវត្តយន្តការសន្ទនាក្នុងភាពជាដៃគូរវាងរដ្ឋ និង វិស័យឯកជន ក្នុងកម្រិតគោលនយោបាយ និង បច្ចេកទេស, ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, ដើម្បីជំរុញការពិភាក្សាផ្នែកគោលនយោបាយ និង ស្វែងរកដំណោះ-ស្រាយបញ្ហាប្រឈម ដោយលើកកម្ពស់ការប្រើប្រាស់តួនាទីនៃសភាពាណិជ្ជកម្ម ។

ទី៤- ការជំរុញ និង ការលើកទឹកចិត្តឱ្យវិស័យឯកជនវិនិយោគឡើងវិញ (Reinvest) លើការចូលរួមអភិវឌ្ឍមូលធនមនុស្ស និង នវានុវត្តន៍ ។

### ២.២.២. បរិស្ថានគ្របដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រនាំចមូល

បរិស្ថានគ្របដណ្តប់ល្អប្រសើរ គឺជាមូលដ្ឋា នគ្រឹះសម្រាប់អនុវត្តប្រកបដោយជោគជ័យនូវអាទិភាពគោលនយោបាយតាមផ្នែកនៃ « **ចតុកោណយុទ្ធ-សាស្ត្រ**» ទាំង ៤ ដើម្បីធានាសម្រេចឱ្យបាននូវគោលដៅនៃការអភិវឌ្ឍ ។ ជារួម, កម្ពុជាត្រូវបន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សុវត្ថិភាព និង ពង្រឹងសណ្តាប់ធ្នាប់សាធារណៈ ដើម្បីបង្កលទ្ធភាព និង ផ្តល់កាលានុវត្តក្នុងការបន្តដំណើរអភិវឌ្ឍទៅមុខ ។ ដោយសារកម្ពុជាប្រកាន់អភិក្រមដែលកំណត់តួនាទីនៃវិស័យឯកជនជាចលករនៃកំណើនសេដ្ឋកិច្ច, ដូច្នេះការធានាបរិយាកាសអំណោយផលសម្រាប់ធុរកិច្ច ការវិនិយោគ និង ការអភិវឌ្ឍ មានសារៈសំខាន់ជាខ្លាំង សម្រាប់ទាក់ទាញការវិនិយោគ, ទាំងនៅក្នុង និង ពីក្រៅប្រទេស ក៏ដូចជាសម្រាប់ភាព-លូតលាស់របស់វិស័យឯកជន ។ នៅក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការដើម្បីអភិវឌ្ឍ, កម្ពុជាត្រូវពង្រឹងភាពជាម្ចាស់ ភាពជាដៃគូ និង យន្តការនៃសហប្រតិ-

បត្តិការ ដើម្បីប្រមូលផ្តុំធនធានហិរញ្ញវត្ថុ បច្ចេកទេស និង ចំណេះដឹង មកបម្រើឱ្យការអភិវឌ្ឍ ។ ក្នុងរយៈពេលកន្លងមក, កម្ពុជាទទួលបានជោគជ័យល្អប្រសើរ ក្នុងការអភិវឌ្ឍតាមរយៈការបើកចំហសេដ្ឋកិច្ច ។ អភិក្រមនេះ នៅបន្តដើរតួនាទីជាកត្តាកំណត់នៅក្នុងដំណើរឈានឡើងទៅមុខទៀតរបស់កម្ពុជា ដែលការណ៍នេះទាមទារឱ្យយើងបន្តខិតខំពង្រឹងសមត្ថភាពធ្វើសមាហរណកម្មខ្លួន ចូលក្នុងសេដ្ឋកិច្ចតំបន់ និង ពិភពលោក ។

### ទី១. សន្តិភាព ស្ថិរភាពនយោបាយ និង សណ្តាប់ធ្នាប់សាធារណៈ

ការបន្តការពារសន្តិភាព ស្ថិរភាពនយោបាយ និង ពង្រឹងសណ្តាប់ធ្នាប់សាធារណៈ គឺជាកិច្ចការដ៏មានសារៈសំខាន់ ។ កិច្ចការពារ និង ថែរក្សាសន្តិភាពទាមទារនូវការផ្តោតការយកចិត្តទុកដាក់លើការចាត់វិធានការម៉ឺងម៉ាត់ សំដៅទប់ស្កាត់ការប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់នៅក្នុងគ្រប់រូបភាព ជាពិសេសតាមរយៈបដិវត្តន៍ពណ៌ ។ ការពង្រឹងស្ថិរភាពនយោបាយ តម្រូវឱ្យផ្តោតការយកចិត្តទុកដាក់លើការបន្តធានាប្រក្រតីភាពនៃស្ថាប័នសាធារណៈ, ការពង្រឹងការបំពេញមុខងារនៃស្ថាប័ននយោបាយ, និង ការបន្តអនុវត្តយន្តការប្រជាធិបតេយ្យ នៅក្នុងការជ្រើសរើសអ្នកនយោបាយសម្រាប់ដឹកនាំប្រទេស តាមរយៈការបោះឆ្នោតជាទៀងទាត់ដែលកំណត់ដោយច្បាប់ ។ ការលើកកម្ពស់ស ណ្តាប់ធ្នាប់សាធារណៈទាមទារនូវការយកចិត្តទុកដាក់លើការអនុវត្តច្បាប់ដោយម៉ឺងម៉ាត់ និង ហ្មត់ចត់, ការធានាសុវត្ថិភាពជូនប្រជាជនគ្រប់រូប និង ការប្រយុទ្ធប្រឆាំងនឹងការជួញដូរ និង ប្រើប្រាស់គ្រឿងញៀន ។

ក្នុងនីតិកាលទី ៥ នៃរដ្ឋសភា, រាជរដ្ឋាភិបាលបានសម្រេចជោគជ័យក្នុងការការពារអធិបតេយ្យជាតិ និង បូរណភាពទឹកដី តាមរយៈការសម្រាលស្ថានភាព

តានតឹងនៅតំបន់មួយចំនួននៃព្រំដែន និង ការដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសជិតខាងដោយសន្តិវិធី; ការទប់ ស្កាត់ដោយជោគជ័យនូវចលនាបដិវត្តន៍ពណ៌; ការពង្រឹងស្ថិរភាពនយោបាយ, នីតិរដ្ឋ និង លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស; ការលើកកម្ពស់ការគោរពសិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស; ការសម្រេចបាននូវការបោះឆ្នោតដោយជោគជ័យ, ទាំងសកល និង អសកល, និង ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, ជាបន្តបន្ទាប់ ប្រកបដោយភាពសេរី ត្រឹមត្រូវ និង យុត្តិធម៌; និង ការពង្រឹងការអនុវត្តច្បាប់ ក៏ដូចជាសន្តិសុខ និង សណ្តាប់ធ្នាប់សាធារណៈ តាមរយៈការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវគោលនយោបាយ **«ភូមិ- ឃុំមានសុវត្ថិភាព»** ព្រមទាំងការទប់ស្កាត់ និង បង្ក្រាបដោយជោគជ័យនូវបទល្មើសព្រហ្ម-ទណ្ឌគ្រប់ប្រភេទ រួមបញ្ចូលទាំងការប្រយុទ្ធប្រឆាំងភេរវកម្ម និង ហិរញ្ញប្បទានភេរវកម្ម, ការប្រយុទ្ធប្រឆាំងសកម្មភាពខុសច្បាប់ពាក់ព័ន្ធគ្រឿងញៀន ការជួញដូរមនុស្ស និង ឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ ។

ទន្ទឹមនឹងសមិទ្ធផល និង ជោគជ័យខាងលើ, កម្ពុជានៅបន្តជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ដូចជា : ការបន្តប៉ុនប៉ងរបស់បរទេសក្នុងការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងកម្ពុជា និង ការចិញ្ចឹមចិត្តផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ តាមរយៈបដិវត្តន៍ពណ៌, ការបន្តពង្រឹងបរិយាកាសនីតិរដ្ឋ និង ប្រក្រតីភាពក្នុងការបំពេញមុខងារនៃស្ថាប័នសាធារណៈ, ការបន្តកសាងព្រំដែនសន្តិភាព និង សហប្រតិបត្តិការ, ការបន្តទប់ស្កាត់ និង បង្ក្រាបបទល្មើស ព្រហ្មទណ្ឌគ្រប់ប្រភេទ, ការជួញដូរ និង ប្រើប្រាស់គ្រឿងញៀន, ការជួញដូរមនុស្ស និង អាជីវកម្មផ្លូវភេទ, អន្តោប្រវេសន៍ខុសច្បាប់, គ្រោះថ្នាក់ចរាចរណ៍ និង បទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា ។

រាជរដ្ឋាភិបាលនៃនីតិកាលទី ៦ នៃរដ្ឋសភា នឹងផ្តោតអាទិភាពលើ ÷

ទី១- ការការពារអធិបតេយ្យជាតិ និង បូរណភាពទឹកដី មិនឱ្យបរទេសណាលូកដៃជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងកម្ពុជា ជាដាច់ខាត, ព្រមទាំងការទប់ស្កាត់ និង ប្រឆាំងដាច់ខាត រាល់សកម្មភាពផ្សេងៗដែលពាក់ព័ន្ធនឹងបដិវត្តន៍ពណ៌ ឬ ការញុះញង់ណាមួយ ដើម្បីធ្វើសកម្មភាពខុសច្បាប់ បង្កអស្ថិរភាពនយោបាយ ឬ ចលាចលក្នុងសង្គម ។

ទី២- ការបន្តពង្រឹងនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ វប្បធម៌សន្តិភាព សីលធម៌សង្គម ការគោរពសិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស, និង ការបន្តពង្រឹងបរិយាកាស និង ប្រក្រតីភាពក្នុងការបំពេញមុខងារនៃស្ថាប័នសាធារណៈ ។

ទី៣- ការបន្តដោះស្រាយបញ្ហាព្រំដែនគោក និង ទឹកជាមួយប្រទេសជិតខាង ដោយផ្អែកលើមូលដ្ឋានច្បាប់អន្តរជាតិ រួមជាមួយនឹងការបន្តរៀបចំ និង ជំរុញអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍតំបន់ព្រំដែន ជាព្រំដែនសន្តិភាព មិត្តភាព និង សហប្រតិបត្តិការ ទន្ទឹមនឹងការបន្តប្រកាន់ខ្ជាប់នូវគោលការណ៍មិនអនុញ្ញាតឱ្យប្រើប្រាស់ទឹកដីកម្ពុជា ដើម្បីប្រឆាំងនឹងប្រទេសជិតខាង ។

ទី៤- ការទប់ស្កាត់ និង បង្ក្រាបបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ រួមទាំងការប្រយុទ្ធប្រឆាំងភេរវកម្ម និង ហិរញ្ញប្បទានភេរវកម្ម, ការប្រឆាំងការសម្អាតប្រាក់, ការប្រយុទ្ធប្រឆាំងសកម្មភាពខុសច្បាប់ពាក់ព័ន្ធនឹងការជួញដូរ និង ប្រើប្រាស់គ្រឿងញៀន, ការប្រយុទ្ធប្រឆាំងសកម្មភាពខុសច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និង អាជីវកម្មផ្លូវភេទ, ក៏ដូចជាការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទផ្សេងទៀត ព្រមជាមួយនឹងការបន្តជំរុញអនុវត្ត **«គោលនយោបាយភូមិ- ឃុំមានសុវត្ថិភាព»** ។

ទី៥- ការបន្តពង្រឹងសុវត្ថិភាពចរាចរណ៍ និង សណ្តាប់ធ្នាប់សាធារណៈ

រួមទាំងការលុបបំបាត់ប៉ុស្តិ៍ត្រួតពិនិត្យមិនស្របច្បាប់ និង លុបបំបាត់រថយន្តដឹក-ជញ្ជូនធំៗ ដែលកែច្នៃខុសបច្ចេកទេសនៃបទដ្ឋានក្នុងការដឹកជញ្ជូនដែលនាំឱ្យមានការខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និង ការបង្កគ្រោះថ្នាក់ចរាចរណ៍ញឹក-ញាប់ ។

ទី៦- ការបន្តពង្រឹងការអនុវត្តច្បាប់សញ្ជាតិ និង ច្បាប់អន្តោប្រវេសន៍តាមរយៈការទប់ស្កាត់លំហូរជនអន្តោប្រវេសន៍ នៅតាមព្រំដែនគោក អាកាស-យានដ្ឋាន និង ព្រំដែនទឹក ជាមួយនឹងការស្រាវជ្រាវរកជនអន្តោប្រវេសន៍ខុសច្បាប់ដែលកំពុងរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីបញ្ជូនចេញទៅប្រទេសដើមវិញ ។

ទី៧- ការពង្រឹងការអនុវត្តច្បាប់ និង កសាងសមត្ថភាព ដើម្បីទប់ស្កាត់បទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា ។

### ទី២. បរិយាកាសអំណោយផល សម្រាប់ធុរកិច្ច ការវិនិយោគ និង ការ-អភិវឌ្ឍ

បរិយាកាសអំណោយផលសម្រាប់ធុរកិច្ច ការវិនិយោគ និង ការអភិវឌ្ឍរួមមាន : ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, ភាពងាយស្រួលក្នុងការបង្កើតធុរកិច្ច និង បរិយា-កាសប្រកួតប្រជែងប្រកបដោយយុត្តិធម៌ ។ ក្នុងការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ** ទាំង ៣ ដំណាក់កាល, កម្ពុជាសម្រេចបានការធានានូវបរិយាកាសកំណើនខ្ពស់ និង ស្ថិរភាពល្អប្រសើរផ្នែកម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងបានកែលម្អបរិយាកាសធុរកិច្ច និង រៀបចំបាននូវមូលដ្ឋានចាំបាច់ក្នុងការធានាការប្រកួតប្រជែងដោយស្មើភាព ។ ក្នុងដំណាក់កាលទី ៤ នេះ, រាជរដ្ឋាភិបាលនឹងបន្តកែលម្អបរិយាកាសនេះថែមទៀតដោយផ្តោតលើការធានាការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចដោយប្រុងប្រយ័ត្ន, ការកាត់

បន្ថយចំណាយ និង ពេលវេលា ក្នុងការបង្កើតធុរកិច្ចទៅតាមប្រភេទ និង ទីតាំង និង ការពង្រឹងបរិយាកាសសម្រួលដល់ការធ្វើពាណិជ្ជកម្ម ។

ក្នុងនីតិកាលកន្លងទៅ, រាជរដ្ឋាភិបាលទទួលបានជោគជ័យក្នុងការរក្សាស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ដោយសម្រេចបានកំណើនមធ្យមក្នុងរង្វង់ប្រមាណ ៧% ក្នុងមួយឆ្នាំ ដែលតាមរយៈនេះ កម្ពុជាបានក្លាយខ្លួនជាប្រទេសមានចំណូលមធ្យមកម្រិតទាបកាលពីឆ្នាំ ២០១៦ ។ អត្រាអតិផរណាត្រូវបានរក្សាឱ្យស្ថិតក្នុងកម្រិតទាប និង អាចគ្រប់គ្រងបាន ខណៈដែលអត្រាប្តូរប្រាក់បន្តមានស្ថិរភាពក្នុងរង្វង់ ៤០៥០ រៀល ក្នុងមួយដុល្លារអាមេរិក ។ ទន្ទឹមនេះ, ទុនវិនិយោគដែលត្រូវបានអនុម័តចាប់ពីឆ្នាំ ២០១៣ មកដល់ ២០១៧ មានទំហំសរុប ២៣,៣ ប៊ីលានដុល្លារអាមេរិក ដែលបញ្ជាក់ពីទំនុកចិត្តខ្ពស់របស់វិនិយោគិន មកលើបរិយាកាសវិនិយោគរបស់កម្ពុជា ។

ក្នុងរយៈពេលមធ្យម, បញ្ហាប្រឈម ដូចជា ៖ ការកើនថ្លៃប្រេង, សង្គ្រាមពាណិជ្ជកម្ម, ការបង្កើនអត្រាការប្រាក់ និង កំណើនយឺតនៃសេដ្ឋកិច្ចប្រទេសអភិវឌ្ឍជាដើម អាចនឹងបង្កការប៉ះពាល់ដល់ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។ ជារួម, ប្រតិបត្តិការធុរកិច្ច ដែលត្រូវការពេលវេលាយូរ នីតិវិធីស្មុគស្មាញ ថ្លៃដែល មិនច្បាស់លាស់ និង មិនអាចប៉ាន់ប្រមាណបាន នៅបន្តជាបញ្ហាប្រឈមសម្រាប់បរិស្ថានធុរកិច្ចនៅកម្ពុជានៅឡើយ ។ លើសពីនេះ, កម្ពុជានៅមានលទ្ធភាពច្រើនថែមទៀតក្នុងការសម្រួលដល់ការធ្វើពាណិជ្ជកម្ម, ទាំងក្នុងស្រុក និង អន្តរជាតិ ។

សម្រាប់នីតិកាលទី ៦ នេះ, រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ÷

ទី១- ការបន្តអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដោយប្រុងប្រយ័ត្ន ដោយប្រកាន់យកនូវការផ្សំនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គោលនយោបាយរូបិយវត្ថុ និង ការកែទម្រង់រចនាសម្ព័ន្ធ ដែលមានលក្ខណៈបុរេសកម្ម

តែប្រយ័ត្នប្រយែង, ដើម្បីធានាឱ្យបាននូវស្ថិរភាពកំណើន អតិផរណាទាប ស្ថិរភាពអត្រាប្តូរប្រាក់ និង ជំរុញការវិនិយោគ ។

ទី២- ការរៀបចំនូវយន្តការគ្រប់គ្រងវិបត្តិ និង ហានិភ័យផ្នែកសេដ្ឋកិច្ចដែលអាចកើនឡើងក្នុងវិស័យហិរញ្ញវត្ថុ, ទាំងវិស័យធនាគារ និង វិស័យមិនមែនធនាគារ, ទាំងវិស័យអចលនទ្រព្យ និង ក្នុងវិស័យដទៃផ្សេងទៀត ។

ទី៣- ការជំរុញបញ្ចប់ការធ្វើវិសោធនកម្មច្បាប់ស្តីពីវិនិយោគ និង ការជំរុញការអនុវត្តច្បាប់នេះ រួមទាំងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេសផង ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ទី៤- ការជំរុញរៀបចំការកែទម្រង់ប្រព័ន្ធពន្ធដារគ្រប់ជ្រុងជ្រោយ និង ស៊ីជម្រៅ រួមទាំងការរៀបចំច្បាប់ស្តីពីសារពើពន្ធថ្មីផង ដោយឈរលើគោលការណ៍បង្កើនប្រសិទ្ធភាពប្រមូលចំណូលថវិកាជាតិ, ធានាបាននូវបរិយាកាសប្រកួតប្រជែងដោយតម្លាភាព គណនេយ្យភាព ស្មើភាព និង យុត្តិធម៌, លើកទឹកចិត្តដល់សកម្មភាពសេដ្ឋកិច្ច ធុរកិច្ច និង ការវិនិយោគ, ព្រមទាំងធានាបាននូវសមធិមសង្គម ។

ទី៥- ការរៀបចំ និង ជំរុញអនុវត្តនូវយន្តការសម្រួលដល់ការបង្កើតធុរកិច្ចថ្មី ដោយកាត់បន្ថយពេលវេលានៃការចុះបញ្ជី ការស្នើសុំអាជ្ញាប័ណ្ណ និង នីតិវិធីពាក់ព័ន្ធផ្សេងៗទៀត ព្រមទាំងរៀបចំកែលម្អនូវសេវាសាធារណៈដែលបម្រើធុរជន ឬ ដំណើរការធុរកិច្ច ។

ទី៦- ការបន្តជំរុញកិច្ចសម្រួលពាណិជ្ជកម្ម ដោយបញ្ចប់នូវការរៀបចំប្រព័ន្ធបញ្ជរជាតិតែមួយ (National Single Window), ការកែលម្អយន្តការត្រួតពិនិត្យនៅតាមព្រំដែនឱ្យស្ថិតក្នុងកម្រិតអប្បបរមា, និង ការបន្តកាត់បន្ថយនីតិវិធី ដែលមិនចាំបាច់ និង ជាឧបសគ្គដល់ពាណិជ្ជកម្ម ។

## ទី៣. ការពង្រឹងភាពជាម្ចាស់ ភាពជាដៃគូក្នុងការអភិវឌ្ឍ និង សហប្រតិបត្តិការអន្តរជាតិ

ថ្វីត្បិតតែសមត្ថភាពហិរញ្ញវត្ថុរបស់កម្ពុជាផ្ទាល់សម្រាប់ជំរុញការអភិវឌ្ឍប្រទេសមានការកើនឡើងជាច្រើនក្តី, ក៏ជំនួយផ្នែកបច្ចេកទេស និង ហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ នៅតែមានសារៈសំខាន់ ជាពិសេសចំពោះគម្រោងវិនិ-យោគធំៗ និង មានភាពស្មុគស្មាញ ។ ក្នុងន័យនេះ, កម្ពុជាត្រូវពង្រឹងភាពជាម្ចាស់ក្នុងភាពជាដៃគូសន្ទនាផ្នែកគោលនយោបាយ, ទាំងជាមួយនឹងដៃគូអភិវឌ្ឍផ្លូវការ, វិស័យឯកជន, និង អង្គការមិនមែនរដ្ឋាភិបាល, ក្នុងបេសកកម្មជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមទៅមុខ ប្រកបដោយចីរភាព និង គ្រប់ជ្រុងជ្រោយ ។

ក្នុងនីតិកាលទី ៥ នៃរដ្ឋសភា កន្លងមកនេះ, រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្ត **«យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍ និង ភាពជាដៃគូឆ្នាំ ២០១៤- ២០១៨»** ដោយបានកំណត់គោលការណ៍ និង ឧបករណ៍មួយចំនួនសម្រាប់ជាមូលដ្ឋាន ក្នុងការពង្រីកភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព ព្រមទាំងបានបង្កើន និង ពង្រឹងកិច្ចសហប្រតិបត្តិការ ជាមួយស្ថាប័នអន្តរជាតិនានា និង ជាមួយបណ្តាប្រទេសជាមិត្តចំនួន ១៥៨ ប្រទេស ដែលក្នុងនោះ កម្ពុជាមានស្ថានឯកអគ្គរាជទូត និង មានស្ថានបេសកកម្មអចិន្ត្រៃយ៍ប្រចាំនៅបរទេស សរុបចំនួន ៣៨ ។ ក្នុងកម្រិតអាស៊ាន និង រវាងដៃគូសន្ទនារបស់អាស៊ាន, កម្ពុជាបានធ្វើការងារយ៉ាងសកម្មជាមួយនឹងប្រទេសសមាជិកអាស៊ានទាំងអស់ ដើម្បីសម្រេចបាននូវគោលដៅរបស់អាស៊ានជាសហគមន៍មួយ ដែលផ្អែកលើវិធានច្បាប់ ដោយយកចិត្តទុកដាក់លើប្រជាជន និង យកប្រជាជនជាស្នូល ។ គិតចាប់ពីឆ្នាំ ២០០៨ មក, កម្ពុជាកៀរគរធនធានហិរញ្ញប្បទានសហប្រតិបត្តិការបានជាមធ្យមប្រមាណជាង ១ ប៊ីលានដុល្លារអាមេរិក

ក្នុងមួយឆ្នាំ ។ លើសពីនេះ, រាជរដ្ឋាភិបាលបានសម្រេចដាក់ឱ្យអនុម័ត**«ច្បាប់ស្តីពីសមាគម និង អង្គការមិនមែនរដ្ឋាភិបាល»** ដើម្បីបង្កើតបរិយាកាសភាពជាដៃគូប្រកបដោយសុខដុមនីយកម្ម ។

បញ្ហាប្រឈមក្នុងរយៈពេលមធ្យម រួមមាន : ការធ្លាក់ចុះនៃហិរញ្ញប្បទានឥតសំណងដែលត្រូវជំនួសដោយកម្ចីសម្បទាន, ការពង្រឹងសមត្ថភាពក្នុងការគ្រប់-គ្រង និង ការបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ, ការបន្តពង្រីក និង ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ព្រមទាំងការលើកកម្ពស់សកម្មភាពកម្ពុជាក្នុងអង្គការសហប្រជាជាតិ អាស៊ាន និង អង្គការអន្តរជាតិផ្សេងទៀត ដើម្បីបង្កើតកាលានុវត្តភាពផ្នែកសេដ្ឋកិច្ច និង លើកស្ទួយកិត្យានុភាពជាតិ ។

ក្នុងនីតិកាលទី ៦ នៃរដ្ឋសភា, រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ÷

ទី១- ការបន្តពង្រឹងភាពជាដៃគូប្រកបដោយបរិយាប័ន្ន ជាមួយបណ្តាតួអង្គអភិវឌ្ឍ ដើម្បីកៀរគរធនធានហិរញ្ញប្បទានពីគ្រប់ប្រភព យកមកបម្រើឱ្យកិច្ចប្រឹង-ប្រែងសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ ២០៣០ ដោយឈរលើគោលការណ៍ភាពជាម្ចាស់ និង ភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាល ។

ទី២- ការរៀបចំ និង អនុវត្ត**«យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍ និង ភាពជាដៃគូឆ្នាំ ២០១៩-២០២៣»** ដើម្បីពង្រឹងភាពជាម្ចាស់របស់រាជរដ្ឋាភិបាល, លើកកម្ពស់ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និង ចីរភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធា-រណៈ, អភិវឌ្ឍយន្តការគណនេយ្យភាពសង្គម, ព្រមទាំងពង្រឹងសមត្ថភាពស្ថាប័ន និង ធនធានមនុស្ស ក្នុងបរិការណ៍ដែលកម្ពុជាសម្រេចបាននូវគោលដៅប្រកបដោយមហិច្ឆតា ជាប្រទេសមានចំណូលមធ្យមកម្រិតទាប ហើយកំពុងតែរៀបចំខ្លួនឈានទៅចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច ។

ទី៣- ការបន្តចូលរួមយ៉ាងសកម្មក្នុងកិច្ចការតំបន់ និង ពិភពលោក ដើម្បីបង្កើនកាលានុវត្តភាពសម្រាប់ការអភិវឌ្ឍប្រទេស ពិសេសទាក់ទាញនូវទំនុកចិត្តមកលើសុខសន្តិភាព សុវត្ថិភាព និង បរិស្ថានវិនិយោគរបស់កម្ពុជា ក៏ដូចជា ដើម្បីគោលដៅនៃការលើកកម្ពស់កិត្យានុភាពរបស់កម្ពុជាផងដែរ ។

ទី៤- ការបន្តអនុវត្តនូវការប្តេជ្ញានានា ដែលកម្ពុជាបានឯកភាពនៅក្នុងវេទិកាអន្តរជាតិស្តីពីស័ក្តិសិទ្ធភាពក្នុងកិច្ចអភិវឌ្ឍ ព្រមជាមួយនឹងការបន្តពង្រឹងការអនុវត្តយន្តការពិគ្រោះយោបល់ដែលមានស្រាប់ សម្រាប់ពិភាក្សាលើប្រធានបទនានា ពាក់ព័ន្ធនឹងការអភិវឌ្ឍប្រទេសជាតិ ។

ទី៥- ការបន្តពង្រឹងភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីសមាគម និង អង្គការមិនមែនរដ្ឋាភិបាល ដើម្បីលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាពនៃកិច្ចសហប្រតិបត្តិការនេះ ។

ទី៦- ការបន្តពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និង ការបង្កើតបន្ថែមនូវយន្តការថ្មីៗ ដើម្បីទាក់ទាញការវិនិយោគថែមទៀត, ទាំងពីវិស័យឯកជន និង ពីស្ថាប័នអភិវឌ្ឍផ្លូវការ, ក៏ដូចជាដើម្បីអភិវឌ្ឍវិស័យពាណិជ្ជកម្ម, ជំរុញការធ្វើពិពិធភាវូបនីយកម្មឧស្សាហកម្ម និង កសិកម្ម ដែលផ្តល់តម្លៃបន្ថែមខ្ពស់ ។

### ទី៤. ការពង្រឹងសមត្ថភាពកម្ពុជា ដើម្បីបន្តជំរុញសមាហរណកម្មខ្លួនចូលក្នុងសេដ្ឋកិច្ចតំបន់ និង ពិភពលោក

ការធ្វើសមាហរណកម្មខ្លួន ចូលក្នុងសេដ្ឋកិច្ចតំបន់ និង ពិភពលោក គឺជាយុទ្ធសាស្ត្រដ៏សំខាន់សម្រាប់ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ ក្នុងនីតិកាលទី ៥ នៃរដ្ឋសភាកន្លងមកនេះ, រាជរដ្ឋាភិបាលបានសម្រេចលទ្ធផលធំៗជាច្រើន ដូចជា : ការចូលរួមជាសមាជិកនៃ«**សហគមន៍សេដ្ឋកិច្ចអាស៊ាន**» ដែលជាតំបន់ពាណិជ្ជ-

កម្មសេរីមានប្រជាជនសរុប ៦២២ លាននាក់ និង ជាភាគីហត្ថលេខីមួយនៃកិច្ច-ព្រមព្រៀងពាណិជ្ជកម្មសេរីរវាងអាស៊ាន និង ប្រទេស ឬ តំបន់ដៃគូ; ការបង្កើនការតភ្ជាប់ខាងផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង អរូបវន្ត ជាមួយនឹងប្រទេសក្នុងតំបន់; ការកែលម្អជាលំដាប់នូវក្របខណ្ឌគតិយុត្ត និង ស្ថាប័ន; និង ការធ្វើពិពិធកម្មទីផ្សារ ជាដើម ។ កម្ពុជាបានចូលរួមក្នុងគំនិតផ្តួចផ្តើម**«ខ្សែក្រវាត់មួយ- ផ្លូវមួយ»** ដែលមានសក្តានុពលខ្ពស់ក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម, សហគ្រាសធុនតូច និង មធ្យម, វិស័យទេសចរណ៍, វិស័យហិរញ្ញវត្ថុ និង ធនាគារ និង វិស័យសេវាផ្សេងទៀត ។ ទន្ទឹមនេះ, ទាំងក្នុងក្របខណ្ឌទ្វេភាគី និង ក្របខណ្ឌអាស៊ាន, កម្ពុជាបានពង្រឹងទំនាក់ទំនងធុរកិច្ចយ៉ាងសកម្ម តាមរយៈការចូលរួមក្នុងវេទិកាធុរកិច្ច ការតាំងពិព័រណ៍ និង ការចាប់ដៃគូអាជីវកម្មនានា ។ កិច្ចប្រឹងប្រែងទាំងអស់នេះបានផ្តល់ផលជាកំណើននៃសកម្មភាពសេដ្ឋកិច្ច ពាណិជ្ជកម្ម និង ការវិនិយោគ ដែលបានបង្កើតការងារសម្រាប់ប្រជាជនរាប់ម៉ឺននាក់ ។

ការវិវត្តនៃភូមិសាស្ត្រនយោបាយថ្មីៗនេះ បានធ្វើឱ្យតួនាទីអង្គការពាណិជ្ជ-កម្មពិភពលោកមានភាពមិនច្បាស់លាស់ និង ទន់ខ្សោយ ហើយបង្កើតនូវការមិនសូវយកចិត្តទុកដាក់លើជំហរមជ្ឈភាពរបស់អាស៊ាន ក្នុងការបង្កើតតំបន់ពាណិជ្ជ-កម្មសេរីជាមួយទីផ្សារសំខាន់ៗនៅក្រៅតំបន់ ។ លើសពីនេះ, ការចាកចេញរបស់កម្ពុជាពីឋានៈប្រទេសដែលមានកម្រិតអភិវឌ្ឍតិចតួចនៅក្នុងពេលខាងមុខ ក៏នឹងបណ្តាលឱ្យបាត់បង់នូវភាពអនុគ្រោះ ព្រមទាំងអត្ថប្រយោជន៍នានា នៅក្នុងការ-អនុវត្តកិច្ចព្រមព្រៀង និង កាតព្វកិច្ចផ្សេងៗ ដែលកម្ពុជាកំពុងតែមានក្នុងពេលបច្ចុប្បន្នផងដែរ ។ ទោះជាយ៉ាងនេះក្តី, ក្របខណ្ឌពាណិជ្ជកម្មនៅក្រោមអង្គការពាណិជ្ជកម្មពិភពលោក និង អាស៊ាន នៅតែមានសារៈសំខាន់សម្រាប់កម្ពុជា ។

យ៉ាងណាក៏ដោយ, តទៅមុខ, កម្ពុជាមិនត្រឹមតែត្រូវបន្តខិតខំរក្សាឱ្យបាននូវទីផ្សារនាំចេញដែលខ្លួនមាន ក្នុងពេលបច្ចុប្បន្នប៉ុណ្ណោះទេ, ប៉ុន្តែ ថែមទាំងត្រូវប្រឹងប្រែងបើកច្រកចូលទីផ្សារ សម្រាប់ការនាំចេញឱ្យកាន់តែធំទូលាយថែមទៀត ដោយផ្អែកលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដែលមានលក្ខណៈអចិន្ត្រៃយ៍ (ជា-ជាងពឹងផ្អែកលើការអនុគ្រោះពាណិជ្ជកម្មក្នុងលក្ខណៈទ្វេភាគី ដែលអាចនឹងងាយបាត់បង់ទៅវិញ) ដើម្បីបង្កើនទំហំនៃវិមាត្រសេដ្ឋកិច្ចដែលជាចលករដ៏ចម្បងមួយសម្រាប់ជំរុញលើកកម្ពស់កំណើនប្រកបដោយចីរភាព ។

ក្នុងនីតិកាលទី ៦ នៃរដ្ឋសភា, រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ÷

ទី១- ការបន្តខិតខំបំពេញនូវកាតព្វកិច្ចសេសសល់នានា ក្នុងក្របខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក សហគមន៍សេដ្ឋកិច្ចអាស៊ាន និង ក្របខណ្ឌទ្វេភាគី ជាពិសេសការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង អរូបវន្ត, ព្រមទាំងការកែលម្អក្របខណ្ឌគតិយុត្ត ក៏ដូចជាការកសាងសមត្ថភាពស្ថាប័ន និង មនុស្ស ដើម្បីទាញយកចំណេញឱ្យបានអតិបរមាពីសមាហរណកម្ម និង ពីការលើកកម្ពស់លំហូរពាណិជ្ជកម្ម និង ការវិនិយោគ នៅក្នុងតំបន់ និង ពិភពលោក ។

ទី២- ការជំរុញបង្កើតតំបន់ពាណិជ្ជកម្មសេរីទ្វេភាគីជាមួយដៃគូពាណិជ្ជ-កម្មសំខាន់ៗ និង បង្កើតតំបន់ពាណិជ្ជកម្មសេរីពហុភាគីជាមួយនឹងតំបន់សំខាន់ៗ ដូចជា : អឺរ៉ាស៊ី សហគមន៍អឺរ៉ុប ព្រមទាំងកិច្ចព្រមព្រៀងភាពដៃគូសេដ្ឋកិច្ចគ្រប់-ជ្រុងជ្រោយ (RCEP) និង កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីផ្សេងទៀត ។

ទី៣- ការបន្តពង្រឹងការតភ្ជាប់ផ្នែកធុរកិច្ច ដោយរៀបចំឱ្យមានវេទិកាដំណើរទស្សនកិច្ច ឬ ការតាំងបង្ហាញផលិតផល សំដៅលើកកម្ពស់ការចាប់ដៃគូពាណិជ្ជកម្ម និង ការស្វែងយល់អំពីតម្រូវការទីផ្សារ ព្រមជាមួយនឹងការបន្តជំរុញ

ពិពិធកម្មទីផ្សារនាំចេញ ។

ទី៤- ការបន្តជំរុញការចូលរួមដោយសកម្មរបស់កម្ពុជា ក្នុងកិច្ចសហប្រតិបត្តិការ និង គំនិតផ្តួចផ្តើម ក្នុងផ្នែកសមាហរណកម្មសេដ្ឋកិច្ច នៅកម្រិតអន្តរជាតិ តំបន់ និង ទ្វេភាគី ។

ទី៥- ការជំរុញកិច្ចសហប្រតិបត្តិការ និង ការសម្របសម្រួលរវាងក្រសួង - ស្ថាប័នរបស់រាជរដ្ឋាភិបាល និង គ្រប់តួអង្គអភិវឌ្ឍផ្សេងទៀត ក្នុងគោលដៅពង្រឹងសមត្ថភាព និង ប្រព័ន្ធជាតិ ដើម្បីកែលម្អនូវការផ្តល់សេវា និង ពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជា ។

ទី៦- ការបន្តកសាងសមត្ថភាព សម្រាប់ការតាមដាននិន្នាការពាណិជ្ជកម្មនៅគ្រប់វិស័យ ។

## ២ . ៣ . ចតុកោណយុទ្ធសាស្ត្រទាំងបួន

### ចតុកោណទី ១ . ការអភិវឌ្ឍធនធានមនុស្ស

ការអភិវឌ្ឍធនធានមនុស្ស ត្រូវបានចាត់ទុកជាអាទិភាពនៃការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ** នៅគ្រប់ដំណាក់កាល, ពិសេសបានក្លាយជាអាទិភាពទី ១ នៅក្នុងដំណាក់កាលទី ៣ និង ទី ៤ នេះ, សំដៅលើកកម្ពស់ចំណេះដឹងជំនាញវិជ្ជាជីវៈ សមត្ថភាព សហគ្រិនភាព ការច្នៃប្រឌិត នវានុវត្តន៍ គុណធម៌ សីលធម៌ មនសិការស្នេហាជាតិ និង ស្មារតីទទួលខុសត្រូវ, សុខភាពល្អ និង កាយសម្បទារឹងមាំ, តួនាទីស្ត្រី និង កិច្ចគាំពារសង្គម។ ក្នុងន័យនេះ, ការអភិវឌ្ឍធនធានមនុស្ស ក្នុងនីតិកាលទី ៦ នឹងបន្តផ្តោតលើ : ១). ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា; ២) . ការបណ្តុះបណ្តាលជំនាញបច្ចេកទេស; ៣) . ការលើកកម្ពស់សេវាសុខភាពសាធារណៈ និង អាហារូបត្ថម្ភ; និង ៤) . ការពង្រឹង

សមភាពយេនឌ័រ និង ការគាំពារសង្គម ។

### មុំទី១. ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺអភិវឌ្ឍ«**ប្រព័ន្ធអប់រំប្រកបដោយគុណភាព សមធម៌ និង បរិយាប័ន្ន**» ដោយផ្ដោតសំខាន់លើវិទ្យាសាស្ត្រ និង បច្ចេកវិទ្យា, ការតម្រង់ទិសសម្រាប់ទីផ្សារការងារ និង ការយកចិត្តទុកដាក់លើការអប់រំកាយ សម្រាប់ទ្រទ្រង់ការអភិវឌ្ឍសង្គម- សេដ្ឋកិច្ចជាតិ ។

ជាលទ្ធផល, រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលសំខាន់ៗ ជាអាទិ៍ៈ អត្រាចូលរៀនខ្ពស់នៅកម្រិតបឋមសិក្សា, ការលើកកម្ពស់គុណភាព និង តម្លៃនៃការអប់រំ, ការធ្វើទំនើបកម្មប្រព័ន្ធអប់រំ ដូចជាៈ ការបញ្ចូលមុខវិជ្ជា STEM ក្នុងកម្មវិធីសិក្សា និង សៀវភៅសិក្សាគោល, ការរៀបចំបរិស្ថានសិក្សា និង ការរៀបចំឱ្យមានសាលាជំនាន់ថ្មី, ការពង្រឹងអធិការកិច្ចវិស័យអប់រំ និងការកែទម្រង់ឧត្តម-សិក្សា, ព្រមទាំងការរៀបចំ និង អនុវត្តផែនការគោលសម្រាប់ការអប់រំបច្ចេកទេសនៅវិទ្យាល័យចំណេះទូទៅ និង បច្ចេកទេស ពិសេសលើមុខជំនាញអគ្គិសនី អេឡិច-ត្រូនិក មេកានិក បសុវប្បកម្ម និង កសិក្រសាស្ត្រ ។

ទន្ទឹមនឹងសមិទ្ធផលខាងលើ, កម្ពុជាក៏នៅជួបបញ្ហាប្រឈមមួយចំនួន ជាអាទិ៍ៈ លទ្ធផលនៃការសិក្សានៅគ្រប់កម្រិត នៅមិនទាន់បានល្អតាមការរំពឹងចង់បាន, អត្រាសិស្សបោះបង់ការសិក្សានៅកម្រិតមធ្យមសិក្សានៅតែខ្ពស់, អភិបាលកិច្ចតាមសាលារៀននៅមានកម្រិត, វិសាលភាពគ្របដណ្តប់នៃការអប់រំបច្ចេកទេសនៅមានកម្រិត ហើយការចូលរួមពីវិស័យឯកជនក្នុងវិស័យអប់រំបច្ចេកទេសនៅមិនទាន់ទូលំទូលាយ, ការអប់រំមិនទាន់ឆ្លើយតបពេញលេញទៅនឹងទីផ្សារការងារ និងការរស់នៅ, គុណភាពឧត្តមសិក្សានៅមានគម្លាតខ្ពស់ធៀបទៅនឹងតម្រូវការ និង

ស្តង់ដារតំបន់, ព្រមទាំងប្រសិទ្ធភាពនៃការគ្រប់គ្រង និង អភិបាលកិច្ចលើគ្រឹះស្ថានឧត្តមសិក្សានៅមានកម្រិត ។ លើសពីនេះ, វិស័យកីឡាក៏ត្រូវការនូវការពង្រឹងថែមទៀត, ទាំងការអប់រំកាយ និង ការត្រៀមខ្លួន ឆ្ពោះទៅធ្វើជាម្ចាស់ផ្ទះនៃការប្រកួតកីឡាស៊ីហ្គេមនៅឆ្នាំ ២០២៣ ។

ក្នុងនីតិកាលទី ៦ នៃរដ្ឋសភានេះ, រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ÷

ទី១- ការបន្តដំឡើងបៀវត្ស និង ប្រាក់លើកទឹកចិត្តផ្អែកតាមសមិទ្ធកម្មជូនគ្រូបង្រៀន និង បុគ្គលិកអប់រំ, ការលើកកម្ពស់សមត្ថភាពគ្រប់គ្រងរបស់នាយកសាលាដោយផ្សារភ្ជាប់សមិទ្ធកម្មទៅនឹងថវិកាសាលារៀន, ការបន្តលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន សមត្ថភាពបង្រៀន និង គន្លងអាជីពគ្រូបង្រៀន ដោយបង្កើនការបណ្តុះ-បណ្តាល និង វិក្រឹតការគ្រូបង្រៀនយ៉ាងតិចកម្រិតបរិញ្ញាបត្រ, ការពង្រាយគ្រូបង្រៀនសមត្ថភាពខ្ពស់ ទៅតំបន់ខ្វះគ្រូបង្រៀន និង បង្កើតយន្តការជួយសិស្ស ដែលរៀនខ្សោយ ដោយលើកទឹកចិត្តតាមការជាក់ស្តែង,ការស្រាវជ្រាវ និង ការអភិវឌ្ឍវិធីសាស្ត្របង្រៀន និង រៀនតាមបែបថ្មី, ការបន្តអនុវត្តការកែទម្រង់ការប្រឡង និង ការវាយតម្លៃការសិក្សាឱ្យបានជាទៀងទាត់, ការបង្កើនការវិនិយោគលើសម្ភារសិក្សា ឧបករណ៍ពិសោធន៍ និង បរិក្ខារបង្រៀន ពិសេស ពង្រីកវិសាលភាព សាលាជំនាន់ថ្មី និង លើកកម្ពស់ការចូលរួមពីសហគមន៍ និង មាតាបិតាសិស្ស ។

ទី២- ការបន្តវិនិយោគលើការកសាងសាលាបឋមសិក្សាឱ្យបានដល់ភូមិ និង អនុវិទ្យាល័យឱ្យបានគ្រប់ឃុំតាមការចាំបាច់ផ្អែកលើស្ថានភាពសង្គម- សេដ្ឋកិច្ច, ការបន្តផ្តល់អាហារូបករណ៍ និង មធ្យោបាយទ្រទ្រង់ចាំបាច់ផ្សេងៗទៀត ដល់សិស្សក្រីក្រ សិស្សស្ថិតនៅតំបន់ជួបការលំបាក និង សិស្សមានពិការភាព, ការរៀបចំយុទ្ធនាការផ្សព្វផ្សាយទូទាំងប្រទេស អំពីសារៈប្រយោជន៍នៃការអប់រំកម្រិតមូលដ្ឋាន,

ការបង្កើនការវិនិយោគដើម្បីអភិវឌ្ឍកុមារតូច និង ការបន្តបង្កើតថ្នាក់មត្តេយ្យសិក្សាគ្រប់រូបភាព, ព្រមទាំងជំរុញការរៀបចំឱ្យមានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានតាមដានព័ត៌មានសិស្ស សំដៅផ្តល់កិច្ចអន្តរាគមន៍ឱ្យទាន់ពេលវេលាតាមគ្រប់មធ្យោបាយដើម្បីទប់ស្កាត់នូវការបោះបង់ការសិក្សារបស់សិស្សានុសិស្ស ។

ទី៣- ការពង្រឹងអធិការកិច្ចគ្រប់ជ្រុងជ្រោយលើការគ្រប់គ្រងសាលារៀន សំដៅធានាការបង្រៀនឱ្យបានពេញលេញទៅតាមកម្មវិធីសិក្សា និង បង្កើនគុណ-ភាពអភិបាលកិច្ចសាលារៀន ដោយរៀបចំឱ្យមានយន្តការចូលរួមជាប្រចាំពីអ្នកពាក់ព័ន្ធ និង បង្កើតប្រអប់ទទួលព័ត៌មាន, រៀបចំប្រព័ន្ធពិនិត្យ និង តាមដានដំណើរការសាលារៀន ព្រមទាំងរៀបចំប្រព័ន្ធឆ្លើយតបប្រកបដោយប្រសិទ្ធភាព និង ទាន់ពេលវេលាពីកម្រិតជាតិ ។ ទន្ទឹមនេះ, ការពិនិត្យឡើងវិញ និង ការពង្រឹងតួនាទីនៃយន្តការត្រួតពិនិត្យគុណភាពអប់រំនៅគ្រឹះស្ថានសិក្សាចំណេះទូទៅ ក៏នឹងត្រូវបានយកចិត្តទុកដាក់ផងដែរ ។

ទី៤- ការធ្វើបច្ចុប្បន្នភាព និង ការជំរុញការអនុវត្តផែនការគោលសម្រាប់ការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ សំដៅបង្កើនការតម្រង់ទិសការសិក្សាទៅកាន់អាជីព និង ពង្រីកការអប់រំបច្ចេកទេសឱ្យមានវិសាលភាពគ្របដណ្តប់ទូទាំងប្រទេសតាមទស្សនាទាន **«ខេត្តមួយមានវិទ្យាល័យចំណេះទូទៅ និង បច្ចេកទេសមួយយ៉ាងតិច សម្រាប់រយៈពេលមធ្យម និង ស្រុកមួយមានវិទ្យាល័យចំណេះទូទៅ និង បច្ចេកទេសមួយយ៉ាងតិច សម្រាប់រយៈពេលវែង»** ព្រមទាំងលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជន ជាពិសេសតាមយន្តការភាពជាដៃគូរវាងរដ្ឋ និង ឯកជន (PPP) ។

ទី៥- ការបង្កើនភាពឆ្លើយតបឱ្យកាន់តែពេញលេញនៃការអប់រំ ទៅនឹងទីផ្សារ

ការងារ និង ការរស់នៅ តាមរយៈទស្សនាទាន **«យុវជនម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត»** ដោយរៀបចំកម្មវិធីបង្កើនគំនិតសហគ្រិនភាព និង ភាសាបរទេស, ពង្រឹងការអប់រំផ្នែក STEM ដោយបង្កើតឱ្យមានមជ្ឈមណ្ឌលអប់រំ និង វិទ្យាសាស្ត្រ, បន្តជំរុញកម្មវិធីបំណិនជីវិត ពិសេសកម្មវិធីយុវជនក្នុងភាពជាអ្នក-ដឹកនាំ, សីលធម៌ និង សុជីវធម៌ក្នុងការរស់នៅ, ការចូលរួមការងារសង្គម បរិស្ថាន និង ការអភិវឌ្ឍ ព្រមទាំងបន្តបង្កើតក្រុមប្រឹក្សាកុមារ និង យុវជន ឱ្យបានគ្រប់សាលារៀន ។

ទី៦- ការរៀបចំក្របខណ្ឌកម្មវិធីសិក្សាគោលគ្រប់ជ្រុងជ្រោយ រួមទាំងការបញ្ចូល STEM និង វិទ្យាសាស្ត្រសង្គមគន្លឹះៗ សម្រាប់ឧត្តមសិក្សាស្របទៅនឹងក្របខណ្ឌគុណវុឌ្ឍិជាតិ ស្តង់ដារតំបន់ និង អន្តរជាតិ; ការពង្រឹងយន្តការទទួលស្គាល់គុណភាពឧត្តមសិក្សា; ការបង្កើនចំនួនសាស្ត្រាចារ្យកម្រិតបណ្ឌិតប្រកបដោយគុណភាពនៅឧត្តមសិក្សា; ការបង្កើនការវិនិយោគលើឧត្តមសិក្សា និង ការបង្កើតក្របខណ្ឌគោលនយោបាយជាតិសំដៅអភិវឌ្ឍមូលនិធិអាហារូបករណ៍ និង ឥណទានសម្រាប់និស្សិតនៅឧត្តមសិក្សា; ការជំរុញការអភិវឌ្ឍសមត្ថភាព និង ធនធាន សម្រាប់គាំទ្រការរៀន ការបង្រៀន និង ការសិក្សាស្រាវជ្រាវ; ការបង្កើតមូលនិធិសិក្សាស្រាវជ្រាវ និង យន្តការលើកទឹកចិត្តការប្រកួតប្រជែងស្នាដៃ; ព្រមទាំងការបង្កើតក្របខណ្ឌគោលនយោបាយជាតិស្តីពីអភិបាលកិច្ច និង ការគ្រប់គ្រងឧត្តមសិក្សា ។

ទី៧- ការត្រៀមប្រកួតកីឡាស៊ីហ្គេម (SEA Games) ឆ្នាំ ២០២៣ ដោយបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកីឡាសំខាន់ៗ, រៀបចំប្រភេទកីឡាអាទិភាព, បណ្តុះ-បណ្តាលគ្រូបង្វឹក និង បច្ចេកទេសកីឡាកម្រិតខ្ពស់, ពង្រឹងការបណ្តុះបណ្តាល និង ការហ្វឹកហាត់កីឡាករ- កីឡាការិនីថ្នាល និង ជំរុញចលនា**«យុវជនម្នាក់ចេះកីឡា**

**មួយប្រភេទយ៉ាងតិចប្រចាំជីវិត»** និង រៀបចំវិទ្យាសាស្ត្រសុខាភិបាលកីឡា ដើម្បីគាំទ្រដំណើរការប្រកួតកីឡាស៊ីហ្គេម ។

### មុំទី២. ការបណ្តុះបណ្តាលជំនាញបច្ចេកទេស

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺសំដៅធានាថា «**យុវជនម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត»** ពិសេសដើម្បីជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ឱ្យឈានឡើងមួយកម្រិតទៀត ។ ការបណ្តុះបណ្តាលជំនាញបច្ចេកទេសធ្វើឡើងក្នុងរូបភាពពីរ ដែលមានការផ្សារភ្ជាប់គ្នា គឺធនធានមនុស្សនៅក្នុងប្រព័ន្ធអបរំ និង ធនធានមនុស្សនៅក្រៅប្រព័ន្ធអប់រំ ឬ ក្នុងទីផ្សារការងារ ។

ក្នុងគោលដៅនេះ, រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលសំខាន់ៗ ជាអាទិ៍ : បានអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ ២០១៧-២០២៥; បានអនុវត្តក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ស្តង់ដារជាតិសមត្ថភាព និង កម្មវិធីសិក្សាផ្អែកលើសមត្ថភាព, ក្របខណ្ឌទទួលស្គាល់ឆ្លងពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ទៅគ្រឹះស្ថានឧត្តមសិក្សា; បានបង្កើតមជ្ឈមណ្ឌលគំរូសម្រាប់ការបណ្តុះបណ្តាលបច្ចេកទេសជាច្រើនកន្លែង និងបានរៀបចំទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ ។

ទន្ទឹមនេះ, កម្ពុជាក៏នៅមានបញ្ហាប្រឈមមួយចំនួន ជាអាទិ៍ : ការបណ្តុះ-បណ្តាលជំនាញបច្ចេកទេសកម្រិតមធ្យម និង កម្រិតខ្ពស់នៅមិនទាន់គ្រប់គ្រាន់; ការបង្កើនសមត្ថភាពជំនាញនៃកម្លាំងពលកម្មដើម្បីបង្កើនផលិតភាព នៅមិនទាន់ទូលំទូលាយ; ភាពមិនទាន់ឆ្លើយតបបានពេញលេញ, ទាំងផ្នែកមុខជំនាញ, កម្មវិធីសិក្សា, មនសិការ, វិជ្ជាជីវៈ និង គុណភាពនៃការបណ្តុះបណ្តាលបច្ចេកទេស, ទៅនឹងតម្រូវការទីផ្សារជាក់ស្តែង; និង ភាពនៅមានកម្រិតនៃការចូលរួមពីវិស័យឯកជន

ក្នុងការបណ្ដុះបណ្ដាលជំនាញបច្ចេកទេស និង វិជ្ជាជីវៈ ។

ក្នុងនីតិកាលទី ៦ នៃរដ្ឋសភា, រាជរដ្ឋាភិបាលនឹងផ្ដោតអាទិភាពលើ ÷

ទី១- ការបន្តជំរុញការអនុវត្ត **«គោលនយោបាយជាតិស្ដីពីការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និង វិជ្ជាជីវៈ ឆ្នាំ ២០១៧-២០២៥»**សំដៅលើកកម្ពស់ការបណ្ដុះបណ្ដាលជំនាញបច្ចេកទេស ពិសេសកម្រិតមធ្យម និង កម្រិតខ្ពស់ ដល់យុវជន ដោយគ្របដណ្ដប់មុខវិជ្ជាពហុជំនាញ ដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារពលកម្ម, វិស័យឧស្សាហកម្ម និង ការចាប់ផ្ដើមធុរកិច្ចថ្មី ។

ទី២- ការបង្កើនកិច្ចសហការរវាងសាលារៀន និង សហគ្រាស ក្នុងការ-បណ្ដុះបណ្ដាល សំដៅបង្កើនសមត្ថភាពជំនាញបច្ចេកទេស និង ផលិតភាពរបស់កម្លាំងពលកម្ម ដែលកំពុងបម្រើការងារ និង ការរៀបចំកម្មវិធីគ្រប់គ្រងការផ្លាស់ប្ដូរជំនាញស្របតាមនិន្នាការផ្លាស់ប្ដូរនៃបច្ចេកវិទ្យាថ្មីៗ និង ជំរុញការអនុវត្ត**«មូលនិធិជាតិសម្រាប់ការអភិវឌ្ឍជំនាញ»** ។

ទី៣- ការបន្តរៀបចំមជ្ឈមណ្ឌលបណ្ដុះបណ្ដាលជំនាញ តាមតម្រូវការជាក់ស្ដែងរបស់វិស័យនីមួយៗ ពិសេសគាំទ្រដល់ការអភិវឌ្ឍឧស្សាហកម្ម ដោយមានកិច្ចសហប្រតិបត្តិការរវាងរដ្ឋ វិស័យឯកជន និង អង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងបង្កើនកិច្ចសហការជាក់លាក់រវាងគ្រឹះស្ថានបណ្ដុះបណ្ដាល និង សហគ្រាស ក្នុងការបណ្ដុះបណ្ដាលជំនាញបច្ចេកទេស ដើម្បីពង្រឹងគុណភាព និង បង្កើនភាព-ឆ្លើយតបទៅនឹងសភាពការណ៍វិវឌ្ឍថ្មីៗ ។

ទី៤- ការធ្វើវិចារណកម្ម និង អភិវឌ្ឍគ្រឹះស្ថានបណ្ដុះបណ្ដាលជំនាញបច្ចេកទេស និង វិជ្ជាជីវៈ ក្នុងការផ្គត់ផ្គង់ជំនាញច្រើនប្រភេទ ឆ្លើយតបទៅនឹងតម្រូវការទីផ្សារពលកម្មផង និង ការចាប់ផ្ដើមធុរកិច្ចថ្មីផង ដោយមានកិច្ចសហការ

ជាមួយវិស័យឯកជន ។

ទី៥- ការតម្រង់ទិសវិជ្ជាជីវៈនៅតាមអនុវិទ្យាល័យ និង វិទ្យាល័យក្នុងប្រព័ន្ធអប់រំចំណេះទូទៅ និង ការបន្តបង្កើនការផ្សព្វផ្សាយអំពីសារៈសំខាន់ និង ភា ព-ចាំបាច់អំពីជំនាញបច្ចេកទេស និង វិជ្ជាជីវៈ ក្នុងការកសាងអ នាគតរបស់យុវជន គ្រួសារ និង ប្រទេសជាតិ ។

### មុំទី៣. ការលើកកម្ពស់សេវាសុខភាពសាធារណៈ និង អាហារូបត្ថម្ភ

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺសំដៅលើកកម្ពស់សុខភាពប្រជាជន និង អាហារូបត្ថម្ភ ដើម្បីគាំទ្រដល់ការអភិវឌ្ឍធនធានមនុស្ស កំណើនសេដ្ឋកិច្ច និង វឌ្ឍនភាពសង្គម ប្រកបដោយចីរភាព ។

ជាលទ្ធផលក្នុងកិច្ចការនេះ, រាជរដ្ឋាភិបាលបានសម្រេចគោលដៅអភិវឌ្ឍសហស្សវត្ស ក្នុងការកាត់បន្ថយអត្រាមរណភាពមាតា ទារក និង កុមារ, ការកាត់បន្ថយការឈឺ និង ស្លាប់ ដោយសារជំងឺឆ្លង ដូចជា ជំងឺអេដស៍ គ្រុនចាញ់ និង របេង, និង ការលុបបំបាត់ជំងឺកញ្ជ្រិលទាំងស្រុងនៅឆ្នាំ ២០១៦ ។ ទន្ទឹមនេះ, អាយុកាលសង្ឃឹមរស់ជាមធ្យមរបស់ប្រជាជនបានកើនពី ៥៦,៧ ឆ្នាំ នៅឆ្នាំ ១៩៩៨ ដល់ ៧០,៦ ឆ្នាំ នៅឆ្នាំ ២០១៨ ។ ចំណាយប្រាក់ចេញពីហោប៉ៅរបស់ប្រជាជនលើការ-ថែទាំសុខភាព ពិសេសប្រជាជនក្រីក្រ និង ក្រុមជនងាយរងគ្រោះ ត្រូវបានកាត់បន្ថយដោយសារការពង្រីកការគ្របដណ្តប់នៃប្រព័ន្ធគាំពារសង្គម មានជាអាទិ៍ មូលនិធិសមធម៌សុខាភិបាលសម្រាប់ប្រជាជនក្រីក្រ និង របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព កាន់តែទូលាយដល់ប្រជាជនជាង ៣ លាននាក់ ។ វឌ្ឍនភាពនេះ, បានធ្វើឱ្យគ្រួសារដែលជួបភយន្តរាយនៃចំណាយលើការថែទាំសុខភាពថយចុះពី ៨,៨% នៃចំនួនគ្រួសារសរុប នៅឆ្នាំ ២០០៩ មកត្រឹម ៣,៧% នៅឆ្នាំ ២០១៦

និង គ្រួសារធ្លាក់ខ្លួនក្រ ដោយសារភយន្តរាយនៃចំណាយលើការថែទាំសុខភាពបាន ថយចុះពី ៥,៧% មកត្រឹម ១,៦% ក្នុងអំឡុងពេលដូចគ្នា ។

ទោះបីជាសម្រេចបាននូវសមិទ្ធផលធំៗដូចខាងលើ ក៏កម្ពុជានៅតែជួប បញ្ហាប្រឈមមួយចំនួន ជាអាទិ៍ ៖ សេវាថែទាំសុខភាពបឋមនៅមិនទាន់ឆ្លើយតប បានពេញលេញ និង ទាន់ពេលវេលា, គុណភាពនៃការផ្តល់សេវាថែទាំ និង ព្យា-បាល នៅមានកម្រិត, ចំនួនគ្រូពេទ្យ និង បុគ្គលិកសុខាភិបាលតាមប្រភេទជំនាញ នៅពុំទាន់គ្រប់គ្រាន់តាមនិយាមនៅឡើយ, ប្រព័ន្ធធានារ៉ាប់រងសុខភាពមិនទាន់ គ្របដណ្តប់សម្រាប់ទាំងអស់គ្នា, ការយល់ដឹងពីការប្រើប្រាស់ឱសថ ថ្នាំជក់ គ្រឿង-ស្រវឹង និង ការយល់ដឹងពីអនាម័យ និង សុវត្ថិភាពចំណីអាហារ នៅមានកម្រិត ហើយមរណភាពមាតា ទារក និង កុមារ និង កង្វះអាហារូបត្ថម្ភរបស់ស្ត្រី ទារក និង កុមារ ក្នុងចំណោមគ្រួសារក្រីក្រនៅតំបន់ជនបទនៅតែជាបញ្ហាប្រឈម ។

ក្នុងនីតិកាលទី ៦ នៃរដ្ឋសភានេះ, រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ÷

ទី១- ការបន្តជំរុញការអនុវត្ត និង ធ្វើបច្ចុប្បន្នកម្ម **«ផែនការយុទ្ធសាស្ត្រ សុខាភិបាល ២០១៦-២០២០»** ដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាព និង សមធម៌ នៃសេវាសុខភាព ។

ទី២- ការជំរុញវិសាលភាពគ្របដណ្តប់សុខភាពសកល (Universal Health Coverage) នៅកម្ពុជា ដោយបង្កើនវិសាលភាពគ្របដណ្តប់នៃមូលនិធិសមធម៌ សុខាភិបាល, បន្តអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខ ភាព សម្រាប់មន្ត្រី-សាធារណៈ អតីតមន្ត្រីរាជការ និង អតីតយុទ្ធជន និង របបថែទាំសុខភាព សម្រាប់ កម្មករនិយោជិត ដែលស្ថិតនៅក្រោមច្បាប់ស្តីពីការងារ និង ដោយរៀបចំរបប ថែទាំសុខភាពសម្រាប់បុគ្គលស្វ័យនិយោជន៍ ។

ទី៣- ការលើកកម្ពស់គុណភាព សុវត្ថិភាព និង ប្រសិទ្ធភាព សេវាសុខភាព ជាពិសេសសេវាជាសារវន្ត និង សេវាសង្គ្រោះបន្ទាន់ ដោយបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល និង បច្ចេកវិទ្យាវេជ្ជសាស្ត្រ; ដាក់ឱ្យដំណើរការប្រព័ន្ធទទួលស្គាល់គុណភាពនៅមូលដ្ឋានសុខាភិបាល; ពង្រឹងការងារគ្រប់គ្រងសមត្ថភាពនិយ័តកម្មអធិការកិច្ច, ទាំងនៅមូលដ្ឋានសុខាភិបាលសាធារណៈ និង ឯកជន; រៀបចំ និង ពង្រឹងការអនុវត្តច្បាប់ បទប្បញ្ញត្តិ និង នីតិក្រមសុខាភិបាលពិសេសពាក់ព័ន្ធនឹងការទទួលខុសត្រូវ និង ការផ្លាស់ប្តូរឥរិយាបថរបស់អ្នកផ្តល់សេវាសុខាភិបាលប្រកបដោយសីលធម៌; លើកកម្ពស់សមត្ថភាព និង អភិវឌ្ឍការស្រាវជ្រាវសុខាភិបាល ក្នុងនោះ មានទាំងការសិក្សាស្រាវជ្រាវអំពីជំងឺឆ្លង និង ជំងឺមិនឆ្លង; និង បន្តពង្រឹងប្រព័ន្ធអង្កេត តាមដាន និង ឆ្លើយតបជំងឺ ស្របតាមលក្ខខណ្ឌតម្រូវនៃបទដ្ឋាននិយ័តកម្មសុខភាពអន្តរជាតិ ។

ទី៤- ការរៀបចំ និង អនុវត្តឱ្យមានប្រសិទ្ធភាព នូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍធនធានមនុស្ស ក្នុងវិស័យសុខាភិបាល សំដៅពង្រឹងបន្ថែមនូវសមត្ថភាព និង ជំនាញធនធានមនុស្ស ក្នុងវិស័យសុខាភិបាល ដោយលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល, ទាំងការបណ្តុះបណ្តាលមូលដ្ឋាន ឬ មុនពេលបម្រើការងារ និង ទាំងការបណ្តុះបណ្តាលបន្ត ឬ ក្នុងពេលបម្រើការងារ, រៀបចំ និង ពង្រឹងយន្តការធានា និង ទទួលស្គាល់គុណភាពអប់រំវិស័យសុខាភិបាល, អភិវឌ្ឍប្រព័ន្ធទិន្នន័យគ្រប់គ្រងធនធានមនុស្សសុខាភិបាល និង គ្រប់គ្រងការពង្រាយបុគ្គលិកសុខាភិបាល ដែលមានសមត្ថភាពជំនាញច្បាស់លាស់ប្រកបដោយសមធម៌ និង ពង្រឹងយន្តការលើកទឹកចិត្តដ៏សមរម្យជូនដល់បុគ្គលិកសុខាភិបាល ពិសេសនៅតាមទីជនបទដាច់ស្រយាល ។

ទី៥- ការពង្រឹងការអនុវត្តច្បាប់ និង បទប្បញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រង និង ការត្រួតពិនិត្យគុណ ភាពផលិតផលឱសថ, ការប្រើប្រាស់ឱសថដោយគ្មានវេជ្ជបញ្ជា, ការប្រើសារធាតុគីមីក្នុងចំណីអាហារ និង ការប្រើគ្រឿងស្រវឹង និង ថ្នាំជក់ ។

ទី៦- ការជំរុញអនុវត្តវិធានការទប់ស្កាត់ បង្ការ និង កាត់បន្ថយជំងឺ ដោយបង្កើនកិច្ចសហការជាមួយសហគមន៍ និង គ្រប់ភាគីពាក់ព័ន្ធ ដើម្បីអប់រំ និង ផ្សព្វផ្សាយអំពីអនាម័យ សុវត្ថិភាពចំណីអាហារ ការថែទាំសុខភាព និង ផលប៉ះពាល់ពីការប្រើសារធាតុគីមី, ការប្រើគ្រឿងស្រវឹង និង ថ្នាំជក់, និង ការប្រែប្រួលអាកាសធាតុមកលើសុខភាព ។

ទី៧- ការដាក់ឱ្យអនុវត្តកម្មវិធីឧបត្ថម្ភស្ត្រីមានផ្ទៃពោះ និង កុមារអាយុក្រោម ២ ឆ្នាំ នៃគ្រួសារក្រីក្រ, ការរៀបចំកិច្ចអន្តរាគមន៍ផ្សេងៗ សំដៅលើកកម្ពស់អាហារូបត្ថម្ភ និង រៀបចំឱ្យមានយន្តការពហុវិស័យ ដោយមានការចូលរួមពីសហគមន៍ និង រដ្ឋបាលថ្នា ក់ក្រោមជាតិនៃតំបន់ដែលទទួលរងនូវកង្វះអាហារូបត្ថម្ភកម្រិតខ្ពស់ ។

## មុំទី៤. ការពង្រឹងសមភាពយេនឌ័រ និង ការគាំពារសង្គម

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺការពង្រឹងសមភាពយេនឌ័រ និង ការគាំពារសង្គម ដើម្បីលើកស្ទួយស្ថានភាពសង្គម- សេដ្ឋកិច្ច និង ពង្រឹងតួនាទីស្ត្រី  ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និង សង្គមជាតិ ។

ជាលទ្ធផល, រាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធផលគួរឱ្យកត់សម្គាល់ជាអាទិ៍ : បានបញ្ជ្រាបយេនឌ័រទៅក្នុងក្របខណ្ឌគោលនយោបាយ និង ផែនការអភិវឌ្ឍជាតិ, បានកាត់បន្ថយគម្លាតយេនឌ័រក្នុងវិស័យអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ មុខងារសាធារណៈ, បានពង្រីកសហគ្រិនភាពរបស់ស្ត្រី, បានកាត់បន្ថយអំពើហិង្សា

និង ការរំលោភបំពានផ្លូវភេទលើស្ត្រី និង កុមារ, បានលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និង គ្រួសារខ្មែរ និង បានពង្រឹងកិច្ចការពារផ្លូវច្បាប់ដល់ស្ត្រី និង កុមារ ។ ក្នុងផ្នែកគាំពារសង្គម, រាជរដ្ឋាភិបាលបានដាក់ចេញ និង អនុវត្ត«**ក្របខណ្ឌគោល-នយោបាយជាតិគាំពារសង្គម ២០១៦-២០២៥**» ដែលមានភាពគ្រប់ជ្រុងជ្រោយ ស្របតាមដំណាក់កាល និង កម្រិតនៃការអភិវឌ្ឍប្រទេស ព្រមទាំងបាន និង កំពុងបន្តរៀបចំស្ថាប័នគ្រប់គ្រងឡើងវិញ ។ ជា ក់ស្តែង, រាជរដ្ឋាភិបាលកំពុងអ នុវត្តគម្រោងស្បៀងបម្រុង, កម្មវិធីផ្តល់អាហារតាមសាលារៀន, កម្មវិធីអាហារូបករណ៍ និង កម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់ស្ត្រីមានផ្ទៃពោះ និង កុមារដែលជាផ្នែកនៃប្រព័ន្ធជំនួយសង្គម; និង កំពុងអនុវត្តមូលនិធិសមធម៌សុខាភិបាល, របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និង ហានិភ័យការងារ សម្រាប់កម្មករនិយោជិត នៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ, របបស ន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និង អ តីតយុទ្ធជន និង មូលនិធិជនពិការ ដែលជាផ្នែកនៃប្រព័ន្ធសន្តិសុខសង្គម ។

ទន្ទឹមនឹងសមិទ្ធផលនេះ, កម្ពុជាក៏នៅមានបញ្ហាប្រឈមមួយចំនួន ជាអាទិ៍ : ការរើសអើងលើស្ត្រីនៅតែមាន, បន្ទុកការងារ និង គ្រួសារ នៅតែរារាំងឱកាសស្ត្រីក្នុងការងារអប់រំ សេដ្ឋកិច្ច សង្គម និង នយោបាយ, ការជួញដូរ និង អំពើហិង្សាលើស្ត្រី និង កុមារនៅបន្តកើតមាន ពិសេសចំពោះស្ត្រីចំណាកស្រុក, វិសាលភាពគ្របដណ្តប់នៃកម្មវិធីជាតិជំនួយសង្គម និង របបសន្តិសុខសង្គមនៅមិនទាន់ទូលំ-ទូលាយ និង ពេញលេញ, ដំណើរការគ្រប់គ្រងកម្មវិធី និង របប នៃប្រព័ន្ធគាំពារសង្គមមិនទាន់មានលក្ខណៈប្រមូលផ្តុំ ។

ក្នុងនីតិកាលទី ៦ នៃរដ្ឋសភា, រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ÷

ទី១- ការបន្តលើកកម្ពស់តួនាទីស្ត្រី តាមរយៈការបង្កើនសមាមាត្រ និង ការពង្រឹងសមត្ថភាពស្ត្រីក្នុងជួរថ្នាក់ដឹកនាំ, ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, ក្រសួង- ស្ថាប័ន, ទាំងកម្រិតនយោបាយ និង កម្រិតជំនាញ ។

ទី២- ការធ្វើបច្ចុប្បន្នភាព និង អនុវត្ត **«ផែនការយុទ្ធសាស្ត្រនារីរតនៈ»** ដោយបន្តជំរុញការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ និង ផែនការអភិវឌ្ឍគ្រប់ផ្នែក គ្រប់វិស័យ និង គ្រប់កម្រិត, បន្តលើកកម្ពស់សហគ្រិនភាពរបស់ស្ត្រី តាមរយៈការពង្រីកកម្មវិធីអប់រំ និង បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ស្ត្រី, ព្រមទាំងបន្តលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និង គ្រួសារខ្មែរ តាមរយៈការបង្កើនការវិនិ-យោគលើសមភាពយេនឌ័រ និង ការពង្រឹងភាពជាដៃគូរវាងស្ថាប័នពាក់ព័ន្ធ សំដៅទប់ស្កាត់ការជួញដូរ និង អំពើហិង្សាលើស្ត្រី និង កុមារ ។

ទី៣- ការជំរុញអនុវត្ត **«ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥»** ពិសេសដោយដាក់ឱ្យអនុវត្តនូវរបបហានិភ័យការងារមន្ត្រីសាធា-រណៈ និង របបសោធនសម្រាប់កម្មករនិយោជិតដែលស្ថិតនៅក្រោមបទប្ប ញ្ញត្តិនៃច្បាប់ស្តីពីការងារ, ការកែទម្រង់របបសោធនសម្រាប់មន្ត្រីរាជការ, ការធ្វើសមា-ហរណកម្មប្រតិបត្តិករប្រព័ន្ធសន្តិសុខសង្គម និង ក្របខណ្ឌអភិបាលកិច្ចប្រព័ន្ធគាំពារសង្គម; ទន្ទឹមនឹងការជំរុញការអនុវត្តគោលនយោបាយជាតិប្រជាជន ២០១៦-២០៣០ និង គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០ ។

ទី៤- ការរៀបចំក្របខណ្ឌគតិយុត្ត និង ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ[2] ដើម្បីដាក់ឱ្យដំណើរការកម្មវិធីជាតិជំនួយសង្គមថ្មីៗ និង ពង្រីកកម្មវិធីដែលមានស្រាប់ សំដៅ

[2] *នៅទីនេះ សំដៅប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណ និង អត្រានុកូលដ្ឋាន, ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណប្រជាជនក្រីក្រ និង ជនងាយរងគ្រោះ, និង ប្រព័ន្ធចុះបញ្ជីរបស់ស្ថាប័នប្រតិបត្តិករ ។*

បង្កើនការគាំពារបន្ថែមដល់ជនក្រីក្រ និង ជនងាយរងគ្រោះ និង ដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមថ្មី ព្រមទាំងពង្រីកវិសាលភាពលើរបបដែលមានស្រាប់ សំដៅបង្កើនការគាំពារដល់ប្រជាជនគ្រប់រូប ។

### ចតុកោណទី ២ . ការធ្វើពិពិធកម្មសេដ្ឋកិច្ច

ការធ្វើពិពិធកម្មសេដ្ឋកិច្ច ជាដំណើរការចាំបាច់នៃការបង្កើតចន្ទល់ឱ្យបានច្រើនសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច សំដៅពង្រីកការនាំចេញ ឬ បង្កើតតម្លៃបន្ថែមពីសកម្មភាពសេដ្ឋកិច្ចដែលមានស្រាប់ ដើម្បីអាចរក្សាកំណើនសេដ្ឋកិច្ចនៅក្នុងកម្រិតខ្ពស់ ក្នុងរយៈពេលមធ្យម និង វែងខាងមុខ។ ការធ្វើពិពិធកម្មសេដ្ឋកិច្ចផ្តោតលើអាទិភាពចំនួន ៤ ដែលមានភាពប្រទាក់ក្រឡាគ្នាយ៉ាងជិតស្និទ្ធ និង បំពេញឱ្យគ្នាទៅវិញទៅមក គឺ :១). ការកែលម្អប្រព័ន្ធឡូជីស្ទីក, ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និង ឌីជីថល; ២). ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះ និង ថ្មីៗ; ៣). ការរៀបចំខ្លួន សម្រាប់សេដ្ឋកិច្ចឌីជីថល និង ឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី ៤; និង ៤). ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និង ធនាគារ ។

#### មុំទី១. ការកែលម្អប្រព័ន្ធឡូជីស្ទីក, ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹក-ជញ្ជូន ថាមពល និង ឌីជីថល

រាជរដ្ឋាភិបាលបានប្រឹងប្រែងកែលម្អហេដ្ឋារចនាសម្ព័ន្ធ តាមរយៈការតភ្ជាប់ផ្នែកដឹកជញ្ជូនដោយធ្វើសមាហរណកម្មផ្នែកក្នុងប្រទេស, ការពង្រីកវិសាលភាពនៃការតភ្ជាប់ផ្នែកថាមពល និង ការតភ្ជាប់ផ្នែកឌីជីថល ។ គោលដៅចម្បងនៃការ-តភ្ជាប់ទាំងនេះ គឺឈានទៅរៀបចំនូវប្រព័ន្ធឡូជីស្ទីកដ៏រស់រវើក ដើម្បីការតភ្ជាប់នៅតាមប៉ូលសេដ្ឋកិច្ចសំខាន់ៗ រួមចំណែកលើកកម្ពស់សមត្ថភាពប្រកួតប្រជែង និង

ជំរុញពិពិធកម្មមូលដ្ឋានគាំទ្រកំណើនសេដ្ឋកិច្ច ។

គិតត្រឹមដំណាច់ឆ្នាំ ២០១៧, កម្ពុជាកសាង, ទាំងផ្លូវជាតិ និង ផ្លូវខេត្ត បាន ប្រវែងសរុប ១៦ ២៩២ គីឡូម៉ែត្រ នៅក្នុងនោះបានចាក់កៅស៊ូ និង បេតុង ប្រវែង ៨ ៥២៦ គីឡូម៉ែត្រ ស្មើនឹង ៥២,៣៣% នៃប្រវែងសរុប ។ បន្ថែមលើនេះ, រាជ-រដ្ឋាភិបាលបានធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តដទៃទៀត ដើម្បីទ្រទ្រង់ សកម្មភាពសេដ្ឋកិច្ចជាតិ តាមរយៈការកែលម្អ និង ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវលំជនបទ កំពង់ផែ ផ្លូវដែក ផ្លូវអាកាស និង ហេដ្ឋារចនាសម្ព័ន្ធទីក្រុង នានា ។ ចំពោះផ្នែកឡូជីស្ទីក, កម្ពុជាទទួលបានចំណាត់ថ្នាក់កាន់តែប្រសើរគួរឱ្យ កត់សម្គាល់, ពីលេខរៀងទី ១២៩ ក្នុង ចំណោម ១៥៥ ប្រទេស ក្នុងឆ្នាំ ២០១០, មក ត្រឹមលេខ ៩៨ ក្នុងចំណោម ១៦៧ប្រទេស ក្នុងឆ្នាំ ២០១៨, ក្នុងសន្ទស្សន៍នៃការវាយ តម្លៃឡូជីស្ទីក (LPI) របស់ធនាគារពិភពលោក ។ ចំពោះវិស័យអគ្គិសនី, រាជ-រដ្ឋាភិបាលបានកាត់បន្ថយសមាមាត្រនៃការនាំចូលអគ្គិសនី ពីប្រទេសជិតខាងពី ៦៣,១% នៃថាមពលសរុប នៅឆ្នាំ ២០១១ មកត្រឹម ១៨,៦% នៅឆ្នាំ ២០១៧, បានពង្រីកប្រព័ន្ធខ្សែបញ្ជូន និង បណ្តាញចែកចាយគ្រប់ប្រភេទ ដើម្បីលើកកម្ពស់ ជីវភាពរបស់ប្រជាជន និយាយជារួម, និង និយាយដោយឡែក ក្នុងតំបន់ឧស្សា-ហកម្ម ដើម្បីកាត់បន្ថយថ្លៃអគ្គិសនីជាបន្តបន្ទាប់ សម្រាប់គាំទ្រវិស័យឧស្សាហកម្ម និង ពាណិជ្ជកម្ម ។ ក្នុងផ្នែកឌីជីថល, រាជរដ្ឋាភិបាលបានជំរុញការតភ្ជាប់បណ្តាញ ខ្សែកាប្លិ៍អុបទិកផ្លូវគោក ដែលបានកើនដល់ប្រវែង ៣៧ ៤៤១ គីឡូម៉ែត្រ ក្នុងឆ្នាំ ២០១៧ ព្រមទាំងការតភ្ជាប់បណ្តាញខ្សែកាប្លិ៍អុបទិកក្រោមបាតសមុទ្របានចំនួន ២ ក្នុងឆ្នាំ ២០១៧ ។ លើសពីនេះ, ការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន មានកំណើនគួរឱ្យកត់សម្គាល់ ដោយចំនួនលេខទូរស័ព្ទចល័តភ្ជាប់សេវាអ៊ីនធឺណិត

បានកើនឡើងពី ២,៧ លានលេខ ក្នុងឆ្នាំ ២០១២ ដល់ប្រមាណ ១០ លានលេខ ក្នុងឆ្នាំ ២០១៧ ។

ទោះជាយ៉ាងនេះក្តី, កម្ពុជានៅមានបញ្ហាប្រឈមសំខាន់ៗមួយចំនួនក្នុងវិស័យខាងលើ ដែលរួមមាន : ថ្លៃឡូជីស្ទិកនៅតែខ្ពស់, ការសម្របសម្រួលស្ថាប័នក្នុងការអភិវឌ្ឍ និង ការថែទាំហេដ្ឋារចនាសម្ព័ន្ធ នៅមានភាពទន់ខ្សោយ, ហេដ្ឋារចនាសម្ព័ន្ធនៅតែមិនទាន់គ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍក្នុងដំណាក់កាលថ្មី និង ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ពុំទាន់បានគិតគូរគ្រប់ជ្រុងជ្រោយ និង ដល់ទីតាំងសហគ្រាស ឬ រោងចក្រ ឱ្យស្របតាមប្លង់គោលរៀបចំដែនដីនគរូបនីយកម្ម និង ប្លង់ប្រើប្រាស់ដីធ្លី ។ ផ្នែកថាមពលនៅប្រឈមនឹងថ្លៃអគ្គិសនីខ្ពស់, បញ្ហាស្ថិរភាពនៃការផ្គត់ផ្គង់អគ្គិសនី និង ប្រភពថាមពលកកើតឡើងវិញនៅមិនទាន់បញ្ចូលក្នុងល្បាយថាមពល ឱ្យអស់សក្តានុពលសេដ្ឋកិច្ចនៅឡើយ ។ ផ្នែកឌីជីថលនៅបន្តជួបបញ្ហាមួយចំនួន ដែលពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃការវិនិយោគ និង ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចជាការពង្រីកវិសាលភាព និង ប្រសិទ្ធភាពនៃហេដ្ឋារចនាសម្ព័ន្ធខ្សែកាប្លិ៍អុបទិកផ្ទឹងខ្មង និងខ្សែកាប្លិ៍អុបទិកក្រោមបាតសមុទ្រ ។

លើមូលដ្ឋាននេះ, រាជរដ្ឋាភិបាល ក្នុងនីតិកាលទី ៦ នឹងផ្តោតអាទិភាពលើ ÷

ទី១- អនុម័ត និង ការអនុវត្តផែនការមេ សម្រាប់វិស័យដឹកជញ្ជូនពហុមធ្យោបាយ និង ឡូជីស្ទិក ដើម្បីបង្កើនល្បឿនសមាហរណកម្ម, ការតភ្ជាប់ប៉ូលសេដ្ឋកិច្ចសំខាន់ៗ និង អភិវឌ្ឍរបៀងសេដ្ឋកិច្ចគន្លឹះ ឱ្យកាន់តែមានលក្ខណៈប្រកួតប្រជែងខ្ពស់ នៅក្នុងតំបន់ និង ពិភពលោក ។

ទី២- ការបន្តបង្កើនថវិកាវិនិយោគ និង កៀរគរហិរញ្ញប្បទាន ដើម្បីស្ថារ កសាង និង អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, ទាំងផ្លូវគោក ស្ពាន ផ្លូវដែក ផ្លូវទឹក និង ផ្លូវអាកាស ព្រមទាំងផ្លូវល្បឿនលឿន, សំដៅឆ្លើយតបឱ្យបាន, ទាំងបរិមាណ គុណភាព សុវត្ថិភាព និង ភាពធន់មាំ ទៅនឹងតម្រូវការនៃការអភិវឌ្ឍប្រទេស ដែល កិច្ចការនេះ ត្រូវដើរទន្ទឹមគ្នាជាមួយនឹងការពង្រឹងការសម្របសម្រួលយន្តការស្ថាប័ន ឱ្យកាន់តែប្រសើរឡើង ។

ទី៣- ការបន្តបញ្ចុះថ្លៃអគ្គិសនី, ពង្រីកបណ្តាញគ្របដណ្តប់ និង បង្កើន ស្ថិរភាពអគ្គិសនីដោយសាងសង់អនុស្ថានីយ៍បន្ថែម ឱ្យដល់តំបន់ប៉ូលសេដ្ឋកិច្ច និង តំបន់សក្តានុពលសេដ្ឋកិច្ចខ្ពស់ ។

ទី៤- ការបន្តអភិវឌ្ឍការតភ្ជាប់ផ្នែកឌីជីថល តាមរយៈការពង្រឹង និង ពង្រីក ហេដ្ឋារចនាសម្ព័ន្ធខ្សែកាប្លិ៍អុបទិកជាបណ្តាញចែកចាយ, ហេដ្ឋារចនាសម្ព័ន្ធខ្សែកាប្លិ៍ អុបទិកឆ្អឹងខ្នង និង ខ្សែកាប្លិ៍អុបទិកក្រោមបាតសមុទ្រ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធ ទូរស័ព្ទចល័ត ប្រកបដោយគុណភាព មានលក្ខណៈទំនើបទាន់សម័យ មានថ្លៃប្រកួត-ប្រជែង និង មានសេវាគ្របដណ្តប់ទូទាំងប្រទេស ។

ទី៥- ការពង្រឹងសមត្ថភាពស្ថាប័ន ក្នុងការធ្វើផែនការ ការរៀបចំថវិកា ការអនុវត្ត និង ការត្រួតពិនិត្យ វាយតម្លៃគម្រោង ។

### មុំទី ២. ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះ និង ថ្មីៗ

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺធានានូវកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាព ដែលមានលក្ខណៈបរិយាប័ន្ន, លើមូលដ្ឋានទូលំទូលាយ, រឹងមាំ ធន់នឹងវិបត្តិ និង មានភាពប្រកួតប្រជែង ។

ជាលទ្ធផល, កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរង្វង់ ៧% ក្នុង

រយៈពេល ២ ទសវត្សរ៍ចុងក្រោយនេះ, ក៏ប៉ុន្តែ, មូលដ្ឋានទ្រទ្រង់កំណើននៅមិនទាន់ទូលាយ ។ ចន្ទល់ទ្រទ្រង់កំណើនសេដ្ឋកិច្ចបច្ចុប្បន្ន ដែលរួមមាន : កសិកម្ម ទេសចរណ៍ វាយនភ័ណ្ឌ និង សំណង់ មិនអាចធានាបាននូវកំណើនខ្ពស់ក្នុងរយៈពេលវែង ដោយសារការប្រែប្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ចក្នុងស្រុក រចនាសម្ព័ន្ធប្រជាសាស្ត្រ ការប្រកួតប្រជែងខ្ពស់ និង ការងាយទទួលហានិភ័យពីខាងក្រៅ ។ ក្នុងន័យនេះ, ចាំបាច់ត្រូវគិតគូរលើការបង្កើតប្រភពកំណើនថ្មី តាមរយៈការជំរុញការអភិវឌ្ឍវិស័យសេដ្ឋកិច្ចថ្មីៗ, ការបង្កើត និង បង្កើនតម្លៃបន្ថែម ក្នុងចន្ទល់កំណើនដែលមានស្រាប់ ។

លើមូលដ្ឋាននេះ, រាជរដ្ឋាភិបាល ក្នុងនីតិកាលទី ៦ ផ្តោតអាទិភាពលើ ÷

ទី១- ការបន្តជំរុញការអនុវត្ត **«គោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥»** ពិសេសជំរុញការអភិវឌ្ឍខេត្តព្រះសីហនុឱ្យក្លាយទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ទន្ទឹមនឹងការវាយតម្លៃពាក់កណ្តាលអាណត្តិ ។

ទី២- ការរៀបចំ និង អនុវត្តយុទ្ធសាស្ត្រការអភិវឌ្ឍវិស័យកាត់ដេរ និងផលិតស្បែកជើង ដើម្បីបង្កើនភាពប្រកួតប្រជែង, បង្កើតតម្លៃបន្ថែម, បង្កើតឧស្សាហកម្មគាំទ្រ និង អភិវឌ្ឍខ្សែច្រវាក់តម្លៃ ។

ទី៣- ការបន្តជំរុញកិច្ចដំណើរការ និង ទាក់ទាញការវិនិយោគនៅតាមតំបន់សេដ្ឋកិច្ចពិសេស ដើម្បីកសាងមូលដ្ឋានឧស្សាហកម្ម រួមទាំងការកែច្នៃកសិផល, ការផ្គុំ និង ដំឡើង, ការផលិតគ្រឿងសង្ហារឹម សម្ភារប្រើប្រាស់ក្នុងលំនៅឋាន, ការផលិតវត្ថុអនុស្សាវរីយ៍បម្រើឱ្យវិស័យទេសចរណ៍ ជាដើម ។

ទី៤- ការរៀបចំផែនការមេអភិវឌ្ឍវិស័យទេសចរណ៍ ដោយផ្តោតលើការធ្វើពិពិធកម្មផលិតផល និង គោលដៅទេសចរណ៍, ការទាក់ទាញភ្ញៀវចំណាយខ្ពស់

និង ការលើកទឹកចិត្តឧស្សាហកម្មគាំទ្រវិស័យទេសចរណ៍ ។

ទី៥- ការជំរុញការអភិវឌ្ឍវិស័យសេវាផ្នែកកំសាន្ត អក្សរសិល្ប៍ សិល្បៈ គំនូរជីវចល និង ភាពយន្ត ដែលជាឧស្សាហកម្មច្នៃប្រឌិតមានសក្តានុពលខ្ពស់ក្នុងការបង្កើតតម្លៃបន្ថែម និង បង្កើតការងារ ព្រមទាំងការលើកកម្ពស់ការផលិត និង ការប្រើប្រាស់ផលិតផលក្នុងស្រុក ពិសេសផលិតផលមានលក្ខណៈប្រពៃណីខ្មែរ និង ផលិតផលសម្គាល់ភូមិសាស្ត្រ ។

ទី៦- ការជំរុញការអភិវឌ្ឍវិស័យប្រេងកាត និង ឧស្ម័ន ជាពិសេសការដាក់ដំណើរការអណ្តូងប្រេងដំបូងឱ្យបានឆាប់ ទន្ទឹមគ្នានឹងការពង្រឹងការគ្រប់គ្រងចំណូលដែលបានមកពីធនធានទាំងនេះ ប្រកបដោយប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាព ។

### មុំទី៣. ការរៀបចំខ្លួន សម្រាប់សេដ្ឋកិច្ចឌីជីថល និង ឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី ៤

បដិវត្តន៍ឧស្សាហកម្មសកល បានធ្វើឱ្យមានការផ្លាស់ប្តូរយ៉ា ងខ្លាំង នូវស្ថានភាពសង្គម- សេដ្ឋកិច្ចសកល ដោយសារនវានុវត្តន៍បច្ចេកវិទ្យា ហើយកំពុងស្ថិតក្នុងដំណាក់កាលផ្លាស់ប្តូរថ្មីមួយទៀត គឺបដិវត្តន៍ឧស្សាហកម្មទី ៤ ។ ករណីនេះតម្រូវឱ្យរាជរដ្ឋាភិបាលយកចិត្តទុកដាក់លើការរៀបចំខ្លួនចាប់យកកាលានុវត្តភាព និង ការត្រៀមខ្លួនឆ្លើយតបនឹងបញ្ហាប្រឈម ដែលកើតចេញពីវិស័យសេដ្ឋកិច្ចថ្មីៗ, ការអភិវឌ្ឍសហគ្រាសធុនតូច និង មធ្យម, ការលើកកម្ពស់ផលិតភាព និង ប្រសិទ្ធភាពវិស័យកសិកម្ម,ការធ្វើឱ្យប្រសើរនូវប្រព័ន្ធសុខាភិបាល, ការបង្កើនសមត្ថភាពរៀបចំខ្លួនសម្រាប់ទប់ទល់នឹងគ្រោះមហន្តរាយ ព្រមទាំងការរៀបចំ នគរូបនីយកម្មប្រកបដោយប្រសិទ្ធភាព និង ការគ្រប់គ្រងបរិស្ថាន ជាដើម ។ លើសពីនេះ,

រាជរដ្ឋាភិបាលត្រូវគ្រប់គ្រងផលវិបាកបណ្តាលមកពីបដិវត្តន៍ឧស្សាហកម្ម ដូចជា : ការប្រែប្រួលនូវរបៀបរបបនៃការធ្វើធុរកិច្ច និង ការបាត់បង់ការងារ, អស្ថិរភាពនយោបាយ និង សង្គម, និង ការវាយប្រហារផ្នែកបច្ចេកវិទ្យាព័ត៌មាន ។

លើមូលដ្ឋាននេះ, រាជរដ្ឋាភិបាល ក្នុងនីតិកាលទី ៦ នឹងផ្តោតអាទិភាពលើ ÷

ទី១- ការរៀបចំ និង អនុវត្តក្របខណ្ឌយុទ្ធសាស្ត្រសេដ្ឋកិច្ចឌីជីថលរយៈ-ពេលវែង និង ដាក់វិស័យឌីជីថល ជាអនុវិស័យនៅក្នុងប្រព័ន្ធគណនីជាតិ ។

ទី២- ការបន្តធ្វើបច្ចុប្បន្នភាព និង អនុវត្តគោលនយោបាយអភិវឌ្ឍវិស័យទូរគមនាគមន៍ និង បច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន, ផែនការមេបច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន ព្រមទាំងច្បាប់ស្តីពីទូរគមនាគមន៍ និង បទប្បញ្ញត្តិពាក់-ព័ន្ធនានា, ការរៀបចំ និង អនុវត្តក្របខណ្ឌយុទ្ធសាស្ត្ររយៈពេលវែង សម្រាប់វិស័យបច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន ។

ទី៣- ការបន្តពង្រឹង និង ពង្រីកការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រចាំបាច់រួមមាន៖ ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន, ហេដ្ឋារចនា-សម្ព័ន្ធប្រៃសណីយ៍ និង ដឹកជញ្ជូនបញ្ញើរហ័សក្នុងស្រុក ព្រមទាំងឡូជីស្ទិក និង ហេដ្ឋារចនាសម្ព័ន្ធទូទាត់ការសងប្រាក់អេឡិកត្រូនិក ព្រមទាំងពិនិត្យលទ្ធភាពកសាងហេដ្ឋារចនាសម្ព័ន្ធច្រកចេញ- ចូលប្រព័ន្ធអ៊ីនធឺណិតថ្នាក់ជាតិ (National Internet Gateway) ។

ទី៤- ការជំរុញ និង ការបង្កើតមូលដ្ឋានគតិយុត្តគាំទ្រដល់ការអភិវឌ្ឍវិស័យឌីជីថល ដោយរួមទាំងការជំរុញការអនុវត្តយុទ្ធសាស្ត្ររដ្ឋាភិបាលឌីជីថល និង សន្តិ-សុខព័ត៌មាន, ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ច្បាប់ស្តីពីបទល្មើស

បច្ចេកវិទ្យាព័ត៌មាន ព្រមទាំងវិសោធនកម្មច្បាប់ និង បទប្បញ្ញត្តិពាក់ព័ន្ធ ដែលគាំទ្រ និង ជំរុញការរីកចម្រើន និង ការការពារហានិភ័យក្នុងវិស័យនេះ ។

ទី៥- ការអភិវឌ្ឍជំនាញ និង ការអប់រំ ការបណ្តុះបណ្តាល ដោយផ្តោតលើការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលឱ្យបានទូលាយ និង បញ្ចូលការប្រើប្រាស់ និង ការយល់ដឹងពីបច្ចេកវិទ្យាឌីជីថលទៅក្នុងកម្មវិធីសិក្សា ស្របតាមតម្រូវការទីផ្សារការងារ រួមទាំងការបង្កើតយន្តការភាពជាដៃគូរវាងធុរកិច្ច និង គ្រឹលស្ថានអប់រំ និង គ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបង្កើតកម្មវិធីអភិវឌ្ឍ និង បណ្តុះបណ្តាលជំនាញឌីជីថលថ្មីៗ ។

ទី៦- ការអភិវឌ្ឍសហគ្រិនភាព និង ប្រព័ន្ធអេកូឡូស៊ីឌីជីថល ដែលជាបរិស្ថានអំណោយផលដល់ការបង្កើតធុរកិច្ចថ្មីៗ, ការជំរុញការប្រើប្រាស់ប្រព័ន្ធឌីជី-ថលក្នុងធុរកិច្ច និង ការបង្កើតយន្តការសហប្រតិបត្តិការសហគ្រិនភាព ក្នុងក្របខណ្ឌរាជរដ្ឋាភិបាល ឬ ភាពជាដៃគូជាមួយវិស័យឯកជន ។

### មុំទី ៤. ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និង ធនាគារ

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺបន្តអភិវឌ្ឍវិស័យហិរញ្ញវត្ថុឱ្យកាន់តែមានពិពិធភាព, រឹងមាំធន់នឹងវិបត្តិ និង ប្រកបដោយបរិយាប័ន្ន ដោយផ្អែកលើគោលការណ៍ទីផ្សារ ស្របតាមសមាហរណកម្មសេដ្ឋកិច្ច និង ហិរញ្ញវត្ថុក្នុងតំបន់ សំដៅរួមចំណែកទ្រទ្រង់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និង លើកកម្ពស់ជីវភាពប្រជាជន ។

កន្លងមក, រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលគួរឱ្យកត់សម្គាល់ មានជាអាទិ៍ : ការអភិវឌ្ឍគោលនយោបាយ និង ក្របខណ្ឌគតិយុត្ត ពិសេសការពង្រឹងយន្តការគ្រប់គ្រង និង ត្រួតពិនិត្យវិស័យហិរញ្ញវត្ថុ និង ធនាគារ, ការពង្រឹង និង

អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ, ការផ្តល់លក្ខខណ្ឌកាន់តែអនុគ្រោះ សម្រាប់ប្រជាជន តាមរយៈការដាក់ពិដានអត្រាការប្រាក់ ១៨% លើកម្ចីពីគ្រឹះស្ថានមីក្រូ-ហិរញ្ញវត្ថុ, ការបន្តអភិវឌ្ឍវិស័យធានារ៉ាប់រង និង ការបន្តអភិវឌ្ឍទីផ្សារមូលបត្រ ដែលរួមមាន : ការបង្កើតទីផ្សារគោល និង ទីផ្សារកំណើន, ការបង្កើតទីផ្សារឧបករណ៍និស្សន្ទ, និង ការបង្កើតកម្មវិធីឧត្តមភាព សម្រាប់ជួយសម្រួលដំណើរការចុះបញ្ជីរបស់សហគ្រាសខ្នាតតូច និង មធ្យម ។

យ៉ាងណាមិញ, វិស័យនេះ នៅបន្តជួបបញ្ហាប្រឈមមួយចំនួន រួមមាន : ឧបករណ៍ហិរញ្ញវត្ថុនៅមិនទាន់ត្រូវបានធ្វើពិពិធកម្មឱ្យអស់លទ្ធភាព, យន្តការបង្ការ និង ដោះស្រាយវិបត្តិ រួមទាំងយន្តការផ្តល់សញ្ញាជាមុន នៅពុំទាន់ត្រូវបានរៀបចំរួចរាល់, ការសម្របសម្រួលគោលនយោបាយ នៅមិនទាន់មានភាពល្អប្រសើរគ្រប់គ្រាន់, ចំណេះដឹងផ្នែកហិរញ្ញវត្ថុរបស់ប្រជាជន នៅមានកម្រិត ខណៈដែលប្រព័ន្ធហិរញ្ញវត្ថុមានការរីកចម្រើនឆាប់រហ័ស, ការសន្សំក្នុងស្រុកនៅមានកម្រិតទាប, អត្រាការប្រាក់នៅមានកម្រិតខ្ពស់នៅឡើយ, កម្រិតខ្ពស់នៃដុល្លារូបនីយកម្ម ដែលបន្តដាក់កំហិតលើប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ និង ការអភិវឌ្ឍវិស័យធានារ៉ាប់រងនៅមានកម្រិត ។

លើមូលដ្ឋាននេះ, រាជរដ្ឋាភិបាលនីតិកាលទី ៦ នឹងផ្តោតទៅលើ ÷

ទី១- ការបន្តអនុវត្ត «**យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥**» និង ការបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធច្រកចេញ- ចូលនៃប្រព័ន្ធទូទាត់, ការជំរុញការអភិវឌ្ឍប្រព័ន្ធទូទាត់ដោយប្រើបច្ចេកវិទ្យាហិរញ្ញវត្ថុ, ការសម្របសម្រួលក្របខណ្ឌគោលនយោបាយ និង ក្របខណ្ឌគតិយុត្ត, ការពង្រឹងសមត្ថភាពស្ថាប័ន និង ធនធានមនុស្ស ដែលពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុ និង ធនាគារ ឱ្យស្របតាម

ការរីកចម្រើននៃសេដ្ឋកិច្ចកម្ពុជា ក៏ដូចជាឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃសមា-ហរណកម្មប្រព័ន្ធហិរញ្ញវត្ថុកម្ពុជា ទៅក្នុងតំបន់ និង អន្តរជាតិ ។

ទី២- ការបន្តធានាស្ថិរភាពហិរញ្ញវត្ថុ ពិសេសតាមរយៈការពង្រឹងយន្តការគ្រប់គ្រង និង ត្រួតពិនិត្យវិស័យហិរញ្ញវត្ថុ និង ធនាគារ តាមវិធីសាស្ត្រផ្អែកលើហានិភ័យ និង ទស្សនអនាគត, ការពន្លឿនដំណើរការបង្កើតគណៈកម្មាធិការស្ថិរភាពហិរញ្ញវត្ថុ ក៏ដូចជាការអភិវឌ្ឍយន្តការបង្ការ និង ដោះស្រាយវិបត្តិ រួមមានៈ យន្តការផ្តល់សញ្ញាជាមុន, ជម្រើសហិរញ្ញប្បទាន និង ច្បាប់ស្តីពីកិច្ចការពារប្រាក់បញ្ញើ ។

ទី៣- ការបន្តពង្រីកតួនាទីវិស័យធនាគារ ដើម្បីកៀរគរធនធានហិរញ្ញវត្ថុនៅក្នុងស្រុក, ការសិក្សា និង រៀបចំគោលនយោបាយ និង យន្តការដើម្បីពង្រីកវិសាលភាពសេវាហិរញ្ញវត្ថុ ព្រមទាំងការពង្រីកគោលការណ៍គាំពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ ដើម្បីលើកកម្ពស់ជីវភាពប្រជាជន និង ជំរុញការអភិវឌ្ឍសេដ្ឋកិច្ច ។

ទី៤- ការបន្តអភិវឌ្ឍទីផ្សារមូលបត្រ ដោយជំរុញ និង លើកទឹកចិត្តដល់សហគ្រាស និង ក្រុមហ៊ុន ឱ្យបោះផ្សាយមូលបត្រជាសាធារណៈ, ការលើកកម្ពស់យន្តការជួញដូរដោយបង្កើតឱ្យមានវិនិយោគិនស្ថាប័ន, ការបង្កើតប្រតិបត្តិករទីផ្សារមូលបត្រអនាគត ព្រមទាំងការសិក្សា និង បង្កើតយន្តការគ្រប់គ្រងការជួញដូរទ្រព្យឌីជីថល ។

ទី៥- ការសិក្សា និង រៀបចំឱ្យមានទីផ្សារសញ្ញាបណ្ណរដ្ឋ ដើម្បីជាមូលដ្ឋានសម្រាប់កំណត់អត្រាការប្រាក់គោល, ការកៀរគរធនធានហិរញ្ញវត្ថុសម្រាប់ការ-វិនិយោគសាធារណៈ និង ការជួយពង្រឹងគោលនយោបាយរូបិយវត្ថុ ។

ទី៦- ការជំរុញ និង លើកទឹកចិត្តដល់ការអភិវឌ្ឍ និង ការប្រើប្រាស់បច្ចេក-វិទ្យាហិរញ្ញវត្ថុ (FinTech) ក្នុងវិស័យធនាគារ និង ហិរញ្ញវត្ថុ ដើម្បីលើកកម្ពស់

ប្រតិបត្តិការធនាគារ ឱ្យកាន់តែទំនើប មានប្រសិទ្ធភាព សុវត្ថិភាព និង មានតម្លៃសមរម្យ ។

ទី៧- ការលើកកម្ពស់ និង បង្កើនសមត្ថភាពវិភាគ តាមដាន និង ត្រួត-ពិនិត្យកិច្ចការប្រឆាំងការសម្អាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម ។

ទី៨- ការបន្តលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ឱ្យកាន់តែទូលំទូលាយ តាមរយៈការបង្កើតគោលនយោបាយថ្នាក់ជាតិ ដែលបង្កើនការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ និង ការបន្តលើកកម្ពស់ការយល់ដឹងរបស់ប្រជាជនលើវិស័យហិរញ្ញវត្ថុ សំដៅបង្កើនប្រសិទ្ធភាព និង ការរួមចំណែករបស់វិស័យហិរញ្ញវត្ថុ នៅក្នុងកំណើនសេដ្ឋកិច្ចជាតិ ។

ទី៩- ការបន្តពង្រឹង និង ពង្រីកផលិតផលធានារ៉ាប់រងថ្មីៗ ពិសេសសេវាធានារ៉ាប់រងអាយុជីវិត និង ធានារ៉ាប់រងខ្នាតតូច ដោយរៀបចំ និង កែសម្រួលក្របខណ្ឌគតិយុត្ត, ការពង្រឹងសមត្ថភាពបញ្ញត្តិករធានារ៉ាប់រង និង កិច្ចការពារអ្នកប្រើប្រាស់ ។

## ចតុកោណទី៣ . ការអភិវឌ្ឍវិស័យឯកជន និង ការងារ

ការអភិវឌ្ឍវិស័យឯកជន នៅតែបន្តជាអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងអភិក្រមអភិវឌ្ឍសេដ្ឋកិច្ចទីផ្សារ និង មានតួនាទីគន្លឹះ ក្នុងការជំរុញកំណើន និង ការអភិវឌ្ឍសង្គម- សេដ្ឋកិច្ច ។ ក្នុងស្មារតីនេះ, ការអភិវឌ្ឍវិស័យឯកជន នឹងត្រូវបានអនុវត្ត តាមរយៈ វិធានការជាកញ្ចប់ និង គ្រប់ជ្រុងជ្រោយដោយគ្របដណ្តប់មុំ ៤ គឺ : ១) • ការអភិវឌ្ឍទីផ្សារការងារ; ២) • ការលើកស្ទួយសហគ្រាសធុនតូច និង មធ្យម និង សហគ្រិនភាព; ៣) • ការរៀបចំ និង អនុវត្តភាពជាដៃគូរវាងវិស័យសាធារណៈ និង វិស័យឯកជន; និង ៤) • ការពង្រឹងការប្រកួតប្រជែង ។

## មុំទី១. ការអភិវឌ្ឍទីផ្សារការងារ

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺការអភិវឌ្ឍទីផ្សារការងារ ដែលមានប្រាក់ចំណូលខ្ពស់ មានលក្ខខណ្ឌការងារល្អ និង ការយកចិត្តទុកដាក់លើសុខុមាលភាពកម្មករ- និយោជិត, ទាំងក្នុង និង ក្រៅប្រព័ន្ធ ។

ជាលទ្ធផល, រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលកាន់តែប្រសើរ ក្នុងការបង្កើត និង អភិវឌ្ឍការងារជូនប្រជាជន ពិសេសយុវជន, ទាំងការងារក្នុងស្រុក និង ក្រៅស្រុក ។ ចំនួនរោងចក្រសហគ្រាស និង គ្រឹះស្ថានគ្រប់ប្រភេទ, ទាំងក្នុង និង ក្រៅប្រព័ន្ធ, បានកើនឡើង ពី ២ ៤០០ សហគ្រាស ដែលមានកម្មករ- និយោជិត ជាង ៤៤ ម៉ឺននាក់ នៅឆ្នាំ ២០០៨ មកដល់ជាង ៥៨ ម៉ឺនសហគ្រាស ដែលបានបង្កើតការងារជាង ៤ លាននាក់ នៅឆ្នាំ ២០១៧ ។ ពលករទេសន្តរប្រវេសន៍ មានការកើនឡើងពីជាង ៥ ម៉ឺននាក់ នៅឆ្នាំ ២០០៨ ដល់ជាង ១,១៥ លាននាក់ នៅឆ្នាំ ២០១៧ និង បាននាំប្រាក់ចំណូលមកក្នុងប្រទេសជាង ១,៧ ប៊ីលានដុល្លារអាមេរិក ជាមធ្យមក្នុងមួយឆ្នាំ ។ ប្រាក់ឈ្នួលអប្បបរមាក្នុងវិស័យវាយនភណ្ឌកាត់ដេរ និង ផលិតស្បែកជើង បានកើនឡើងពី ៤០ ដុល្លារអាមេរិក ក្នុងមួយខែ នៅឆ្នាំ ១៩៩៧ ដល់ ១៧០ ដុល្លារអាមេរិក ក្នុងមួយខែ នៅឆ្នាំ ២០១៨ ហើយប្រសិនបើបូកនឹងប្រាក់អត្ថប្រយោជន៍បន្ថែម, កម្មករ- និយោជិតម្នាក់ អាចទទួលបានប្រាក់ឈ្នួលពី ១៨៧ ដល់ ១៩៨ ដុល្លារអាមេរិក ក្នុងមួយខែ ។ ទន្ទឹមនេះ, សិទ្ធិសេរីភាព លក្ខខណ្ឌការងារ និង ភាពសុខដុមរមនា ក្នុងទំនាក់ទំនងវិជ្ជាជីវៈ រវាងកម្មករ- និយោជិត និង និយោជក និង ការដោះស្រាយវិវាទការងារ ក៏ត្រូវបានលើកកម្ពស់កាន់តែប្រសើរជាលំដាប់ ។

ទន្ទឹមនេះ, កម្ពុជានៅបន្តជួបបញ្ហាប្រឈមមួយចំនួន ដូចជា ៖ គុណភាព

និង ផលិតភាពនៃកម្លាំងពលកម្មនៅមានកម្រិតទាប បើធៀបទៅនឹងបណ្តាប្រទេសក្នុងតំបន់, កម្លាំងពលកម្មភាគច្រើន ធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ, ប្រព័ន្ធគ្រប់គ្រងទិន្នន័យការងារ និង អតីតភាពការងារមិនទាន់រឹងមាំ, ការរៀបចំប្រព័ន្ធគ្រប់គ្រងសុខភាព និង សុវត្ថិភាពការងារ នៅតាមរោងចក្រសហគ្រាសមិនទាន់ល្អ, ការដឹកជញ្ជូនកម្មករ- និយោជិត មិនសូវមានសុវត្ថិភាព, ការគ្រប់គ្រងការបិទរោងចក្រ និង ការទូទាត់ប្រាក់អតីតភាពការងារ នៅមិនទាន់បានល្អ និង សេវាគាំពារពលករទេសន្តរប្រវេសន៍នៅមានកម្រិត ។

ក្នុងនីតិកាលទី ៦ នៃរដ្ឋសភា, រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ÷

ទី១- ការបន្តពង្រឹងយន្តការ«**វេទិកាការងារ**»; ការផ្តល់ការបណ្តុះបណ្តាលតម្រង់ទិសមុនចូលធ្វើការ និង ការពង្រីកការផ្តល់សេវារកការងារ និង ការផ្សព្វផ្សាយ; ព្រមទាំងការបញ្ជ្រាបអំពីព័ត៌មានទីផ្សារការងារ, ទាំងក្នុង និង ក្រៅប្រទេស, ដើម្បីបង្កើនឱកាសការងារប្រកបដោយសមធម៌ និង កាត់បន្ថយចំណាកស្រុកដោយប្រថុយប្រថាន ។

ទី២- ការអនុវត្តច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ឱ្យមានប្រសិទ្ធភាព ដោយបន្តពង្រឹងយន្តការត្រីភាគី, លក្ខណៈវិនិច្ឆ័យ និង គោលការណ៍ ដែលបាន និង កំពុងអនុវត្ត សម្រាប់ចរចាដំឡើងប្រាក់ឈ្នួលអប្បបរមារបស់កម្មករ- និយោជិតជារៀងរាល់ឆ្នាំ ស្របតាមស្ថានភាពសង្គម- សេដ្ឋកិច្ច និង ផលិតភាព, ការរៀបចំបើកប្រាក់ឈ្នួលប្រចាំខែ ក្នុងរយៈពេល ២ សប្តាហ៍ម្តង និង ការទូទាត់ប្រាក់អតីតភាពការងារប្រចាំឆ្នាំឱ្យបានទៀងទាត់ ដល់កម្មករ- និយោជិត ។

ទី៣- ការពង្រឹង និង ពង្រីកការអនុវត្តកម្មវិធីហ្វឹកហ្វឺនកូនជាង/កម្មសិក្សា

ទី៣- ការពង្រឹង និង ពង្រីកការអនុវត្តកម្មវិធីហ្វឹកហ្វឺនកូនជាង/កម្មសិក្សា ដោយធ្វើវិសោធនកម្មច្បាប់ស្តីពីការងារ និង ធ្វើស្ថាប័នីយកម្មប្រព័ន្ធហ្វឹកហ្វឺនកូន-ជាង/កម្មសិក្សា ដោយភ្ជាប់ជាមួយប្រព័ន្ធលើកទឹកចិត្តដល់សហគ្រាស និង គ្រឹះស្ថានដែលអនុវត្តប្រព័ន្ធនេះ ។

ទី៤- ការពង្រឹងគុណភាព និង ប្រសិទ្ធភាពអធិការកិច្ចការងារ តាមរយៈការអនុវត្តឱ្យបានពេញលេញនូវច្បាប់ស្តីពីការងារ ច្បាប់ស្តីពីសហជីព ច្បាប់ស្តីពីរបបសន្តិសុខសង្គម និង បទដ្ឋានការងារអន្តរជាតិ ដើម្បីធានាសិទ្ធិ សេរីភាពអង្គការវិជ្ជាជីវៈ លក្ខខណ្ឌការងារ សុខភាព និង សុវត្ថិភាពការងារនៅកន្លែងធ្វើការ ក៏ដូចជាសុវត្ថិភាពដឹកជញ្ជូនកម្មករ- និយោជិត ព្រមទាំងអត្ថប្រយោជន៍កម្មករនិយោជិត និង ការពង្រឹងប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្មករនិយោជិត ដើម្បីគ្រប់គ្រងការផ្តល់បណ្ណការងារ និង ការបើកផ្តល់ប្រាក់រង្វាន់អតីតភាពការងារ និង ប្រាក់សោធន-និវត្តន៍ ។

ទី៥- ការពង្រឹងភាពសុខដុមរមនានៅក្នុងទំនាក់ទំនងវិជ្ជាជីវៈ តាមរយៈការពង្រឹងយន្តការដោះស្រាយវិវាទការងារ, ការអនុវត្តច្បាប់ស្តីពីសហជីព និង ការបកស្រាយលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធច្បាប់ស្តីពីការងារ ច្បាប់-ស្តីពីសហជីព ច្បាប់ស្តីពីរបបសន្តិសុខសង្គម និង អនុសញ្ញាអន្តរជាតិស្តីពីការងារ ។

ទី៦- ការបន្តពង្រឹងអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ និង ពង្រីកកិច្ច-សហប្រតិបត្តិការពហុភាគី និង ទ្វេភាគី ដើម្បីបើកទូលាយទីផ្សារកាងារស្របច្បាប់នៅក្រៅប្រទេស, ទប់ស្កាត់ទេសន្តរប្រវេសន៍ការងារដោយខុសច្បាប់, លើកកម្ពស់ការគាំពារសិទ្ធិ ផលប្រយោជន៍ សុខភាព និង សុវត្ថិភាពការងារ, កិត្តិយស និង សេចក្តីថ្លៃថ្នូររបស់ពលករ, ការផ្តល់ការសម្របសម្រួលទំនាក់ទំនងជាមួយគ្រួសារ

និង ការរៀបចំធ្វើសមាហរណកម្មពលករទេសន្តរប្រវេសន៍ ដែលធ្វើមាតុភូមិនិវត្ត តាមរយៈការទទួលស្គាល់ជំនាញ, ការផ្ទេររបបសន្តិសុខសង្គមមកក្នុងប្រទេស, ការ-ផ្តល់ការប្រឹក្សារកការងារធ្វើ និង ការបង្កើតមុខរបរដោយខ្លួនឯង ។

ទី៧- ការបន្តពង្រីកការតបណ្តាញអគ្គិសនី និង ទឹកស្អាត ដោយតម្លៃទាប សមរម្យជូនកម្មករ- និយោជិត សិស្ស- និស្សិត នៅតាមផ្ទះជួល, ការជំរុញការ-រៀបចំកន្លែងស្នាក់នៅ និង មធ្យោបាយធ្វើដំណើរ សម្រាប់កម្មករ- និយោជិត ដោយសុវត្ថិភាព, ការអនុញ្ញាតឈប់លំហែមាតុភាពរយៈពេល ៣ ខែ ដោយទទួលបានប្រាក់ឈ្នួលពលកម្ម ១២០%, ការផ្តល់សេវាថែទាំសុខភាព និង ការពិនិត្យផ្ទៃពោះដល់កម្មការិនីដោយឥតគិតថ្លៃ នៅតាមមន្ទីរពេទ្យ/មណ្ឌលសុខភាពរដ្ឋ, ការផ្តល់ការឧបត្ថម្ភដល់កម្មការិនីដែលមានផ្ទៃពោះ និង សម្រាលកូនរួច, និង ការ-បន្តកែសម្រួលកម្រិតប្រាក់ឈ្នួលអប្បបរមា ដែលត្រូវជាប់ពន្ធ និង ការអនុគ្រោះពន្ធចំពោះប្រាក់អត្ថប្រយោជន៍បន្ថែម ។

## មុំទី២. ការលើកស្ទួយសហគ្រាសធុនតូច និង មធ្យម និង សហគ្រិនភាព

សហគ្រាសធុនតូច និង មធ្យម រួមចំណែកយ៉ាងសំខាន់ នៅក្នុងការជំរុញកំណើនសេដ្ឋកិច្ច, ការបង្កើតការងារ និង ក្នុងការកាត់បន្ថយភាពក្រីក្រ និង ការធ្វើចំណាកស្រុក ។ គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺបន្តពង្រឹងការអភិវឌ្ឍសហគ្រាសធុនតូច និង មធ្យម, លើកកម្ពស់សហគ្រិនភាព និង សហគ្រាសបង្កើតថ្មី ដើម្បីជំរុញផលិតកម្មនៅក្នុងស្រុកជំនួសការនាំចូល, តភ្ជាប់សហគ្រាសធុនតូច និង មធ្យម ជាមួយនឹងក្រុមហ៊ុនវិនិយោគផ្ទាល់ពីបរទេស និង ជំរុញការនាំចេញផលិតផល ដែលមានសក្តានុពល ជាពិសេសក្នុងវិស័យកសិកម្ម កែច្នៃម្ហូបអាហារ និង កសិឧស្សាហកម្ម ។

ជាលទ្ធផល, រាជរដ្ឋាភិបាលបានពង្រឹងបរិស្ថានធុរកិច្ច សម្រាប់ការអភិវឌ្ឍសហគ្រាសធុនតូច និង មធ្យម តាមរយៈការពង្រឹងអភិបាលកិច្ច ការផ្ដល់ការលើកទឹកចិត្តផ្នែកសារពើពន្ធ, ការលើកកម្ពស់ស្តង់ដារគុណភាពផលិតផល និង ការធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលធ្វើឱ្យសហគ្រាសធុនតូច និង មធ្យម មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ។ ជាក់ស្ដែង, សហគ្រាសធុនតូច និង មធ្យម កម្មន្តសាល និង សិប្បកម្ម ដែលបានចុះបញ្ជីនៅក្រសួងឧស្សាហកម្ម និង សិប្បកម្ម គិតត្រឹមឆ្នាំ ២០១៧ មានចំនួនជិត ១៦ ម៉ឺនកន្លែង និង កំពុងប្រើប្រាស់កម្លាំងពលកម្មសរុបចំនួនជាង ១ លាននាក់ ។

បញ្ហាប្រឈមក្នុងការអភិវឌ្ឍសហគ្រាសធុនតូច និង មធ្យម មានជាអាទិ៍ៈ ការផ្ដល់សេវាសាធារណៈ និង ការសម្របសម្រួលស្ថាប័ន នៅមិនទាន់មានប្រសិទ្ធភាពល្អ ស្មុគស្មាញ និង ប្រើពេលវេលាច្រើន, ការទទួលបានឥណទាន នៅមានកម្រិត និង ប្រភពទុនវិនិយោគនៅមានភាពចង្អៀត, ការលើកទឹកចិត្តផ្នែកពន្ធមិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយ, កង្វះខាតនូវសហគ្រិនភាព និង សមត្ថភាពគ្រប់គ្រងសហគ្រាសខ្លួនឯងផ្ទាល់, ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ដូចជា : មន្ទីរពិសោធន៍ថ្នាក់ជាតិនៅមានកម្រិត, កិច្ចសម្រួលពាណិជ្ជកម្ម នៅមិនទាន់មានប្រសិទ្ធភាពគ្រប់គ្រាន់ និង ចំណាយថ្លៃដើមខ្ពស់ ធៀបនឹងប្រទេសជិតខាងក្នុងតំបន់ ។

ក្នុងនីតិកាលទី ៦ នៃរដ្ឋសភា, រាជរដ្ឋាភិបាលនឹងផ្ដោតអាទិភាពលើ ÷

ទី១- ការបញ្ចប់ការរៀបចំ និង ជំរុញការអនុវត្ត«**គោលនយោបាយគាំទ្រសហគ្រាសធុនតូច និង មធ្យម**» ឱ្យមានប្រសិទ្ធភាព ។

ទី២- ការពង្រឹងការអនុវត្តយន្តការគាំទ្រ ដើម្បីជួយសម្រួលដល់ការចុះបញ្ជី, ការផ្ដល់សេវាសម្របសម្រួល, ការផ្សព្វផ្សាយព័ត៌មានទីផ្សារឱ្យបានទូលំទូលាយ

និង ទាន់ពេលវេលា, ការផ្សព្វផ្សាយ និង បញ្ជាបបច្ចេកវិទ្យាថ្មី និង ការបន្តខិតខំស្វែងរក និង ជ្រៀតចូលទីផ្សារនាំចេញ សម្រាប់ផលិតផលកម្ពុជា ។

ទី៣- ការបង្កើត **«ធនាគារសហគ្រាសធុនតូច និង មធ្យម»** ដើម្បីផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុនតូច និង មធ្យម, ព្រមទាំងការជំរុញការរៀបចំ និង អនុវត្តនូវជម្រើសហិរញ្ញប្បទាននានា រួមទាំងយន្តការគ្រប់គ្រងអាជីវកម្មគម្រោងវិនិយោគរួម (Collective Investment Scheme) ផង ។

ទី៤- ការបង្កើត **«មូលនិធិជាតិសហគ្រិនភាព»** និង **«មជ្ឈមណ្ឌលអភិវឌ្ឍសហគ្រិនភាព»** ដោយសហការជាមួយវិស័យឯកជន សំដៅលើកកម្ពស់សហ-គ្រិនភាព និង ប្រសិទ្ធភាពធុរកិច្ច ។

ទី៥- ការពង្រឹង និង ពង្រីកបន្ថែមការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ដូចជា : មន្ទីរពិសោធន៍ថ្នាក់ជាតិ, ការបន្តកែលម្អកិច្ចសម្រួលពាណិជ្ជកម្ម, ការ-កែលម្អប្រព័ន្ធឡូជីស្ទីក ព្រមទាំងការបន្តលើកទឹកចិត្ត និង ការទាក់ទាញការវិនិយោគក្នុងការបង្កើតចង្កោមសហគ្រាសធុនតូច និង មធ្យម (SME Cluster) ។

ទី៦- ការជំរុញការលើកកម្ពស់គុណភាពផលិតផលនៃសហគ្រាសធុនតូច និង មធ្យម តាមរយៈការពង្រឹងអនុលោមភាពលក្ខខណ្ឌអនាម័យ និង ភូតគាមអនាម័យ និង ស្តង់ដារ ព្រមទាំងការលើកកម្ពស់នវានុវត្តន៍ តាមរយៈការការពារកម្មសិទ្ធិបញ្ញា និង ការផ្តល់ប្រកាសនីយបត្រតក្កកម្ម (Patents) ។

### មុំទី៣. ការរៀបចំ និង អនុវត្តភាពជាដៃគូវិស័យសាធារណៈ និង វិស័យឯកជន

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺ : បង្កើត និង អនុវត្តឱ្យបានពេញលេញនូវប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ តាមរយៈយន្តការភាពជា-

ដៃគូរវាងរដ្ឋ និង ឯកជន ប្រកបដោយភាពប្រទាក់ក្រឡា និង គ្រប់ជ្រុងជ្រោយ ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ ។

ជាលទ្ធផល, កម្ពុជាសម្រេចបានវឌ្ឍនភាពសំខាន់ៗ ក្នុងការជំរុញ ការ-ចូលរួមរបស់វិស័យឯកជន ដោយបានដាក់ចេញនូវ **«ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និង ឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០»** និង បានបង្កើតយន្តការស្ថាប័ន ព្រមទាំងបានអនុវត្តគម្រោងវិនិយោគធំៗ ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ថាមពល និង បច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន ជាពិសេសក្នុងទម្រង់ **«សាងសង់-អាជីវកម្ម- ផ្ទេរ»** ។

បញ្ហាប្រឈមសំខាន់ៗ រួមមាន : ការបន្តប្រើប្រាស់ **«យន្តការចំពោះកិច្ច»** ក្នុងការអនុវត្តគម្រោងភាពជាដៃគូរវាងរដ្ឋ និង ឯកជន, មិនទាន់មានការវាយតម្លៃហានិភ័យនៃគម្រោងហិរញ្ញវត្ថុ, ក្របខណ្ឌគតិយុត្តមិនទាន់គ្រប់គ្រាន់, សមត្ថភាពផ្តួចផ្តើមរៀបចំការចរចា និង ការគ្រប់គ្រងគម្រោង នៅមានកម្រិត ។

ក្នុងនីតិកាលទី ៦ នៃ រដ្ឋសភា រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ÷

ទី១- ការបន្តអនុវត្ត **«ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និង ឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០»** និង ការរៀបចំ **«គោលនយោបាយអនុវត្តគម្រោងវិនិយោគសាធារណៈក្រោមយន្តការភាពជាដៃគូរវាងរដ្ឋ និង ឯកជន»** សម្រាប់រយៈពេលវែង ដើម្បីរួមចំណែកបង្កើតបរិស្ថានអំណោយផល សម្រាប់បន្តជំរុញ និង លើកទឹកចិត្តការចូលរួមរបស់វិស័យឯកជន និង ស្ថាប័នហិរញ្ញវត្ថុ ។

ទី២- ការបន្តរៀបចំក្របខណ្ឌគតិយុត្ត និង បទប្បញ្ញត្តិពាក់ព័ន្ធ, ការដាក់ឱ្យ

អនុវត្តនីតិវិធីគ្រប់គ្រងប្រតិបត្តិការរួម ព្រមទាំងការពិនិត្យលទ្ធភាពរៀបចំបង្កើតយន្តការគាំទ្រហិរញ្ញវត្ថុនានា តាមការចាំបាច់ និង ស្របតាមបរិការណ៍អភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ។

ទី៣- ការបន្តអភិវឌ្ឍសមត្ថភាពស្ថាប័ន និង ធនធានមនុស្ស តាមក្រសួង-ស្ថាប័នពាក់ព័ន្ធ លើការគ្រប់គ្រង និង អនុវត្តគម្រោងតាមរូបភាពយន្តការភាពជាដៃគូរវាងរដ្ឋ និង ឯកជន ។

ទី៤- ការបន្តអភិវឌ្ឍគម្រោងវិនិយោគសាធារណៈ តាមរយៈយន្តការភាពជាដៃគូរវាងរដ្ឋ និង ឯកជន ដើម្បីឱ្យហិរញ្ញប្បទានពីវិស័យឯកជន អាចចូលរួមបង្កើន និង ពន្លឿនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និង ការផ្តល់សេវាសាធារណៈ ប្រកបដោយគុណភាព សំដៅគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ក៏ដូចជាគាំទ្រដល់ការបន្ធូរបន្ទុកថវិកាជាតិ និង បំណុលសាធារណៈ ។

### មុំទី៤. ការពង្រឹងការប្រកួតប្រជែង

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺបង្កើនផលិតភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច, លើកកម្ពស់ឧត្តមភាព និង ជំរុញនវានុវត្តន៍ ដែលចាំបាច់ត្រូវធ្វើជាប្រចាំ, ទាំងសម្រាប់ស្ថាប័នសាធារណៈ ធុរជន និង ប្រជាជន ។ ជាវឌ្ឍនភាព, សន្ទស្សន៍នៃភាពប្រកួតប្រជែងសកល[3] របស់កម្ពុជាត្រូវបានកែលម្អឱ្យប្រសើរឡើង ពីចំណាត់ថ្នាក់ទី ១១២ ក្នុងចំណោម ១១៧ ប្រទេស នៅឆ្នាំ ២០០៥ មកចំណាត់ថ្នាក់ទី ៩៤ ក្នុងចំណោម ១៣៧ ប្រទេស នៅឆ្នាំ ២០១៧-២០១៨ ។

យ៉ាងណាមិញ, ការប្រកួតប្រជែងបាន និង កំពុងជួបបញ្ហាប្រឈមសំខាន់ៗមួយចំនួន រួមមាន ៖ កង្វះក្របខណ្ឌច្បាប់ក្នុងការលើកកម្ពស់ការប្រកួតប្រជែងដោយ

[3] *The Global Competitiveness Report 2017-2018, World Economic Forum.*

ស្មើភាព និង ស្មោះត្រង់, សមត្ថភាពកែច្នៃនិង បង្កើតតម្លៃបន្ថែម នៅមានកម្រិត, កង្វះពលកម្មជំនាញ, និង ប្រសិទ្ធភាពនៃវិស័យគាំទ្រនៅមានកម្រិត ។

លើមូលដ្ឋាននេះ, រាជរដ្ឋាភិបាលនីតិកាលទី ៦ នឹងផ្តោតអាទិភាពលើ ÷

ទី១- ការជំរុញរៀបចំ និង អនុម័តច្បាប់ស្តីពីការប្រកួតប្រជែង (Anti-trust/competition Law) ដែលជាក្របខ ណ្ឌសម្រាប់ជំរុញការប្រកួតប្រជែង, ពង្រឹងរចនាសម្ព័ន្ធឧស្សាហកម្ម, រៀបចំយន្តការសម្រាប់អនុវត្តច្បាប់ និង លើកកម្ពស់វប្បធម៌ប្រកួតប្រជែង ។

ទី២- ការពិនិត្យឡើងវិញ និង ធ្វើវិសោធនកម្មច្បាប់ស្តីពីក្ស័យធន ដែលជំរុញការទទួលយកហានិភ័យ និង ការពារសហគ្រិនភាព ។

ទី៣- ការជំរុញអនុវត្តយន្តការមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (Commercial Arbitration) ដែលមានសមត្ថភាព អាចទុកចិត្តបាន និង ដោះស្រាយជម្លោះធុរកិច្ចដែលអាចទទួលយកបាន ។

ទី៤- ការបន្តជំរុញការរៀបចំ និង ការអ នុវត្តស្តង់ដារទំនិញ សេវា និង ការគ្រប់គ្រង ហើយលើកកម្ពស់ស្តង់ដារទាំងនោះជាប្រចាំ ដើម្បីជំរុញការចាប់យកបច្ចេកវិទ្យាថ្មី និង លើកកម្ពស់គុណភាព ។

ទី៥- ការជំរុញរៀបចំ និង អ នុម័តច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់ (Consumer Protection Law) និង រៀបចំយន្តការអនុវត្ត ដើម្បីការពារសិទ្ធិ និង សុវត្ថិភាពអ្នកប្រើប្រាស់, លើកកម្ពស់សុខភាព, ពង្រឹងស្តង់ដារទំនិញ និង សេវា ព្រមទាំងលើកកម្ពស់ការប្រកួតប្រជែង ។

ទី៦- ការពង្រឹងយន្តការជំរុញការប្រកួតប្រជែងដោយស្មើភាព ជាពិសេសក្នុងការបំពេញកាតព្វកិច្ចពន្ធ- អាករ និង ការអនុវត្តលទ្ធកម្មសាធារណៈ ប្រកប

ដោយតម្លាភាព និង ភាពត្រឹមត្រូវ ។

### ចតុកោណទី៤ . ការអភិវឌ្ឍប្រកបដោយចីរភាព និង បរិយាប័ន្ន

ទន្ទឹមនឹងការជំរុញកំណើនសេដ្ឋកិច្ចខ្ពស់, រាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍប្រកបដោយចីរភាព និង បរិយាប័ន្ន ជាពិសេសផ្សារភ្ជាប់ទៅនឹង **«គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា»** ។

ក្នុងការអនុវត្តកិច្ចការនេះ, បញ្ហាប្រឈមសំខាន់ៗ រួមមានៈ កំណើនទាបក្នុងវិស័យកសិកម្ម, ប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានធម្មជាតិនៅមានកម្រិត, ការរីកចម្រើននៃនគរូបនីយកម្មក្នុងសន្ទុះលឿន ប៉ុន្តែ មិនទាន់ធានាបាននូវតុល្យ-ភាព, និង ភាពចាំបាច់ ក្នុងការបង្កើនសមត្ថភាព ដើម្បីឆ្លើយតបនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ។ ការណ៍នេះ តម្រូវឱ្យរាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់លើ : ១). កាលើកស្ទួយវិស័យកសិកម្ម និង ការអភិវឌ្ឍជនបទ; ២) . ការ-គ្រប់គ្រងធនធានធម្មជាតិ និង វប្បធម៌ ប្រកបដោយចីរភាព; ៣) . ការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម; និង ៤) . ការធានាចីរភាពបរិស្ថាន និង ការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ។

#### មុំទី១. ការលើកស្ទួយវិស័យកសិកម្ម និង ការអភិវឌ្ឍជនបទ

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺពង្រឹងតួនាទីវិស័យកសិកម្ម ក្នុងការបង្កើតការងារ, ការធានាសន្តិសុខស្បៀង, ការកាត់បន្ថយភាពក្រីក្រ និង ការអភិវឌ្ឍជនបទ ។

ជាលទ្ធផល, វិស័យកសិកម្មបានផ្តល់ការងាររហូតដល់ ៤១,៥% ។ កម្ពុជាបានផលិតស្បៀងលើសពីតម្រូវការក្នុងស្រុក ព្រមទាំងបានផលិត និង នាំចេញកសិផលជាច្រើនមុខ ពិសេសបាននាំចេញអង្ករជាង ៦០ ម៉ឺនតោន ក្នុងឆ្នាំ ២០១៧

ហើយអង្ករកម្ពុជា ក៏ទទួលបាននូវការលើកតម្កើងកេរ្តិ៍ឈ្មោះនៅលើឆាកអន្តរជាតិ ។ លើសពីនេះ, តំបន់ជនបទមានការរីកចម្រើនគួរឱ្យកត់សម្គាល់ តាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់, ប្រព័ន្ធធារាសាស្ត្រ, ការតភ្ជាប់អគ្គិសនី, និង ការលើកកម្ពស់ការទទួលបានទឹកស្អាត និង អនាម័យ ។

យ៉ាងណាក៏ដោយ, វិស័យកសិកម្មនៅមានបញ្ហាប្រឈមមួយចំនួន ដូចជា ផលិតភាពនៅមានកម្រិត, គុណភាពទាបនៃធាតុចូលកសិកម្ម, ការផ្តល់សេវាបច្ចេកទេសមិនទាន់ឆ្លើយតបនឹងតម្រូវការ, ការអភិវឌ្ឍខ្សែច្រវាក់ផ្គត់ផ្គង់កសិផលមិនទាន់ឆ្លើយតបបានទៅនឹងតម្រូវការទីផ្សារ, ការចិញ្ចឹមសត្វ និង វារីវប្បកម្ម នៅមានកម្រិត, យន្តការសម្រួលការនាំចេញ នៅមិនទាន់មានភាពប្រទាក់ក្រឡា និងបំពេញគ្នាបាន, ការបន្តការនាំចូលកសិផល ដែលអាចមានលទ្ធភាពផ្គត់ផ្គង់ក្នុងស្រុក, ប្រព័ន្ធអនាម័យ និង ភូតគាមអនាម័យ នៅមិនទាន់រឹងមាំ, មិនទាន់មានយន្តការផ្តល់ព័ត៌មានទីផ្សារកសិកម្ម ដោយផ្សារភ្ជាប់នឹងផែនការដាំដុះ និង ប្រមូលផល, ការស្រាវជ្រាវ និង ការអភិវឌ្ឍ (R&D) នៅមិនទាន់ទូលំទូលាយ ព្រមទាំងការ-ប្រើប្រាស់ដីធ្លីកសិកម្មនៅមិនទាន់អស់សក្តានុពល ។ ជាមួយនេះ, បញ្ហាប្រឈមផ្នែកអភិវឌ្ឍជនបទ រួមមាន ៖ ភាពចាំបាច់ក្នុងការបន្តលើកកម្ពស់គុណភាព និង ការថែទាំហេដ្ឋារចនាសម្ព័ន្ធជនបទ, ការទទួលបានទឹកស្អាតប្រកបដោយសុវត្ថិភាព និង ការជំរុញការលើកកម្ពស់អនាម័យជនបទ ។

លើមូលដ្ឋាននេះ, ក្នុងនីតិកាលទី ៦ នៃរដ្ឋសភា, រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ÷

ទី១- ការជំរុញការរៀបចំ និង ដាក់ឱ្យអនុវត្ត «**ផែនការមេសម្រាប់អភិវឌ្ឍវិស័យកសិកម្មឆ្ពោះទៅឆ្នាំ ២០៣០**» និង «**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យ**

**កសិកម្មឆ្នាំ ២០១៩-២០២៣»** ។

ទី២- ការបន្តជំរុញការរៀបចំ អនុម័ត និង ការអនុវត្ត **«ច្បាប់ស្តីពីការការពាររុក្ខជាតិ និង ភូតគាមអនាម័យ»** និង **«ច្បាប់ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា»** ។

ទី៣- ការបង្កើនផលិតភាព គុណភាព និង ពិពិធកម្ម តាមរយៈការបង្កើនការវិនិយោគលើការស្រាវជ្រាវ និង ការអភិវឌ្ឍពូជដំណាំ ពូជសត្វ និង ការចិញ្ចឹមត្រី ដែលផ្តល់តម្លៃបន្ថែមខ្ពស់; ការជំរុញការអភិវឌ្ឍកសិដ្ឋានគំរូ (Model Farm); ការជំរុញការផ្តល់សេវាបច្ចេកទេស សកសិកម្ម; ការពង្រឹងការគ្រប់គ្រងសហគមន៍កសិករ; ការរៀបចំយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា; ការបន្តកាត់បន្ថយថ្លៃ និង ពង្រឹងគុណភាពនៃធាតុចូលកសិកម្ម; ការសិក្សារៀបចំឱ្យមានសេវាធានារ៉ាប់រងផលិតកម្មកសិកម្ម; ការរៀបចំឱ្យមានផលិតផលហិរញ្ញវត្ថុ សម្រាប់ផលិតកម្មកសិកម្ម; និង ការជំរុញការប្រើប្រាស់បច្ចេកវិទ្យាវៃឆ្លាត និង ឌីជីថល ។

ទី៤- ការលើកកម្ពស់ឧស្សាហកម្មកែច្នៃ តាមរយៈការជំរុញឱ្យមានការវិនិយោគឯកជនលើកសិផល ដែលមានសក្តានុពល ដូចជា៖ ស្រូវ ដំឡូងមីស្វាយ ស្វាយចន្ទី ចេក កៅស៊ូ បន្លែ ជាដើម តាមរយៈការរៀបចំយុទ្ធសាស្ត្រតាមមុខដំណាំនីមួយៗ ។

ទី៥- ការបន្តជំរុញការដាំបន្លែគ្រប់ប្រភេទជំនួសឱ្យការនាំចូល និង ការរៀបចំបង្កើតទីផ្សារបោះដុំ និង ចែកចាយបន្លែ ដែលមានស្តង់ដារ និង អនាម័យខ្ពស់ ។

ទី៦- ការជំរុញពាណិជ្ជូបនីយកម្មកសិកម្ម តាមរយៈការបន្តពង្រឹងប្រព័ន្ធអនាម័យ និង ភូតគាមអនាម័យ (SPS), ការសម្រួលពាណិជ្ជកម្ម, ការវិនិយោគ

បន្ថែមលើមន្ទីរពិសោធន៍គុណភាពសម្រាប់ការនាំចេញ, ព្រមទាំងការជំរុញការ-ផលិត និង ប្រើប្រាស់ផលិតផលកសិកម្មក្នុងស្រុក ។

ទី៧- ការជំរុញការចិញ្ចឹមសត្វ និង វារីវប្បកម្ម តាមរយៈការបន្តអនុវត្ត **«ច្បាប់ស្តីពីសុខភាពសត្វ និង ផលិតកម្មសត្វ»** , **«ក្របខណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យបសុសត្វ ឆ្នាំ ២០១៦-២០២៥»** និង **«ផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍវារីវប្បកម្មឆ្នាំ ២០១៦-២០៣០»** ។

ទី៨- ការពង្រឹងការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច, ការបន្តជំរុញការ-បោសសម្អាតមីន និង យុទ្ធភណ្ឌមិនទាន់ផ្ទុះ និង ការបន្តផ្តល់ដីសម្បទានសង្គមកិច្ចពិសេសដល់គ្រួសារក្រីក្រសម្រាប់ការធ្វើកសិកម្មជាលក្ខណៈគ្រួសារ ។

ទី៩- ការធ្វើវិចារណកម្មក្នុងការវិនិយោគលើប្រព័ន្ធធារាសាស្ត្រ ដោយយកចិត្តទុកដាក់លើការបង្កើនការតភ្ជាប់ទៅនឹងផលិតកម្មកសិកម្ម, ការថែទាំជា-ប្រព័ន្ធ និង ការពង្រឹងការគ្រប់គ្រង ។

ទី១០- ការបន្តជំរុញការអភិវឌ្ឍជនបទឱ្យរស់រវើក ដោយបន្តវិនិយោគលើផ្លូវជនបទ ប្រព័ន្ធធារាសាស្ត្រខ្នាតតូច, ការពង្រីកការគ្របដណ្តប់ការប្រើប្រាស់អគ្គិសនី, ការពង្រីកការទទួលបានទឹកស្អាត, ការលើកកម្ពស់អនាម័យ, ការរៀបចំភូមិ និង លំនៅឋាន, ព្រមទាំងការលើកកម្ពស់ជីវភាពប្រជាជន តាមរយៈការបន្តអនុវត្ត **«ចលនាភូមិមួយ-ផលិតផលមួយ»** និង **«ចលនាភូមិថ្មី»** ។

### មុំទី ២. ការគ្រប់គ្រងធនធានធម្មជាតិ និង វប្បធម៌ ប្រកបដោយចីរភាព

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺរក្សាតុល្យភាពរវាងការ-អភិវឌ្ឍ និង ការអភិរក្ស សំដៅលើកកម្ពស់វិភាគទានកិច្ចការនេះ ចំពោះការអភិវឌ្ឍវិស័យកសិកម្ម ឧស្សាហកម្ម និង ទេសចរណ៍, ការពង្រឹងការគ្រប់គ្រងធនធានរ៉ែ,

ការធានាចីរភាពធនធានព្រៃឈើ ជលផល និង ប្រព័ន្ធអេកូឡូស៊ី ព្រមទាំងការ-ការពារ និង អភិវឌ្ឍបេតិកភណ្ឌវប្បធម៌ជាតិ ។

ជាលទ្ធផល, គម្របព្រៃឈើត្រូវបានរក្សាក្នុងរង្វង់ ៦០% នៃផ្ទៃប្រទេស; ដីសម្បទានសេដ្ឋកិច្ចជាង ៤១ ម៉ឺនហិចតា ត្រូវបានដកហូត ដើម្បីយកមកអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច, ឬ ធ្វើប្រទានកម្ម, ឬ ដាំដើមឈើឡើងវិញ; កន្លែងអភិរក្សជលផលជាង ៩៧ ម៉ឺនហិចតា ត្រូវបានអភិរក្ស ក្រោយការរំសាយឡូតិ៍នេសាទ; សហគមន៍ព្រៃឈើ ចំនួន ៦១០ និង សហគមន៍នេសាទចំនួន ៥១៦ ត្រូវបានបង្កើត; បេតិកភណ្ឌវប្បធម៌រូបី និង អរូបី រួមមានប្រាសាទសំបូរព្រៃគុក ចាប៉ីដងវែង ល្បែងទាញព្រ័ត្រ និង ប្រពៃណីទាញព្រ័ត្រ និង ប្រពៃណីនិទានរឿង រាមកេរ្តិ៍ តាគ្រុឌ ត្រូវបានដាក់បញ្ចូលក្នុងបញ្ជីបេតិកភណ្ឌនៃអង្គការយូណេស្កូ ។

បញ្ហាប្រឈមពាក់ព័ន្ធនឹងវិស័យនេះ រួមមាន ៖ អភិបាលកិច្ច និងប្រព័ន្ធគ្រប់គ្រងធនធានរ៉ែ នៅមិនទាន់រឹងមាំ និង ការធ្វើអាជីវកម្មរ៉ែនៅមានអនាធិប-តេយ្យ; សម្ពាធនៃតម្រូវការដីសម្រាប់ប្រើប្រាស់ ទល់នឹងការចាំបាច់ក្នុងការការពារគម្របព្រៃឈើ; ការហ៊ុមព័ទ្ធ និង ការឈូសឆាយដីព្រៃធ្វើកម្មសិទ្ធិ; ការទន្ទ្រានដីព្រៃលិចទឹក និង ដែននេសាទ; បទល្មើសព្រៃឈើ សត្វព្រៃ និង ជលផលនៅបន្តជាក្តីកង្វល់; ព្រមទាំងការអភិវឌ្ឍបេតិកភណ្ឌវប្បធម៌ ក៏នៅមិនអស់សក្តានុពល ។

ក្នុងនីតិកាលទី ៦ នៃរដ្ឋសភា, រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ៖

ទី១- ការជំរុញអនុវត្ត«**គោលនយោបាយជាតិស្តីពីធនធានរ៉ែ ឆ្នាំ ២០១៨-២០២៨**» ដោយពង្រឹងអភិបាលកិច្ច និង ការគ្រប់គ្រងធនធាន និង អាជីវកម្មរ៉ែ, ទន្ទឹមនឹងការជំរុញការចូលរួមពីសហគមន៍ ដើម្បីកាត់បន្ថយផលប៉ះពាល់បរិស្ថាន-សង្គម និង ពង្រឹងការប្រមូលចំណូលថវិកាជាតិ ។

ទី២- ការពង្រឹងយន្តការគ្រប់គ្រងធនធាន និង អាជីវកម្មខ្សាច់ ដោយកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ផ្នែកសង្គម និង បរិស្ថាន ។

ទី៣- ការបន្តគ្រប់គ្រងធនធានព្រៃឈើ និង សត្វព្រៃ ដោយថែរក្សាគម្របព្រៃឈើ ឱ្យលើស ៦០% នៃផ្ទៃប្រទេស, ការលើកកម្ពស់ការអភិរក្សព្រៃឈើ និង សត្វព្រៃ, ការទប់ស្កាត់ការទន្ទ្រានកាន់កាប់ និង ឈូសឆាយដីព្រៃធ្វើកម្មសិទ្ធិ, ការលើកកម្ពស់ការចូលរួមរបស់សហគមន៍ក្នុងការការពារ និង ស្តារព្រៃឈើឡើងវិញ; ព្រមទាំងការបង្ក្រាបបទល្មើសព្រៃឈើ និង ការជួញដូរសត្វព្រៃ ។

ទី៤- ការបន្តជំរុញការអភិរក្ស និង គ្រប់គ្រងធនធានជលផល តាមរយៈការបង្ក្រាបបទល្មើសជលផល, ការធ្វើឱ្យប្រសើរឡើងនូវសហគមន៍នេសាទ និង ការបង្កើនវារីវប្បកម្ម ។

ទី៥- ការលើកកម្ពស់ការថែរក្សាប្រព័ន្ធអេកូឡូស៊ី និង ការការពារតំបន់ធម្មជាតិ ដោយផ្តោតលើការការពារជីវចម្រុះ តំបន់ដីសើម និង តំបន់ឆ្នេរ ដើម្បីធានាគុណភាពដី និង ចីរភាពប្រភពទឹក ។

ទី៦- ការបន្តអភិរក្ស និង អភិវឌ្ឍបេតិកភណ្ឌវប្បធម៌ ដោយជំរុញការចុះបញ្ជី, ពង្រឹងការគ្រប់គ្រង, ការសិក្សាស្រាវជ្រាវ និង ចងក្រង ព្រមទាំងការបង្កើតតម្លៃពីបេតិកភណ្ឌវប្បធម៌ ។

### មុំទី ៣. ការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺអភិវឌ្ឍទីក្រុងដើម្បីឱ្យមានបរិស្ថានល្អ សម្រាប់ការរស់នៅ និង មានសាភ័ណភាព ព្រមទាំងលើកកម្ពស់សុខុមាលភាពរបស់ប្រជាជន និង ប្រសិទ្ធភាពសង្គម- សេដ្ឋកិច្ច ។

ជាលទ្ធផល, រាជរដ្ឋាភិបាលបានអនុម័ត និង ដាក់ឱ្យអនុវត្តនូវគោល-

នយោបាយជាតិស្តីពីការរៀបចំដែនដី; បានរៀបចំចក្ខុវិស័យនៃយុទ្ធសាស្រ្តតម្រង់ទិសអភិវឌ្ឍរាជធានីភ្នំពេញ; បានដាក់ឱ្យអនុវត្តប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញឆ្នាំ ២០៣៥; បានអភិវឌ្ឍប្លង់នគរូបនីយកម្ម និង កំពុងកសាងទីរួមខេត្តត្បូងឃ្មុំ; បានអនុម័តប្លង់គោលប្រើប្រាស់ដី នៅខេត្តព្រះសីហនុ និង ខេត្តបាត់ដំបង; បានអនុម័តគោលនយោបាយជាតិស្តីពីលំនៅឋាន និង គោលនយោបាយស្តីពីការលើកទឹកចិត្ត និង ការបង្កើតកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ; បានសាង-សង់លំនៅឋានតម្លៃសមរម្យមួយចំនួន ក្នុងរាជធានីភ្នំពេញ និង ខេត្តកណ្តាល; បានរៀបចំប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងទិន្នន័យសំណង់ ដោយតភ្ជាប់នឹងប្រព័ន្ធព័ត៌មានភូមិសាស្រ្តរបស់កម្មវិធី Google Map; និង បានផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដីសម្បទានសង្គមកិច្ច និង សាងសង់ផ្ទះជូនគ្រួសារយោធិន និង នគរបាល, គ្រួសារអតីតយុទ្ធជនពលី ពិការ មរណៈ និង បាត់បង់សមត្ថភាពការងារ ដែលមានជីវភាពក្រីក្រ, គ្មានដីគ្មានផ្ទះ កំពុងឈរជើងតាមបណ្តោយព្រំដែន ។

ទន្ទឹមនេះ, រាជរដ្ឋាភិបាលនៅជួបបញ្ហាប្រឈមមួយចំនួន រួមមាន : ប្លង់-គោលប្រើប្រាស់ដី និង យុទ្ធសាស្រ្តតម្រង់ទិសអភិវឌ្ឍនៅមិនទាន់ត្រូវបានសិក្សាចប់ និង អនុម័តសម្រាប់ខេត្តក្រុងភាគច្រើន; ការតាំងទីលំនៅមិនទាន់មានសណ្តាប់ធ្នាប់ល្អនៅឡើយ; ការរំលោភយកចំណីផ្លូវ; ការរំលោភបំពានលើបឹងធម្មជាតិ ដីគម្របព្រៃ និង ការចាប់យកដីសាធារណៈ នៅមិនទាន់ត្រូវបានដោះស្រាយបានល្អនៅឡើយ; ផែនការមេអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តទីក្រុង មិនទាន់ត្រូវបានរៀបចំឱ្យមានភាពប្រទាក់ក្រឡា; ការដឹកជញ្ជូន និង ចរាចរណ៍នៅក្នុងក្រុង មិនទាន់មានសណ្តាប់ធ្នាប់ល្អ ដែលធ្វើឱ្យមានការខាតបង់ខាងសង្គម និង សេដ្ឋកិច្ច; និង ការ-មិនទាន់រៀបចំបាននូវក្របខណ្ឌច្បាស់លាស់ សម្រាប់លើកកម្ពស់សោភ័ណភាព

និង អភិរក្សសំណង់ប្រវត្តិសាស្រ្ត នៅក្នុងក្រុង ។

ក្នុងនីតិកាលទី ៦ នៃរដ្ឋសភា, រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ÷

ទី១- ការបន្តជំរុញដំណើរការកែទម្រង់ដីធ្លី និង ការបង្កើនល្បឿននៃការកសាងផែនការមេ និង ប្លង់គោលនៃការរៀបចំដែនដី នគរូបនីយកម្ម និង សំណង់, ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, ក្នុងគោលដៅគ្រប់គ្រង និង អភិវឌ្ឍវិស័យដីធ្លីឱ្យកាន់តែមានប្រសិទ្ធភាព ។

ទី២- ការពង្រឹងសមត្ថភាពអនុវត្តការងារនគរូបនីយកម្ម, ការងារប្លង់គោលប្រើប្រាស់ដីរាជធានី, ការកសាងប្លង់គោលប្រើប្រាស់ដីក្រុង ស្រុក- ខណ្ឌ ឃុំ- សង្កាត់នៅទូទាំងរាជធានី- ខេត្ត, ការរៀបចំយុទ្ធសាស្រ្តតម្រង់ទិសក្នុងការកំណត់បែងចែកតំបន់ប្រើប្រាស់ និង ការគ្រប់គ្រងលំនៅឋានដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ។

ទី៣- ការរៀបចំផែនការមេអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុង និង ទីប្រជុំជនសំខាន់ៗ សម្រាប់គាំទ្រការអភិវឌ្ឍផ្លូវថ្នល់ ផ្លូវដែក និង ផ្លូវទឹក ក៏ដូចជាប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី និង ទឹកស្អាត និងជាពិសេសប្រព័ន្ធលូ និង ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ។

ទី៤- ការជំរុញការអភិវឌ្ឍវិស័យសំណង់ និង ការរៀបចំទីក្រុង ទីប្រជុំជន, ពិសេសក្រុងប៉ោយប៉ែត និង ក្រុងបាវិត, ដោយជំរុញការអភិវឌ្ឍ និង ពង្រឹងការ-អនុវត្តតាមច្បាប់ បទដ្ឋានគតិយុត្ត បច្ចេកទេស និង ស្តង់ដារសំណង់ ដែលធានាគុណភាព សុវត្ថិភាព សោភ័ណភាព ប្រសិទ្ធភាពខ្ពស់ និង គោលការណ៍ទីក្រុងឆ្លាតវៃ ព្រមទាំងជំរុញអនុវត្តកម្មវិធីអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ ។

ទី៥- ការបន្តពង្រឹងសោភ័ណភាព និង សេវាទីក្រុង ទីប្រជុំជនសំខាន់ៗតាមរយៈការគ្រប់គ្រងការប្រមូលសំរាម និង អនាម័យ, ការរៀបចំផ្លូវថ្មើរជើង,

ទីធ្លាចំណត, ការរៀបចំសួនច្បារសាធារណៈ, ការកសាង និង ការពារច្រាំងទន្លេ និង ទំនប់, ការរៀបចំសណ្ដាប់ធ្នាប់ និង ភ្លើងបំភ្លឺនៅក្នុងក្រុង, ការអភិរក្សសំណង់ដែលមានតម្លៃប្រវត្តិសាស្ត្រ ព្រមទាំងការបន្តរៀបចំពង្រីក និង ពង្រឹងគុណភាព ក៏ដូចជាជំរុញការប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈក្នុងទីក្រុង ។

### មុំទី៤. ការធានាចីរភាពបរិស្ថាន និង ការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺកាត់បន្ថយផលប៉ះពាល់បរិស្ថានជាអតិបរមា, ពង្រឹងសមត្ថភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ, និង ចូលរួមចំណែកក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុសកល ដើម្បីធានាការ-អភិវឌ្ឍប្រកបដោយចីរភាព ។

សមិទ្ធផលចម្បងៗដែលរាជរដ្ឋាភិបាលសម្រេចបាន រួមមាន : ការពង្រឹងសមត្ថភាពបច្ចេកទេស និង ស្ថាប័ន ក្នុងការគ្រប់គ្រងបរិស្ថាន; ការបញ្ជ្រាបការ-ប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយ បទដ្ឋានគតិយុត្ត និង ផែនការ, ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ; ការដាក់ចេញនូវវិធានការ ដើម្បីគ្រប់គ្រងការ-បំពុលបរិស្ថាន ធនធានទឹក និង ប្រព័ន្ធអេកូឡូស៊ី; ព្រមទាំងការបង្កើនសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យា, ការចូលរួមចំណែកក្នុងការផលិតថាមពលស្អាត និង កិច្ច-សហការជាមួយដៃគូអភិវឌ្ឍ ក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ។

បញ្ហាប្រឈមសំខាន់ៗ រួមមាន : ការកើនឡើងនៃការប្រើប្រាស់ធនធានធម្មជាតិ, ការថយចុះគុណភាពបរិស្ថាន, ទាំងទឹក ដី និង ខ្យល់, សមត្ថភាពយល់ដឹងក្នុងការបញ្ជ្រាបបច្ចេកវិទ្យាដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងកិច្ច-សហប្រតិបត្តិការ និង ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធនៅមានកម្រិត, និង មាន

តម្រូវការធានាសន្តិសុខទឹក និង សន្តិសុខថាមពលស្អាត ក្នុងរយៈពេលវែង ។

ក្នុងនីតិកាលទី ៦ នៃរដ្ឋសភា, រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ÷

ទី១- ការបន្តអនុវត្ត **«ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតង ២០១៣-២០៣០», «ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣»**, **«យុទ្ធសាស្ត្រ និង ផែនការសកម្មភាពបរិស្ថានជាតិ ២០១៦-២០២៣», «ផែនការយុទ្ធសាស្ត្រវេជបូកជាតិ»;** និង ការប្រើប្រាស់មូលនិធិបរិស្ថានសង្គមឱ្យមានប្រសិទ្ធភាព ដើម្បីធានាការអភិវឌ្ឍសេដ្ឋកិច្ចបំភាយកាបូនទាប និង ធន់នឹងការប្រែប្រួលអាកាសធាតុ ។

ទី២- ការបន្តពង្រឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ អភិរក្សជីវៈចម្រុះ អភិរក្សសម្បត្តិធម្មជាតិ ពិសេសប្រព័ន្ធអេកូឡូស៊ីបឹងទន្លេសាប ទន្លេមេគង្គ និង តំបន់ឆ្នេរ ។

ទី៣- ការបន្តពង្រឹងការគ្រប់គ្រងសំណល់រឹង រាវ ឧស្ម័ន និង សារធាតុគ្រោះថ្នាក់ តាមរយៈការអនុវត្តគោលការណ៍កាត់បន្ថយការប្រើប្រាស់ឡើងវិញ ការកែច្នៃឡើងវិញ និង ការបដិសេធ ព្រមទាំងការពង្រឹងយន្តការតាមដាន និង ត្រួតពិនិត្យការបំពុល ។

ទី៤- ការលើកកម្ពស់ការរស់នៅ ដោយមានប្រសិទ្ធភាព និង ចីរភាពធនធាន តាមរយៈការអនុវត្តគោលការណ៍នៃការប្រើប្រាស់ និង ផលិតកម្ម ប្រកបដោយចីរភាព (Sustainable Consumption and Production) ។

ទី៥- ការបង្កើនការប្រើប្រាស់បច្ចេកវិទ្យាភាតរបរិស្ថាន និង ភាតរអាកាស-ធាតុ (Environmentally-friendly and Climate-friendly Technologies) ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និង ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។

ទី៦- ការបន្តជំរុញការអនុវត្តយន្តការពាណិជ្ជកម្មកាបូន និង ក្របខណ្ឌគតិយុត្តពាក់ព័ន្ធ, ការពង្រឹងសមត្ថភាពរៀបចំ និង អនុវត្តវិធានការ ដើម្បីបន្សាំ និង ធន់ ទៅនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងការពិនិត្យលទ្ធភាពសិក្សាពីភាពធន់ផ្នែកហិរញ្ញវត្ថុ ក្នុងការឆ្លើយតបទៅគ្រោះមហន្តរាយបណ្តាលមកពីការប្រែ-ប្រួលអាកាសធាតុ ។

ទី៧- ការបន្តជំរុញការអភិវឌ្ឍ និង អនុវត្តផែ នការគ្រប់គ្រងទឹកចម្រុះ (Integrated Water Resource Management) ដើម្បីពង្រីកការផ្គត់ផ្គង់ទឹកបានគ្រប់គ្រាន់តាមតម្រូវការ, កាត់បន្ថយជាអតិបរមានូវហានិភ័យបណ្តាលមកពីគ្រោះ-ទឹកជំនន់ និង គ្រោះរាំងស្ងួត ព្រមទាំងធានាសន្តិសុខទឹករយៈពេលវែង ។

ទី៨- ការបន្តការលើកទឹកចិត្ត និង បង្កើនការវិនិយោគលើថាមពលស្អាត និង ថាមពលកកើតឡើងវិញ ពិសេសថាមពលពន្លឺព្រះអាទិត្យ ទន្ទឹមនឹងការកាត់បន្ថយការផលិតថាមពលពីប្រភពមិនស្អាត ដើម្បីធានាសន្តិសុខថាមពលរយៈពេលវែង ។

ទី៩- ការបន្តពង្រឹងក្របខណ្ឌគតិយុត្ត ព្រមទាំងការសិក្សាស្រាវជ្រាវ និង ការអភិវឌ្ឍសមត្ថភាពជំនាញ និង ចំណេះដឹង ដល់មន្ត្រីថ្នាក់ជាតិ និង ថ្នាក់ក្រោម-ជាតិ លើផ្នែកបរិស្ថាន ការអភិវឌ្ឍបៃតង ការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងធនធានទឹកចម្រុះ និង ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព ។

# សេចក្តីសន្និដ្ឋាន

ក្នុងរយៈពេល ១៥ ឆ្នាំ កន្លងទៅនេះ, កម្ពុជាបានអនុវត្តប្រកបដោយជោគជ័យនូវ **យុទ្ធសាស្រ្តចតុកោណ** ដំណាក់កាលទី ១, ទី ២, និងទី ៣, ដោយបានធ្វើឱ្យកម្ពុជាឈានឡើងទៅកាន់ដំណាក់កាលថ្មីមួយទៀត កាន់តែខ្ពស់ត្រដែត នៅលើវិថីនៃការអភិវឌ្ឍសង្គម- សេដ្ឋកិច្ច ។ តាមរយៈនេះ, កម្ពុជាសម្រេចបានសមិទ្ធផលសំខាន់ៗ ដែលមានអត្ថន័យជាប្រវត្តិសាស្រ្ត រួមមាន ÷

ទី១- ការធានាចីរភាពនៃសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម; ក៏ដូចជាការលើកស្ទួយនីតិរដ្ឋ ការលើកកម្ពស់សិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស; ការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស; ការលើកស្ទួយកិត្យានុភាពជាតិ ឱ្យខ្ពស់ត្រដែតនៅលើឆាកតំបន់ និង អន្តរជាតិ; ការការពារបានដោយឥតរវាតនូវអធិបតេយ្យជាតិ, ឯកភាពជាតិ និង បូរណភាពទឹកដី; ព្រមទាំងការពង្រឹងភាពជាដៃគូយុទ្ធសាស្រ្ត និង ការធានានូវផលប្រយោជន៍របស់ជាតិ នៅក្នុងកិច្ចសហប្រតិបត្តិការជាមួយដៃគូអន្តរជាតិ ។

ទី២- ការសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងអត្រាប្រមាណ ៧% ជាមធ្យមក្នុងមួយឆ្នាំ ក្នុងរយៈពេលជាងមួយទសវត្សរ៍ចុងក្រោយ, ប្រកបដោយចីរភាព បរិយាប័ន្ន និង ធន់នឹងវិបត្តិ, នៅលើមូលដ្ឋានកាន់តែទូលាយ និង មានសមត្ថភាពប្រកួតប្រជែង ព្រមទាំងមានផលិតភាព និង ការប្រើប្រាស់ក្នុងស្រុកខ្ពស់ជាងមុន, ក្នុងបរិការណ៍អត្រាអតិផរណាទាបជាង ៥% ជាមធ្យម ក្នុងមួយឆ្នាំ ដែលតាមរយៈនេះ បានធ្វើឱ្យកម្ពុជាប្រែក្លាយខ្លួន ពីប្រទេ សដែលមានចំណូលកម្រិតទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប ។

ទី៣- ការកាត់បន្ថយអត្រានៃភាពក្រីក្របានលើស ១% ក្នុងមួយឆ្នាំ, ការធ្លាក់ចុះនៃគម្លាតប្រាក់ចំណូលរបស់ប្រជាជន និង ការធានាកែលម្អសូចនាករសំខាន់ៗ ក្នុងវិស័យសង្គមកិច្ច ពិសេសក្នុងវិស័យអប់រំ សុខាភិបាល និង សមភាពយេនឌ័រ ។

ទី៤- ការបង្កើនវិសាលភាព ប្រសិទ្ធភាព និង គុណភាពសេវាសាធារណៈ ឱ្យកាន់តែប្រសើរឡើង ហើយទទួលបាននូវការជឿទុកចិត្តកាន់តែខ្លាំងឡើងពីសំណាក់ប្រជាជន ។

លើមូលដ្ឋាននេះ, រាជរដ្ឋាភិបាលនីតិកាលទី ៦ បានដាក់ចេញនូវ **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤** ដើម្បីឆ្លើយតបទៅនឹងបេសកកម្មជាប្រវត្តិសាស្ត្រដ៏ចម្បងពីរយ៉ាងរបស់ជាតិ គឺ : **ទីមួយ**- ការបន្តដំណើរទៅមុខក្នុងជំនឿដ៏មុតមាំ សំដៅសម្រេចឱ្យបានពេញលេញនូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាព និង **ទីពីរ**- ការបង្កើតឡើងនូវបុរេលក្ខខណ្ឌចាំបាច់ និង បរិស្ថានអនុគ្រោះ ដែលកសាងមូលដ្ឋានគ្រឹះរឹងមាំជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ ២០៣០ សម្រាប់ដំណើរការផ្លាស់ប្តូរស៊ីជម្រៅរបស់កម្ពុជា ឈានទៅសម្រេចចក្ខុវិស័យជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ ២០៥០ ។

ក្នុងគោលដៅនេះ, **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤** បានឆ្លុះបញ្ចាំងឱ្យឃើញយ៉ាងច្បាស់នូវរបៀបវារៈគោលនយោបាយសង្គម- សេដ្ឋកិច្ចកម្ពុជា សម្រាប់អនុវត្ត **កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា** ក្នុងរយៈពេល ៥ ឆ្នាំ ខាងមុខ ដែលផ្តោតទៅលើ **«គោលដៅជាយុទ្ធសាស្ត្រ ៤»** និង **«អាទិភាព ៤»** ដូចបានគូសបញ្ជាក់ពីខាងដើម ។ ដូច្នេះ, ក្នុងរយៈពេល ៥ ឆ្នាំខាងមុខ **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤** នឹងនាំកម្ពុជាឱ្យបន្តដំណើរប្រកបដោយជវភាព ឈានទៅមុខកាន់តែស្វាហាប់ ដោយឆ្លង

កាត់នូវរបត់ថ្មីៗ និង ការផ្លាស់ប្ដូរមុខមាត់ជាប្រវត្តិសាស្ត្រ នៅក្នុងទិដ្ឋភាពសំខាន់ៗ ដូចខាងក្រោម ÷

ទី១- ការថែរក្សាយ៉ាងខ្ជាប់ខ្ជួននូវសន្តិភាព ស្ថិរភាព និង សណ្ដាប់ធ្នាប់សាធារណៈនៅទូទាំងប្រទេស; ការបង្កើតបរិយាកាសអំណោយផលសម្រាប់ធុរកិច្ច ការវិនិយោគ និង ការអភិវឌ្ឍ; ការពង្រឹងភាពជាម្ចាស់, ភាពជាដៃគូក្នុងការអភិវឌ្ឍ, និង សហប្រតិបត្តិការអន្តរជាតិ, ពិសេសការពង្រឹងសមត្ថភាពកម្ពុជា សម្រាប់សមាហរណកម្មទៅក្នុងសេដ្ឋកិច្ចតំបន់ និង ពិភពលោក, ដោយខិតខំប្រើប្រាស់ឱ្យបានប្រកបដោយប្រសិទ្ធភាពខ្ពស់នូវបណ្ដាកាលានុវត្តភាព និង លក្ខខណ្ឌអំណោយ-ផលទាំងឡាយ ដែលកើតចេញមកពីកិច្ចដំណើរការទាំងអស់នេះ សំដៅទាញយកប្រយោជន៍ជាអតិបរមាសម្រាប់កម្ពុជា ។

ទី២- ការកែទម្រង់ដ៏ស៊ីជម្រៅទាំងឡាយ ដើម្បីអភិបាលកិច្ចល្អ ពិសេសការកែទម្រង់រដ្ឋបាលសាធារណៈ, ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការកែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ, ការកែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិ-ធម៌ និង ការកែទម្រង់វិស័យកងកម្លាំងប្រដាប់អាវុធ ។ កិច្ចការនេះ នឹងត្រូវបានឆ្លុះបញ្ចាំងតាមរយៈការពង្រឹងស្ថាប័នសាធារណៈ ពិសេសការពង្រឹងភាពជាអ្នកដឹកនាំ, សមត្ថភាព និង ប្រសិទ្ធភាពនៃស្ថាប័នសាធារណៈ, ព្រមទាំងការសម្រិតសម្រាំងរកមន្ត្រីមានសមត្ថភាពខ្ពស់ និង គុណវុឌ្ឍិល្អ សម្រាប់កាន់មុខតំណែងដឹកនាំនៅក្នុងមុខងារសាធារណៈ; ការកសាងរដ្ឋបាលស្អាតស្អំ; ការពង្រឹងស្ថាប័នយុត្តិធម៌ និង តុលាការ ពិសេសការលើកកម្ពស់សេវាយុត្តិធម៌ និង ការប្រយុទ្ធប្រឆាំងនឹងអំពើអយុត្តិធម៌ក្នុងសង្គម; និង ការជំរុញការអភិវឌ្ឍ និង លើកកម្ពស់សមត្ថភាពកងកម្លាំងប្រដាប់អាវុធជាតិកម្ពុជា ។

ទី៣- ការវិនិយោគលើ **«មូលធនមនុស្ស»** និង ការអភិវឌ្ឍប្រកបដោយចីរភាព ដែលផ្តោតលើការអភិវឌ្ឍធនធានមនុស្ស ទីផ្សារការងារ និង ការគាំពារសង្គម ព្រមទាំងនគរូបនីយកម្ម និង បរិស្ថាន ។ ដំណើរការនេះ, នឹងត្រូវបានអនុវត្តតាមរយៈការពង្រឹងគុណភាពវិស័យអប់រំ និង ជំនាញបច្ចេកទេស, ការលើកកម្ពស់ប្រសិទ្ធភាពផ្តល់សេវាសុខភាពសាធារណៈ, ការអភិវឌ្ឍទីផ្សារការងារ, ការពង្រឹងសមភាពយេនឌ័រ និង ការគាំពារសង្គម, ការឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី ៤, ការអភិវឌ្ឍនគរូបនីយកម្ម, ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព, ការធានាចីរភាពបរិស្ថាន និង ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ។ ការជំរុញអនុវត្តកិច្ចការទាំងនេះ នឹងអនុញ្ញាតឱ្យកម្ពុជាកសាងបាននូវមូលដ្ឋានគ្រឹះ សម្រាប់ជំរុញការអភិវឌ្ឍសង្គម- សេដ្ឋកិច្ច ប្រកបដោយចីរភាព និង បរិយាប័ន្ន ព្រមទាំងបន្តលើកស្ទួយសុខុមាលភាពរបស់ប្រជាជន ក្នុងបរិការណ៍ដែលកម្ពុជាកំពុងតែអាចទទួលបាននូវកាលានុវត្តភាពនៃការអភិវឌ្ឍពីផលលាភប្រជាសាស្ត្រ និង ការរីកចម្រើននៃបច្ចេកវិទ្យា ។

ទី៤- ការធ្វើពិពិធកម្មសេដ្ឋកិច្ច តាមរយៈការពង្រឹងហេដ្ឋារចនាសម្ព័ន្ធរូបវន្តឡូជីស្ទីក និង ថាមពល, ការអភិវឌ្ឍឧស្សាហកម្មគន្លឹះ ដោយផ្តោតលើការពង្រឹងផលិតភាព ការកែច្នៃ និង ការប្រកួតប្រជែង, ការជំរុញការអភិវឌ្ឍសហគ្រាសធុនតូច និង មធ្យម និង ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និង ធនាគារ ។ ដំណើរការនេះ នឹងពង្រីកបាននូវមូលដ្ឋានកំណើនសេដ្ឋកិច្ច, ផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច និង បង្កើនភាពធន់នឹងវិបត្តិ សំដៅឈានទៅជាប្រទេសមានមូលដ្ឋានឧស្សាហកម្មធំ និង រឹងមាំ, បង្កើនតម្លៃបន្ថែមខ្ពស់ក្នុងប្រព័ន្ធខ្សែច្រវាក់តម្លៃសកល និង ប្រែក្លាយវិស័យកសិកម្មទៅជាកសិកម្មបែបប្រពលកម្ម, មានផលិតភាពខ្ពស់

និង ផលិតសម្រាប់ធ្វើពាណិជ្ជកម្ម ។

ដូចនីតិកាលមុនដែរ«**កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា**» និង«**យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី ៤**» នឹងត្រូវបានអនុវត្តតាមរយៈ «**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិឆ្នាំ ២០១៩- ២០២៣**» ដែលនឹងត្រូវបានដាក់ចេញក្នុងពេលដ៏ឆាប់ខាងមុខ ។ ផែនការយុទ្ធសាស្ត្រនេះ នឹងកំណត់លម្អិតបន្ថែមនូវវិធានការ ផែនការសកម្មភាពតាមវិស័យ និង ការបញ្ជាក់នូវការទទួលខុស-ត្រូវអនុវត្តរបស់ក្រសួងស្ថាប័ន, ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ។ ទន្ទឹមនេះ, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក៏នឹងត្រូវរៀបចំនូវ «**យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមឆ្នាំ ២០១៩- ២០២៣**» ដែលជាមូលដ្ឋានសម្រាប់ធានាប្រសិទ្ធភាពនៃការគ្រប់គ្រងការប្រមូលចំណូល ដើម្បីឆ្លើយតបទៅនឹងតម្រូវការចំណាយរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី ៤** នេះ ។

បន្ថែមលើនេះ, ដើម្បីធានានូវការអនុវត្តប្រកបដោយប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាព និង នៅក្នុងភាពប្រទាក់ក្រឡាគ្នាគ្រប់ជ្រុងជ្រោយ, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវរៀបចំក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈរយៈ-ពេលមធ្យម សំដៅកំណត់តម្រូវការធនធាន និង ហិរញ្ញប្បទានរយៈពេលបីឆ្នាំរំកិលទៅមុខ ឱ្យបានជាក់លាក់ ។ បន្ទាប់មក, ក្រសួង- ស្ថាប័ននីមួយៗ, ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, ត្រូវរៀបចំ «**ផែនការយុទ្ធសាស្ត្រថវិកា**» របស់ខ្លួន ដើម្បីធានាការផ្សារភ្ជាប់ថវិកាទៅនឹងអាទិភាពគោលនយោបាយ ដែលមានចែងនៅក្នុង **យុទ្ធសាស្ត្រចតុកោណ** និង«**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ**» ដោយកំណត់ឱ្យកាន់តែច្បាស់លាស់ និង គ្រប់ជ្រុងជ្រោយ អំពីគោលបំណងគោលនយោបាយ ព្រមទាំងរចនាសម្ព័ន្ធកម្មវិធី ដែលនឹងត្រូវយកទៅអនុវត្តក្នុងក្របខណ្ឌនៃថវិកាសមិទ្ធកម្ម

ស្របតាម «**យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ ២០១៨- ២០២៥**» ។ ជាជំហានបន្ត, «**ផែនការយុទ្ធសាស្ត្រថវិកា**» របស់ក្រសួង- ស្ថាប័ន នឹងត្រូវបានយកទៅផ្សារផ្គងជាមួយក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និង ក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ពិចារណារៀបចំការវិភាជថវិកាប្រចាំឆ្នាំ ប្រកបដោយប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាព សំដៅឆ្លើយតបទៅនឹងអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល ។ ដូច្នេះ, ថវិកាប្រចាំឆ្នាំ គឺជាឧបករណ៍ចម្បងបំផុត សម្រាប់សម្រេចឱ្យបាននូវគោលដៅទាំងឡាយ ដែលត្រូវបានដាក់ចេញមកក្នុង «**យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាល ទី ៤**» ។ ក្នុងការអនុវត្តជាក់ស្តែង, ការតាមដានការត្រួតពិនិត្យ និង ការវាយតម្លៃការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ** នឹងត្រូវបានធ្វើឡើង ដោយប្រើប្រាស់យន្តការនៃការអនុវត្តថវិកា តាមរយៈការពង្រឹងការអនុវត្តថវិកាកម្មវិធី និង ការអនុវត្ត «**ថវិកាព័ត៌មានសមិទ្ធកម្ម**» ។

ផ្អែកលើសមិទ្ធផលសម្រេចបានកន្លងមក, ផ្អែកលើសក្តានុពលដ៏ធំធេងរបស់កម្ពុជា ឆន្ទៈដ៏មោះមុត និង ទេពកោសល្យរបស់ប្រជាជនកម្ពុជា, ព្រមទាំងផ្អែកលើសមត្ថភាពក្នុងការរៀនសូត្រ ការដកស្រង់នូវបទពិសោធន៍ ការតម្រឹម ការបន្ស៊ាំ និង ការចេះជ្រើសយកវិធានការចាំបាច់របស់រាជរដ្ឋាភិបាល និង របស់ប្រជាជនកម្ពុជាទាំងមូល, រួមជាមួយនឹងយុទ្ធសាស្ត្រដ៏ត្រឹមត្រូវដែលបានដាក់ចេញមកនេះ; រាជរដ្ឋាភិបាលមានជំនឿយ៉ាងមុតមាំថា កម្ពុជានឹងជម្នះបាននូវបញ្ហាប្រឈម និងឧបសគ្គទាំងឡាយ នៅលើមាគ៌ាឆ្ពោះទៅកាន់វឌ្ឍនភាព វិបុលភាព និង ភាពថ្កើងថ្កាន រុងរឿង ហើយកសាងបានដោយជោគជ័យនូវមូលដ្ឋានគាំទ្រសំខាន់ៗសម្រាប់ឈានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ២០៥០ ។

## គំនូសបំព្រួញស្តីពី «យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី ៤»
## ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព : កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០



# រាជរដ្ឋាភិបាលកម្ពុជា

# យុទ្ធសាស្ត្របញ្ចកោណ

## ដំណាក់កាលទី ១

## ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និង ចីរភាព
## កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០

## រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា

ធ្វើនៅ រាជធានីភ្នំពេញ, ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧
ត្រូវនឹង ខែសីហា គ្រិស្តសករាជ ២០២៣

# យុទ្ធសាស្ត្របញ្ចកោណ

## ដំណាក់កាលទី ១

## ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និង ចីរភាព

## កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេច

## ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០

ធ្វើនៅ រាជធានីភ្នំពេញ ខែស្រាពណ៍ ឆ្នាំថោះ ពុទ្ធសករាជ ២៥៦៧

ត្រូវនឹង ខែសីហា គ្រិស្តសករាជ ២០២៣

# មាតិកា

**សេចក្តីផ្តើម** ១

**ផ្នែកទី ១**

១.១. សមិទ្ធផលធំៗ រយៈពេល ២៥ ឆ្នាំ កន្លងមក ៧

១.២. និន្នាការសកលធំៗ ១៤

១.៣. បញ្ហាប្រឈម ១៩

១.៤. កាលានុវត្តភាព ២២

១.៥. ការសម្លឹងទៅមុខ ២៥ ឆ្នាំ ឆ្ពោះទៅសម្រេច ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០ ២៤

១.៦. ភាពចាំបាច់ក្នុងការរៀបចំយុទ្ធសាស្ត្របញ្ចកោណ ២៦

**ផ្នែកទី ២**

២.១. រចនាសម្ព័ន្ធ ៣៥

២.២. ស្នូល ៣៥

២.៣. បរិស្ថានគ្របដណ្តប់ ៤២

២.៤. បញ្ចកោណយុទ្ធសាស្ត្រ ទាំង ៥ ៥១

២.៥. កម្មវិធីគោលនយោបាយអាទិភាព ទាំង ៦ ៩៦

**ផ្នែកទី ៣**

៣.១. យន្តការជំរុញការអនុវត្ត ៩៩

៣.២. យន្តការស្ថាប័នដឹកនាំសម្របសម្រួល ១០០

៣.៣. យន្តការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃ ១០២

**សន្និដ្ឋាន** ១០៥

**គំនូសបំព្រួញស្តីពីយុទ្ធសាស្ត្របញ្ចកោណ**

## សេចក្តីផ្តើម

ក្នុងរយៈពេល ២៥ ឆ្នាំចុងក្រោយ បន្ទាប់ពីការសម្រេចបាននូវ សុខសន្តិភាពពេញលេញ, ឯកភាពជាតិ និង ឯកភាពទឹកដីទាំងស្រុង តាមរយៈ **នយោបាយឈ្នះ-ឈ្នះ** របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**, រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តប្រកបដោយជោគជ័យនូវ **យុទ្ធសាស្ត្រត្រីកោណ** និង **យុទ្ធសាស្ត្រចតុកោណ ទាំង ៤ ដំណាក់កាល**, ដោយសម្រេចបានសមិទ្ធផលធំៗ លើគ្រប់វិស័យ, ទាំងនយោបាយ, សង្គម, និង សេដ្ឋកិច្ច ដែលនាំឱ្យកម្ពុជាសម្រេចបាននូវការផ្លាស់ប្តូរមុខមាត់ថ្មី គួរជាទីមោទនៈបំផុត ។

ជាក់ស្តែង, កម្ពុជា ដែលពីមុនធ្លាប់ត្រូវបានហែកហួរ ដោយសង្គ្រាម និង ធ្លាប់តែល្បីថា ជាវាលពិឃាត, ជាតំបន់អសន្តិសុខ និង ជាចម្ការមីន ដែលគេភ័យខ្លាចគ្រប់គ្នា, បានក្លាយទៅជារដ្ឋអធិបតេយ្យ និង ឯករាជ្យ ដែលមានសន្តិភាព, មាននីតិរដ្ឋ និង ស្ថិរភាពនយោបាយ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស, និង មាន **ព្រះមហាក្សត្រ** គង់ប្រថាប់ជាម្លប់ជាទីគោរពសក្ការៈ ។ កម្ពុជាដែលពីមុនធ្លាប់តែត្រូវបានហ៊ុមព័ទ្ធ និង ឯកោ, ទាំងនយោបាយ និង សេដ្ឋកិច្ច, ឥឡូវ មានសមាហរណកម្មពេញលេញ ក្នុងរចនាសម្ព័ន្ធ និង និម្មាបនកម្ម តំបន់ និង សកល, និង បានដើរតួយ៉ាងសំខាន់ ក្នុងការរក្សាសណ្តាប់ធ្នាប់ តំបន់ និង សកល ក៏ដូចជា ការការពារសន្តិភាពនៃសកលលោក ។ ប្រជាជនកម្ពុជារាប់លាននាក់ បានចាកផុតពីភាពក្រីក្រ និង កំពុងរស់នៅជាមួយនឹងជីវភាពសមរម្យ, មានចំណេះដឹង, មានសុខុមាលភាពកាន់តែប្រសើរ ហើយអាយុកាលសង្ឃឹមរស់ជាមធ្យម បានកើនឡើងគួរឱ្យកត់សម្គាល់ ។

មូលដ្ឋានសេដ្ឋកិច្ចកម្ពុជា ក៏បានប្រែប្រួលពីប្រទេសដែលពឹងផ្អែកស្ទើរទាំងស្រុង ទៅលើវិស័យកសិកម្មបែបប្រពៃណី ទៅជាប្រទេសមានមូលដ្ឋានសេដ្ឋកិច្ចទូលាយ និង រឹងមាំ ដែលអាចចាប់យកឧស្សាហកម្មថ្មីៗ និង មានតម្លៃបន្ថែមខ្ពស់ ។ កម្ពុជាដែលពីមុនមានវិបត្តិខ្វះសាច់ប្រាក់រ៉ាំរ៉ៃ និង ត្រូវពឹងផ្អែក

ស្ទើរទាំងស្រុងទៅលើជំនួយបរទេស ទើបអាចរស់រានបាន, ឥឡូវបានក្លាយជាប្រទេសមានស្វ័យភាព និង ភាពម្ចាស់ការពេញលេញផ្នែកហិរញ្ញវត្ថុ នៅក្នុងការ-កំណត់ជោគវាសនា និង អនាគតរបស់ខ្លួន ។ ដួងព្រលឹងនៃមរតកសិល្បៈវប្បធម៌ខ្មែរ, ទាំងរូបី និង អរូបី, ដែលធ្លាប់ត្រូវបានលួច, បាត់បង់ ឬ ខូចខាត ដោយសារសង្គ្រាម, ឥឡូវត្រូវបានស្តារ ឱ្យរស់ និង លើកស្ទួយឡើងវិញ ជាបេតិកភណ្ឌជាតិ និង បេតិកភណ្ឌពិភពលោក ក៏ដូចជាត្រូវបានទទួលស្គាល់ និង ជូនត្រឡប់មកកាន់មាតុភូមិកំណើតវិញ ។ បន្ថែមលើនេះ, ស្នាដៃធំៗ និង ថ្មីៗ របស់រាជរដ្ឋា-ភិបាល រួមមាន ការគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩, ជោគជ័យនៃការទទួលធ្វើជាប្រធានអាស៊ានជាលើកទី ៣ ក្នុងប្រវត្តិសាស្ត្រ ដោយបានដឹកនាំកិច្ចប្រជុំកំពូលអាស៊ាន និង កិច្ចប្រជុំកំពូលពាក់ព័ន្ធ ដោយផ្ទាល់ ក្រោយពីវិបត្តិជំងឺកូវីដ-១៩, ព្រមទាំងជោគជ័យនៃការធ្វើជាម្ចាស់ផ្ទះនៃការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ និង ការប្រកួតកីឡាអាស៊ានប៉ារ៉ាហ្គេមលើកទី ១២ គឺជាទឡ្ហីករណ៍មិនអាចប្រកែកបានមួយចំនួនទៀតនៃការរីកចម្រើន ប្រកបដោយមោទនភាពរបស់កម្ពុជា ។

ជារួម, **យុទ្ធសាស្ត្រត្រីកោណ** និង **យុទ្ធសាស្ត្រចតុកោណទាំង ៤ ដំណាក់កាល** បានបំពេញតួនាទីយ៉ាងប្រសើរ, ជារបៀបវារៈគោលនយោបាយអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ដែលបានផ្ដល់នូវក្របខ័ណ្ឌរួម សម្រាប់ការ-កសាងស្ថាប័នរដ្ឋមួយ រឹងមាំ និង ឯករាជ្យ, ដែលប្រព័ន្ធអភិបាលកិច្ចត្រូវបានធ្វើទំនើបកម្មជាប្រចាំ ឱ្យកាន់តែគ្រប់ជ្រុងជ្រោយ, មានភាពធន់ និង មានប្រសិទ្ធ-ភាព; និង សម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ក្នុងល្បឿនខ្ពស់ ដែលត្រូវបានទទួលស្គាល់, ទាំងក្នុងតំបន់ និង សកលលោក; ជាពិសេស សម្រាប់ការប្រែ-ក្លាយកម្ពុជា ជាប្រទេសចំណូលមធ្យមកម្រិតទាប ក្នុងរយៈពេលដ៏ខ្លី ជាមួយកំណើនសេដ្ឋកិច្ចខ្ពស់ និង ការកាត់បន្ថយភាពក្រីក្រយ៉ាងរហ័ស, ព្រមទាំងការ-ធ្វើសមាហរណកម្មដោយជោគជ័យ ទៅក្នុងតំបន់ និង សកលលោក ។

ជោគជ័យដ៏ធំធេង និង ត្រចះត្រចង់ខាងលើ បានមកពីកិច្ចខិតខំប្រឹង-ប្រែងយ៉ាងប្តូរផ្តាច់របស់រាជរដ្ឋាភិបាល ដែលប្រកាន់ខ្ជាប់នូវការតម្កល់ប្រយោជន៍ជាតិ និង ប្រជាជន ជាធំ, ព្រមទាំងការអនុវត្តការកែទម្រង់ជាប្រចាំ ដោយមានការគាំទ្រពីគ្រប់ដៃគូអភិវឌ្ឍន៍ និង តួអង្គពាក់ព័ន្ធ, ក៏ដូចជាការចូលរួមយ៉ាងសកម្មពីសំណាក់ប្រជាជនគ្រប់ស្រទាប់ជាន់ថ្នាក់ ។ កិច្ចប្រឹងប្រែង និង ការចូលរួមទាំងនេះ ក៏ជាមូលដ្ឋានដ៏រឹងមាំ ដែលអនុញ្ញាតឱ្យកម្ពុជារក្សាបានគត់មត់នូវសុខ-សន្តិភាព និង ស្ថិរភាពនយោបាយ, ហើយលើសពីនេះ ពង្រឹងភាពជាម្ចាស់លើជោគវាសនាប្រទេសជាតិ ព្រមទាំងលើកកម្ពស់វិបុលភាពជូនប្រជាជន ជាបន្តបន្ទាប់ មកទល់បច្ចុប្បន្ន ។

ពេលនេះ, ដំណើរការកសាងជាតិកម្ពុជា បានឈានដល់ដំណាក់កាលថ្មីមួយ នៅក្នុងបរិការណ៍នៃពិភពលោក ដែលកាន់តែប្រែប្រួល លំបាក និង មិនប្រាកដប្រជា ។ កម្ពុជាត្រូវប្រឈមនឹងបញ្ហាថ្មី ក្នុងអន្តរកាលឆ្ពោះទៅសម្រេចឋានៈជាប្រទេសមានចំណូលខ្ពស់ និង ត្រូវសម្របជាប្រចាំ តាមនិន្នាការប្រែ-ប្រួលសកល ដែលទាមទារនូវការយកចិត្តទុកដាក់ខ្ពស់ ចំពោះការលើកកម្ពស់ភាពជាអ្នកដឹកនាំ និង សមត្ថភាពស្ថាប័នគ្រប់កម្រិត ដោយផ្សារភ្ជាប់នឹងការធានាបាននូវគោលនយោបាយសមស្រប និង សមត្ថភាពអនុវត្តជាក់ស្តែង, លទ្ធផលការងារ និង ការទទួលខុសត្រូវ ។ ក្នុងបរិការណ៍នេះ, ទិសដៅការងារអាទិភាពសំខាន់ៗ មានជាអាទិ៍ : ការពង្រឹងអភិបាលកិច្ច, ប្រសិទ្ធភាព និង សមត្ថភាពស្ថាប័ន; ការទ្រទ្រង់កំណើន និង ការធ្វើទំនើបកម្មសេដ្ឋកិច្ច; ការបង្កើតការងារ, ទាំងគុណភាព និង បរិមាណ; ការលើកស្ទួយវិស័យឯកជន និង សហគ្រិនភាព; ការកសាងមូលធនមនុស្ស ដោយផ្តោតជាពិសេស លើគុណភាព វិស័យអប់រំ, សេវាសុខាភិបាល និង សីលធម៌សង្គម; ការលើកស្ទួយសេវាគាំពារសង្គម និងសុខុមាលភាពប្រជាជន, ជាពិសេស សម្រាប់គ្រួសារងាយរងហានិភ័យ និង ក្រុម-ជនងាយរងគ្រោះ; ការពង្រឹងគុណភាពនគរូបនីយកម្ម, ជាពិសេស ការកាត់-

បន្ថយគម្លាតរវាងទីក្រុង និង ជនបទ; ការពង្រឹងចីរភាព បរិស្ថាន និង ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ; ព្រមទាំងការជំរុញធ្វើបរិវត្តកម្មឌីជីថល, ទាំងក្នុងសង្គម និង សេដ្ឋកិច្ច ។

លើមូលដ្ឋាននេះ, ការគិតគូរអំពីរបៀបវារៈអភិវឌ្ឍសង្គម-សេដ្ឋកិច្ចសម្រាប់ដំណាក់កាលបន្ទាប់ គឺជាការសម្លឹងឆ្ពោះទៅសម្រេច **ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០** ដោយផ្អែកលើបទពិសោធ និង សមិទ្ធផល ២៥ ឆ្នាំកន្លងមក និង ការវាយតម្លៃប្រមើល សម្រាប់ ២៥ ឆ្នាំទៅមុខ, ដោយត្រូវរៀបចំជាយុទ្ធសាស្ត្រអនុវត្តសម្រាប់ ៥ ដំណាក់កាល ។ កន្លងមក, **យុទ្ធសាស្ត្រត្រីកោណ** និង **យុទ្ធ-សាស្ត្រចតុកោណ ទាំង ៤ ដំណាក់កាល** អាចត្រូវបានចាត់ទុកជាដំណាក់-កាលមួយនៃការកសាងជាតិ ដោយផ្តោតជាសំខាន់លើការស្តារ និង ការកសាងប្រទេស ដែលទើបងើបចេញពីសង្គ្រាម, ការរក្សាសុខសន្តិភាព និង សណ្តាប់ធ្នាប់សង្គម, ការធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធ និង និម្មាបនកម្ម តំបន់ និង សកល, ការអភិវឌ្ឍ និង ការរក្សាស្ថិរភាពសង្គម-សេដ្ឋកិច្ច, និង ការលើកកម្ពស់ជីវភាពប្រជាជន ។ សម្រាប់រយៈពេល ២៥ ឆ្នាំបន្ទាប់ ដែលជាវដ្តថ្មី, កម្ពុជាមានមហិច្ឆតាចង់លើកស្ទួយមោទនភាពជាតិឱ្យឈានកាន់តែខ្ពស់ឡើង ដូចសម័យអង្គរ តាមរយៈ ការកសាងជាតិមួយឱ្យរឹងមាំ, រស់រវើក, រុងរឿង និង មានវិបុល-ភាព ក្លាយជាប្រទេសមានចំណូលខ្ពស់ នៅត្រឹមឆ្នាំ ២០៥០ ។

ក្នុងក្របខ័ណ្ឌនៃទស្សនវិស័យនេះ និង ផ្អែកតាម **កម្មវិធីនយោបាយសម្រាប់នីតិកាលទី ៧ នៃរដ្ឋសភា**, រាជរដ្ឋាភិបាលដាក់ចេញនូវ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និង ចីរភាព**, ដោយបន្តផ្តោតជាសំខាន់លើរបៀបវារៈ ធានា **"ប្រសិទ្ធភាពសមិទ្ធកម្ម"** តាមរយៈការអនុវត្តអភិក្រម **"ឆ្លុះកញ្ចក់, ងូតទឹក, ដុសក្អែល, ព្យាបាល និង វះ-កាត់"** និង អភិក្រម **"ជវភាពនៃប្រព័ន្ធតួអង្គតែមួយ"** (Dynamics of Stakeholder System) ។ ទន្ទឹមនេះ, **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១** កំណត់យក

**អាទិភាពគន្លឹះ ៥** គឺ : "**មនុស្ស, ផ្លូវ, ទឹក, ភ្លើង** និង **បច្ចេកវិទ្យា**" ជាពិសេស គឺ "**បច្ចេកវិទ្យាឌីជីថល**" សម្រាប់ឆ្លើយតបទៅនឹងបដិវត្តឧស្សាហកម្មទី ៤ និង បរិវត្តកម្មឌីជីថលនៃ សេដ្ឋកិច្ច និង សង្គម កម្ពុជា ព្រមទាំងតម្រូវការក្នុងការលើកកម្ពស់ផលិតភាពសេដ្ឋកិច្ច ដែលជាគ្រឹះ និង មធ្យោបាយដ៏សំខាន់ នៃការសម្រេចបាន **ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០** ។ គោលដៅចម្បងនៃយុទ្ធសាស្ត្រនេះរួមមាន ម្យ៉ាង, រក្សាចលនាការណ៍នៃសុខសន្តិភាព, កំណើនសេដ្ឋកិច្ច និង ការអភិវឌ្ឍជារួម; និង ម្យ៉ាងទៀត, កសាង និង ពង្រឹងមូលដ្ឋានគ្រឹះសម្រាប់ជំរុញសម្ទុះនៃការអភិវឌ្ឍ ប្រទេសជាតិ តាមរយៈ ការកសាងភាពធន់នៃវិស័យទាំង ៥ រួមមាន : ភាពធន់នៃវិស័យសាធារណៈ, វិស័យសេដ្ឋកិច្ច, វិស័យហិរញ្ញវត្ថុ, វិស័យមូលធនមនុស្ស និង សង្គម, និង ភាពធន់នៃវិស័យបរិស្ថាន និង ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ។

សរុបសេចក្តីមក, **កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា** និង **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** នឹងរួមគ្នាបំពេញតួនាទីជាក្របខ័ណ្ឌគោលនយោបាយគ្រប់ជ្រុងជ្រោយ សម្រាប់រៀបចំ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ឆ្នាំ ២០២៤-២០២៨, ផែនការអភិវឌ្ឍតាមវិស័យ** និង **ផែនការពាក់ព័ន្ធផ្សេងទៀត** ដែលមានកំណត់សូចនាករ និង ក្របខ័ណ្ឌពេលច្បាស់លាស់ ។ ទន្ទឹមនេះ, **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ក៏ដើរតួបន្ថែមជាមគ្គុទេសក៍តម្រង់ទិសការអនុវត្ត ដល់គ្រប់តួអង្គពាក់ព័ន្ធ ស្របតាមអភិក្រម "**ជវភាពនៃប្រព័ន្ធតួអង្គតែមួយ**", ដោយរួមបញ្ចូលផងដែរ នូវ យន្តការជំរុញការអនុវត្ត, ការតាមដាន, ការត្រួតពិនិត្យ និង ការវាយតម្លៃ ដែលនឹងត្រូវបានកំណត់ដាក់ចេញ នៅក្នុងយុទ្ធសាស្ត្រនេះ ។

នៅក្នុងខ្លឹមសារនេះ, **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១** គឺជា**របៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច** នៃ **កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា** នៅក្រោមដំបូលនៃរដ្ឋធម្មនុញ្ញ និង ក្រោម

ម្លប់ដ៏ត្រជាក់នៃអង្គ **ព្រះមហាក្សត្រ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៃព្រះរាជា-
ណាចក្រកម្ពុជា ។

## ផ្នែកទី ១

### ១.១. សមិទ្ធផលធំៗ រយៈពេល ២៥ ឆ្នាំកន្លងមក

កម្ពុជាសម្រេចបានសមិទ្ធផល និង បរិវត្តកម្មសំខាន់ៗ ជាច្រើន លើគ្រប់វិស័យ, ទាំងខាងនយោបាយ, សន្តិសុខ, សណ្ដាប់ធ្នាប់សង្គម និង ទាំងខាងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច, ទោះបីជាត្រូវប្រឈមនឹងសភាពការណ៍ ប្រែប្រួលផ្ទៃកនយោបាយ និង បញ្ហាប្រឈមថ្មីៗ ពាក់ព័ន្ធនឹងវិបត្តិសុខភាពសាធារណៈធ្ងន់ធ្ងរ, ជម្លោះភូមិសាស្ត្រនយោបាយសកល កាន់តែស្រួចស្រាល់, ព្រមទាំងភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកល, ការគំរាមចំពោះអធិបតេយ្យជាតិ និងបូរណភាពទឹកដី, គ្រោះធម្មជាតិផ្ទួនៗ, និង តម្រូវការដោះស្រាយសំណូមពររបស់ប្រជាជនគ្រប់ស្រទាប់ ។ ក្នុងការអនុវត្ត **យុទ្ធសាស្ត្រត្រីកោណ** និង **យុទ្ធ-សាស្ត្រចតុកោណ ទាំង ៤ ដំណាក់កាល** រយៈពេល ២៥ ឆ្នាំកន្លងមក, រាជរដ្ឋា-ភិបាលសម្រេចបាននូវសមិទ្ធផលធំៗ ដូចខាងក្រោម ៖

### ផ្ទៃកនយោបាយ និង ការទូត

តាមរយៈ **នយោបាយឈ្នះ-ឈ្នះ**, កម្ពុជា សម្រេច និង រក្សាបាននូវចីរភាពនៃសុខសន្តិភាពពេញលេញ ចាប់តាំងពីចុងឆ្នាំ ១៩៩៨; ក៏ដូចជា រក្សាការពារបានយ៉ាងរឹងមាំនូវអធិបតេយ្យ, សណ្ដាប់ធ្នាប់សង្គម, សន្តិសុខ, សុវត្ថិភាពសង្គម និង ស្ថិរភាពនយោបាយ ដោយប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍នីតិរដ្ឋ និង លទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស; ការពង្រឹងសាមគ្គីភាពផ្ទៃក្នុង; ការទប់ស្កាត់ដោយជោគជ័យប្រឆាំងនឹងឧបាយកលនានា ដើម្បីផ្ដួលរំលំរាជ-រដ្ឋាភិបាលស្របច្បាប់; ការការពារប្រទេសជាតិ មិនឱ្យធ្លាក់ចូលក្នុងកលិយុគ; ការប្រយុទ្ធប្រឆាំងនឹងវិបត្តិខាងក្រៅ; និង ការរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច; ដែលទាំងអស់នេះ គឺជាបុរេលក្ខខណ្ឌមិនអាចខ្វះបាន និង ជាមូលដ្ឋានដ៏រឹងមាំសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមជាតិ ។ លើឆាកអន្តរជាតិ និង ការទូត, កម្ពុជាបានកសាងទំនាក់ទំនងយ៉ាងជិតស្និទ្ធ និង កិច្ចសហប្រតិបត្តិការដ៏ល្អ

ជាមួយបណ្ដាប្រទេសជាច្រើនលើសកលលោក; និង បានដើរតួនាទីកាន់តែសកម្ម និង សំខាន់ ក្នុងកិច្ចការតំបន់ និង សកល ដោយស្មើភាព និង ស្មើសិទ្ធិ; ព្រមទាំងទទួលបាននូវទំនុកចិត្ត និង ការគាំទ្រឱ្យដឹកនាំយន្តការពហុភាគីនានានៅក្នុងការជំរុញរបៀបវារៈសន្តិភាព, សន្តិសុខ និង ការអភិវឌ្ឍ ប្រកបដោយចីរភាព នៅក្នុងតំបន់ និង សកលលោក ។ កិត្យានុភាពកម្ពុជាបានលេចឡើងកាន់តែខ្ពស់ តាមរយៈ សកម្មភាពដឹកនាំ និង ការចូលរួមចំណែកសំខាន់ៗ ដូចជាការធ្វើជាប្រធានអាស៊ាន ជាលើកទី ៣ ក្នុងប្រវត្តិសាស្ត្រ ដោយបានដឹកនាំកិច្ចប្រជុំកំពូលអាស៊ាន និង កិច្ចប្រជុំកំពូលពាក់ព័ន្ធ ប្រកបដោយជោគជ័យ; ការទទួលធ្វើជាប្រធានសម្របសម្រួលនៃប្រទេសមានការអភិវឌ្ឍតិចតួច, អនុប្រធានមហាសន្និបាតអង្គការសហប្រជាជាតិ និង សមាជិកក្រុមប្រឹក្សាសង្គម-សេដ្ឋកិច្ចនៃអង្គការសហប្រជាជាតិ; និង ការបញ្ជូនកងកម្លាំងរក្សាសន្តិភាពសរុប ចំនួន ៨ ៦៧១ នាក់ ទៅបំពេញបេសកកម្មរក្សាសន្តិភាព នៅក្នុងប្រទេសជាច្រើន ។

### ផ្នែកសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ និង ប្រកបដោយចីរភាព ក្នុងអត្រាកំណើនជាមធ្យមប្រមាណជាង ៧% ក្នុងមួយឆ្នាំ សម្រាប់រយៈពេលជាង ២ ទសវត្សរ៍កន្លងមក ដែលនាំឱ្យកម្ពុជាសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប, កម្រិតជីវភាពប្រជាជនមានភាពប្រសើរឡើង ដែលឆ្លុះបញ្ចាំង តាមរយៈ ការកើនឡើងនៃទំហំផលិតផលក្នុងស្រុកសរុប (ផសស) ប្រមាណ ១០ ដង គឺពីប្រមាណ ៣,១១ ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ ១៩៩៨ ដល់ប្រមាណ ២៩,៦០ ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ ២០២២ ។ ជាមួយនេះ, ផសស សម្រាប់មនុស្សម្នាក់ បានកើនឡើងរហូតដល់ ៧ ដង គឺពីប្រមាណ ២៥៣ ដុល្លារអាមេរិក ក្នុងឆ្នាំ ១៩៩៨ ដល់ប្រមាណ ១ ៧៨៤ ដុល្លារអាមេរិក ក្នុងឆ្នាំ ២០២២; អត្រាភាពក្រីក្រធ្លាក់ចុះ នៅក្រោម ១០% នៅមុនវិបត្តិជំងឺកូវីដ-១៩ និង គម្លាតវិសមភាពសង្គមកាន់តែរួមតូច; រចនាសម្ព័ន្ធសេដ្ឋកិច្ច មាន

ការផ្លាស់ប្តូរពីសេដ្ឋកិច្ចពឹងផ្អែកជាចម្បងលើកសិកម្មប្រពៃណី ទៅជាសេដ្ឋកិច្ចទំនើបដែលពឹងផ្អែកលើកសិកម្មវៃឆ្លាត, ឧស្សាហកម្ម និង សេវាកម្ម, និង មានការតភ្ជាប់កាន់តែខ្លាំងទៅនឹងខ្សែច្រវាក់តម្លៃ និង ផ្គត់ផ្គង់ តំបន់ និង សកលរួម-ជាមួយនឹងការកើតមានឡើងនូវឧស្សាហកម្មថ្មីៗ ដែលមានតម្លៃបន្ថែមខ្ពស់, ព្រមទាំងការបន្តពង្រឹង និង ការពង្រីកពិពិធកម្មមូលដ្ឋានឧស្សាហកម្ម និង ពាណិជ្ជកម្មអន្តរជាតិ ជាពិសេស វឌ្ឍនភាពគួរជាទីមោទនៈនៃវិស័យកាត់ដេរ និង ទេសចរណ៍ និង ការកើនឡើងនៃទំហំពាណិជ្ជកម្មអន្តរជាតិ ។ ជាងនេះទៀត, ការរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ប្រសិទ្ធភាពនៃការអនុវត្តគោលនយោ-បាយថវិកា និង គោលនយោបាយរូបិយវត្ថុ, ការធានាបាននូវចីរភាពថវិកាជាតិ និង បរិយាបន្នហិរញ្ញវត្ថុ ក៏ដូចជា ការកៀរគរបានយ៉ាងច្រើននូវហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍ និង ការកសាងភាពជាដៃគូប្រកបដោយបរិយាបន្ន បានរួមចំណែកយ៉ាងសំខាន់ ដល់ការលើកកម្ពស់កំណើនសេដ្ឋកិច្ច និង ការ-បែងចែក និង ការប្រើប្រាស់ធនធាន ប្រកបដោយប្រសិទ្ធភាព ។

តាមរយៈ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ឯករាជ្យនៃថវិកាជាតិ ជាពិសេស ប្រសិទ្ធភាពនៃការកៀរគរចំណូល, ការអនុវត្តចំណាយថវិកា, និង ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ, ព្រមជាមួយនឹងចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ ក៏ត្រូវបានពង្រឹងកាន់តែមាំមួនឡើងជាលំដាប់ ។ ជាក់ស្តែង, ការប្រមូលចំណូលក្នុងស្រុកសរុប បានកើនឡើងពីប្រមាណ ២៤៧ លានដុល្លារអាមេរិក ឬ ៨% នៃ ផសស ក្នុងឆ្នាំ ១៩៩៨ ដល់ប្រមាណ ៦,៨ ប៊ីលានដុល្លារអាមេរិក ឬ ២៣% នៃ ផសស ក្នុងឆ្នាំ ២០២២ ។ ទន្ទឹមនេះ, ចំណាយសរុបបានបន្តកើនឡើងពីប្រមាណ ៤០៩ លានដុល្លារអាមេរិក ឬ ១៣% នៃ ផសស នៅឆ្នាំ ១៩៩៨ ដល់ប្រមាណ ៧,៩ ប៊ីលានដុល្លារអាមេរិក ឬ ២៧% នៃ ផសស នៅឆ្នាំ ២០២២ ដែលអនុញ្ញាតឱ្យរាជរដ្ឋាភិបាលអនុវត្តកម្មវិធីនយោបាយរបស់ខ្លួន បានប្រកបដោយប្រសិទ្ធភាព និង ប្រសិទ្ធផលខ្ពស់ ។ ច្បាប់ស្តីពីការគ្រប់គ្រងការប្រើ-

ប្រាស់ និង ការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ ត្រូវបានអនុម័ត និង ប្រកាសដាក់ឱ្យប្រើ នៅក្នុងឆ្នាំ ២០២០ រួមជាមួយនឹងការកែលម្អ និង ការពង្រឹងបន្ថែមជាបន្តបន្ទាប់ លើការងារគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ។ ជាមួយនេះ, សន្និធិបំណុលសាធារណៈក្រៅប្រទេស ក៏ត្រូវបានគ្រប់គ្រងឱ្យស្ថិតក្នុងកម្រិតទាប, ពោល គឺត្រឹមប្រមាណ ២៤,៩% នៃ ផសស នៅឆ្នាំ ២០២២, ដែលត្រូវបានទទួលស្គាល់ថា មានចីរភាព និង ហានិភ័យទាប ។

បន្ថែមលើនេះ, វិស័យហិរញ្ញវត្ថុ, ទាំងវិស័យធនាគារ និងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ, មានការរីកចម្រើនយ៉ាងរហ័សគួរឱ្យកត់សម្គាល់ ។ វិស័យធនាគារ ដែលពេលមុន ប្រជាជនមិនសូវទុកចិត្ត, ពេលនេះ បានក្លាយជាប្រព័ន្ធធនាគាររឹងមាំ និង មានស្ថិរភាព ដែលឆ្លុះបញ្ចាំងតាមរយៈដើមទុនរឹងមាំ, មានសន្ទនីយភាពគ្រប់គ្រាន់ និង មានកំណើនឥណទានសមស្រប ។ គិតត្រឹមឆ្នាំ ២០២២, ទ្រព្យសកម្មសរុប, ឥណទាន, និង ប្រាក់បញ្ញើ បានកើនឡើងដល់ ២៧៤%, ១៩៣%, និង ១៥០% រៀងគ្នា, ជាមួយនឹងទុនបម្រុងអន្តរជាតិត្រូវបានគរពូនជាលំដាប់ ដល់ ១៨ ប៊ីលានដុល្លារអាមេរិក; រូបិយវត្ថុចរាចរណ៍ក្នុងទីផ្សារ និង ប្រាក់បញ្ញើជារៀល បានកើនឡើងប្រមាណ ៥៥ ដង; ការប្រើប្រាស់ប្រព័ន្ធទូទាត់ បានកើនឡើងយ៉ាងរហ័ស ដោយទឹកប្រាក់ទូទាត់រាយតាមប្រព័ន្ធអេឡិចត្រូនិក មានទំហំស្មើនឹងប្រមាណ ១០ ដង នៃ ផសស ។ វិហូរវិនិយោគផ្ទាល់ពីបរទេសមានកំណើនគួរឱ្យកត់សម្គាល់, ពោល គឺបានកើនឡើងប្រមាណ ១៥ ដង ក្នុងចន្លោះឆ្នាំ ២០០៧-២០២២ ។ ដោយឡែក, វិស័យហិរញ្ញវត្ថុមិនមែនធនាគារ មានការវិវឌ្ឍយ៉ាងល្អ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ និងមានសក្តានុពលបន្តរីកចម្រើនយ៉ាងលឿនទៅមុខ ដែលឆ្លុះបញ្ចាំង តាមរយៈការកើនឡើងនៃអ្នកចូលរួមក្នុងទីផ្សារហិរញ្ញវត្ថុ; ចំនួន និង ប្រភេទផលិតផលហិរញ្ញវត្ថុ; វិហូរមូលធនវិនិយោគ; ការធ្វើសមាហរណកម្ម; និង ការកែទម្រង់យន្តការស្ថាប័ន, អភិបាលកិច្ច, ការគ្រប់គ្រង និង ការត្រួតពិនិត្យ លើវិស័យហិរញ្ញ-

វត្ថុមិនមែនធនាគារ តាមរយៈ ការបង្កើតអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ។ ជាក់ស្តែង, គិតត្រឹមពាក់កណ្តាល ឆ្នាំ ២០២៣, ក្រុមហ៊ុនចំនួន ១១ បានបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ, ហើយ ក្រុមហ៊ុនចំនួន ៩ បានបោះផ្សាយលក់មូលបត្របំណុល ដែលប្រមូលបានសាច់ប្រាក់ប្រមាណ ៣២៨,៣៨ លានដុល្លារអាមេរិក, ខណៈដែលមូលធនូបនីយកម្មទីផ្សារ មានទំហំប្រមាណ ១០,៣៧% នៃ ផសស ។ តម្លៃជួញដូរមូលបត្រគិតត្រឹមត្រីមាសទី ១ ឆ្នាំ ២០២៣ មានចំនួន ៣១០,៨ លានដុល្លារអាមេរិក ។ ក្នុងរយៈពេលដូចគ្នា, ក្រុមហ៊ុនធានារ៉ាប់រង មានសរុបចំនួន ៣៩ ដែលក្នុងនោះ ក្រុមហ៊ុនធានារ៉ាប់រងទូទៅមានចំនួន ១៨, ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត មាន ១៤ និង ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច មានចំនួន ៧ ។ ទំហំទីផ្សារធានារ៉ាប់រងរីកចម្រើនយ៉ាងឆាប់រហ័ស ដោយបុព្វលាភធានារ៉ាប់រង មានចំនួន ៣៣២ លានដុល្លារអាមេរិក និង មានកំណើន ២៨% ជាមធ្យមប្រចាំឆ្នាំ ។ ទន្ទឹមនេះ, កម្ពុជាបានបង្កើតទីផ្សារបរធនបាលកិច្ចជាមួយនឹងប្រតិបត្តិការពេញលេញ ដែលក្នុងនោះ បរធនបាលកិច្ចចុះបញ្ជីបានកើនដល់ចំនួន ៥៥៧ ករណី, ជាមួយទំហំបរធន ប្រមាណជា ១,១៣ ប៊ីលានដុល្លារអាមេរិក ។

## ផ្នែកស្ថាប័ន និង អភិបាលកិច្ច

កម្ពុជាសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្នុងការកែទម្រង់ស្ថាប័ន និង អភិបាលកិច្ច ។ ជាក់ស្តែង, វិស័យរដ្ឋបាលសាធារណៈ ជាពិសេស រចនាសម្ព័ន្ធក្រសួង-ស្ថាប័ន, ធនធានមនុស្ស, បៀវត្ស និង ប្រាក់សោធន ត្រូវបានកែលម្អជាលំដាប់ ដែលបានរួមចំណែកលើកកម្ពស់ប្រសិទ្ធភាពស្ថាប័ន និង សេវាសាធារណៈ ។ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានពង្រឹង តាមរយៈការបង្កើនភាពជឿទុកចិត្តបាននៃថវិកា, ការលើកកម្ពស់គណនេយ្យភាពហិរញ្ញវត្ថុ, ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ, និង ការពង្រឹងគណនេយ្យភាពសមិទ្ធកម្ម ដែលបានរួមចំណែកដល់ការលើកកម្ពស់ប្រសិទ្ធភាព នៃការផ្តល់

សេវាសាធារណៈផង និង ការគ្រប់គ្រងស្ថិរភាព ម៉ាក្រូសេដ្ឋកិច្ចផង ។ លើសពីនេះ, ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល និង ធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ត្រូវបានកែសម្រួលឱ្យប្រសើរឡើង, ជាពិសេស ការគ្រប់គ្រង និង ការអភិវឌ្ឍធនធានមនុស្ស, និង ការផ្ទេរមុខងារថវិកា និង ការទទួលខុសត្រូវ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ។ ជាមួយនេះ, ក្របខ័ណ្ឌច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ត្រូវបានកែទម្រង់ស៊ីជម្រៅ តាមរយៈ ការដាក់ឱ្យដំណើរការនូវសាលាឧទ្ធរណ៍តំបន់, ការលើកកម្ពស់សមត្ថភាពមន្ត្រីអនុវត្តច្បាប់ និង ស្ថាប័ន នៅក្នុងវិស័យយុត្តិធម៌, ការពង្រឹងប្រសិទ្ធភាពនៃយន្តការអធិការកិច្ច, ការលើកកម្ពស់យន្តការផ្តល់សេវាជំនួយផ្នែកច្បាប់, ការជំរុញការដោះស្រាយការកកស្ទះសំណុំរឿងព្រហ្មទណ្ឌនៅតាមសាលាដំបូងរាជធានី-ខេត្ត, និង ការលើកកម្ពស់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ។ កងកម្លាំងប្រដាប់អាវុធ ត្រូវបានកែទម្រង់, ជាពិសេស តាមរយៈ ការពង្រឹងសមត្ថភាពវិជ្ជាជីវៈ និង ការធ្វើទំនើបកម្មកងកម្លាំងប្រដាប់អាវុធ ។ ការប្រយុទ្ធប្រឆាំងអំពើពុករលួយ ត្រូវបានលើកកម្ពស់ តាមរយៈការបង្កើតស្ថាប័នប្រឆាំងអំពើពុករលួយ និង ការជំរុញអនុវត្ត វិធានការអប់រំ, ការបង្ការ, ការទប់ស្កាត់ និង ការបង្ក្រាបបទល្មើសពុករលួយ ។ អភិបាលកិច្ចវិស័យឯកជន និង ធុរកិច្ច ត្រូវបានពង្រឹង តាមរយៈ ការបង្កើតក្របខ័ណ្ឌនិយ័តកម្ម និង អភិបាលកិច្ចសាជីវកម្ម ។

### ផ្នែកហេដ្ឋារចនាសម្ព័ន្ធ និង ការតភ្ជាប់

ហេដ្ឋារចនាសម្ព័ន្ធ និង ការតភ្ជាប់ ត្រូវបានកែលម្អ និង ធ្វើទំនើបកម្មគួរឱ្យកត់សម្គាល់ ។ កម្ពុជាសម្រេចបានការសាងសង់ផ្លូវជាតិ និង ផ្លូវតាមខេត្ត ដោយក្រាលកៅស៊ូ និង បេតុង គ្រប់ប្រភេទ ប្រវែង ១១ ០៤២ គីឡូម៉ែត្រ, ផ្លូវល្បឿនភ្នំពេញ-ក្រុងព្រះសីហនុ ប្រវែង ១៨៧,៥ គីឡូម៉ែត្រ, ស្ពានតូច-ធំ គ្រប់ប្រភេទ ចំនួន ២ ៥៣០, ស្ពាន ប្រវែង ៨៦,២ គីឡូម៉ែត្រ, បណ្តាញផ្លូវនាវាចរណ៍តាមដងទន្លេមេគង្គ, ទន្លេសាប និង ទន្លេបាសាក់ ប្រវែង ១ ៧៥០ គីឡូម៉ែត្រ ។

ជាមួយគ្នានេះ, រាជរដ្ឋាភិបាលក៏បានពង្រីក និង ធ្វើទំនើបកម្មផងដែរ នូវហេដ្ឋា-រចនាសម្ព័ន្ធសំខាន់ៗផ្សេងទៀត, ជាពិសេស អាកាសយានដ្ឋាន, កំពង់ផែទឹក-ជ្រៅ, ផ្លូវនាវាចរណ៍, និង ប្រព័ន្ធឡូជីស្ទីក ។ ពាក់ព័ន្ធនឹងវិស័យថាមពល, អត្រាគ្របដណ្តប់នៃអគ្គិសនី នៅឆ្នាំ ២០២២ មានរហូតដល់ ៩០% ។ បន្ថែមលើនេះ, ហេដ្ឋារចនាសម្ព័ន្ធក្នុងវិស័យបច្ចេកវិទ្យាព័ត៌មាន ក៏មានការវិវឌ្ឍគួរឱ្យកត់សម្គាល់ តាមរយៈ ការកើនឡើងនៃការតភ្ជាប់បណ្តាញខ្សែកាបអុបទិកលើគោក និង ក្រោមបាតសមុទ្រ; ការកើនឡើងជាគំហុកនៃការប្រើប្រាស់សេវាទូរស័ព្ទ និង អ៊ីនធឺណិត; និង ការដាក់ឱ្យប្រើប្រាស់ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា, ថ្នាលផ្ទៀង-ផ្ទាត់ឯកសារ, ព្រមទាំងប្រព័ន្ធ និង កម្មវិធីបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់-គ្រងហិរញ្ញវត្ថុសាធារណៈ ។

### ផ្នែកសង្គម និង វប្បធម៌

វិស័យសង្គម និង វប្បធម៌ សម្រេចបានវឌ្ឍនភាពគួរជាទីមោទនៈ ។ វិស័យអប់រំ និង ការបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានកែទម្រង់ជាប្រចាំ និង សម្រេចបានសមិទ្ធផលជាច្រើន, ទាំងបរិមាណ និង គុណភាព, ដែលឆ្លុះបញ្ចាំង តាមរយៈ ការទទួលបានពានរង្វាន់អក្ខរកម្មពិភពលោកឆ្នាំ ២០២៣ និង ជ័យ-លាភីជាច្រើនរបស់សិស្ស-និស្សិត ក្នុងការប្រឡងប្រណាំងជាអន្តរជាតិ ។ វិស័យសុខភាពសាធារណៈ និង អាហារូបត្ថម្ភ ត្រូវបានកែលម្អ និង ពង្រឹង ដែលធ្វើឱ្យកម្ពុជាមានសមត្ថភាពពេញលេញ ក្នុងការប្រយុទ្ធឈ្នះវិបត្តិសុខភាពសាធារណៈនានា ដូចជា ការសម្រេចបានជោគជ័យខ្ពស់ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩; ការកាត់បន្ថយយ៉ាងខ្លាំងនូវអត្រាមរណភាព មាតា ទារក និង កុមារ, អត្រាឈឺ និង ស្លាប់ដោយជំងឺ និង អត្រាគ្រិនរបស់កុមារអាយុក្រោម ៥ ឆ្នាំ; ការកើនឡើងនៃអាយុកាលសង្ឃឹមរស់ជាមធ្យមរបស់ប្រជាជនកម្ពុជា ដល់ ៧៥,៥ ឆ្នាំ នៅឆ្នាំ ២០១៩; និង ការលុបបំបាត់ជំងឺចម្បងៗជាច្រើនទៀត ។ លើសពីនេះ, ប្រព័ន្ធគាំពារសង្គម ត្រូវបានពង្រឹង និង ពង្រីក ដែលបានជួយរក្សានូវលំនឹងជីវភាព

ប្រជាជនជាទូទៅ, ជាពិសេស នៅក្នុងគ្រាមានគ្រោះអាសន្ន ឬវិបត្តិនានា ដូចជាការរាតត្បាតនៃជំងឺកូវីដ-១៩ ជាដើម, តាមរយៈការអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម, ការកសាងប្រព័ន្ធគាំពារសង្គម, ការបង្កើតនិយ័តករ សន្តិសុខសង្គម និង មូលនិធិជាតិជំនួយសង្គម, និង ការលើកកម្ពស់អភិបាលកិច្ចល្អក្នុងវិស័យប្រព័ន្ធគាំពារសង្គម ។ ចំពោះផ្នែកយេនឌ័រ, តួនាទីរបស់ស្ត្រីកម្ពុជាត្រូវបានលើកកម្ពស់ជាបន្តបន្ទាប់ តាមរយៈ ការធ្វើស្ថាប័នូបនីយកម្ម និង ការបញ្ជ្រាបយេនឌ័រ ដែលធ្វើឱ្យកម្ពុជាទទួលបានចំណាត់ថ្នាក់ខ្ពស់បំផុត ជាប្រទេសផ្តល់សេរីភាពទូលំទូលាយសម្រាប់ស្ត្រី ។ ក្នុងវិស័យវប្បធម៌, មរតកសិល្បៈវប្បធម៌ដែលបានបាត់បង់ និង/ឬ ប្រឈមនឹងការបាត់បង់ ត្រូវបានស្តារឱ្យរស់ឡើងវិញ និង លើកកម្ពស់បន្ថែមទៀត ដែលបានស្នួយឱ្យខ្ពស់ត្រដែតនូវកិត្យានុភាពជាតិ ព្រមទាំងជំរុញទេសចរណ៍វប្បធម៌ និង ការអភិវឌ្ឍសិល្បៈវប្បធម៌របស់ជាតិ ។ ជាក់ស្តែង, បេតិកភណ្ឌវប្បធម៌ជាតិ សរុបចំនួន ១១ ត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក; បញ្ជីបេតិកភណ្ឌវប្បធម៌រូបីនៃមនុស្សជាតិ និង បញ្ជីស្មារតីចងចាំពិភពលោក; សំណង់បេតិកភណ្ឌ សរុបចំនួន ១៩៥ ត្រូវបានជួសជុល; វត្ថុបុរាណ សរុបចំនួន ៦៣៤ ត្រូវបានបញ្ជូនពីបរទេសត្រឡប់មកកម្ពុជា; វត្ថុបុរាណ ចំនួន ៦ ១០៥ ត្រូវបានជួសជុល និង អភិរក្ស; និង វត្ថុបុរាណ សរុបចំនួន ១១ ៨០៤ ដែលទទួលបានមកវិញ ត្រូវបានធ្វើប័ណ្ណកម្មសិទ្ធិរដ្ឋ ។ បន្ថែមលើនេះ, ការអភិវឌ្ឍឧស្សាហកម្មវប្បធម៌ និង ច្នៃប្រឌិត ក៏ត្រូវបានលើកកម្ពស់ជាប្រចាំផងដែរ ។

### ១.២. និន្នាការសកលធំៗ

#### ក. និន្នាការនយោបាយ

ភូមិសាស្ត្រនយោបាយសកល កំពុងស្ថិតក្នុងស្ថានភាពផុយស្រួយ និង ប្រឈមនឹងភាពតានតឹងខ្លាំងឡើង ដោយសារការប្រណាំងប្រជែងរវាងប្រទេសមហាអំណាចធំៗ ក៏ដូចជា ការបែកបាក់ និង ភាពប្រទាញគ្នារវាងនិន្នាការពហុ-

ប៉ូលសកលូបនីយកម្ម និង និន្នាការឯកប៉ូលគាំពារនិយម ដែលធ្វើឱ្យសណ្តាប់ធ្នាប់សកល នាអនាគត កាន់តែស្មុគស្មាញ និង ពិបាកធ្វើការវាយតម្លៃ ។ ជាងនេះទៀត, និន្នាការនេះ អាចជំរុញឱ្យមានចរន្តបដិសកលភាវូបនីយកម្ម ខណៈដែលចរន្តតំបន់និយមកំពុងក្លាយជានិន្នាការថ្មី ។ ការណ៍នេះ នឹងជះឥទ្ធិពលដល់ទំនាក់ទំនងសេដ្ឋកិច្ច, ពាណិជ្ជកម្ម, សន្តិសុខ, និង នយោបាយការទូត, ដែលធ្វើឱ្យប្រទេសកំពុងអភិវឌ្ឍ, មានសេដ្ឋកិច្ចតូច-បើកចំហ និង ពឹងផ្អែកលើការនាំចេញ, ទទួលរងផលប៉ះពាល់ខ្លាំងជាងគេ ។

និម្មាបនកម្មអន្តរជាតិ, ជាពិសេស អង្គការសហប្រជាជាតិ, កំពុងប្រឈមនឹងការបាត់បង់ទំនុកចិត្តពីប្រទេសសមាជិក នៅក្នុងការដោះស្រាយបញ្ហាប្រឈមនានា ក្នុងការថែរក្សាសន្តិភាព, សន្តិសុខ និង ស្ថិរភាព តំបន់ និង សកល ។ បន្ថែមលើនេះ, ការប្រកួតប្រជែងរវាងមហាអំណាច កំពុងធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់អន្តរជាតិ និង យន្តការពហុភាគីនិយម ក្នុងការដោះស្រាយបញ្ហាប្រឈមសកល, និង បានក្លាយជាការដាក់គំនាបលើការអនុវត្តគោលនយោបាយការបរទេស តាមគោលការណ៍អព្យាក្រឹតអចិន្ត្រៃយ៍ និង មិនចូលបក្សសម្ព័ន្ធ, និង ការអនុវត្តគោលនយោបាយសេដ្ឋកិច្ច, ហិរញ្ញវត្ថុ, ពាណិជ្ជកម្ម, និង បច្ចេកវិទ្យា, សម្រាប់បម្រើដល់ការអភិវឌ្ឍរបស់ប្រទេសកំពុងអភិវឌ្ឍ ដោយសារតែការកើនឡើងនៃការប្រើប្រាស់វិធានការបង្ខិតបង្ខំជាឯកតោភាគី និង ក្រៅដែនអធិបតេយ្យ និង ការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ដែលជាការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋអធិបតេយ្យ ក្រោមលេស និង ហេតុផល នៃគុណតម្លៃប្រជាធិបតេយ្យ និង សិទ្ធិមនុស្ស ។

ក្នុងស្ថានភាពបែបនេះ, ប្រទេសកំពុងអភិវឌ្ឍទាំងអស់ កំពុងមានការលំបាកខ្លាំងនៅក្នុងការរៀបចំ និង ការដឹកនាំកិច្ចអភិវឌ្ឍប្រទេស ប្រកបដោយចីរភាព, ដោយម្ខាង, ត្រូវរក្សាផលប្រយោជន៍ស្នូលរបស់ខ្លួន, និង ម្ខាងទៀត, ត្រូវសម្របខ្លួនទៅនឹងការចាប់បង្ខំឱ្យប្រកាន់យកជំហរនយោបាយការបរទេស

ដែលផ្អែកលើឆន្ទៈ និង ផលប្រយោជន៍ខ្លួន ដើម្បីឆ្លើយតបទៅនឹងតថភាពភូមិសាស្ត្រនយោបាយ ។ ថ្មីៗនេះ, ប្រទេសជាច្រើនបានងើបតវ៉ាប្រឆាំង ទៅនឹងសម្ពាធទាំងអស់នេះ ដោយខិតខំប្រមូលផ្តុំកម្លាំងសាមគ្គីភាពនៃក្រុមប្រទេសសកលខាងត្បូង (Global South) ។ សម្រាប់អនាគត, ការបន្តអនុវត្តនយោបាយការបរទេសឯករាជ្យ ដោយផ្អែកលើច្បាប់ និង ការកសាងមិត្តភាព និង កិច្ចសហប្រតិបត្តិការល្អ រវាងកម្ពុជាជាមួយប្រទេសទាំងអស់ នៅលើសកលលោក និង ជាមួយអង្គការអន្តរជាតិនានា ព្រមជាមួយនឹងការចូលរួមយ៉ាងសកម្ម ចំពោះបុព្វហេតុសន្តិភាព, ស្ថិរភាព, សន្តិសុខ និង វិបុលភាព ក្នុងតំបន់ និង ពិភពលោក ដោយភាពទន់ភ្លន់រស់រវើក និង ដោយប្រកាន់ខ្ជាប់នូវគោលការណ៍នៃ "**កិច្ចសហប្រតិបត្តិការអន្តរជាតិ ដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមក និង ផ្អែកលើវិធាននៃច្បាប់**" និង គោលការណ៍ "**ពហុភាគីនិយម និង ការលើកកម្ពស់ការបើកចំហពាណិជ្ជកម្មអន្តរជាតិ**" គឺជាអាទិភាព និង ជាយន្តការចាំបាច់ ដើម្បីស្វែងរកដំណោះស្រាយឈ្នះ-ឈ្នះ និង ធានាប្រយោជន៍របស់កម្ពុជា ឱ្យបានជាអតិបរមាពីការវិវត្តថ្មីៗនៃនយោបាយសង្គម-សេដ្ឋកិច្ចសកល ។

## ខ. និន្នាការភូមិសាស្ត្រសេដ្ឋកិច្ច

និម្មាបនកម្មសេដ្ឋកិច្ចសកលកំពុងប្រែប្រួលយ៉ាងខ្លាំង ដោយមជ្ឈភាពនៃកំណើនសកល កំពុងបន្តនិន្នាការងាកមករកតំបន់អាស៊ី ។ ទន្ទឹមនេះ, ក្រុមប្រទេសសេដ្ឋកិច្ចកំពុងរីកលូតលាស់, ជាពិសេស ក្រុមប្រទេស BRICS, ក៏កំពុងចូលរួមចំណែកដឹកមុខកំណើនសកល, ខណៈដែលសេដ្ឋកិច្ចរបស់បណ្តាប្រទេសលោកខាងលិច, ជាពិសេស ប្រទេសមហាអំណាចទាំង ៧ (G7), អាចនឹងបន្តថមថយ ។ បន្ថែមលើនេះ, និន្នាការគាំពារនិយម និង ការបែកខ្ញែកភូមិសាស្ត្រសេដ្ឋកិច្ច អាចនឹងបង្កើនល្បឿននៃចរន្តបដិសកលភាវូបនីយកម្ម និង ជំរុញនិន្នាការតំបន់ូបនីយកម្ម ដែលនឹងប៉ះពាល់ដល់លំហូរទំនិញ, សេវា, ការវិនិយោគ និង ពលកម្ម, ការផ្ទេរបច្ចេកវិទ្យា, និង កិច្ចសហប្រតិបត្តិការអន្តរជាតិ ។ ជាក់ស្តែង,

រចនាសម្ព័ន្ធខ្សែច្រវាក់ផ្គត់ផ្គង់ និង ផលិតកម្ម តំបន់ និង សកល កំពុងត្រូវបានរៀបចំឡើងវិញ តាមរយៈ ការផ្លាស់ប្តូរមូលដ្ឋានផលិតកម្មមកក្នុងប្រទេសវិញ ឬទៅប្រទេសជាសម្ព័ន្ធមិត្ត ដែលផ្តោតសំខាន់លើកត្តាភូមិសាស្ត្រនយោបាយ, ជាពិសេស សម្រាប់ទំនិញយុទ្ធសាស្ត្រ ។ ទន្ទឹមនេះ, ប្រព័ន្ធទូទាត់អន្តរជាតិ ក៏ត្រូវប្រឈមនឹងហានិភ័យនៃការបែងចែកដាច់ពីគ្នា តាមតំបន់នៃកិច្ចសហប្រតិបត្តិការនីមួយៗ ដែលអាចជះឥទ្ធិពលអវិជ្ជមាន ដល់ប្រសិទ្ធភាពនៃការទូទាត់, ខណៈការបង្កើតស្ថាប័នហិរញ្ញវត្ថុអន្តរជាតិថ្មីៗ នឹងដើរតួនាទីសំខាន់ ក្នុងការកៀរគរធនធានសម្រាប់ការអភិវឌ្ឍ ។

ក្នុងបរិការណ៍នេះ និង ផ្អែកលើកម្មវិបាកនៃនិន្នាការខាងលើ, កម្ពុជាត្រូវគិតគូរឡើងវិញ អំពីអភិក្រម និង យុទ្ធសាស្ត្រថ្មីសម្រាប់ការអភិវឌ្ឍ, ជាពិសេស ដើម្បីសម្របខ្លួនទៅនឹងនិម្មាបនកម្មថ្មីនៃរចនាសម្ព័ន្ធសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នាអនាគត ដែលស្មុគស្មាញ និង ពិបាកព្យាករ ។

### គ. និន្នាការបច្ចេកវិទ្យា និង ឌីជីថល (បរិវត្តកម្មឌីជីថល)

ស្របតាមចលនាការណ៍នៃការធ្វើបរិវត្តកម្មឌីជីថល នៅក្នុងតំបន់ និង សកល, ការបង្កើនល្បឿនឌីជីថលភាវូបនីយកម្ម និង ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និង ទូរគមនាគមន៍ និង ស្វ័យប្រវត្តិកម្ម នឹងបង្ហាញនូវតួនាទីកាន់តែសំខាន់នៃបច្ចេកវិទ្យាឌីជីថល ក្នុងសកម្មភាពសេដ្ឋកិច្ច, ធុរកិច្ច និង អភិបាលកិច្ច ។ ក្នុង ២ ទសវត្សរ៍ចុងក្រោយ, បច្ចេកវិទ្យាឌីជីថល បានក្លាយជាផ្នែកសំខាន់នៃសកម្មភាព សេដ្ឋកិច្ច និង សង្គម ព្រមទាំងបានផ្តល់នូវកាលានុវត្តភាពថ្មីជាច្រើន ក្នុងការនាំមកនូវគំរូធុរកិច្ចថ្មីៗ ប្រកបដោយការនវានុវត្ត, ការបង្កើនប្រសិទ្ធភាព និង ផលិតភាព, និង ការធ្វើឱ្យបរិយាកាសប្រកួតប្រជែង មានភាពកាន់តែប្រសើរឡើង ។

នាពេលថ្មីៗនេះ, ពិសេស ក្នុងបរិការណ៍នៃការរីករាលដាលជំងឺកូវីដ-

១៩, បច្ចេកវិទ្យាឌីជីថល ត្រូវបានមើលឃើញថា មានសម្ទុះខ្លាំងទ្វេដង ក្នុងការ-ជំរុញ និង ការសម្រួលដល់សកម្មភាពសេដ្ឋកិច្ច និង ធុរកិច្ច និង ដល់ប្រជាជនទូទៅ តាមរយៈ ការនាំមកនូវផលិតផល និង សេវាកម្មថ្មីៗ, និង ក្នុងការបន្តចលនាការណ៍លើការងារ, ការរៀនសូត្រ និង ការចាប់យកកាលានុវត្តភាពថ្មីៗ ។ បន្ថែមលើនេះ, បច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech) កំពុងដើរតួនាទីកាន់តែសំខាន់ក្នុងការសម្រួលសកម្មភាពសេដ្ឋកិច្ច តាមរយៈ ការធ្វើឱ្យប្រសើរនូវពាណិជ្ជកម្មឆ្លងដែន, ការពង្រឹងប្រសិទ្ធភាពនៃប្រតិបត្តិការអាជីវកម្មរបស់ធុរជន, ព្រមទាំងការលើកកម្ពស់បរិយាកាសធុរកិច្ចក្នុងស្រុក និង ការទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ កាន់តែងាយស្រួល ប្រកបដោយបរិយាបន្ន និង ចីរភាព ។ ជារួម, សម្ទុះយ៉ាងលឿននៃការចាប់យកបច្ចេកវិទ្យាឌីជីថល ក្នុងចំណោមភ្នាក់ងារសេដ្ឋកិច្ច, ជាពិសេស ធុរជន និង អ្នកប្រើប្រាស់, បានកើតឡើងព្រមគ្នាជានិន្នាការដ៏មានថាមភាព ទាំងក្នុងកម្រិតសកល, តំបន់, និង ប្រទេស, បើទោះបីជាមានវឌ្ឍន-ភាពមិនស្មើគ្នា ទៅតាមតំបន់ភូមិសាស្ត្រក៏ដោយ ។

ជានិន្នាការទៅមុខ, ប្រទេសនានាផ្តោតអាទិភាពជាចម្បង លើវិស័យពាក់ព័ន្ធសំខាន់ៗ តាមរយៈ ការជំរុញការធ្វើឌីជីថលភាវូបនីយកម្ម និង បរិវត្តកម្មឌីជីថល ដោយផ្តល់អាទិភាពលើការកសាងរដ្ឋាភិបាល សេដ្ឋកិច្ច និង សង្គមឌីជី-ថល ដើម្បីបង្កើនផលិតភាព និង កសាងភាពធន់នៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។

### ឃ. និន្នាការបរិស្ថាន និង ការប្រែប្រួលអាកាសធាតុ

ការគិតគូរលើបញ្ហាបរិស្ថាន និង ការប្រែប្រួលអាកាសធាតុ គឺជានិន្នាការសកលដ៏សំខាន់ ។ និរន្តរភាពបរិស្ថានសកល បាន និង កំពុងរងការ-គំរាម ដោយសារការបំពុលបរិស្ថាន, ការរេចរឹលធនធានធម្មជាតិ, ការបាត់បង់ប្រព័ន្ធជីវៈចម្រុះ, និង ការប្រែប្រួលអាកាសធាតុ ដែលជះផលអវិជ្ជមានដល់ការ-អភិវឌ្ឍសេដ្ឋកិច្ច និង សង្គម ដូចជា ការបម្លាស់ទី, សន្តិសុខទឹក ស្បៀង និង ថាមពល, ការធ្វើកសិកម្ម, ឧស្សាហូបនីយកម្ម, នគរូបនីយកម្ម និង ហេដ្ឋារចនា-

សម្ព័ន្ធ, ប្រព័ន្ធគាំពារសង្គម និង សុខភាពសាធារណៈ ។ ក្នុងន័យនេះ, នាបច្ចុប្បន្ន និង ទៅអនាគត, សកលលោក កាន់តែត្រូវបង្កើនកិច្ចសហការគ្នា ដោយផ្ដោតលើវិធានការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និង ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដូចជា ការទប់ស្កាត់ និង ការបង្ក្រាបការកាប់ព្រៃឈើខុសច្បាប់ និង ការដាំដើមឈើ, ការជំរុញការធ្វើអន្តរកាលថាមពលពីការប្រើប្រាស់ផូស៊ីលឥន្ធនៈ ឆ្ពោះទៅរកប្រភពថាមពលស្អាត, ការអនុវត្តកម្មវិធីប្រសិទ្ធភាពថាមពល, ការវិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបៃតង, ការជំរុញហិរញ្ញប្បទានបៃតង, ការជំរុញសេដ្ឋកិច្ចចក្រា, ការផលិតផលិតផលដែលគិតគូរពីចីរភាពបរិស្ថាន, ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ក្នុងការគ្រប់គ្រង និង ការតាមដានការប្រើប្រាស់ និង ការផលិត, ការលើកទឹកចិត្តប្រព័ន្ធដឹកជញ្ជូនបៃតង, និង ការបន្សាំក្នុងវិស័យសំខាន់ៗ ជាដើម ។

### ១.៣. បញ្ហាប្រឈម

ការប្រែប្រួលរចនាសម្ព័ន្ធ និង និម្មាបនកម្ម សេដ្ឋកិច្ច សង្គម បរិស្ថាន និង នយោបាយសកល ដែលបង្កដោយការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ, សង្គ្រាមពាណិជ្ជកម្ម, ការគាំពារនិយម និង ជាតិនិយម, និង ការប្រែប្រួលអាកាសធាតុ និង ប្រជាសាស្ត្រ នាំឱ្យកម្ពុជាត្រូវប្រឈមនឹងបញ្ហាធំៗ ដូចខាងក្រោម ៖

១. ម៉ូដែលកំណើនសេដ្ឋកិច្ចបច្ចុប្បន្ន ពឹងផ្អែកខ្លាំងលើឧស្សាហកម្មអតិពលកម្ម និង មូលដ្ឋានកំណើនតូចចង្អៀត ដែលធ្វើឱ្យកម្ពុជាងាយរងផលប៉ះពាល់ពីខាងក្រៅ និង ជាប់អន្ទាក់ជាប្រទេសចំណូលមធ្យម ។ បញ្ហាប្រឈមថ្មីៗបាន និង កំពុងលេចឡើង ដោយសារភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកល, ការប្រែប្រួលនៃនិម្មាបនកម្មសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសកល, ការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ, ការគាំពារនិយម, ការកើនឡើងនៃថ្លៃថាមពល, ការកើនឡើងនៃសម្ពាធអតិផរណា, ការធ្លាក់ចុះផលិតភាពពលកម្ម, និង បញ្ហាសេដ្ឋកិច្ច

និង សង្គម ផ្សេងទៀត ។

២. គុណភាពធនធានមនុស្សនៅមានកម្រិត សម្រាប់ការកសាងសេដ្ឋកិច្ចផ្អែកលើ ជំនាញ, បច្ចេកវិទ្យា និង ការនវានុវត្ត ។ ការណ៍នេះ ទាមទារនូវការបន្តជំរុញសម្ទុះនៃការអភិវឌ្ឍធនធានមនុស្ស ដោយផ្តោតសំខាន់លើ ការកែទម្រង់វិស័យអប់រំ និង ការកសាងមូលធនមនុស្ស ប្រកបដោយគុណភាព ដែលអាចធានាបាននូវភាពរឹងមាំនៃសេដ្ឋកិច្ចជាតិ, ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គម, ការចាប់យកបច្ចេកវិទ្យា, ការបន្សាំបច្ចេកវិទ្យា និង ការនវានុវត្ត ដើម្បីទាញយកផលប្រយោជន៍ជាអតិបរមាពីការរីកចម្រើននៃបច្ចេកវិទ្យាថ្មីៗ និង ការនវានុវត្ត, ជាពិសេស ក្នុងបរិការណ៍សេដ្ឋកិច្ចឌីជីថល ។

៣. ស្ថាប័នសាធារណៈទោះបីមានការកែលម្អជាបណ្តើរៗ, ប៉ុន្តែនៅមិនទាន់មានប្រសិទ្ធភាពខ្ពស់គ្រប់គ្រាន់នៅឡើយ ។ គុណភាព និង សមត្ថភាពស្ថាប័ន មានសារៈសំខាន់ ក្នុងការបង្កើនប្រសិទ្ធភាពនៃការរៀបចំ និង ការអនុវត្តគោលនយោបាយ, ការកែលម្អបរិយាកាសនៃការវិនិយោគ និង ធុរកិច្ច, ការកាត់បន្ថយថ្លៃដើម និង ពេល, និង ការលើកកម្ពស់ប្រសិទ្ធភាពការងារជាអន្តរវិស័យ ដែលចាំបាច់ត្រូវបន្តលើកកម្ពស់ និង ពង្រឹងបន្ថែម ដើម្បីកសាងស្ថាប័ន រឹងមាំ សម្រាប់ការអភិវឌ្ឍជាតិលើគ្រប់វិស័យ ។

៤. ហេដ្ឋារចនាសម្ព័ន្ធ នៅមិនទាន់គ្រប់គ្រាន់ សម្រាប់ទ្រទ្រង់តម្រូវការនៃការអភិវឌ្ឍ ។ ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដូចជា ហេដ្ឋារចនាសម្ព័ន្ធទីក្រុង, ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន, ប្រព័ន្ធឡជីស្ទីក, ប្រព័ន្ធថាមពល និង ប្រព័ន្ធធារាសាស្ត្រ ជាដើម នៅបន្តជួបបញ្ហាប្រឈម ដែលត្រូវដោះស្រាយឱ្យបានលឿន និង ប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីទ្រទ្រង់ដំណើរការនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយបរិយាបន្ន និង ចីរភាព ។

៥. សេវាសុខាភិបាលនៅមានថ្លៃខ្ពស់ ហើយគុណភាពនៅមានកម្រិត ។ ទោះបីមានការកែលម្អមួយកម្រិតធំ, ប្រព័ន្ធសុខាភិបាលនៅមានបញ្ហា

ប្រឈម ដែលទាមទារត្រូវដោះស្រាយ ក្នុងស្មារតីបុរេសកម្ម, បន្ទាន់ និង ជាប្រចាំ, ជាប់មិនដាច់, ដើម្បីបង្កើនគុណភាពឱ្យកាន់តែខ្ពស់ សំដៅលើកកម្ពស់សុខភាពសាធារណៈ និង កាត់បន្ថយការពឹងផ្អែកលើការនាំចូលសេវាក្នុងវិស័យនេះ ឬ ការចេញទៅប្រើសេវានេះ នៅក្រៅប្រទេស ។ ជាមួយនឹងការពឹងទុកនូវការកើនឡើងនូវចំនួនប្រជាជនវ័យចំណាស់, តម្រូវការសេវាសុខាភិបាល ប្រកបដោយគុណភាព ក៏ត្រូវបានរំពឹងថា នឹងរឹតតែកើនឡើងផងដែរ, ដែលការណ៍នេះ ទាម-ទារឱ្យមានការគិតគូរកែលម្អ និង អភិវឌ្ឍបន្ថែម លើគ្រប់ទិដ្ឋភាព, ទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល, អភិបាលកិច្ច, ធនធានមនុស្ស, និង ជំនាញវិជ្ជាជីវៈ ប្រកបដោយក្រមសីលធម៌ខ្ពស់ ។

៦. ការសន្សំក្នុងស្រុកនៅមានកម្រិតទាប ដែលបង្កផលប៉ះពាល់ដល់ការវិនិយោគ និង កំណើនសេដ្ឋកិច្ច រយៈពេលវែង ។ ទោះបីការសន្សំមានការអភិវឌ្ឍគួរឱ្យកត់សម្គាល់, វិស័យហិរញ្ញវត្ថុកម្ពុជានៅបន្តមានបញ្ហាប្រឈមផ្សេងទៀត ដូចជា ការផ្គត់ផ្គង់ និង តម្រូវការហិរញ្ញប្បទាន នៅមានកម្រិតទាប, ដុល្លារូបនីយកម្មនៅបន្តមានកម្រិតខ្ពស់ ដែលធ្វើឱ្យបាត់បង់ប្រសិទ្ធភាពនៃការ-អនុវត្តគោលនយោបាយរូបិយវត្ថុ, អត្រាការប្រាក់មានកម្រិតខ្ពស់, ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និង ហិរញ្ញវត្ថុឌីជីថល នៅមានកម្រិតទាប, ផលិតផលហិរញ្ញវត្ថុមានលក្ខណៈប្រមូលផ្តុំ, ការជឿទុកចិត្តលើវិស័យធនាគារនៅមានកម្រិត, និង បំណុលគេហជនមានកម្រិតខ្ពស់ ហើយការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ក៏ត្រូវការនូវការពង្រឹងបន្ថែមទៀត ក្នុងទិដ្ឋភាពជាច្រើន ។

៧. ការគ្រប់គ្រងធនធានធម្មជាតិ និង បរិស្ថាន ត្រូវបានកែលម្អគួរឱ្យកត់សម្គាល់ តាមរយៈការដាក់ចេញគោលនយោបាយជាតិ សម្រាប់គ្រប់-គ្រង និង កែទម្រង់ក្នុងវិស័យនេះ ។ យ៉ាងណាក៏ដោយ, បញ្ហាប្រឈមនៅបន្តមានច្រើន ដោយសារការកើនឡើងនៃតម្រូវការអភិវឌ្ឍ, ការប្រែប្រួលអាកាស-ធាតុ, ការបង្កើតលក្ខខណ្ឌតម្រូវថ្មីៗលើផលិតផលកម្ពុជា ជាដើម ។ ក្នុងន័យ

នេះ, គ្រប់គោលនយោបាយអភិវឌ្ឍជាតិ ទាមទារឱ្យមានការគិតគូរថ្លឹងថ្លែងគ្រប់ជ្រុងជ្រោយ, ពិសេស អំពីចីរភាព និង ប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន ក៏ដូចជា ការពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ ។

### ១.៤. កាលានុវត្តភាព

បរិការណ៍សកល និង នៅក្នុងប្រទេស នាបច្ចុប្បន្ន ផ្តល់ឱ្យកម្ពុជានូវកាលានុវត្តភាពសំខាន់ៗ ដូចតទៅ ៖

១. ក្នុងបរិការណ៍នៃការប្រកួតប្រជែងលើផ្នែកភូមិសាស្ត្រនយោបាយសេដ្ឋកិច្ច និង ពហុប៉ូល, ការបន្តពង្រឹងស្មារតីសន្តិសហវិជ្ជមាន ដោយកសាង និង ពង្រីកទំនាក់ទំនងល្អជាមួយបណ្តាដៃគូសំខាន់ៗ គួបផ្សំជាមួយនឹងការអនុវត្តនយោបាយការទូតប្រកបដោយភាពប៉ិនប្រសប់ នឹងបើកនូវឱកាសកាន់តែប្រសើរឡើងបន្ថែមទៀត សម្រាប់ការជំរុញពាណិជ្ជកម្មអន្តរជាតិ, ការវិនិយោគ, ការធ្វើពិពិធកម្មសេដ្ឋកិច្ច, ការផ្ទេរបច្ចេកវិទ្យា និង ការផ្សារភ្ជាប់កម្ពុជាកាន់តែខ្លាំង ទៅនឹងខ្សែប្រវាក់ផ្គត់ផ្គង់ និង ខ្សែប្រវាក់តម្លៃសកល ដើម្បីទាញយកប្រយោជន៍ឱ្យបានជាអតិបរមា សម្រាប់ជាតិ និង ប្រជាជន ។

២. ជាមួយនឹងឧត្តមភាពនៃទីតាំងភូមិសាស្ត្ររបស់កម្ពុជា, ចរន្តនៃការបន្តផ្លាស់ប្តូរទីប្រជុំទម្ងន់នៃកំណើនសេដ្ឋកិច្ចមកទ្វីបអាស៊ី បង្កើតជា **ឱកាសមាស** សម្រាប់កម្ពុជា ក្នុងការអភិវឌ្ឍ និង ការធ្វើឧស្សាហូបនីយកម្ម, ការធ្វើពិពិធកម្មសេដ្ឋកិច្ច, ការកើនឡើងនៃផលិតកម្ម និង សេវាកម្ម, ការបង្កើនការតភ្ជាប់សេដ្ឋកិច្ចកម្ពុជាទៅនឹងសេដ្ឋកិច្ចតំបន់ និង សកល ប្រកបដោយជវភាព និង សក្តានុពល, និង ការធ្វើសមាហរណកម្មជាមួយនឹងសេដ្ឋកិច្ចនៃប្រទេស ក្នុងតំបន់កំពុងមានជវភាពខ្ពស់ ។

៣. ផលលាភសន្តិភាព នឹងផ្តល់ឧត្តមប្រយោជន៍សម្រាប់វឌ្ឍនភាពផ្នែកសេដ្ឋកិច្ច និង សង្គម ។ ច្បាស់ណាស់, ការរក្សាបានរឹងមាំ និង ជាប់មិនដាច់នូវសុខសន្តិភាព និង ស្ថិរភាពនយោបាយ បាន, កំពុង និង បន្តបង្កើតបរិយាកាស

អនុគ្រោះដ៏ប្រសើរមិនអាចខ្វះបាន សម្រាប់ការជំរុញសន្ទុះនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច, ការរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, ការលើកកម្ពស់ការវិនិយោគឯកជន និង ធុរកិច្ច ដែលជាចន្ទល់នៃកំណើនសេដ្ឋកិច្ច និង ការបង្កើតការងារសម្រាប់ប្រជាជនកម្ពុជា ។

៤. ការអភិវឌ្ឍជាលំដាប់នៃប្រព័ន្ធហិរញ្ញវត្ថុ, ទាំងប្រព័ន្ធធនាគារ និង ប្រព័ន្ធហិរញ្ញវត្ថុមិនមែនធនាគារ, បាន និង កំពុង បន្តផ្តល់លទ្ធភាពទូលំទូលាយក្នុងការបំពេញតម្រូវការសេវាហិរញ្ញវត្ថុ នៅក្នុងប្រទេស និង ក្នុងការឆ្លើយតបនឹងតម្រូវការនៃការធ្វើសមាហរណកម្មសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងតំបន់ ។ ការធ្វើបរិវត្តកម្មឌីជីថលនៃសេវាហិរញ្ញវត្ថុ នឹងគាំទ្រដល់ការអនុវត្តគោលនយោបាយសេដ្ឋកិច្ចឌីជីថល និង ការបង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច និង បរិយាបន្នហិរញ្ញវត្ថុ ។

៥. ការអភិវឌ្ឍសមត្ថភាពឧស្សាហកម្មគាំទ្រក្នុងស្រុក នឹងជួយបង្កើតឱកាសសម្រាប់វិស័យឧស្សាហកម្ម ក្នុងការបង្កើនតម្លៃបន្ថែម ក៏ដូចជាក្នុងការលើកកម្ពស់ប្រសិទ្ធភាព, ផលិតភាព និង ភាពប្រកួតប្រជែង តាមរយៈការបង្កើនប្រសិទ្ធភាពនៃការផ្គត់ផ្គង់ធាតុចូល សម្រាប់ដំណើរការផលិតកម្ម, ការកាត់បន្ថយថ្លៃដើម, ការចែករំលែកបច្ចេកវិទ្យា និង ការផ្តល់ព័ត៌មានអំពីកត្តាផលិតកម្ម ជាដើម ។ល។

៦. ការរីកចម្រើនផ្នែកបច្ចេកវិទ្យា និង ឌីជីថលភាវូបនីយកម្ម ផ្តល់នូវកាលានុវត្តភាពថ្មី ក្នុងការបង្កើតមុខរបរ និង ធុរកិច្ចថ្មីៗជាច្រើនបន្ថែមទៀត ព្រមទាំងជំរុញល្បឿននៃការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល នៅកម្ពុជា, ដែលការណ៍នេះ នឹងរួមចំណែកដល់ការកសាង **ម៉ូដែលថ្មីនៃកំណើន** ផ្អែកលើជំនាញ, បច្ចេកវិទ្យា និង ការនវានុវត្ត ។

៧. ស្ថានភាពប្រជាសាស្ត្ររបស់កម្ពុជានាបច្ចុប្បន្ន ផ្តល់នូវកាលានុវត្តភាព សម្រាប់ការទាញយកប្រយោជន៍ឱ្យបានជាអតិបរមាពីផលលាភប្រជា-

សាស្ត្រ, ការពង្រឹងភាពធន់ប្រជាសាស្ត្រ និង ការលើកកម្ពស់សមភាពយេនឌ័រ, ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល, ការផ្ទេរបច្ចេកវិទ្យា, ការលើកកម្ពស់ផលិតភាពនៃកម្លាំងពលកម្ម, និង ការធ្វើឱ្យប្រសើរឡើងនូវភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិដើម្បីជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយបរិយាបន្ន, ភាពធន់ និង ចីរភាព ។

### ១.៥. ការសម្លឹងទៅមុខ ២៥ ឆ្នាំ ឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០

ក្នុងរយៈពេល ២៥ ឆ្នាំ ខាងមុខ, **យុទ្ធសាស្ត្របញ្ចកោណ** នឹងត្រូវបានជំរុញអនុវត្តប្រកបដោយភាពប្រទាក់ក្រឡាគ្នា ក្នុងស្មារតីបុរេសកម្ម និង ច្បាស់-លាស់ ក្នុងគោលបំណងកសាងកម្ពុជា ជាអរិយប្រទេសមួយ ដែលឆ្លើយតបនឹងលក្ខណសម្បត្តិ ដូចខាងក្រោម ៖

១. កម្ពុជា ជា "**សង្គមជាតិមួយដ៏រស់រវើក**" ដែលមានសុខសន្តិភាពឋិតថេរចីរកាល, មានស្ថិរភាពនយោបាយ និង សណ្តាប់ធ្នាប់សាធារណៈមាំមួន, មានការគោរពច្បាប់ និង នីតិរដ្ឋ, មានយុត្តិធម៌សង្គម, និង មានការគោរពសិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស; ជារដ្ឋរឹងប៉ឹង ដែលមាន ឯករាជ្យ អធិបតេយ្យ និង បូរណភាពទឹកដី ពេញលេញ, មានភាពជាម្ចាស់រឹងមាំ, មានអត្តសញ្ញាណជាតិជាក់លាក់, មានកិត្យានុភាពខ្ពស់ត្រដែត និង ស្មើភាព និង ស្មើសិទ្ធិ លើឆាកអន្តរជាតិ; និង ជារដ្ឋប្រជាធិបតេយ្យ ដែលមានអភិបាលកិច្ចល្អ និង ស្ថាប័នរឹងមាំប្រកបដោយតម្លាភាព និង គណនេយ្យភាព ហើយដំណើរការបម្រើជាតិ និង ប្រជាជន ប្រកបដោយប្រសិទ្ធភាព នៅក្នុងជវភាពនៃប្រព័ន្ធតួអង្គតែមួយ ។

២. កម្ពុជា ជា "**ប្រទេសមានចំណូលខ្ពស់ និង មានសេដ្ឋកិច្ចធន់រឹងមាំ**" ប្រកបដោយប្រសិទ្ធភាព, ភាពប្រកួតប្រជែងបើកចំហ, បរិយាបន្ន និង ចីរភាព ដោយរដ្ឋប្រកាន់យកតួនាទី ជាយុទ្ធសាស្ត្រវិទូ, អ្នកដឹកនាំ និង អ្នកគ្រប់-គ្រងការអភិវឌ្ឍ; ជាអ្នកការពារកម្មសិទ្ធិ និង ទ្រព្យសម្បត្តិឯកជន; និង ជាអ្នក-

គាំទ្រ និង លើកកម្ពស់ការអភិវឌ្ឍវិស័យឯកជន ។ ក្នុងការដឹកនាំ និង ការគ្រប់-គ្រងការអភិវឌ្ឍ, រដ្ឋប្រកាន់យកការបើកចំហឆ្ពោះទៅខាងក្រៅ ដោយពង្រឹង និង ពង្រីក ក្របខ័ណ្ឌពាណិជ្ជកម្មសេរី, ទាំងទ្វេភាគី និង ពហុភាគី; ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច; ការជំរុញធ្វើពិពិធកម្មសេដ្ឋកិច្ច; ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល; និង ការបង្កើនភាពរឹងមាំនៃវិស័យហិរញ្ញវត្ថុ ។

៣. ប្រជាជនកម្ពុជា "**មានចំណេះដឹងខ្ពស់ និង ជំនាញមួយយ៉ាងតិចប្រចាំជីវិត**" ប្រកបដោយអំណត់ធន់, សហគ្រិនភាព, ការនវានុវត្ត និង សីល-ធម៌ប្រពៃ ដោយរដ្ឋធានា ផ្តល់សេវាអប់រំជាមូលដ្ឋានសម្រាប់ទាំងអស់គ្នាយ៉ាងតិចត្រឹមថ្នាក់ទី ៩; បំពាក់ជំនាញ និង បច្ចេកវិទ្យា ដែលជាតម្រូវការទីផ្សារការងារ និង ធុរកិច្ច; ពង្រឹងការបណ្តុះបណ្តាល និង ការផ្លាស់ប្តូរជំនាញ ស្របនឹងតម្រូវការទីផ្សារការងារ; ពង្រឹងគុណភាពវិស័យឧត្តមសិក្សា ឱ្យក្លាយជាមណ្ឌលមូលធនបញ្ញាជាតិ និង ឃ្លាំងពុទ្ធិសកល; និង យកចិត្តទុកដាក់លើជីវភាពគ្រូបង្រៀន, បុគ្គលិកសិក្សា និង សាស្ត្រាចារ្យ ។

៤. ប្រជាជនកម្ពុជា "**រស់នៅក្នុងសេចក្តីថ្លៃថ្នូរ សុភមង្គល និង ទទួលបានការគាំពារសង្គម ប្រកបដោយសមធម៌ ស្មើសិទ្ធិ ស្មើឱកាស**" ក្នុងសង្គមជាតិ ដោយរដ្ឋផ្តល់សារៈសំខាន់លើការរៀបចំឱ្យបានរឹងមាំនូវប្រព័ន្ធសន្តិសុខសង្គម និង ជំនួយសង្គម; ការលើកកម្ពស់វិស័យជានារ៉ាប់រង; ការពង្រឹង និង ការធ្វើទំនើបកម្មប្រព័ន្ធសុខាភិបាល; ការយកចិត្តទុកដាក់លើវិស័យកីឡា និង សុខភាពសាធារណៈ; ការលើកកម្ពស់សមភាពយេនឌ័រ; និង ការលើកកម្ពស់សង្គមឌីជីថល ។

៥. កម្ពុជា ជាប្រទេសមាន "**បរិស្ថានរូបវន្ត និង ធម្មជាតិ ប្រកបដោយ សុខដុមភាព, ភាពធន់, បរិយាបន្ន និង តុល្យភាពរវាងការអភិវឌ្ឍ និង ការអភិរក្សធនធានធម្មជាតិ**" សម្រាប់ការរស់នៅប្រកបដោយផាសុកភាព ដោយរដ្ឋផ្តល់សារៈសំខាន់ចំពោះ សន្តិសុខថាមពល; ការរៀបចំប្រព័ន្ធទឹកស្អាត និង

ប្រព័ន្ធគ្រប់គ្រងកាកសំណល់គ្រប់ប្រភេទ ប្រកបដោយប្រសិទ្ធភាព; ការរៀបចំប្រព័ន្ធធារាសាស្ត្រ តាមបែបទំនើប និង ស្វ័យប្រវត្តិ; ការទប់ទល់ និង ការកសាងប្រព័ន្ធបន្សាំរឹងមាំទៅនឹងការប្រែប្រួលអាកាសធាតុ; ការប្រើប្រាស់ប្រព័ន្ធអេកូឡូស៊ីប្រកបដោយចីរភាព; ការបំពាក់បច្ចេកវិទ្យាទាន់សម័យ ក្នុងវិស័យកសិកម្ម; និង ការគ្រប់គ្រង និង ការប្រើប្រាស់ធនធានធម្មជាតិ ដោយគិតគូរដល់តុល្យភាពបរិស្ថាន ។

## ១.៦. ភាពចាំបាច់ក្នុងការរៀបចំយុទ្ធសាស្ត្របញ្ចកោណ

ក្នុងបរិការណ៍ក្រោយការរាតត្បាតនៃជំងឺកូវីដ-១៩ និង ការប្រែប្រួលយ៉ាងរហ័សនៃភូមិសាស្ត្រនយោបាយសកល, កម្ពុជាមានភាពចាំបាច់ក្នុងការងើបឈរឡើង និង ពង្រឹងខ្លួនឱ្យបានមាំមួន ដើម្បី, ម៉្យាង, ស្តារឡើងវិញនូវការខាតបង់បណ្តាលមកពីវិបត្តិជំងឺកូវីដ-១៩ និង វិបត្តិសកលផ្សេងទៀត; និងម៉្យាងទៀត, ពូនផ្តុំកម្លាំងបន្តដំណើរជាមួយនឹងការកសាងភាពធន់រឹងមាំ ឆ្លងកាត់បង្គោលចរនៃការប្រែក្លាយខ្លួនជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ ២០៣០ ឆ្ពោះទៅសម្រេចឱ្យបាននូវ "**ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០**" នៃការប្រែក្លាយខ្លួនជាប្រទេសមានចំណូលខ្ពស់ ជាមួយនឹងលក្ខណសម្បត្តិជាគោល ទាំង ៥ យ៉ាង ដូចបានគូសរំលេចខាងលើ ។

ផ្អែកលើសមិទ្ធផលនៃការអនុវត្ត **យុទ្ធសាស្ត្រត្រីកោណ** និង **យុទ្ធសាស្ត្រចតុកោណ ទាំង ៤ ដំណាក់កាល** ក្នុងរយៈពេល ២៥ ឆ្នាំកន្លងមក, រាជរដ្ឋាភិបាលបានធ្វើការវាយតម្លៃ ពេញលេញ និង ម៉ត់ចត់ លើភាពខ្លាំង និង បណ្តាបញ្ហាប្រឈម ដែលត្រូវបន្តដោះស្រាយ ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា ២០២៣-២០២៨ ។ ចំណុចខ្លាំងនៃ **យុទ្ធសាស្ត្រត្រីកោណ** និង **យុទ្ធសាស្ត្រចតុកោណ ទាំង ៤ ដំណាក់កាល** គឺ : យុទ្ធសាស្ត្រទាំងពីរនេះ បានផ្តល់ក្របខ័ណ្ឌគោលនយោបាយច្បាស់លាស់, ចំគោលដៅ, ប្រទាក់ក្រឡាគ្នា, គ្រប់ជ្រុងជ្រោយ និង ប្រកបដោយសង្គតិភាព ព្រមទាំងគ្របដណ្តប់ទៅលើគ្រប់វិស័យអាទិភាព

សម្រាប់ការដឹកនាំសកម្មភាពអនុវត្ត ។ ជាមួយនេះ, គ្រប់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល, ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, ក៏បានចូលរួមយ៉ាងសស្រាក់-សស្រាំ ក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ ប្រកបដោយស្មារតីសកម្ម និង បុរេសកម្ម ដែលនាំមកនូវសមិទ្ធផលដ៏ប្រសើរ ជាបន្តបន្ទាប់ ជូនប្រទេសជាតិ និង ប្រជា-ជន ។ យ៉ាងណាមិញ, រាជរដ្ឋាភិបាលក៏បានកត់សម្គាល់ឃើញនូវចំណុចខ្សោយមួយចំនួនផងដែរ ក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ នាពេលកន្លងមក ដែលជារួមពាក់ព័ន្ធទៅនឹងសមត្ថភាព និង គុណភាព នៃស្ថាប័ន ក៏ដូចជាប្រសិទ្ធភាពនៃការសម្របសម្រួលរវាងក្រសួង-ស្ថាប័ន ក្នុងការដាក់ចេញ និង ការអនុវត្តនូវ-វិធានការគោលនយោបាយ និង ផែនការសកម្មភាពជាក់ស្តែង ក្នុងវិស័យក្រោមសមត្ថកិច្ចរៀងខ្លួន ។ម៉្យាងទៀត, សកម្មភាពអនុវត្តរបស់ក្រសួង-ស្ថាប័ននៅមានគម្លាត និង មិនទាន់បានផ្សារភ្ជាប់ល្អពេញលេញ ទៅនឹងគោលបំណងគោល-នយោបាយរបស់រាជរដ្ឋាភិបាល ។ លើសពីនេះ, ការផ្សព្វផ្សាយក៏នៅមានកម្រិត ដែលជាការរួមចំណែកដល់បញ្ហាប្រសិទ្ធភាពនៃការចូលរួមគាំទ្រ ក៏ដូចជាការ-ចូលរួមអនុវត្តយុទ្ធសាស្ត្រផងដែរ ។

លើមូលដ្ឋាននៃការបូកសរុបសមិទ្ធផល សម្រាប់រយៈពេល ២៥ ឆ្នាំកន្លងមក និង ការពិនិត្យវាយតម្លៃនិន្នាការតំបន់ និង សកល ជាមួយនឹងការ-ប្រមើល សម្រាប់រយៈពេល ២៥ ឆ្នាំ សំដៅឆ្លើយតបនឹងបំណងប្រាថ្នារបស់ប្រជាជន ឆ្ពោះទៅសម្រេចបាននូវ **ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០**, ក្នុងការដាក់ចេញនូវ **"យុទ្ធសាស្ត្របញ្ចកោណ"** បន្តពី **"យុទ្ធសាស្ត្រចតុកោណ"**, រាជរដ្ឋា-ភិបាលបានគិតគូរយ៉ាងម៉ត់ចត់ ដោយផ្តោតលើការសម្រេចឱ្យបាននូវគោលដៅរយៈពេលវែងនៃការកសាងជាតិ និង ប្រកាន់យកនូវអភិក្រមនៃការអនុវត្តជា-ដំណាក់កាលៗដោយពង្រីកវិសាលភាព, សម្រិតសម្រាំង, ធ្វើអាទិភាវូបនីយកម្មនៃកោណអាទិភាពឡើងវិញ, ព្រមទាំងកែលម្អគោលនយោបាយ និង យន្តការអនុវត្ត ទៅតាមការប្រែប្រួលនៃបរិការណ៍ជាតិ និង អន្តរជាតិ និង ដំណាក់កាល

នីមួយៗនៃការអភិវឌ្ឍ; ប៉ុន្តែ នៅរក្សាជានិច្ចនូវរចនាសម្ព័ន្ធប្រទាក់ក្រឡាគ្នា ដូចធ្លាប់បានគិតគូរនៅក្នុងការរៀបចំ "**យុទ្ធសាស្ត្រចតុកោណ**" ដូច្នោះដែរ ។

ក្នុងស្មារតីនេះ, រាជរដ្ឋាភិបាលដាក់ចេញនូវ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដើម្បី កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និង ចីរភាព** សំដៅ ការពារ ថែរក្សា និង ពូនជ្រុំ សមិទ្ធផលជាតិ, លើកកម្ពស់កិត្យានុភាពជាតិឱ្យខ្ពស់ត្រដែត, ជំរុញសន្ទុះនៃកំណើនសេដ្ឋកិច្ច, និង កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចបាន **ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០** ដោយយោងលើភាពចាំបាច់នៅក្នុងទិដ្ឋភាពសំខាន់ៗ ដូចខាងក្រោម ៖

១. ភាពចាំបាច់ ក្នុងការបន្តពង្រឹង និង ពង្រីក សមិទ្ធផលនានា ដែលរាជរដ្ឋាភិបាលសម្រេចបាន នៅក្នុងនីតិកាលកន្លងមក នៅក្នុងក្របខ័ណ្ឌ **យុទ្ធសាស្ត្រត្រីកោណ** និង **យុទ្ធសាស្ត្រចតុកោណ ទាំង ៤ ដំណាក់កាល** តាម-រយៈ ការបន្តពង្រឹងសុខសន្តិភាព, ស្ថិរភាពនយោបាយ និង សណ្តាប់ធ្នាប់សង្គម; ការពង្រឹងការគោរពច្បាប់ និង វិធាននៃច្បាប់, ការលើកស្ទួយនីតិរដ្ឋ, សិទ្ធិសេរី-ភាព, សេចក្តីថ្លៃថ្នូររបស់មនុស្ស និង លទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស; និង ការអនុវត្តវិធានការជាក់ស្តែងនានា សំដៅលើកកម្ពស់កម្រិតជីវភាព និង សុខុ-មាលភាពប្រជាជន, ជាពិសេស ការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃអភិបាលកិច្ច, ស្ថាប័ន និង យុត្តិធម៌សង្គម ព្រមទាំងការពង្រឹងភាពស្អាតស្អំ និង គុណភាពសេវាសាធារណៈ ។

២. ភាពចាំបាច់ ក្នុងការបន្តកែទម្រង់ស្ថាប័ន និង អភិបាលកិច្ច ឱ្យសម្រេចបាននូវរដ្ឋបាលសាធារណៈមួយ ដែលមានសមត្ថភាពខ្ពស់, ខ្លាំង, វៃឆ្លាត និង ស្អាតស្អំ ហើយបំពេញការងារនៅក្នុង "**ជីវភាពនៃប្រព័ន្ធតួអង្គតែមួយ**" ព្រមទាំងធានាបាននូវប្រសិទ្ធភាពខ្ពស់ នៅក្នុងគ្រប់ទិដ្ឋភាពនៃកិច្ចប្រតិបត្តិការរបស់ខ្លួន, ទាំងការដឹកនាំ, ការសម្របសម្រួល, ការត្រួតពិនិត្យ និង ការវាយតម្លៃលើការអនុវត្តគោលនយោបាយ និង យុទ្ធសាស្ត្រនានា ក្នុងបរិការណ៍នៃការវិវត្ត

សភាពការណ៍សង្គម-សេដ្ឋកិច្ច, ទាំងក្នុង និង ក្រៅ ប្រទេស ។

៣. ភាពចាំបាច់ ក្នុងការបន្តកសាង និង ការពង្រឹងមូលដ្ឋានសម្រាប់ជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គម ដោយផ្តោតជាសំខាន់លើការកសាងមូលធនមនុស្សរឹងមាំ, ពិសេស តាមរយៈ ការកែទម្រង់ វិស័យអប់រំ និង វិស័យសុខាភិបាល; ការបង្កើនផលិតភាពសេដ្ឋកិច្ច; ការលើកកម្ពស់ចំណេះដឹងរបស់ប្រជាជន និង សមត្ថភាពជំនាញរបស់ពលករ; ការពង្រឹងអភិបាលកិច្ចវិស័យឯកជន និង ធុរកិច្ច; និង ការលើកកម្ពស់ការតភ្ជាប់ ព្រមទាំងការជំរុញអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្រប់ប្រភេទ, ទាំងរឹង និង ទន់, រួមបញ្ចូលនូវហេដ្ឋារចនាសម្ព័ន្ធឌីជីថលផង, ដើម្បីឈានទៅបង្កើតឡើងនូវម៉ូដែលថ្មីនៃកំណើនដែលផ្អែកលើជំនាញ, បច្ចេកវិទ្យា និង ការនវានុវត្ត ។

៤. ភាពចាំបាច់ ក្នុងការបង្កើនការធ្វើពិពិធកម្មសេដ្ឋកិច្ច និង ភាពប្រកួតប្រជែងរបស់កម្ពុជា និង ក្នុងការកសាងភាពធន់ទៅនឹងការប្រែប្រួលនៃកត្តាសង្គម-សេដ្ឋកិច្ច និង កត្តាបរិស្ថានធម្មជាតិ ដើម្បីពង្រឹងមូលដ្ឋានកំណើនសេដ្ឋកិច្ច និង ធានាចីរភាពនៃកំណើនខ្ពស់ តាមរយៈ ការបង្កើនតម្លៃបន្ថែម ក្នុងវិស័យចន្ទល់កំណើនសេដ្ឋកិច្ចដែលមានស្រាប់ និង វិស័យផ្សេងទៀតដែលកម្ពុជាមានសក្តានុពល; ការជំរុញការវិនិយោគ ក្នុងវិស័យកសិកម្ម និង កសិ-ឧស្សាហកម្ម; ការជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម និង ឧស្សាហូបនីយកម្ម; ការលើកកម្ពស់ការប្រកួតប្រជែងស្មើភាព និង ការលើកស្ទួយភាពប្រកួតប្រជែងរបស់កម្ពុជា; ការកសាងភាពធន់ទល់នឹងគ្រោះអាសន្ន និង វិបត្តិនានា; ព្រមទាំងការលើកកម្ពស់ទំនាក់ទំនងអន្តរជាតិ និង ការទូត និង ការធ្វើសមាហរណកម្មស៊ីជម្រៅទៅក្នុងតំបន់ និង សកលលោក សំដៅទាញយកផលប្រយោជន៍សេដ្ឋកិច្ច និង សង្គម ឱ្យបានជាអតិបរមាជូនប្រទេសជាតិ ។

៥. ភាពចាំបាច់ ក្នុងការដាក់ចេញនូវ **របៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច** គ្រប់ជ្រុងជ្រោយមួយ នៃ "**កម្មវិធីនយោបាយរបស់រាជរដ្ឋាភិ-**

បាល **នីតិកាលទី ៧ នៃរដ្ឋសភា**" ដើម្បីកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំ សម្រាប់ការបន្តដំណើរឈានទៅសម្រេចបាននូវ **ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០** ។

លើមូលដ្ឋាននេះ, ជាមួយនឹង **បាវចនាទាំង ៥** គឺ : **កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និង ចីរភាព,** រាជរដ្ឋាភិបាលសម្រេចកំណត់យក **គោលដៅយុទ្ធសាស្ត្រ ចំនួន ៥** និង **អាទិភាពគន្លឹះ ចំនួន ៥** សម្រាប់ "**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១**" ។

## គោលដៅយុទ្ធសាស្ត្រ ៥ មាន ដូចខាងក្រោម ៖

១. ធានាឱ្យបានកំណើនសេដ្ឋកិច្ច ក្នុងអត្រាមធ្យមប្រចាំឆ្នាំ ក្នុងរង្វង់ ៧% ប្រកបដោយភាពធន់នឹងវិបត្តិនានា តាមរយៈ ការជំរុញសម្ទុះនៃការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច ដើម្បីបង្កើតចន្ទល់ថ្មីៗនៃកំណើន; ការលើកកម្ពស់ភាពប្រកួតប្រជែង; និង ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដោយគ្រប់គ្រងអត្រាអតិផរណាឱ្យនៅទាប, ធានាស្ថិរភាពអត្រាប្តូរប្រាក់, ខិតខំបង្កើនទុនបម្រុងជា-ប្រចាំ, និង ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, រួមបញ្ចូលទាំងការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និង ការគ្រប់គ្រងបំណុលសាធា-រណៈ ប្រកបដោយចីរភាព ។

២. បង្កើតការងារឱ្យបានកាន់តែច្រើន, ទាំងបរិមាណ និង គុណ-ភាព, ជូនដល់ប្រជាជនកម្ពុជា, ជាពិសេស សម្រាប់យុវជន, តាមរយៈការពង្រឹងគុណភាពអប់រំ និង ការបណ្តុះបណ្តាលជំនាញ, ទាំងជំនាញរឹង និង ជំនាញទន់, ឱ្យសមស្របនឹងតម្រូវការ ក្នុងទីផ្សារការងារ; ការផ្តល់ព័ត៌មានឱ្យបានទូលំ-ទូលាយអំពីទីផ្សារការងារ; ការកែលម្អលក្ខខណ្ឌការងារប្រកបដោយផាសុក-ភាព; ការលើកកម្ពស់ផលិតភាព; ការលើកកម្ពស់សកម្មភាពពាណិជ្ជកម្ម និងធុរកិច្ច; និង ការជំរុញ និង ការទាក់ទាញ ការវិនិយោគ, ទាំងការវិនិយោគក្នុងស្រុក និង ការវិនិយោគផ្ទាល់ពីបរទេស ។

៣. សម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ ក្នុងអត្រា

ទាបជាង ១០% និង បន្តខិតខំទាញទម្លាក់អត្រានៃភាពក្រីក្រ ឱ្យស្ថិតនៅក្នុងកម្រិតជាអប្បបរមា តាមរយៈ វិធានការបង្រួមវិសមភាពសេដ្ឋកិច្ច; ការអភិវឌ្ឍ និង ការកសាងប្រព័ន្ធគាំពារសង្គមឱ្យមានលក្ខណៈប្រមូលផ្តុំ និង សង្គតិភាព; ការកាត់បន្ថយបន្ទុកជីវភាពប្រជាជន; និង ការផ្តល់សេវាសាធារណៈ ប្រកបដោយគុណភាព, ប្រសិទ្ធភាព និង បរិយាបន្ន ។

៤. បន្តពង្រឹងសមត្ថភាព អភិបាលកិច្ច និង លើកកម្ពស់គុណភាពស្ថាប័ន, ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពនៃសេវាសាធារណៈ; បន្តពង្រឹងអភិបាលកិច្ចវិស័យឯកជន; និង បន្តកិច្ចប្រឹង-ប្រែងលើកកម្ពស់បរិយាកាសអំណោយផល សម្រាប់ធុរកិច្ច, ការវិនិយោគ និងពាណិជ្ជកម្ម ។

៥. ធានាចីរភាពនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និង កសាងភាព-ធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ដោយធ្វើបរមភាវូបនីយកម្ម (Optimization) ផលលាភប្រជាសាស្ត្រ និង ពង្រឹងភាពធន់នៃប្រជាសាស្ត្រ; លើកកម្ពស់សមភាពយេនឌ័រ; គ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព; បង្កើនហិរញ្ញ-ប្បទានចីរភាព និង បៃតង នៅក្នុងបណ្តុំកម្ចីសរុប ដើម្បីបង្កើនលំហូរហិរញ្ញវត្ថុឆ្ពោះទៅរកការវិនិយោគបៃតង និង សេដ្ឋកិច្ចបៃតង; ជំរុញការវិនិយោគសាធា-រណៈ ដែលមានភាពធន់នឹងអាកាសធាតុ និង មានការបញ្ចេញកាបូនទាប; និងធានាចីរភាពបរិស្ថាន ព្រមទាំងត្រៀមខ្លួនជាស្រេច ដើម្បីឆ្លើយតបទៅនឹងការ-ប្រែប្រួលអាកាសធាតុ ។

## អាទិភាពគន្លឹះ ៥ រួមមាន ដូចខាងក្រោម ៖

នៅក្នុងការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ក្នុងរយៈកាលកន្លងមក, រាជរដ្ឋាភិបាលបានកំណត់យកអាទិភាពគន្លឹះ ចំនួន ៤ រួមមាន **មនុស្ស ផ្លូវ ទឹក** និង **ភ្លើង** ដើម្បីជំរុញការអភិវឌ្ឍប្រទេស ដែលលំដាប់នៃសារៈ-សំខាន់របស់អាទិភាពទាំងនេះ ត្រូវបានផ្លាស់ប្តូរទៅតាមដំណាក់កាលនីមួយៗ ។

**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** កំណត់យកអាទិភាពគន្លឹះចំនួន ៥ ដោយបន្ថែមបច្ចេកវិទ្យា និង បន្តកំណត់យក **មនុស្ស** ជាអាទិភាពទី ១ ហើយ **ផ្លូវ ទឹក ភ្លើង** និង **បច្ចេកវិទ្យា** គឺជាអាទិភាព បន្តបន្ទាប់តាមលំដាប់ ។ ក្នុងន័យនេះ, បញ្ចកោណយុទ្ធសាស្ត្រ ទាំង ៥ ត្រូវបានគិតគូរឡើងវិញ ទៅតាមអាទិភាពខាងលើ ដោយរៀបចំឱ្យមានលក្ខណៈប្រទាក់ក្រឡាគ្នា ដើម្បីឆ្លើយតបទៅនឹងតម្រូវ-ការ និង ទិសដៅនៃការអភិវឌ្ឍកម្ពុជា ក្នុងដំណាក់កាលថ្មីខាងមុខ ។ អាទិភាព **"មនុស្ស"** ត្រូវបានឆ្លុះបញ្ចាំងជាចម្បង ក្នុងបញ្ចកោណទី ១ និង បំពេញបន្ថែមដោយមុំទី ១ នៃបញ្ចកោណទី ៣, មុំទី ១ នៃបញ្ចកោណទី ៤, និង មុំទី ១ នៃបញ្ចកោណទី ៥ ។ អាទិភាព **"ផ្លូវ ទឹក និង ភ្លើង"** ត្រូវបានរៀបចំជាចម្បង ក្នុងមុំទី ២ នៃបញ្ចកោណទី ២ និង មានលក្ខណៈបំពេញគ្នា ក្នុងចំណោមមុំផ្សេងទៀតនៃបញ្ចកោណនេះផង ហើយប្រទាក់គ្នាទៅនឹងមុំទី ៣ និង មុំទី ៤ នៃបញ្ចកោណទី ៤ ផង ។ អាទិភាព **"បច្ចេកវិទ្យា"** ត្រូវបានផ្តោតជាសំខាន់ក្នុងបញ្ចកោណទី ៥, ជាពិសេស ការកសាង និង ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល ដែលមាននៅក្នុងមុំទី ៣ និង មានភាពប្រទាក់ក្រឡាយ៉ាងស្អិតរមួត ក្នុងគ្រប់មុំនៃបញ្ចកោណទាំង ៤ ផ្សេងទៀត ។ ជារួម, អាទិភាពគន្លឹះទាំង ៥ ក្នុង ទម្រង់ **"បញ្ចកោណយុទ្ធសាស្ត្រ"** ត្រូវបានរៀបចំ ដូចខាងក្រោម ៖

**បញ្ចកោណទី ១ ៖ ការអភិវឌ្ឍមូលធនមនុស្ស** : (១). ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា; (២). ការបណ្តុះ-បណ្តាលជំនាញបច្ចេកទេស; (៣). ការលើកកម្ពស់សុខភាព និង សុខុមាលភាពប្រជាជន; (៤). ការពង្រឹងប្រព័ន្ធគាំពារសង្គម និង ប្រព័ន្ធស្បៀង; និង (៥). ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីល-ធម៌, សមធម៌ និង បរិយាបន្ន ។

**បញ្ចកោណទី ២ ៖ ការធ្វើពិពិធកម្មសេដ្ឋកិច្ច និង ការបង្កើនភាព-ប្រកួតប្រជែង** : (១). ការអភិវឌ្ឍវិស័យគន្លឹះ និង ប្រភពថ្មី នៃកំណើនសេដ្ឋកិច្ច;

(២). ការលើកកម្ពស់ការតភ្ជាប់ និង ការបង្កើនប្រសិទ្ធភាពនៃវិស័យដឹកជញ្ជូន និង ឡូជីស្ទីក, វិស័យថាមពល, វិស័យទឹកស្អាត និង វិស័យឌីជីថល; (៣). ការកែលម្អបរិយាកាសធុរកិច្ច និង ការវិនិយោគ; (៤). ការពង្រឹងប្រសិទ្ធភាព និង ភាពទាក់ទាញ នៃតំបន់សេដ្ឋកិច្ចពិសេស រួមបញ្ចូលនូវ សួនឧស្សាហកម្ម, សួនកសិ-ឧស្សាហកម្ម, និង តំបន់ពាណិជ្ជកម្មសេរីក្នុងស្រុក (Free-Trade Zone); និង (៥). ការនវានុវត្តយន្តការហិរញ្ញប្បទាន និង ផលិតផលហិរញ្ញវត្ថុ សម្រាប់គាំទ្រដល់ការវិនិយោគ ។

**បញ្ចកោណទី ៣៖ ការអភិវឌ្ឍវិស័យឯកជន និង ការងារ** : (១). ការអភិវឌ្ឍទីផ្សារការងារ; (២). ការលើកស្ទួយសហគ្រាសធុនមីក្រូ តូច និង មធ្យម, ធុរកិច្ចថ្មី, សហគ្រិនភាព និង ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ; (៣). ការពង្រឹងភាពជាដៃគូវិស័យសាធារណៈ និង វិស័យឯកជន; (៤). ការពង្រឹងការប្រកួតប្រជែង; និង (៥). ការពង្រឹងប្រព័ន្ធធនាគារ និង វិស័យហិរញ្ញវត្ថុមិនមែនធនាគារ ។

**បញ្ចកោណទី ៤៖ ការអភិវឌ្ឍប្រកបដោយភាពធន់, ចីរភាព និង បរិយាបន្ន** : (១). ការធ្វើបរមភាវូបនីយកម្មផលលាភប្រជាសាស្ត្រ, ការពង្រឹងភាពធន់ប្រជាសាស្ត្រ និង ការលើកកម្ពស់សមភាពយេនឌ័រ; (២). ការគ្រប់គ្រងធនធានធម្មជាតិ, បេតិកភណ្ឌវប្បធម៌ និង ទេសចរណ៍ ប្រកបដោយចីរភាព; (៣). ការលើកស្ទួយកសិកម្ម និង ការអភិវឌ្ឍជនបទ; (៤). ការពង្រឹងការគ្រប់គ្រង និង ការធ្វើទំនើបកម្មនគរូបនីយកម្ម; និង (៥). ការធានាចីរភាពបរិស្ថាន និង ការរៀបចំខ្លួនឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងការលើកកម្ពស់សេដ្ឋកិច្ចបៃតង ។

**បញ្ចកោណទី ៥ ៖ ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល** : (១). ការកសាងរដ្ឋាភិបាលឌីជីថល និង ពលរដ្ឋឌីជីថល; (២). ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល, ធុរកិច្ចឌីជីថល, ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និង

ប្រព័ន្ធនវានុវត្តឌីជីថល; (៣). ការកសាង និង ការអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធឌីជីថល; (៤). ការកសាងភាពជឿទុកចិត្តលើប្រព័ន្ធឌីជីថល; និង (៥). ការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ ។

# ផ្នែកទី ២

## ២.១. រចនាសម្ព័ន្ធ

យុទ្ធសាស្ត្របញ្ចកោណ គឺជាយុទ្ធសាស្ត្រអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរយៈពេលវែង ដែលនឹងត្រូវអនុវត្តជា ៥ ដំណាក់កាល សម្រាប់រយៈពេល ២៥ ឆ្នាំ ទៅមុខ ។ ជារួម, រចនាសម្ព័ន្ធនៃយុទ្ធសាស្ត្រនេះ មាន ៖ (១). ស្នូលនៃយុទ្ធ-សាស្ត្រគឺ : ការកែទម្រង់ និង ការពង្រឹង អភិបាលកិច្ច; (២). បរិស្ថានគ្របដណ្តប់សម្រាប់ជានាបរិយាកាសអំណោយផល ដល់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល; និង (៣). បញ្ចកោណយុទ្ធសាស្ត្រ សម្រាប់ជំរុញកំណើនសេដ្ឋកិច្ច និង វឌ្ឍន-ភាពសង្គម ។ ដោយឡែក, **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ក៏មានបញ្ចូលផងដែរ នូវ "**កម្មវិធីគោលនយោបាយអាទិភាពចំនួន ៦**" នៃ "**កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា**" ដែលត្រូវចាប់ផ្តើមអនុវត្តភ្លាម ក្នុងឆ្នាំ ២០២៣ ។

## ២.២. ស្នូល

ស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ ផ្តោតលើការកែទម្រង់ និង ការពង្រឹងអភិបាលកិច្ច, និង ការធ្វើទំនើបកម្មស្ថាប័នរដ្ឋ ឱ្យក្លាយជារដ្ឋបាលសាធារណៈទំនើប ប្រកបដោយសមត្ថភាពខ្ពស់, ខ្លាំង, វៃឆ្លាត និង ស្អាតស្អំ តាមរយៈ ការ-អនុវត្តសិទ្ធិអំណាចរដ្ឋខាងផ្នែកនយោបាយ, សេដ្ឋកិច្ច និង រដ្ឋបាល ក្នុងការដឹកនាំ, ការគ្រប់គ្រង និង ការចាត់ចែងកិច្ចការប្រទេសជាតិ, ពិសេស ការជានានិរន្តរភាពតួនាទី និង ដំណើរការរដ្ឋបាលសាធារណៈ ដោយយកចិត្តទុកដាក់លើផលប្រយោជន៍ប្រជាជន, ព្រមជាមួយនឹងការកសាងជាតិ និង ការពង្រឹងនីតិរដ្ឋ សំដៅគាំទ្រដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយបរិយាបន្ន និងចីរភាព ។ ទោះបីសម្រេចបានសមិទ្ធផលជាច្រើនយ៉ាងណាក្តី, រាជរដ្ឋាភិបាលនៅបន្តមានបញ្ហាប្រឈមមួយចំនួន ដូចជា ការត្រួតមុខងារ និង ដែនសមត្ថកិច្ច; ការបែងចែកច្បាស់លាស់នូវមុខងារ, សិទ្ធិអំណាច និង ការទទួលខុសត្រូវរបស់

ស្ថាប័នរដ្ឋ; សមត្ថភាពស្ថាប័ន និង ធនធានមនុស្ស; ការសម្របសម្រួលអន្តរ-ស្ថាប័ន; ក្របខ័ណ្ឌគណនេយ្យភាព, តម្លាភាព និង ការចែករំលែកព័ត៌មាន និង ទិន្នន័យ; ការងារត្រួតពិនិត្យ, អធិការកិច្ច និង សវនកម្ម; ការធ្វើទំនើបកម្មកង-កម្លាំងប្រដាប់អាវុធ; និង ក្របខ័ណ្ឌអភិបាលកិច្ចវិស័យឯកជន ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលបន្តផ្តោតលើ (១). ការពង្រឹង និង ការកែទម្រង់ស្ថាប័ន; (២). ការលើកកម្ពស់សមត្ថភាពធនធានមនុស្ស និង ការពង្រឹងប្រសិទ្ធភាពនៃការអនុ-វត្តការងារ; (៣). ការលើកកម្ពស់ និង ការពង្រឹងភាពស្អាតស្អំ នៅក្នុងរដ្ឋបាល សាធារណៈ; (៤). ការលើកកម្ពស់ និង ការពង្រឹងប្រសិទ្ធភាពនៃ ច្បាប់ និង ប្រព័ន្ធយុត្តិធម៌; និង (៥). ការពង្រឹងអភិបាលកិច្ច វិស័យឯកជន និង ធុរកិច្ច ។

### មុំទី១. ការពង្រឹង និង ការកែទម្រង់ស្ថាប័ន

គោលដៅជាយុទ្ធសាស្ត្រ គឺការកសាងរដ្ឋបាលសាធារណៈ ដែលមាន សមត្ថភាពខ្ពស់, ខ្លាំង, វៃឆ្លាត និង ស្អាតស្អំ ដើម្បីបម្រើផលប្រយោជន៍ជូន ប្រជាជន ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

ទី១- ការធ្វើវិចារណកម្ម មុខងារ និង រចនាសម្ព័ន្ធស្ថាប័ន និង ការ-កំណត់បែបបទនៃការផ្តល់សេវារបស់ក្រសួង-ស្ថាប័នថ្នាក់ជាតិ និង រដ្ឋបាល ថ្នាក់ក្រោមជាតិ, ជាពិសេស ការកំណត់ច្បាស់លាស់នូវ មុខងារ និង ភារកិច្ច; ការធ្វើប្រតិភូកម្មអំណាចសមស្រប; ការកំណត់កម្រិតសិទ្ធិអំណាច, ការទទួល ខុសត្រូវ និង គណនេយ្យភាព ក្នុងក្របខ័ណ្ឌនៃការដឹកនាំ, ការគ្រប់គ្រង និង ប្រតិបត្តិការ; ការពង្រឹងយន្តការសម្របសម្រួលផ្នែកស្ថាប័ន និង សមាហរណ-កម្មសេវា; និង ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ក្នុងរដ្ឋបាលសាធារណៈ ។

ទី២- ការពង្រឹងសមត្ថភាពនៃភាពជាអ្នកដឹកនាំ តាមរយៈ ការរៀបចំ និង ការដាក់ឱ្យអនុវត្ត ក្របខ័ណ្ឌសមត្ថភាពនៃភាពជាអ្នកដឹកនាំ; ការបណ្តុះ-បណ្តាលភាពជាអ្នកដឹកនាំ; ការវាយតម្លៃ និង ការទទួលស្គាល់ អ្នកដឹកនាំគំរូ;

និង ការរៀបចំបណ្តាញអ្នកដឹកនាំ ក្នុងរដ្ឋបាលសាធារណៈ ។

ទី៣- ការពង្រឹងប្រព័ន្ធគ្រប់គ្រងមុខងារសាធារណៈ និង សមត្ថភាពគ្រប់គ្រងរដ្ឋបាលសាធារណៈ តាមរយៈ ការកែលម្អក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធនឹងមុខងារសាធារណៈ; ការដាក់ឱ្យអនុវត្តក្របខ័ណ្ឌនៃការលើកកម្ពស់ផលិតភាពការងារ; ការគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម; និង ការជំរុញចលនាប្រឡងប្រណាំង និង ការនវានុវត្ត ។

ទី៤- ការបន្តជំរុញលើកកម្ពស់សមត្ថភាពកងកម្លាំងប្រដាប់អាវុធ តាមរយៈ ការអភិវឌ្ឍស្ថាប័ន និង ការកសាងមូលធនមនុស្ស; ការយកចិត្តទុកដាក់ខ្ពស់លើជីវភាព និង សុខុមាលភាព នៃកងកម្លាំងប្រដាប់អាវុធ; ព្រមទាំងការជំរុញការអនុវត្តគោលនយោបាយសមស្រប ចំពោះកងកម្លាំងប្រដាប់អាវុធចូលនិវត្តន៍, បាត់បង់សមត្ថភាព, ពលីពិការ ដោយសារបុព្វហេតុថែរក្សាការពារសន្តិសុខជាតិ ។

### មុំទី២. ការលើកកម្ពស់សមត្ថភាពធនធានមនុស្ស និង ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ

គោលដៅជាយុទ្ធសាស្ត្រ គឺការកសាងធនធានមនុស្ស ប្រកបដោយសមត្ថភាព, ជំនាញ, ឆន្ទៈម្ចាស់ការ និង ក្រមសីលធម៌វិជ្ជាជីវៈ ស្របតាមតួនាទី និង ការទទួលខុសត្រូវ ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

ទី១- ការពង្រឹងប្រព័ន្ធគ្រប់គ្រង និង អភិវឌ្ឍធនធានមនុស្ស ក្នុងមុខងារសាធារណៈ ផ្អែកលើគុណាធិបតេយ្យ ក្នុងការជ្រើសរើស, ការតែងតាំង, ការដំឡើងថ្នាក់ និង ឋានន្តរស័ក្តិ, និង ការផ្តល់ការលើកទឹកចិត្តសមស្រប, ព្រមទាំងការរៀបចំប្រព័ន្ធអភិវឌ្ឍសមត្ថភាពគ្រប់ជ្រុងជ្រោយ ។

ទី២- ការរៀបចំ ប្រព័ន្ធបៀវត្ស និង ប្រព័ន្ធលើកទឹកចិត្ត ក្នុងវិស័យសាធារណៈ ឱ្យកាន់តែមានប្រសិទ្ធភាព និង ភាពគ្រប់ជ្រុងជ្រោយ ដោយផ្អែក-

លើគុណាធិបតេយ្យ សំដៅលើកកម្ពស់ ផលិតភាពការងារ, សមិទ្ធកម្ម និង ជីវភាពមន្ត្រីសាធារណៈ ឱ្យមានសង្គតិភាព ជាមួយកំណើនសេដ្ឋកិច្ច និង លទ្ធ-ភាពនៃថវិកាជាតិ ។

ទី៣- ការពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង និង ការអភិវឌ្ឍធនធានមនុស្ស នៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការធ្វើប្រតិភូកម្ម អំណាច និង ការទទួលខុសត្រូវ ក្នុងការជ្រើសរើស, ការគ្រប់គ្រង, ការចាត់ចែង និង ការប្រើ-ប្រាស់ បុគ្គលិក ។

ទី៤- ការបន្តកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការបង្កើននូវភាពជឿទុកចិត្តនៃថវិកា, គណនេយ្យភាពហិរញ្ញវត្ថុ, ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ, និង គណនេយ្យភាពសមិទ្ធកម្ម សំដៅកសាងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ស្របតាម ស្តង់ដា និង ឧត្តមានុវត្តន៍អន្តរជាតិ ។

ទី៥- ការធ្វើវិមជ្ឈការហិរញ្ញវត្ថុ និង ការរៀបចំផែនការ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាធនធានថវិកាសមស្រប សម្រាប់បំពេញ មុខងារ និង អាទិភាពគោលនយោបាយ ដូចមានកំណត់ក្នុង ផែនការអភិវឌ្ឍ, កម្មវិធីវិនិយោគ និង ផែនការយុទ្ធសាស្ត្រថវិកា ។

ទី៦- ការបន្តជំរុញការធ្វើទំនើបកម្ម និង ការប្រើប្រាស់មូលដ្ឋានទិន្នន័យ និង ការចែករំលែក និង ការផ្លាស់ប្តូរព័ត៌មាន ក្នុងរដ្ឋបាលសាធារណៈ ។

### មុំទី៣. ការលើកកម្ពស់ និង ការពង្រឹងភាពស្អាតស្អំ នៅក្នុងរដ្ឋបាលសាធារណៈ

គោលដៅជាយុទ្ធសាស្ត្រ គឺការលើកកម្ពស់ និង ការពង្រឹង ភាពស្អាត-ស្អំ, ភាពសុចរិត និង ជំនឿទុកចិត្តចំពោះរដ្ឋបាលសាធារណៈ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយ ប្រសិទ្ធភាព, បរិយាបន្ន និង ចីរភាព ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

ទី១- ការរៀបចំ និង ការដាក់ឱ្យអនុវត្ត ក្រមសីលធម៌វិជ្ជាជីវៈ និង ក្រមប្រតិបត្តិ ក្នុងមុខងារសាធារណៈ ព្រមទាំងការជំរុញការគោរពខ្ជាប់ខ្ជួននូវគោលការណ៍វិសមិតភាពមុខងារ និង ទំនាស់ផលប្រយោជន៍ ក្នុងការបំពេញការងាររបស់មន្ត្រីសាធារណៈ។

ទី២- ការពង្រឹងប្រសិទ្ធភាពនៃការធ្វើអធិការកិច្ច និង សវនកម្ម ព្រមទាំងការរៀបចំក្របខ័ណ្ឌ និង វិធាន នៃប្រព័ន្ធអធិការកិច្ច និង សវនកម្ម ដើម្បីធានាសុខដុមនីយកម្មនៃមុខងារអធិការកិច្ច និង សវនកម្ម ក្នុងរដ្ឋបាលសាធារណៈ ។

ទី៣- ការពង្រឹងយន្តការគ្រប់គ្រង និង ផ្តល់សេវាសាធារណៈ, ការផ្តល់ការលើកទឹកចិត្ត ផ្អែកលើគុណាធិបតេយ្យ, និង ការចាត់វិធានការម៉ឺងម៉ាត់ តាមច្បាប់ ក្នុងការអនុវត្តតួនាទី និង ភារកិច្ច ដើម្បីបង្កើន ជំនឿទុកចិត្ត និង ប្រសិទ្ធភាព នៃការផ្តល់សេវាសាធារណៈ ។

ទី៤- ការបន្តពង្រឹង និង ពង្រីកការងារអប់រំ និង បង្ការទប់ស្កាត់ជាចម្បង ព្រមទាំងការពង្រឹងការអនុវត្តច្បាប់យ៉ាងម៉ឺងម៉ាត់ ដើម្បីបង្ក្រាបបទល្មើសអំពើពុករលួយ ។

ទី៥- ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងអង្គភាពប្រឆាំងអំពើពុករលួយ និង ស្ថាប័នសាធារណៈ, ជាពិសេស តាមរយៈយន្តការជនបង្គោល, ទាំងការងារអប់រំ និង ការងារបង្ការទប់ស្កាត់, ដើម្បីរៀបចំដាក់ឱ្យអនុវត្ត, តាមដានត្រួតពិនិត្យ និង វាយតម្លៃ ការអនុវត្តផែនការយុទ្ធសាស្ត្រ និង ផែនការលើកកម្ពស់ភាពស្អាតស្អំ នៅតាមស្ថាប័នសាធារណៈ ។

### មុំទី៤. ការលើកកម្ពស់ និង ការពង្រឹង ប្រសិទ្ធភាពនៃច្បាប់ និង ប្រព័ន្ធយុត្តិធម៌

គោលដៅជាយុទ្ធសាស្ត្រ គឺការពង្រឹងគោលការណ៍នីតិរដ្ឋ, ការពង្រឹងការប្រយុទ្ធប្រឆាំងអំពើបំពានដោយអយុត្តិធម៌ក្នុងសង្គម, និង ការពង្រឹងជំនឿ

ទុកចិត្តពីសាធារណជនមកលើវិស័យយុត្តិធម៌ ដែលជាកត្តារួមចំណែកដ៏សំខាន់ក្នុងការធានាថែរក្សាស្ថិរភាពសង្គម, សណ្តាប់ធ្នាប់សាធារណៈ និង ភាពសុខ-ដុមរមនា ក្នុងសង្គមជាតិ ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

ទី១- ការលើកកម្ពស់សមត្ថភាពធនធានមនុស្ស ក្នុងវិស័យយុត្តិធម៌, ទាំងបរិមាណ និង គុណភាព, ដើម្បី បង្កើនប្រសិទ្ធភាពការងារ ក្នុងវិស័យយុត្តិ-ធម៌ និង ប្រសិទ្ធភាព និង ភាពរហ័ស នៃការដោះស្រាយវិវាទ, ទាំងក្នុងប្រព័ន្ធតុលាការ និង ក្រៅប្រព័ន្ធតុលាការ ។

ទី២- ការលើកកម្ពស់ប្រសិទ្ធភាព, សង្គតិភាព និង អនុលោមភាពគតិ-យុត្ត នៃការរៀបចំច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត សំដៅជានាឆ្លើយតបទៅនឹងចក្ខុវិស័យ និង សេចក្តីត្រូវការនានា របស់សង្គមជាតិ ។

ទី៣- ការលើកកម្ពស់ការគោរពច្បាប់ និង ការផ្តល់សេវាជំនួយផ្នែកច្បាប់ តាមរយៈ ការបន្តជំរុញការអប់រំ និង ការផ្សព្វផ្សាយច្បាប់, ការផ្តល់ការ-ពិគ្រោះយោបល់ផ្នែកច្បាប់ និង ការផ្តល់ការការពារក្តី នៅចំពោះមុខតុលាការ សំដៅជានាសិទ្ធិទទួលបានយុត្តិធម៌, ជាពិសេស សម្រាប់ប្រជាពលរដ្ឋក្រីក្រ និង ជនងាយរងគ្រោះ ។

ទី៤- ការលើកកម្ពស់ភាពត្រឹមត្រូវ និង ប្រសិទ្ធភាព នៃការអនុវត្តច្បាប់ពីសំណាក់មន្ត្រីអនុវត្តច្បាប់ និង មន្ត្រីតុលាការ, ជាពិសេស ការពង្រឹងប្រសិទ្ធ-ភាព នៃចំណាត់ការលើសំណុំរឿង, ការពង្រឹង ភាពសុចរិត ភាពស្អាតស្អំ និង ក្រមសីលធម៌វិជ្ជាជីវៈ របស់មន្ត្រីអនុវត្តច្បាប់ និង មន្ត្រីតុលាការ, ព្រមទាំងការពង្រឹងយន្តការអធិការកិច្ច និង ការដាក់វិន័យ សំដៅបង្កើនជំនឿទុកចិត្តលើការ-អនុវត្តច្បាប់ ។

ទី៥- ការលើកកម្ពស់ គុណភាព និង ប្រសិទ្ធភាព នៃប្រព័ន្ធតុលាការតាមរយៈការបន្តធ្វើទំនើបកម្មរដ្ឋបាលតុលាការ ដើម្បីលើកកម្ពស់គុណភាពនៃ

ការផ្តល់សេវាយុត្តិធម៌ឱ្យកាន់តែប្រសើរ និង ការពង្រឹងគុណភាពនៃយុត្តិធម៌ ។

ទី៦- ការជំរុញការរៀបចំក្របខ័ណ្ឌគតិយុត្ត និង យន្តការសម្រុះសម្រួល និង ផ្សះផ្សាវិវាទ, ទាំងក្នុងប្រព័ន្ធតុលាការ និង ក្រៅប្រព័ន្ធតុលាការ, សំដៅលើកកម្ពស់ ប្រសិទ្ធភាព និង ភាពរហ័ស នៃការដោះស្រាយវិវាទ, និង បង្កិតសេវានៃការដោះស្រាយវិវាទ ឱ្យកៀកនឹងប្រជាពលរដ្ឋ ។

## មុំទី៥. ការពង្រឹងអភិបាលកិច្ចវិស័យឯកជន និង ធុរកិច្ច

គោលដៅជាយុទ្ធសាស្ត្រ គឺការពង្រឹងជំនឿទុកចិត្តរបស់តួអង្គពាក់ព័ន្ធមកលើវិស័យឯកជន និង ធុរកិច្ច តាមរយៈការជំរុញឱ្យមានអភិបាលកិច្ចល្អ ក្នុងវិស័យឯកជន និង ធុរកិច្ច ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

ទី១- ការពង្រឹង និង ការលើកកម្ពស់ អភិបាលកិច្ចល្អ ក្នុងវិស័យឯកជន និង ធុរកិច្ច តាមរយៈ ការរៀបចំ និង ការដាក់ចេញ ក្របខ័ណ្ឌគោលនយោបាយពាក់ព័ន្ធនឹងអភិបាលកិច្ចល្អ, លិខិតបទដ្ឋានគតិយុត្ត និង គោលការណ៍ណែនាំពាក់ព័ន្ធចាំបាច់នានា ក្នុងវិស័យឯកជន និង ធុរកិច្ច ។

ទី២- ការជំរុញការរៀបចំ និង ការដាក់ឱ្យអនុវត្ត ក្របខ័ណ្ឌគោលនយោបាយលើកកម្ពស់ការទទួលខុសត្រូវផ្នែកសង្គម និង បរិស្ថាន របស់វិស័យឯកជន និង ធុរកិច្ច ដើម្បីបង្កើនការចូលរួមដោះស្រាយបញ្ហាសង្គម និង លើកកម្ពស់តម្លៃសីលធម៌សង្គម និង វប្បធម៌ជាតិ និង ការថែរក្សាបរិស្ថាន ដោយផ្តល់នូវយន្តការគាំទ្រ និង លើកទឹកចិត្តសមស្រប ដល់ធុរកិច្ចទាំងឡាយណា ដែលអនុវត្តបាននូវអភិបាលកិច្ចល្អ និង មានការទទួលខុសត្រូវខ្ពស់ផ្នែកសង្គម និង បរិស្ថាន ។

ទី៣- ការពិនិត្យឡើងវិញ, ការធ្វើបច្ចុប្បន្នកម្ម, ការកែលម្អ និង ការធ្វើវិសោធនកម្ម ច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ជាធរមាន ព្រមទាំងការពិនិត្យ និង ការដាក់ចេញ នូវយន្តការពង្រឹងការអនុវត្តច្បាប់ ។

ទី៤- ការជំរុញការរៀបចំ និង ការផ្តល់ការគាំទ្រ ដល់វិស័យឯកជន និង អង្គការសង្គមស៊ីវិល ក្នុងការរៀបចំក្រមសីលធម៌ និង វិជ្ជាជីវៈ, និង លើក-ទឹកចិត្តឱ្យមានការរៀបចំស្តង់ដាគុណវុឌ្ឍិ សម្រាប់គណៈគ្រប់គ្រងនៃវិស័យឯកជន និង អង្គការសង្គមស៊ីវិល ដើម្បីបង្កើនការទទួលខុសត្រូវផ្ទាល់ខ្លួន និង កាត់បន្ថយទំនាស់ផលប្រយោជន៍ផ្ទាល់ខ្លួន និង ផលប្រយោជន៍សាធារណៈ ។

ទី៥- ការបង្កើនប្រសិទ្ធភាពយន្តការសន្ទនា និង ភាពជាដៃគូ រវាងរដ្ឋ និង ឯកជន ក្នុងកម្រិតគោលនយោបាយ និង បច្ចេកទេស, ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, ដើម្បីជំរុញការពិភាក្សាផ្នែកគោលនយោបាយ និង ការស្វែងរកដំណោះស្រាយ ចំពោះបញ្ហាប្រឈមនានា ដោយលើកកម្ពស់ការប្រើប្រាស់តួនាទីនៃសភាពាណិជ្ជកម្ម, ទាំងក្នុង និង ក្រៅស្រុក, និង តួអង្គពាក់ព័ន្ធ ។

ទី៦- ការបង្កើន ប្រសិទ្ធភាព និង តម្លាភាព នៃអធិការកិច្ចវិស័យឯក-ជន និង ធុរកិច្ច តាមរយៈ ការជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក្នុងការធ្វើអធិការកិច្ច, ការពង្រឹងសមត្ថភាព និង ភាពសុចរិត របស់អ្នកធ្វើអធិការ-កិច្ច, និង ការជំរុញការអនុវត្តវិធានការអធិការកិច្ច ។

## ២.៣. បរិស្ថានគ្របដណ្តប់

បរិស្ថានគ្របដណ្តប់កំណត់នូវក្របខ័ណ្ឌពេញលេញ និង គ្រប់ជ្រុង-ជ្រោយ ដើម្បីធានាការសម្រេចបាននូវអាទិភាពគោលនយោបាយនៃ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ។ កម្ពុជាទទួលបានជោគជ័យដ៏ត្រចះត្រចង់ ដោយបានកែប្រែ និង លើកមុខមាត់ និង កិត្យានុភាព, ទាំងនៅថ្នាក់តំបន់ និង សកលលោក, តាមរយៈ ការរក្សាបាននូវ សន្តិសុខ និង ស្ថិរភាពនយោបាយ ដែលជាបុរេលក្ខខណ្ឌ ក្នុងការធានាបាននូវការអភិវឌ្ឍ, ការអនុវត្តគោលនយោបាយសេដ្ឋកិច្ចបើកចំហ, ការបន្តអភិវឌ្ឍ និង ការលើកកម្ពស់ការចូលរួមរបស់វិស័យឯកជន, និង ការពង្រឹងភាពជាម្ចាស់, ភាពជាដៃគូ និង យន្តការសម្រាប់កិច្ច-សហប្រតិបត្តិការ ក្នុងការកៀរគរធនធានហិរញ្ញវត្ថុ បច្ចេកទេស និង ចំណេះដឹង

សម្រាប់អភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។ ក្នុងបរិការណ៍នៃភូមិសាស្ត្រនយោបាយ និង និន្នាការសកលធំៗនាបច្ចុប្បន្ន, រាជរដ្ឋាភិបាលបន្តផ្តោតលើ : (១). ការបន្តពង្រឹងសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និង សណ្តាប់ធ្នាប់សាធារណៈ; (២). ការប្រកាន់ខ្ជាប់នូវនយោបាយការបរទេសឯករាជ្យ, ផ្អែកលើច្បាប់ និង ឈ្លាស-វៃ; (៣). ការធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ; (៤). ការបន្តកសាងភាពជាដៃគូប្រកបដោយបរិយាបន្ន និង ស័ក្តិសិទ្ធភាព នៃកិច្ចសហប្រតិ-បត្តិការអភិវឌ្ឍន៍; និង (៥). ការបន្តធ្វើសមាហរណកម្ម ស៊ីជម្រៅ ទៅក្នុងតំបន់ និង សកលលោក ។

## មុំទី១. ការបន្តពង្រឹងសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និង សណ្តាប់ធ្នាប់សាធារណៈ

គោលដៅជាយុទ្ធសាស្ត្រ គឺការបន្តការពារឱ្យបានជាដាច់ខាត នូវសន្តិ-ភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និង សណ្តាប់ធ្នាប់សាធារណៈ ដែលកត្តាទាំងនេះ ជាបុរេលក្ខខណ្ឌមិនអាចខ្វះបាន សម្រាប់ការអភិវឌ្ឍប្រទេសជាតិ ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

ទី១- ការការពារ ឯករាជ្យ, អធិបតេយ្យជាតិ និង បូរណភាពទឹកដី មិនឱ្យមានការលូកដៃជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់កម្ពុជា, ព្រមទាំងការទប់-ស្កាត់ និង ការប្រឆាំងដាច់ខាត រាល់សកម្មភាពប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ឬ ការញុះញង់ណាមួយ ដើម្បីបង្កអស្ថិរភាពនយោបាយ ឬ ចលាចលក្នុងសង្គម ។

ទី២- ការបន្តពង្រឹង នីតិរដ្ឋ, លទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស, វប្ប-ធម៌សន្តិភាព, សីលធម៌សង្គម, ការគោរពសិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស, និង ការបន្តពង្រឹង បរិយាកាសល្អ និង ប្រក្រតីភាពរឹងមាំ ក្នុងការបំពេញមុខងារនៃស្ថាប័នសាធារណៈ ។

ទី៣- ការបន្តដោះស្រាយបញ្ហាព្រំដែនគោក និង សមុទ្រ ជាមួយប្រ-

ទេសជិតខាង ដោយផ្អែកលើមូលដ្ឋានច្បាប់អន្តរជាតិ ក៏ដូចជាការបន្តរៀបចំ និង ការជំរុញ អនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍតំបន់ព្រំដែន ជាព្រំដែនសន្តិភាព, មិត្តភាព, សហប្រតិបត្តិការ និង ការអភិវឌ្ឍ, ទន្ទឹមនឹងការបន្តប្រកាន់ខ្ជាប់គោលការណ៍មិនអនុញ្ញាតឱ្យប្រើប្រាស់ទឹកដីកម្ពុជា ដើម្បីប្រឆាំងនឹងប្រទេសជិតខាង ។

ទី៤- ការទប់ស្កាត់ និង ការបង្ក្រាប បទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ រួមទាំងការប្រយុទ្ធប្រឆាំងភេរវកម្ម, ឧក្រិដ្ឋកម្មឆ្លងដែន, អំពើជួញដូរមនុស្ស, ការជួញដូរពលកម្ម, អាជីវកម្មផ្លូវភេទ, បទល្មើសសម្អាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម, ហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ, ការប្រយុទ្ធប្រឆាំងសកម្មភាពពាក់ព័ន្ធនឹង ការជួញដូរ និង ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់, ល្បែងស៊ីសងខុសច្បាប់, ព្រមទាំងការបន្តពង្រឹងការអនុវត្ត "**គោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព**" ។

ទី៥- ការបន្តពង្រឹង សុវត្ថិភាពចរាចរណ៍ និង សណ្តាប់ធ្នាប់តាមដងផ្លូវ តាមទីក្រុង និង ទីប្រជុំជន ដើម្បី ដោះស្រាយការកកស្ទះចរាចរណ៍ និង កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ សំដៅកាត់បន្ថយថ្លៃនានា និង បង្កើនការធ្វើបរមភាវូបនីយកម្មផលសេដ្ឋកិច្ច ។

ទី៦- ការបន្តជំរុញកិច្ចប្រឹងប្រែង ដើម្បីសម្រេចឱ្យបាននូវ "**កម្ពុជាគ្មានមីនត្រឹមឆ្នាំ ២០២៥**" និង កាត់បន្ថយគ្រាប់មិនទាន់ផ្ទុះឱ្យបានជាអតិបរមា ។

ទី៧- ការបង្ការ និង ការដោះស្រាយ បញ្ហាអគ្គិភ័យ និង គ្រោះថ្នាក់នានា ក្នុងសង្គម ដើម្បីរក្សាសុវត្ថិភាពជូនប្រជាជន ខណៈមានការកើនឡើងនៃនគរូបនីយកម្ម, ប្រជាជននៅទីប្រជុំជន, និង ការអភិវឌ្ឍសំណង់អគារខ្ពស់ៗ ។

ទី៨- ការបន្តពង្រឹងការអនុវត្ត ច្បាប់ស្តីពីសញ្ជាតិ និង ច្បាប់ស្តីពីអន្តោប្រវេសន៍; ការបន្តជំរុញរៀបចំក្របខ័ណ្ឌគតិយុត្ត និង យន្តការនានា ដើម្បីធានាថា "**មនុស្សម្នាក់មានអត្តសញ្ញាណតែមួយ**" និង "**មនុស្សទាំងអស់ត្រូវបានកំណត់អត្តសញ្ញាណ**"; ការគ្រប់គ្រងការចេញ-ចូលកម្ពុជា; ការគ្រប់គ្រង ការស្នាក់នៅ

និង ការប្រកបមុខរបររបស់ជនបរទេស; និង ការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យអន្តោប្រវេសន៍ សំដៅបង្ការ និង ទប់ស្កាត់ ការលបលួចជ្រៀតចូល, ការស្នាក់នៅ និង ការប្រកបមុខរបរ ដោយខុសច្បាប់ ។

ទី៩- ការពង្រឹង ការអនុវត្តច្បាប់ និង ការកសាងសមត្ថភាព ដើម្បីទប់ស្កាត់បទល្មើស តាមប្រព័ន្ធបច្ចេកវិទ្យា ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

ទី១០- ការជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម ឆ្នាំ ២០១៧-២០២៦ ដោយបង្កើតឱ្យមានមជ្ឈមណ្ឌលជាតិគ្រប់គ្រងទិន្នន័យប្រជាជន; រៀបចំឱ្យប្រើប្រាស់លេខសម្គាល់អត្តសញ្ញាណបុគ្គល; និង ជំរុញការអនុវត្តច្បាប់ស្តីពីអត្រានុកូលដ្ឋាន, ស្ថិតិអត្រានុកូលដ្ឋាន និង អត្តសញ្ញាណកម្ម, និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

### មុំទី២. ការប្រកាន់ខ្ជាប់នូវនយោបាយការបរទេសឯករាជ្យ, ផ្អែកលើច្បាប់ និង ឈ្លាសវៃ

គោលដៅជាយុទ្ធសាស្ត្រ គឺការបន្តពង្រឹងការអនុវត្តនយោបាយការបរទេសឯករាជ្យ ផ្អែកលើច្បាប់ ក្នុងកិច្ចការពារ និង ក្នុងការជំរុញបង្កើនផលប្រយោជន៍ស្នូលរបស់ជាតិ; និង ការកសាងមិត្តភាព និង កិច្ចសហប្រតិបត្តិការប្រសើរ ជាមួយប្រទេសទាំងអស់នៅលើសកលលោក និង អង្គការអន្តរជាតិនានា; ព្រមទាំងការចូលរួមយ៉ាងសកម្ម ចំពោះបុព្វហេតុសន្តិភាព, ស្ថិរភាព, សន្តិសុខ និង វិបុលភាព ក្នុងតំបន់ និង សកលលោក ស្របតាមអភិក្រម **"រក្សាចាស់, បង្កើតថ្មី"** ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

ទី១- ការបន្តអនុវត្តនយោបាយការបរទេសឯករាជ្យ ដោយផ្អែកលើច្បាប់អន្តរជាតិ និង គោរពដាច់ខាតនូវ អធិបតេយ្យ, បូរណភាពទឹកដី និង ឯករាជ្យរបស់រដ្ឋសមាជិក អនុលោមតាមធម្មនុញ្ញអង្គការសហប្រជាជាតិ និង គោលការណ៍ដែលទទួលស្គាល់ជាសកល ។

ទី២- ការបន្តប្រកាន់គោលការណ៍មិនគាំទ្រ ការប្រើប្រាស់ ឬ ការគំរាមប្រើប្រាស់កម្លាំង ក្នុងទំនាក់ទំនងអន្តរជាតិ, ការឈ្លានពានប្រឆាំងរដ្ឋឯករាជ្យ, ការបំបែករដ្ឋ, ការកាត់យកទឹកដីពីរដ្ឋអធិបតេយ្យ និង ការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសដទៃ ព្រមទាំងការបន្តប្រកាន់ជំហរម៉ឺងម៉ាត់ ក្នុងការមិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធាបរទេសក្នុងទឹកដីកម្ពុជា ។

ទី៣- ការបន្តប្រកាន់គោលការណ៍អព្យាក្រឹត្យអចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ; និង ការអនុវត្តការទូតទន់ភ្លន់, ប៉ុន្តែ ម៉ឺងម៉ាត់, បត់បែន, និង ថ្លឹងថ្លែង, ស្របតាមការផ្លាស់ប្តូរផ្នែកយុទ្ធសាស្ត្រភូមិសាស្ត្រនយោបាយ ក្នុងតំបន់ និង សកលលោក ។

ទី៤- ការបន្តតម្កល់ផលប្រយោជន៍ស្នូលរបស់ជាតិជាចម្បង ក្នុងការអនុវត្តគោលនយោបាយការបរទេស ដែលចូលរួមចំណែកដល់ការការពារអធិបតេយ្យជាតិ និង បូរណភាពទឹកដី, ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច សម្រាប់លើកកម្ពស់ជីវភាពប្រជាជន, និង ការលើកតម្កើងកិត្យានុភាព និង ឧត្តមភាពជាតិ, ទាំងក្នុងក្របខ័ណ្ឌតំបន់ និង សកលលោក ។

ទី៥- ការលើកកម្ពស់ទំនាក់ទំនងល្អជាមួយប្រទេសជិតខាង ដើម្បីសម្រេចចក្ខុវិស័យប្រែក្លាយព្រំដែនទៅជាតំបន់ សន្តិភាព, ស្ថិរភាព, និង ការរីកចម្រើន, ទន្ទឹមនឹងការបន្តពង្រឹង និង ពង្រីកទំនាក់ទំនងជាមួយដៃគូយុទ្ធសាស្ត្រនានា, ទាំងក្នុង និង ក្រៅតំបន់។

ទី៦- ការបន្តពង្រឹងតួនាទីរបស់កម្ពុជានៅក្នុងអាស៊ាន តាមរយៈ ការចូលរួមយ៉ាងសកម្ម ប្រកបដោយស្មារតីស្ថាបនា នៅក្នុងការងាររក្សាសាមគ្គីភាពផ្ទៃក្នុងអាស៊ាន, និង ការធ្វើសមាហរណកម្មតំបន់ ស្របតាមធម្មនុញ្ញអាស៊ាន ជាពិសេស ការធ្វើការសម្រេចចិត្តនានា ដោយផ្អែកលើការពិភាក្សា និង យន្តការកុងសង់ស៊ីស និង ដោយមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសសមាជិក ។

ទី៧- ការបន្តពង្រឹងពហុភាគីនិយម តាមរយៈ ការចូលរួមសកម្មក្នុង

វេទិកាតំបន់ និង អន្តរជាតិ; ការរួមចំណែកក្នុងប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ; ការចូលរួមរក្សាស្ថិរភាព និង សន្តិភាព ដោយលើកតម្កើងកិច្ចសន្ទនា និង ការដោះស្រាយបញ្ហាដោយសន្តិវិធី; និង ការលើកស្ទួយពាណិជ្ជកម្មពហុភាគីដែលសេរី, បើកចំហ, និង ផ្អែកលើវិធានច្បាប់ ។

ទី៨- ការបន្តអនុវត្តគោលនយោបាយការបរទេសពហុវិមាត្រ និង ពហុសណ្ឋាន សំដៅបង្កើនប្រសិទ្ធភាព ក្នុងកិច្ចការពារ និង ការជំរុញផលប្រយោជន៍ជាតិ ដោយចូលរួមយ៉ាងសកម្ម ក្នុងវិស័យពាក់ព័ន្ធ ដែលបង្កើតឱ្យមានសហថាមពល ក្នុងការបង្កើនអំណាចចរចា; និង សំដៅឆ្លើយតបទាន់ពេល ដើម្បីពង្រីកលំហបត់បែនយុទ្ធសាស្ត្រ នៅក្នុងកិច្ចការទំនាក់ទំនងអន្តរជាតិ ។

ទី៩- ការបន្តពង្រឹង ជំនឿពីអន្តរជាតិ និង ការយល់ឃើញត្រឹមត្រូវមកលើកម្ពុជា, ជាពិសេស អំពីស្ថានភាពពិត និង ជាក់ស្តែង របស់កម្ពុជា, ដើម្បីធ្វើឱ្យប្រសើរឡើងនូវ ទំនាក់ទំនងជាមួយដៃគូ, កិត្យានុភាព និង ការផ្សព្វផ្សាយកម្ពុជាជាសកល សំដៅបង្កើនភាពទាក់ទាញ និង លើកកម្ពស់ ទំនាក់ទំនង សេដ្ឋកិច្ច, ការវិនិយោគ និង ទេសចរណ៍ ។

ទី១០- ការបន្តធ្វើការកែទម្រង់ស្ថាប័ន និង បណ្តុះបណ្តាលធនធានមនុស្ស ក្នុងកិច្ចការការបរទេសឱ្យមាន សមត្ថភាពខ្ពស់, ជំនាញគ្រប់គ្រាន់ និង ភាពប៉ិនប្រសប់ សម្រាប់ការពារប្រយោជន៍ស្នូលរបស់ជាតិ ។

### មុំទី៣. ការធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គឺជាលក្ខខណ្ឌចាំបាច់ សម្រាប់ការលើកកម្ពស់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយ បរិយាបន្ន, ភាពធន់ និង ចីរភាព ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

ទី១- ការបន្តរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដើម្បីធានាបានចីរភាពនៃកំណើនប្រកបដោយបរិយាបន្ន តាមរយៈ ការគ្រប់គ្រងអតិផរណា ឱ្យស្ថិតក្នុង

កម្រិតសមស្រប, ការរក្សាស្ថិរភាពអត្រាប្តូរប្រាក់, ការបង្កើនទុនបម្រុងរបស់ជាតិ និង ការរក្សាលំនឹងជីវភាពប្រជាជន ។

ទី២- ការកែទម្រង់កាន់តែស៊ីជម្រៅ និង មុតស្រួច, ពិសេស ចំពោះ បញ្ហាប្រឈមដែលមានចរិតជារចនាសម្ព័ន្ធ និង អន្តរស្ថាប័ន, សំដៅលើកកម្ពស់ ពិពិធកម្មសេដ្ឋកិច្ច, បង្កើនផលិតភាព និង ភាពប្រកួតប្រជែង របស់កម្ពុជា ។

ទី៣- ការរក្សាចីរភាពហិរញ្ញវត្ថុសាធាណៈ តាមរយៈ ការបន្តជំរុញ អនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយផ្តាតលើការពង្រឹង ការប្រមូលចំណូល និង ការបង្កើនប្រសិទ្ធភាពចំណាយ, ការពង្រឹងការគ្រប់គ្រង ទ្រព្យសម្បត្តិរដ្ឋ, ការគ្រប់គ្រងបំណុលសាធារណៈ ប្រកបដោយចីរភាព, ការ-ជំរុញអភិវឌ្ឍយន្តការកៀរគរហិរញ្ញប្បទាន ពីប្រភពធនធានក្នុងស្រុក, និង ការ-ពង្រីកលំហថវិកាជាតិ ជាលំដាប់ ។

ទី៤- ការពង្រឹង ស្ថិរភាព និង ភាពធន់ហិរញ្ញវត្ថុ, ទាំងវិស័យធនាគារ និង វិស័យហិរញ្ញវត្ថុមិនមែនធនាគារ, ពិសេស តាមរយៈ ការអភិវឌ្ឍបណ្តាញ សុវត្ថិភាពហិរញ្ញវត្ថុ (Financial Safety Net), និង ការជំរុញភាពស៊ីជម្រៅហិរញ្ញ-វត្ថុ (Financial Deepening) ។

ទី៥- ការលើកកម្ពស់កិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុ, ទាំងក្នុងតំបន់ និង សកលលោក, សំដៅរួមចំណែកពង្រឹងស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ, កៀរគរ ធនធាន, និង អភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ និង បច្ចេកវិទ្យាហិរញ្ញវត្ថុថ្មីៗ ។

ទី៦- ការជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ឱ្យមានលក្ខណៈគ្រប់-ជ្រុងជ្រោយ និង ប្រកបដោយបរិយាបន្ន ដើម្បីពង្រឹងភាពធន់នៃសង្គម-សេដ្ឋកិច្ច ។

### មុំទី៤. ការបន្តកសាងភាពជាដៃគូប្រកបដោយបរិយាបន្ន និង ស័ក្តិ-សិទ្ធភាព នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍

ការបន្តលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការ និង ការបន្ត ពង្រឹងភាពជាដៃគូជាមួយគ្រប់តួអង្គអភិវឌ្ឍន៍ គឺជាភាពចាំបាច់ សម្រាប់បង្ក

បរិយាកាសអំណោយផលដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយបរិយាបន្ន, ភាពធន់ និង ចីរភាព ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

ទី១- ការរៀបចំ និង ការអនុវត្ត **"យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍ និង ភាពជាដៃគូ ឆ្នាំ ២០២៤-២០២៨"** ដើម្បីពង្រឹងភាពជាដៃគូ ប្រកបដោយបរិយាបន្ន ។

ទី២- ការកៀរគរ ការសម្របសម្រួល និង ការគ្រប់គ្រង ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍ ពីគ្រប់ប្រភព, និង ការតម្រឹមធនធាន ជាមួយអាទិភាពជាតិ សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន ។

ទី៣- ការបង្កើនប្រសិទ្ធភាពនៃការអនុវត្ត យន្តការ និង ឧបករណ៍នានា នៃភាពជាដៃគូដែលមានស្រាប់ និង អាចបង្កើតថ្មីបន្ថែមទៀត ក្នុងករណីចាំបាច់ ដើម្បីលើកកម្ពស់គណនេយ្យភាពទ្វេទិស និង បន្តពង្រឹងភាពជាដៃគូប្រកបដោយបរិយាបន្ន ។

ទី៤- ការបន្តដំណើរការសមាហរណកម្ម និង ទំនាក់ទំនង នៅក្នុងតំបន់ និង សកលលោក តាមរយៈ យន្តការ, វិធានការ, កម្មវិធី និង គំនិតផ្តួចផ្តើមនានា ដើម្បី លើកកម្ពស់កិត្យានុភាព និង ផលប្រយោជន៍កម្ពុជា ក៏ដូចជាដើម្បីបង្កើនកាលានុវត្តភាព សម្រាប់ការអភិវឌ្ឍ និង ទំនុកចិត្តលើបរិយាកាសវិនិយោគ, ធុរកិច្ច និង ពាណិជ្ជកម្ម នៅកម្ពុជា ដោយឈរលើគោលការណ៍ **"ស្មើសិទ្ធិ និង ស្មើភាព"** ។

ទី៥- ការបន្តអនុវត្តយន្តការភាពជាដៃគូរវាងរដ្ឋ និង ឯកជន តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីភាពជាដៃគូរវាង រដ្ឋ និង ឯកជន ។

ទី៦- ការបន្តពង្រឹងភាពជាដៃគូ ជាមួយអង្គការមិនមែនរដ្ឋាភិបាល តាមរយៈ ការអនុវត្តច្បាប់ស្តីពីសមាគម និង អង្គការមិនមែនរដ្ឋាភិបាល ដើម្បីបង្កើនកិច្ចសហការក្នុងភាពជាដៃគូ ប្រកបដោយសុខដុមនីយកម្ម, ប្រសិទ្ធភាព,

តម្លាភាព, និង គណនេយ្យភាព ។

មុំទី៥. ការបន្តធ្វើសមាហរណកម្មស៊ីជម្រៅ ទៅក្នុងតំបន់ និង សកលលោក

ការធ្វើសមាហរណកម្មសេដ្ឋកិច្ចស៊ីជម្រៅ ទៅក្នុងតំបន់ និង សកលលោក បង្កើតកាលានុវត្តភាពក្នុង ការជំរុញ និង ការគាំទ្រ ពាណិជ្ជកម្មអន្តរជាតិ និង ការទាក់ទាញការវិនិយោគ, ក៏ដូចជាការចូលរួមកាន់តែជ្រៅ ទៅក្នុងខ្សែច្រវាក់តម្លៃ និង ការផ្គត់ផ្គង់ នៃតំបន់ និង ជាសកល សំដៅលើកកម្ពស់ភាពប្រកួតប្រជែងរបស់កម្ពុជា និង ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គម ប្រកបដោយចីរភាព ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

ទី១- ការបន្តចរចាបើកទីផ្សារសក្តានុពលថ្មី, ទាំងទ្វេភាគី និង ពហុភាគី, ឱ្យមានលក្ខណៈកាន់តែទូលំទូលាយ និង ឈានដល់កម្រិតខ្ពស់ថ្មីមួយបន្ថែមទៀត និង ការចរចាកិច្ចព្រមព្រៀងអន្តរជាតិទាក់ទងនឹងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយផ្តោតជាពិសេសលើកិច្ចព្រមព្រៀងទ្វេភាគីដែលត្រូវបានទទួលស្គាល់ថាជាយន្តការមានប្រសិទ្ធភាព និង សក្តានុពលខ្ពស់ សំដៅបង្កើនពិពិធកម្មទីផ្សារ និង ផលិតផលនាំចេញ ។

ទី២- ការរៀបចំយុទ្ធសាស្ត្រ និង ផែនការសកម្មភាព ដើម្បីជំរុញសមាហរណកម្មកម្ពុជាឱ្យកាន់តែស៊ីជម្រៅ តាមរយៈ យន្តការពហុភាគី និង ទ្វេភាគីដែលមានស្រាប់ សំដៅពង្រីកការតភ្ជាប់កម្ពុជា ប្រកបដោយប្រពលភាព ជាមួយខ្សែច្រវាក់តម្លៃ និង ផ្គត់ផ្គង់ ក្នុងតំបន់ និង សកលលោក ។

ទី៣- ការរៀបចំវិធានការគោលនយោបាយ សម្រាប់កាត់បន្ថយថ្លៃពាណិជ្ជកម្ម និង ថ្លៃពាក់ព័ន្ធនានា, និង លុបបំបាត់របាំងពាណិជ្ជកម្ម ដែលមិនចាំបាច់ ដើម្បីបង្កើនភាពប្រកួតប្រជែងរបស់កម្ពុជា; ព្រមទាំងការអភិវឌ្ឍ និង ការលើកកម្ពស់អនុលោមភាពស្តង់ដា និង បទប្បញ្ញត្តិ របស់សហគ្រាសធុនមីក្រូ តូច និង មធ្យម, ពិសេស ឧស្សាហកម្មវ័យក្មេង និង ថ្មីៗ ដែលមានសក្តា-

នុពលនាំចេញ និង ភាពប្រកួតប្រជែងខ្ពស់ ។

ទី៤- ការបន្តជំរុញការចូលរួម ដោយសកម្មរបស់កម្ពុជា ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ និង គំនិតផ្តួចផ្តើមអន្តរជាតិសំខាន់ៗ, និង ការលើកកម្ពស់ប្រព័ន្ធពាណិជ្ជកម្មពហុភាគីដែលមានលក្ខណៈសកល, ឈរលើគោលការណ៍បើកចំហ, តម្លាភាព, បរិយាបន្ន និង ការប្រកួតប្រជែងស្មើភាព ។

ទី៥- ការពង្រឹង និង ការពង្រីក កិច្ចសហការ និង ការសម្រួបសម្រួលរវាងក្រសួងស្ថាប័នសាធារណៈ និង គ្រប់តួអង្គអភិវឌ្ឍន៍ផ្សេងទៀត ដើម្បីលើក-កម្ពស់ភាពប្រកួតប្រជែង និង ពង្រីកសមត្ថភាពឧស្សាហកម្ម និង ពាណិជ្ជកម្មស្របតាមនិន្នាការតំបន់ និង សកល, ពិសេស ការតភ្ជាប់ផលិតកម្ម ក្នុងស្រុកទៅនឹងទីផ្សារផលិតផលអន្តរជាតិ ។

ទី៦- ការរៀបចំ ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់ការត្រៀមខ្លួន ក្នុងការ-ចាកចេញពីក្រុមប្រទេសអភិវឌ្ឍតិចតួច ដោយរលូន និង រឹងមាំ, និង ក្របខ័ណ្ឌគោលនយោបាយតម្រង់ទិសសមាហរណកម្មសេដ្ឋកិច្ច ប្រកបដោយយុទ្ធសាស្ត្រសម្រាប់រយៈពេលវែង ដោយត្រូវបន្តចរចាក្នុងរយៈពេលអន្តរកាល ដើម្បីទទួលបានភាពអនុគ្រោះថ្មីៗ សំដៅរក្សាលំនឹងទីផ្សារនាំចេញ និង ទីផ្សារថ្មីៗ សម្រាប់ផលិតផលកម្ពុជា ។

## ២.៤. បញ្ចកោណយុទ្ធសាស្ត្រទាំង ៥

### បញ្ចកោណទី១. ការអភិវឌ្ឍមូលធនមនុស្ស

ការអភិវឌ្ឍមូលធនមនុស្ស គឺជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបានសម្រាប់ជំរុញពិពិធកម្ម និង កំណើនសេដ្ឋកិច្ច ប្រកបដោយបរិយាបន្ន និង ភាពធន់ ។ មូលធនមនុស្ស មានគុណភាពខ្ពស់ និង សុខភាពល្អ គឺជាទ្រព្យសកម្មជាតិដ៏រឹងមាំ សម្រាប់បង្កើនតម្លៃសេដ្ឋកិច្ច, លើកកម្ពស់តម្លៃវប្បធម៌, និង បង្កើតគំនិតថ្មីៗ សំដៅធានាចីរភាពកំណើនរយៈពេលវែង និង ជវភាពនៃ

ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។ ការណ៍នេះ បង្ហាញថា ការវិនិយោគក្នុងការអភិវឌ្ឍមូលធនមនុស្ស មានសារៈសំខាន់ ដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃតម្រូវ-ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលផ្ដោតលើអាទិភាព ៥ : (១). ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា; (២). ការបណ្ដុះបណ្ដាលជំនាញបច្ចេកទេស; (៣). ការលើកកម្ពស់សុខភាព និង សុខុមាលភាពប្រជាជន; (៤). ការពង្រឹងប្រព័ន្ធគាំពារសង្គម និង ប្រព័ន្ធស្បៀង; និង (៥). ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយ សីលធម៌, សមធម៌ និង បរិយាបន្ន ។

### មុំទី១. ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា

គោលដៅជាយុទ្ធសាស្ត្រ គឺការបង្កើតបរិយាកាសល្អ សម្រាប់ការអប់រំ និង ការបណ្ដុះបណ្ដាល ប្រកបដោយគុណភាព និង ជំនាញខ្ពស់ ដោយផ្ដោតលើការពង្រឹងអភិបាលកិច្ចនៃការគ្រប់គ្រងនៅតាមគ្រឹះស្ថានសិក្សា, ការពង្រឹងគុណភាពនៃការបណ្ដុះបណ្ដាលគ្រប់កម្រិត, ការបង្កើនគុណភាព និង ការចូលរៀនមុខវិជ្ជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និង គណិតវិទ្យា (STEAM), និង ការពង្រឹងការអប់រំកាយ និង កីឡា ។

ក្នុងនីតិកាលទី៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្ដោតអាទិភាពលើ ៖

ទី១- ការបន្តពង្រឹងគុណភាពអប់រំ និង ការបណ្ដុះបណ្ដាលគ្រប់កម្រិត, ការធ្វើបច្ចុប្បន្នកម្មកម្មវិធីសិក្សានៅគ្រប់កម្រិត, និង ការបង្កើតបរិយាកាសល្អ សម្រាប់ការសិក្សាពេញមួយជីវិត ។

ទី២- ការបន្តកែទម្រង់សាលារៀន ដោយផ្ដោតលើការពង្រឹងសមិទ្ធផលដែល មានស្រាប់, ការជំរុញការបង្កើតសាលារៀនជំនាន់ថ្មី និង សាលាគំរូ, ការ-ពង្រឹងអភិបាលកិច្ច និង ប្រសិទ្ធភាពគ្រប់គ្រងនៅមន្ទីរអប់រំ យុវជន និង កីឡា, ព្រមទាំងការជំរុញការចូលរួម និង ភាពជាម្ចាស់ របស់ មាតាបិតា, សហគមន៍ និង វិស័យឯកជន ។

ទី៣- ការពង្រឹងគុណភាពនៃ ការបណ្ដុះបណ្ដាលគ្រូបង្រៀន និង វិធីសាស្ត្របង្រៀន ព្រមទាំងការបន្តលើកកម្ពស់ ជីវភាព និង គុណតម្លៃ បុគ្គលិកសិក្សាគ្រប់កម្រិត ។

ទី៤- ការបន្តលើកកម្ពស់ការអប់រំឌីជីថល, ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលតាមសាលារៀន, និង ការជំរុញនូវការចាប់យកមុខវិជ្ជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និង គណិតវិទ្យា (STEAM) ។

ទី៥- ការលើកកម្ពស់សុខភាពសិក្សា និង ការបង្កើនអាហារូបករណ៍ សម្រាប់សិស្ស-និស្សិត ក្រីក្រ និង ងាយរងគ្រោះ ។

ទី៦- ការពង្រឹងអភិបាលកិច្ចគ្រឹះស្ថានឧត្តមសិក្សា; ការលើកកម្ពស់ការស្រាវជ្រាវ, ការអភិវឌ្ឍ និង ការនវានុវត្ត; និង ការជំរុញភាពជាដៃគូរវាងរដ្ឋ និង ឯកជន ។

ទី៧- ការលើកកម្ពស់វិស័យកីឡាផ្សារភ្ជាប់នឹងការអប់រំ និង ការបន្តជំរុញចលនា "**យុវជនម្នាក់ ចេះកីឡាមួយប្រភេទយ៉ាងតិច ប្រចាំជីវិត**" ។

### មុំទី២. ការបណ្ដុះបណ្ដាលជំនាញបច្ចេកទេស

គោលដៅជាយុទ្ធសាស្ត្រ គឺការធ្វើបរិវត្តកម្មការបណ្ដុះបណ្ដាលជំនាញបច្ចេកទេស និង វិជ្ជាជីវៈ; ការបង្កើនការចុះឈ្មោះចូលរៀន; ការរៀបចំជំនាញឡើងវិញ និង ការបង្កើនជំនាញ (Reskilling and Upskilling); ការពង្រឹងប្រព័ន្ធអេកូឡូស៊ីអភិវឌ្ឍជំនាញ; ការដោះស្រាយបញ្ហានៃភាពមិនស៊ីសង្វាក់គ្នា រវាងការបណ្ដុះបណ្ដាល និង តម្រូវការ, ទាំងប្រភេទ និង គុណភាពជំនាញ; និង ការពង្រឹង ការតាមដាន, ការត្រួតពិនិត្យ និង ការវាយតម្លៃ ការអនុវត្តគោលនយោបាយ និង យុទ្ធសាស្ត្រ ដែលត្រូវបានដាក់ចេញ ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្ដោតអាទិភាពលើ ៖

ទី១- ការពង្រឹងអភិបាលកិច្ចប្រព័ន្ធ និង គ្រឹះស្ថានអប់រំ បណ្ដុះបណ្ដាលបច្ចេកទេសវិជ្ជាជីវៈ, ទាំងរដ្ឋ និង ឯកជន, តាមរយៈ ការធ្វើបច្ចុប្បន្នកម្មគោល-

នយោបាយ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ; ការធ្វើឌីជីថលូបនីយកម្ម; និង ការពង្រឹងយន្តការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃ ។

ទី២- ការបន្តលើកកម្ពស់សមត្ថភាព និង គុណវុឌ្ឍិ តាមរយៈការជំរុញលើកទឹកចិត្តគ្រូបង្រៀន ឱ្យបន្តសិក្សាបន្ថែម និង សិក្សាស្រាវជ្រាវជាប្រចាំ, ព្រមទាំងការទាក់ទាញគ្រូបង្រៀន ដែលមានគុណវុឌ្ឍិខ្ពស់ និង ឧត្តមានុវត្តន៍ជាក់ស្តែង មកបង្រៀននៅតាមបណ្តាគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ នៅទូទាំងប្រទេស ។

ទី៣- ការពង្រឹងគុណភាពជំនាញបច្ចេកទេស និង វិជ្ជាជីវៈ រួមទាំងជំនាញទន់ និង រឹង តាមរយៈ ការដាក់ឱ្យដំណើរការពេញលេញនូវកម្មវិធីបណ្តុះបណ្តាល ផ្អែកលើសមត្ថភាព និង តម្រូវការឧស្សាហកម្ម ។

ទី៤- ការជំរុញ និង ការពង្រឹង កម្មវិធីបង្កើនជំនាញ; ការពង្រីកការបណ្តុះបណ្តាលជំនាញ កម្មវិធីរៀបចំជំនាញឡើងវិញ និង កម្មវិធីធ្វើតេស្តទទួលស្គាល់ជំនាញ; និង ការជំរុញការសិក្សាស្រាវជ្រាវ ការនវានុវត្ត និង បច្ចេកទេសអនុវត្ត ស្របតាមតម្រូវការជាក់ស្តែង; ព្រមទាំងការផ្សព្វផ្សាយគ្រប់ទម្រង់ ។

ទី៥- ការរៀបចំយន្តការផ្តល់ឥណទានដល់សិស្ស-និស្សិត ដើម្បីលើកទឹកចិត្តដល់ការចាប់យកជំនាញបច្ចេកទេសវិជ្ជាជីវៈ, ជាពិសេសជំនាញអាទិភាព ។

ទី៦- ការបន្តពង្រឹងភាពជាដៃគូរវាងរដ្ឋ និង ឯកជន; ការជំរុញកិច្ចសន្ទនាជាប្រចាំរវាងរដ្ឋ វិស័យឯកជន និង ដៃគូអភិវឌ្ឍន៍; និង ការកៀរគរមូលនិធិគាំទ្រដល់ ការស្រាវជ្រាវ និង ការអភិវឌ្ឍ ។

### មុំទី៣. ការលើកកម្ពស់សុខភាព និង សុខុមាលភាពប្រជាជន

គោលដៅជាយុទ្ធសាស្ត្រ គឺការបន្តកាត់បន្ថយអត្រាឈឺ និង ស្លាប់ បណ្តាលពីជំងឺមិនឆ្លងចម្បងៗ; ការបន្តលើកកម្ពស់សុខភាពបន្តពូជ, សុខភាពទារក កុមារ និង មាតា; ការពង្រឹងសមត្ថភាពស្ថាប័ន ក្នុងការដឹកនាំបរិវត្តកម្ម និង អភិបាលកិច្ច ក្នុងវិស័យសុខាភិបាល; ការបន្តបង្កើនគុណភាព និង សមត្ថ-

ភាពរោគវិនិច្ឆ័យ ក្នុងការព្យាបាល និង ការថែទាំ; ការបន្តពង្រឹងគុណភាពនៃការបណ្តុះបណ្តាលវិជ្ជាជីវៈសុខាភិបាល; ការលើកកម្ពស់សមត្ថភាពជំនាញ; ការលើកកម្ពស់កិច្ចសហការរវាងក្រសួងស្ថាប័នពាក់ព័ន្ធ; និង ការចូលរួមរបស់ប្រជាជនតាមសហគមន៍ ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

ទី១- ការពង្រឹងសមត្ថភាពស្ថាប័ន នៅក្នុងការដឹកនាំអភិបាលកិច្ច និង បរិវត្តកម្មឌីជីថល ក្នុងវិស័យសុខាភិបាល; ការរៀបចំច្បាប់ និង នីតិក្រមសុខាភិបាល; ការជំរុញការអនុវត្តយន្តការនិយ័តកម្មសេវាសុខាភិបាលសាធារណៈ និង ឯកជន; ការលើកកម្ពស់ការសិក្សាស្រាវជ្រាវសុខាភិបាល; និង ការតាមដាន ការត្រួតពិនិត្យ និង ការវាយតម្លៃ ។

ទី២- ការពង្រឹងសមត្ថភាពប្រព័ន្ធ សុខាភិបាល និង សេវាសង្គមកិច្ច ដើម្បីឆ្លើយតបទាន់ពេល និង ប្រកបដោយប្រសិទ្ធភាព ទៅនឹងការលើកកម្ពស់សុខភាព និង សុខុមាលភាពសាធារណៈ, រួមទាំងការផ្ទុះឡើងនៃជំងឺកាចសាហាវនានា ។

ទី៣- ការពង្រឹងប្រព័ន្ធផ្តល់សេវាថែទាំសុខភាព ប្រកបដោយការនវានុវត្ត ដោយផ្តោតជាចម្បងលើការថែទាំសុខភាពបឋម; ការលើកកម្ពស់របបអាហារសុខភាពសម្រាប់ទាំងអស់គ្នា; ការបង្កើនគុណភាព, សុវត្ថិភាព និង ប្រសិទ្ធភាព; ការពង្រីកការគ្របដណ្តប់នៃសេវាថែទាំសុខភាព; ការចែកចាយ និង ការប្រើប្រាស់ឱសថ; និង ការជំរុញការអនុវត្តយន្តការ តាមដាន វាយតម្លៃ និង អភិបាលកិច្ចគុណភាព ។

ទី៤- ការបង្កើនការអប់រំសុខភាព និង ការផ្សព្វផ្សាយ សំដៅលើកកម្ពស់ការយល់ដឹង និង ការប្រតិបត្តិ ត្រឹមត្រូវរបស់ប្រជាជន ក្នុងការបង្ការ និង ការគ្រប់គ្រងជំងឺ ឬ បញ្ហាសុខភាពសាធារណៈ ព្រមទាំងការស្វែងរក និង ការប្រើសេវាថែទាំសុខភាពត្រឹមត្រូវ ។

ទី៥- ការបង្កើនគុណភាពនៃការបណ្តុះបណ្តាលវិជ្ជាជីវៈសុខាភិបាល និង វិជ្ជាជីវៈអមសុខាភិបាល ដោយឈរលើសមត្ថភាពជាមូលដ្ឋាន, ការជំរុញការប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈ, និង ការលើកកម្ពស់ការពង្រាយគ្រូពេទ្យ និង បុគ្គលិកសុខាភិបាល សមស្របតាមនិយាមបច្ចេកទេស ។

ទី៦- ការពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត; ការពង្រឹងការផ្គត់ផ្គង់ឱសថបរិក្ខារ; និង ការបំពាក់ឧបករណ៍ពេទ្យ ដល់ប៉ុស្តិ៍សុខភាព, មណ្ឌលសុខភាព, មន្ទីរពេទ្យបង្អែក, មន្ទីរពេទ្យបង្អែកអាទិភាព នៃខេត្តគោលដៅ និង មន្ទីរពេទ្យ-ជាតិ ឱ្យបានស្របតាមនិយាមបច្ចេកទេសទំនើប ។

ទី៧- ការពង្រឹងកិច្ចសហការ ពហុវិស័យ និង អន្តរវិស័យ; ការចូលរួមរបស់សហគមន៍; និង ការលើកកម្ពស់ការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាការផ្តល់សេវាថែទាំសុខភាព ដែលឆ្លើយតបនឹងតម្រូវការជាសារវន្ត ផ្នែកសុខភាព របស់ប្រជាជននៅមូលដ្ឋាន ។

ទី៨- ការកសាងភាពជាដៃគូរវាងរដ្ឋ និង ឯកជន, ដៃគូអភិវឌ្ឍន៍ និង អង្គការមិនមែនរដ្ឋាភិបាល; និង ការបង្កើនកិច្ចសហប្រតិបត្តិការ ក្នុងតំបន់ និង សកលលោក ក្នុងការពង្រឹងភាពធន់, ការអភិវឌ្ឍវិស័យសុខាភិបាល និង ការ-ពង្រីកការគ្របដណ្តប់នៃប្រព័ន្ធគាំពារសុខភាពសង្គម ។

## មុំទី៤. ការពង្រឹងប្រព័ន្ធគាំពារសង្គម និង ប្រព័ន្ធស្បៀង

គោលដៅជាយុទ្ធសាស្ត្រ គឺការកសាង និង ការអភិវឌ្ឍ ប្រព័ន្ធគាំពារសង្គម ឱ្យមានលក្ខណៈ ប្រមូលផ្តុំ និង សង្គតិភាព, ទាំងក្នុងប្រព័ន្ធជំនួយសង្គម និង ប្រព័ន្ធសន្តិសុខសង្គម; និង ការពង្រឹងប្រព័ន្ធស្បៀងដែលផ្តល់សន្តិសុខស្បៀង និង អាហារូបត្ថម្ភ សម្រាប់ប្រជាជនគ្រប់រូប ។ ការបន្តអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ឈរលើស្មារតី **"មិនបោះបង់ពលរដ្ឋខ្មែរណាម្នាក់"** ហើយការពង្រីកវិសាលភាពនៃប្រព័ន្ធគាំពារសង្គម ឈរលើអភិក្រមចំនួន ៤ គឺ : (១). ចីរភាពនៃកម្មវិធី; (២). លទ្ធភាពអាចទ្រទ្រង់បាននៃថវិកាជាតិ; (៣). ការធានាបរិយាបន្ន

និង សមធម៌សង្គម ដោយផ្ដោតលើកិច្ចអន្តរាគមន៍របស់រដ្ឋលើគ្រួសារក្រីក្រ, ងាយរងគ្រោះ និង ងាយរងហានិភ័យ; និង (៤). ភាពអាចពង្រីកវិសាលភាពនៃប្រព័ន្ធគាំពារសង្គម តាមរយៈការអភិវឌ្ឍជាប្រព័ន្ធ ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្ដោតអាទិភាពលើ ៖

ទី១- ការបន្តទ្រទ្រង់ជីវភាពគ្រួសារគោលដៅ តាមកម្មវិធីជាតិជំនួយសង្គម ដោយក្នុងរយៈពេលខ្លី ត្រូវផ្ដោតលើ កម្មវិធីជាតិជំនួយសង្គមជាកញ្ចប់គ្រួសារ; កម្មវិធីបណ្ដុះបណ្ដាល ជំនាញវិជ្ជាជីវៈ និង បច្ចេកទេស ដល់យុវជនគោលដៅ រួមទាំងការលើកកម្ពស់ភាពអង់អាចរបស់ពួកគេ; កម្មវិធីកិច្ចគាំពារសង្គមដើម្បីបញ្ចប់ភាពក្រីក្រ; និង ការធ្វើស្ថាបនូបនីយកម្មក្របខ័ណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ដោយគិតបញ្ចូលផងដែរនូវការពង្រឹងប្រព័ន្ធស្បៀងឱ្យកាន់តែ រឹងមាំ, វៃឆ្លាត, ធន់ និង បរិយាបន្ន ។

ទី២- ការបន្តអភិវឌ្ឍប្រព័ន្ធសន្តិសុខសង្គម, ការអនុវត្តរបបសន្តិសុខសង្គម, និង ការបន្តពង្រីកសេវាថែទាំសុខភាពសង្គម ឆ្ពោះទៅដល់ការគ្របដណ្ដប់សុខភាពសកល ស្របតាមការវិវឌ្ឍនៃស្ថានភាពសង្គម-សេដ្ឋកិច្ច ។

ទី៣- ការបន្តពង្រឹងប្រព័ន្ធអភិបាលកិច្ចឱ្យកាន់តែ រឹងមាំ និង មានប្រសិទ្ធភាព តាមមុខងារទាំង ៣ កម្រិត រួមមាន កម្រិតគោលនយោបាយរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម, កម្រិតនិយ័តករសន្តិសុខសង្គម, និង កម្រិតប្រតិបត្តិករបេឡាជាតិសន្តិសុខសង្គម, មូលនិធិជាតិជំនួយសង្គម និង ប្រតិបត្តិករពាក់ព័ន្ធផ្សេងៗទៀត ឱ្យមានលក្ខណៈស្ដង់ដា ។

ទី៤- ការដាក់ឱ្យដំណើរការទីភ្នាក់ងារជាតិបញ្ជាក់ចំណាយឯករាជ្យដែលគ្របដណ្ដប់គ្រប់របបថែទាំសុខភាព និង របបហានិភ័យការងារ ។

ទី៥- ការលើកកម្ពស់ការប្រើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន; និង ការបន្តពង្រឹង និង កែលម្អប្រព័ន្ធកំណត់ ក្រុមគ្រួសារ និង ក្រុមបុគ្គលគោលដៅ សម្រាប់ប្រព័ន្ធគាំពារសង្គម ឱ្យកាន់តែមានសុក្រឹតភាព និង ឈានដល់ការដាក់ឱ្យដំណើរ-

ការប្រព័ន្ធមូលដ្ឋានចុះបញ្ជី និង ទិន្នន័យសង្គមថ្នាក់ជាតិ ។

ទី៦- ការជំរុញការផ្សព្វផ្សាយអំពីសារៈសំខាន់ និង តួនាទី នៃប្រព័ន្ធគាំពារសង្គម និង ការបង្កើតយន្តការ ផ្តល់មតិ និង សំណូមពរ, និង យន្តការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃ ។

ទី៧- ការជំរុញ និង ការបង្កើន សុខុមាលភាពនៃ គ្រួសារក្រីក្រ, គ្រួសារយុទ្ធជនមានពិការភាព ពលី មរណៈ, និង គ្រួសារអតីតយុទ្ធជន ដោយផ្តល់ការ-គាំពារនានា រួមទាំង ការបន្តធ្វើប្រទានកម្មដី និង ការផ្តល់ដីសម្បទានសង្គមកិច្ចសម្រាប់លំនៅឋាន និង កសិកម្ម ។

### មុំទី៥. ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌, សមធម៌ និង បរិយាបន្ន

គោលដៅជាយុទ្ធសាស្ត្រ គឺការធ្វើពលភាវូបនីយកម្មពលរដ្ឋ (People Revitalization) ឱ្យមាន សមត្ថភាព, ផលិតភាព, សីលធម៌, គុណធម៌ , ចរិយាធម៌, ភាពអំណត់, សុចរិតភាព, វិន័យ, និង ការទទួលខុសត្រូវខ្ពស់; និង ការលើក-កម្ពស់ ស្មារតី និង មនសិការស្នេហាជាតិ, ការពារជាតិ, ឯកភាពជាតិ, ការបេះយកអាសាគ្នា, ការចែករំលែក, ការចូលរួម, គុណតម្លៃសង្គម, និង ស្មារតី គោរពច្បាប់, ស្រឡាញ់សន្តិភាព, វប្បធម៌, ប្រពៃណីទំនៀមទម្លាប់, អំពើល្អ, និង យុត្តិធម៌, សំដៅជានាបាននូវសិនិទ្ធភាពសង្គម (Social Cohesion) និង សុខដុម-រមនាសង្គម ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

ទី១- ការពង្រឹង និង ការបង្កើនកិច្ចសហការក្នុងការអប់រំអំពី សីលធម៌, គុណធម៌, និង សុជីវធម៌ ដល់សិស្ស និស្សិត និង យុវជន, ទាំងក្នុង និង ក្រៅប្រព័ន្ធអប់រំ ។

ទី២- ការរៀបចំផែនទីបង្ហាញផ្លូវ ដើម្បីបណ្តុះទម្លាប់មាន សីលធម៌, គុណធម៌ និង សុជីវធម៌, និង ទម្លាប់គោរព ច្បាប់ និង វិន័យ, និង បញ្ចូលការ-

អប់រំអំពី ព្រះពុទ្ធសាសនា និង ផ្នែកសិល្បៈវប្បធម៌ខ្មែរ, ទាំងរូបី និង អរូបី, ទៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិត, ព្រមទាំងផ្សព្វផ្សាយ និង បញ្ជ្រាប ទៅគ្រប់ក្រសួង-ស្ថាប័ន, ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ។

ទី៣- ការលើកកម្ពស់ការយល់ដឹងអំពី អត្តសញ្ញាណជាតិ និង ភាព-ជាម្ចាស់ ក្នុងការអភិរក្ស និង ការអភិវឌ្ឍ វប្បធម៌ជាតិ; ការជំរុញការច្នៃប្រឌិតផលិតផលវប្បធម៌ថ្មីៗ ដោយរក្សាក្បាច់រចនាខ្មែរ និង ឈរលើមូលដ្ឋានអត្ត-សញ្ញាណជាតិ; ការលើកកម្ពស់ការចូលរួមពីសំណាក់ព្រឹទ្ធាចារ្យសិល្បៈ ដែលជាមរតកមនុស្សរស់ និង ការបណ្តុះអ្នកបន្តវេនសិល្បករបុរាណ; និង ការពង្រឹងការចូលរួមអនុវត្តពីសំណាក់មហាជន ។

ទី៤- ការបណ្តុះទស្សនៈ មនសិការជាតិ និង ឧត្តមគតិវិជ្ជមាន ក្នុងការអភិរក្ស ការអភិវឌ្ឍ និង ការនវានុវត្ត សិល្បៈវប្បធម៌ជាតិ ។

ទី៥- ការពង្រឹងប្រសិទ្ធភាពនៃការស្រាវជ្រាវ ការចងក្រង និង ការ-ផ្សព្វផ្សាយគុណតម្លៃប្រវត្តិសាស្ត្រនៃសំណង់បេតិកភណ្ឌ, វត្ថុបុរាណ, ស្ថានីយបុរាណ, សិលាចារឹក, សាស្ត្រាស្លឹករឹត, ក្បួនច្បាប់បុរាណ, ប្រពៃណីទំនៀម-ទម្លាប់, ចរិយាធម៌ខ្មែរ និង វប្បធម៌កតញ្ញូជាតិ ។

ទី៦- ការបណ្តុះទម្លាប់ ស្មារតីគោរពច្បាប់ និង វិន័យល្អដល់ពលរដ្ឋ; និង ការរៀបចំដាក់ចេញលក្ខណៈវិនិច្ឆ័យ សម្រាប់លើកទឹកចិត្តដល់ការធ្វើអំពើល្អជា ពលរដ្ឋគំរូ និង ពលរដ្ឋសកល ។

ទី៧- ការបន្តលើកកម្ពស់ការគោរព សីលធម៌, តម្លៃស្ត្រី, សេចក្តីថ្លៃថ្នូរក្នុងគ្រួសារ និង សង្គមខ្មែរ ។

ទី៨- ការលើកកម្ពស់ការយល់ដឹង និង ការជំរុញតួនាទីព្រះពុទ្ធសាសនានៅក្នុងការចូលរួមអប់រំសីលធម៌, គុណធម៌ និង សុជីវធម៌; និង ការបំផុសគំនិតច្នៃប្រឌិត ដើម្បីចូលរួមលើកកម្ពស់សង្គមជាតិ ។

## បញ្ហាគោលនាទី២. ការធ្វើពិពិធកម្មសេដ្ឋកិច្ច និង ការបង្កើនភាពប្រកួតប្រជែង

ការធ្វើពិពិធកម្មសេដ្ឋកិច្ច និង ការបង្កើនភាពប្រកួតប្រជែង គឺជាមូលដ្ឋាននៃការគាំទ្រកំណើន ប្រកបដោយចីរភាព និង ភាពធន់ ក្នុងរយៈពេលមធ្យម និង វែង តាមរយៈ ការពង្រីកមូលដ្ឋានផលិតកម្ម, ការបង្កើនតម្លៃបន្ថែម, ការតភ្ជាប់ខ្សែច្រវាក់តម្លៃ និង ផ្គត់ផ្គង់សកល, ព្រមទាំងការទាក់ទាញ និង ការជំរុញវិនិយោគក្នុងឧស្សាហកម្មថ្មីៗ ដែលកំពុងលេចឡើង ។ ឈរលើមូលដ្ឋាននេះ, រាជរដ្ឋាភិបាលផ្តោតលើអាទិភាព ចំនួន ៥ (១). ការអភិវឌ្ឍវិស័យគន្លឹះ និង ប្រភពថ្មីនៃកំណើនសេដ្ឋកិច្ច; (២). ការលើកកម្ពស់ការតភ្ជាប់ និង ការបង្កើនប្រសិទ្ធភាពនៃវិស័យដឹកជញ្ជូន និង ឡូជីស្ទីក, វិស័យថាមពល, វិស័យទឹកស្អាត និង វិស័យឌីជីថល; (៣). ការកែលម្អបរិយាកាស ធុរកិច្ច និង ការវិនិយោគ; (៤). ការពង្រឹងប្រសិទ្ធភាព និង ភាពទាក់ទាញ នៃតំបន់សេដ្ឋកិច្ចពិសេស រួមបញ្ចូលនូវ សួនឧស្សាហកម្ម, សួនកសិ-ឧស្សាហកម្ម និង តំបន់ពាណិជ្ជកម្មសេរីក្នុងស្រុក; និង (៥). ការនវានុវត្តយន្តការហិរញ្ញប្បទាន និង ផលិតផលហិរញ្ញវត្ថុសម្រាប់គាំទ្រដល់ការវិនិយោគ ។

### មុំទី១. ការអភិវឌ្ឍ វិស័យគន្លឹះ និង ប្រភពថ្មី នៃកំណើនសេដ្ឋកិច្ច

គោលដៅជាយុទ្ធសាស្ត្រ គឺការពង្រីក និង ការធ្វើពិពិធកម្ម មូលដ្ឋានកំណើនសេដ្ឋកិច្ច តាមរយៈ ការបង្កើនតម្លៃបន្ថែមក្នុងវិស័យគន្លឹះដែលមានស្រាប់ និង ការអភិវឌ្ឍប្រភពថ្មីនៃកំណើន ដែលជាកត្តាមិនអាចខ្វះបាន ក្នុងការបង្កើនសក្តានុពលកំណើន និង ការពង្រឹងភាពធន់នឹងវិបត្តិ ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

ទី១- ការលើកកម្ពស់ការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និង មធ្យម តាមរយៈ ការពង្រឹងឧស្សាហកម្មប្រតិគមន៍ (Backward Linkages), និង ការលើកកម្ពស់លទ្ធភាពទទួលបាន ការផ្ទេរបច្ចេកវិទ្យា, ការស្រាវជ្រាវ និង ការ-

អភិវឌ្ឍ ព្រមទាំងការរៀបចំ និង ការដាក់ឱ្យអនុវត្តគោលនយោបាយអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និង មធ្យម កម្ពុជា ។

ទី២- ការបន្តជំរុញបង្កើត និង អនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី, ទាំងទ្វេភាគី ពហុភាគី និង តំបន់, ឱ្យមានប្រសិទ្ធភាពខ្ពស់, ជាពិសេស ការពង្រឹងការសម្របសម្រួលអន្តរស្ថាប័ន ។

ទី៣- ការជំរុញ និង ការលើកកម្ពស់ ការទាក់ទាញការវិនិយោគក្នុងឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់ និង ឧស្សាហកម្មបៃតង តាមរយៈ ការអនុវត្តផែនទីចង្អុលផ្លូវការអភិវឌ្ឍវិស័យយានយន្ត និង គ្រឿងបង្គុំអេឡិចត្រូនិកកម្ពុជា; យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ, ផលិតស្បែកជើង និង កាបូបកម្ពុជា ២០២២-២០២៧; និង ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

ទី៤- ការបន្តលើកកម្ពស់ និង បង្កើនតម្លៃបន្ថែម វិស័យកសិកម្ម និង កសិ-ឧស្សាហកម្ម តាមរយៈ ការបន្តអនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្ម ឆ្នាំ ២០២២-២០៣០, និង ការបង្កើនពាណិជ្ជូបនីយកម្ម, ព្រមទាំងការជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិ-ឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៩-២០៣០ ។

ទី៥- ការបន្តលើកកម្ពស់វិស័យទេសចរណ៍ ជាពិសេស ការបន្តជំរុញការអភិវឌ្ឍទេសចរណ៍វប្បធម៌ និង ធម្មជាតិ ដោយបន្ថែមទេសចរណ៍បៃតង ស្អាត និង វៃឆ្លាត, ការជំរុញការបង្កើតប្រភេទទេសចរណ៍ថ្មីៗ ដែលមានតម្លៃបន្ថែមខ្ពស់ និង ទេសចរណ៍ធុរកិច្ច តាមរយៈ ការលើកកម្ពស់ការអនុវត្ត, ក៏ដូចជាការរៀបចំ និង ការដាក់ចេញគោលនយោបាយ និង ផែនការមេអភិវឌ្ឍវិស័យទេសចរណ៍នានា ។

ទី៦- ការបន្តលើកកម្ពស់ការអភិវឌ្ឍវិស័យ សេវាកម្មផ្នែកកំសាន្ត, អក្សរសិល្ប៍, សិល្បៈ, គំនូរជីវចល, ភាពយន្ត និង ឧស្សាហកម្មច្នៃប្រឌិតនានា ដែលមានសក្តានុពលខ្ពស់ ដោយក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវ រៀបចំ និង ដាក់ចេញ

នូវ គោលនយោបាយ, យុទ្ធសាស្រ្ត និង ផែនការនានា ដើម្បីជំរុញការអភិវឌ្ឍ វិស័យទាំងនេះ ។

ទី៧- ការពន្លឿនការអភិវឌ្ឍខេត្តព្រះសីហនុ ឱ្យក្លាយទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ដែលជាប៉ូលសេដ្ឋកិច្ចដ៏សំខាន់ សម្រាប់វិស័យទេសចរណ៍, មជ្ឈមណ្ឌលសេវាហិរញ្ញវត្ថុ, តំបន់ឧស្សាហកម្ម ជាដើម ដោយកំណត់យន្តការអនុវត្តឱ្យបានច្បាស់លាស់គ្រប់ជ្រុងជ្រោយ; និង ការរៀបចំផែនការមេអភិវឌ្ឍបណ្តាខេត្តជាប់ឆ្នេរសមុទ្រកម្ពុជា ជារបៀងសេដ្ឋកិច្ចពហុបំណង និង ប្រទាក់ក្រឡា ។

ទី៨- ការបន្តអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥, និង ការធ្វើបច្ចុប្បន្នកម្មគោលនយោបាយនេះ ឱ្យស្របទៅនឹងបរិការណ៍ថ្មីនៃការផ្លាស់ប្តូរនិម្មាបនកម្មពាណិជ្ជកម្ម និង សេដ្ឋកិច្ចតំបន់ និង សកលលោក ។

ទី៩- ការបន្តជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្មនិស្សារណកម្ម និង ឧស្សាហកម្មគាំទ្រ ដោយ បង្កើត និង ដាក់ឱ្យដំណើរការក្រុមហ៊ុនប្រេងកាតជាតិ; ការបន្តជំរុញការអភិវឌ្ឍវិស័យប្រេងកាត និង ឧស្ម័ន ជាពិសេស ការដាក់ឱ្យដំណើរការអណ្តូងប្រេងកាតឡើងវិញ; និង ការបន្តលើកទឹកចិត្តឱ្យមានការ-វិនិយោគលើឧស្សាហកម្មធនធានរ៉ែ និង ការគិតគូររៀបចំគោលនយោបាយផលិតវត្ថុធាតុដែលកម្ពុជាមានទាយជ្ជទាន ។

### មុំទី២. ការលើកកម្ពស់ការតភ្ជាប់ និង ការបង្កើនប្រសិទ្ធភាពនៃវិស័យដឹកជញ្ជូន និង ឡូជីស្ទីក, វិស័យថាមពល, វិស័យទឹកស្អាត និង វិស័យឌីជីថល

គោលដៅជាយុទ្ធសាស្រ្ត គឺការបន្តកសាង និង ពង្រឹងមូលដ្ឋាន និង បុរេលក្ខខណ្ឌគន្លឹះៗ សម្រាប់បង្កើនផលិតភាព, លើកកម្ពស់ភាពប្រកួតប្រជែង និង ជំរុញពិពិធកម្ម តាមរយៈ ការបង្កើនប្រសិទ្ធភាពហេដ្ឋារចនាសម្ព័ន្ធគាំទ្រ, និង ការកសាង និង ការអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធថ្មីៗ ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

## វិស័យដឹកជញ្ជូន និង ឡូជីស្ទីក

ទី១- ការបន្តជំរុញការអនុវត្តផែនការមេអន្តរកាលស្តីពីការតភ្ជាប់ប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយ និង ភស្តុភារកម្ម ឆ្នាំ ២០២១-២០៣០ ព្រមទាំងជំរុញការអនុម័ត និង ការអនុវត្ត ផែនការមេគ្រប់ជ្រុងជ្រោយស្តីពីប្រព័ន្ធដឹក-ជញ្ជូនអន្តរមធ្យោបាយ និង ឡូជីស្ទីកកម្ពុជា ២០២៣-២០៣០ ។

ទី២- ការជំរុញ និង ការពង្រឹង ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ ២០២២-២០៣០ ។

ទី៣- ការបន្តបង្កើនថវិកាវិនិយោគ និង កៀរគរហិរញ្ញប្បទាន ព្រមទាំងការពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់ ដើម្បីបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តគន្លឹះៗ, ទាំងផ្លូវគោក ផ្លូវដែក ផ្លូវទឹក កំពង់ផែ និង ផ្លូវអាកាស, ជាពិសេសគម្រោងផ្លូវនាវាចរណ៍ និង ប្រព័ន្ធឡូជីស្ទីក, គម្រោងស្តីពីការធ្វើទំនើបកម្មប្រព័ន្ធខ្សែផ្លូវរថភ្លើងភ្នំពេញ-ក្រុងព្រះសីហនុដែលមានស្រាប់ និង ខ្សែផ្លូវរថភ្លើងថ្មីប៉ោយប៉ែត-សៀមរាប-ភ្នំពេញ, ព្រមទាំងការគិតគូរអភិវឌ្ឍផ្លូវល្បឿនបន្ថែមទៀតការតភ្ជាប់ប៉ូលសេដ្ឋកិច្ចសំខាន់ៗ និង ការអភិវឌ្ឍរបៀងសេដ្ឋកិច្ចគន្លឹះ ក្នុងប្រទេស ទៅនឹងប្រទេសជិតខាង ។

ទី៤- ការសិក្សាពីផ្លូវថ្នល់ និង ការធ្វើវិសោធនកម្មច្បាប់ស្តីពីផ្លូវថ្នល់ដើម្បីកែសម្រួលកម្រិតទម្ងន់អតិបរមា; និង ការពន្លឿនការរៀបចំច្បាប់ស្តីពីការដឹកជញ្ជូនផ្លូវគោក, ច្បាប់ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក និង កំពង់ផែ, និងច្បាប់ស្តីពីផ្លូវដែក; ព្រមទាំងការរៀបចំគោលនយោបាយ, យុទ្ធសាស្ត្រ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តច្បាប់ និង ការលើកកម្ពស់ការអភិវឌ្ឍជំនាញឡូជីស្ទីក ។

## វិស័យថាមពល

ទី៥- ការបន្តរក្សាលំនឹងថ្លៃ និង ពិនិត្យលទ្ធភាពបញ្ចុះថ្លៃអគ្គិសនី

ព្រមទាំងធានាភាពគ្រប់គ្រាន់ និង ស្ថិរភាព នៃការផ្គត់ផ្គង់អគ្គិសនី សម្រាប់ឧស្សាហកម្ម និង កសិកម្ម ។

ទី៦- ការជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញ និង ការអនុវត្តកម្មវិធីប្រសិទ្ធភាពថាមពល ឱ្យអស់សក្តានុពល ។

ទី៧- ការបង្កើនការគ្រប់គ្រង ការអភិវឌ្ឍ និង កិច្ចសហប្រតិបត្តិការលើសសរស្តម្ភទាំងបីនៃអនុវិស័យ ថាមពល, បរមាណូស៊ីវិល និងវិទ្យុសកម្ម ដើម្បីធានាបាននូវសន្តិសុខថាមពល ។

## វិស័យទឹកស្អាត

ទី៨- ការរៀបចំ និង ការដាក់ចេញ ផែនការមេស្តីពីការផ្គត់ផ្គង់ទឹកស្អាត ដើម្បីសម្រេចបានគោលដៅផ្គត់ផ្គង់ទឹកស្អាត ១០០% នៅឆ្នាំ ២០៣០ ។

ទី៩- ការបន្តពិនិត្យ និង ការរៀបចំក្របខ័ណ្ឌគតិយុត្ត សម្រាប់គ្រប់គ្រងវិស័យទឹកស្អាត, ជាពិសេស ការសម្រួលនីតិវិធីនៃការស្នើសុំភ្ជាប់បណ្តាញ, ការពង្រឹងការអនុវត្តលក្ខខណ្ឌអាជ្ញាបណ្ណ និង ការរក្សាប្រភពទឹកឆៅ, ព្រមទាំងការបង្កើតយន្តការស្ថាប័នសំខាន់ៗ និង ការបង្កើតនិយ័តករទឹកស្អាត ដើម្បីគ្រប់គ្រង អភិវឌ្ឍ និង ដោះស្រាយបញ្ហាប្រឈមនានា សំដៅធានាឱ្យបាននូវសន្តិសុខទឹក ។

ទី១០- ការលើកកម្ពស់តួនាទីជាយុទ្ធសាស្ត្រ និង ការចូលរួមរបស់រដ្ឋ, និង ការដាក់ចេញការលើកទឹកចិត្តដល់វិស័យឯកជន សម្រាប់ការវិនិយោគលើវិស័យទឹកស្អាត ក្នុងភូមិសាស្ត្រអាទិភាព ដូចជា តំបន់សេដ្ឋកិច្ចពិសេស, សួនបណ្តុំសហគ្រាសធុនតូច និង មធ្យម, និង តំបន់ប៉ូលសេដ្ឋកិច្ច នៅបណ្តារាជធានី-ខេត្ត ជាដើម ។

ទី១១- ការបន្តជំរុញស្វយ័តកម្ម និង លើកទឹកចិត្ត រដ្ឋាករទឹកស្អាតនៅទីប្រជុំជនខេត្ត-ក្រុង ។

### វិស័យឌីជីថល

ទី១២- ការជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ឱ្យបានជាអតិបរមា ជាពិសេស ក្នុងសកម្មភាពធុរកិច្ច និង សេដ្ឋកិច្ច តាមរយៈវិធានការប្រទាក់ក្រឡា និង ជាប្រព័ន្ធ ។

### មុំទី៣. ការកែលម្អបរិយាកាសធុរកិច្ច និង ការវិនិយោគ

គោលដៅជាយុទ្ធសាស្ត្រ គឺការបន្តកែលម្អបរិយាកាសអំណោយផល ដល់ការធ្វើធុរកិច្ច, ការធ្វើពាណិជ្ជកម្ម និង ការវិនិយោគ តាមរយៈ ការសម្រួល និង ការធ្វើសាមញ្ញកម្ម នីតិវិធីពាក់ព័ន្ធនានា, ការធ្វើឌីជីថលភាវូបនីយកម្ម សម្រាប់ការផ្តល់សេវាសាធារណៈ និង កិច្ចការរដ្ឋបាល, ការពង្រឹងសមត្ថភាពស្ថាប័ន, និង ការលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចសម្របសម្រួលអន្តរក្រសួង-ស្ថាប័ន ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

ទី១- ការបន្តរៀបចំ និង ធ្វើវិសោធនកម្មច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត ដូចជា ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម, ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, ច្បាប់ស្តីពីក្ស័យធន; និង ការបញ្ចប់ការរៀបចំច្បាប់ស្តីពីការសម្ងាត់ពាណិជ្ជកម្ម និង ព័ត៌មានមិនអាចផ្សព្វផ្សាយ ដើម្បីជានាដល់ការគ្រប់គ្រងកម្មសិទ្ធិបញ្ញា និង ការពារមិនឱ្យលេចធ្លាយព័ត៌មានពាណិជ្ជកម្ម ។

ទី២- ការលើកកម្ពស់គុណភាព, តម្លាភាព, ប្រសិទ្ធភាព និង ការជឿទុកចិត្ត; និង ការបង្វិតសេវាសាធារណៈ ទៅជិតអ្នកប្រើប្រាស់ តាមរយៈ ការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម និង ថ្នាលបច្ចេកវិទ្យា ក្នុងការផ្តល់សេវាសាធារណៈ ដើម្បីសម្រួលនីតិវិធី, កាត់បន្ថយពេល និង ចំណាយពាក់ព័ន្ធផ្សេងៗ; ព្រមទាំងការធ្វើអធិការកិច្ច និង ការបំពេញអនុលោមភាពផ្សេងទៀត ដើម្បីជានាការផ្តល់សេវាសាធារណៈប្រកបដោយ គុណភាព, ប្រសិទ្ធភាព និង តម្លាភាព ។

ទី៣- ការបន្តជំរុញការកែទម្រង់ស៊ីជម្រៅ និង ការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ ដើម្បីបង្កើនប្រសិទ្ធភាពប្រមូលចំណូល និង បង្កើតការប្រកួត-

ប្រជែងដោយស្មើភាព ក្នុងការធ្វើធុរកិច្ច និង ការវិនិយោគ, និង ដើម្បីកាត់បន្ថយបន្ទុកចំណាយលើការបំពេញតាមកាតព្វកិច្ច និង នីតិវិធីសារពើពន្ធ ។

ទី៤- ការបន្តពង្រឹងអភិបាលកិច្ច និង ពង្រីកតួនាទីរបស់វិស័យឯកជន ក្នុងវេទិកាធុរកិច្ច ក្រោមក្របខ័ណ្ឌអាស៊ាន, អាស៊ានជាមួយដៃគូ, និង អាសិប (RCEP) ដើម្បីជំរុញពាណិជ្ជកម្ម, ទាក់ទាញការវិនិយោគ និង ទេសចរណ៍ ពីបរទេស ។

ទី៥- ការជំរុញការអនុម័តយល់ព្រម ដោយអង្គនីតិប្បញ្ញត្តិនូវកិច្ច-ព្រមព្រៀងក្របខ័ណ្ឌស្តីអំពីកិច្ចសម្រួលពាណិជ្ជកម្មឆ្លងកាត់ព្រំដែន ដោយមិនប្រើក្រដាសស្នាម (Framework Agreement on Cross Border Paper-less Trade Facilitation) និង ការសហការអនុវត្ត ប្រកបដោយប្រសិទ្ធភាព សំដៅជំរុញការនាំចេញ និង ការនាំចូល ដោយប្រើប្រាស់ប្រព័ន្ធឌីជីថល ។

ទី៦- ការលើកកម្ពស់ការដោះស្រាយវិវាទពាណិជ្ជកម្ម, ទាំងក្នុងប្រព័ន្ធតុលាការ និង ក្រៅប្រព័ន្ធតុលាការ, ប្រកបដោយប្រសិទ្ធភាព ជំនាញ និង សមត្ថ-ភាព តាមរយៈ ការរៀបចំលិខិតបទដ្ឋានគតិយុត្ត និង យន្តការតុលាការ ពាណិជ្ជ-កម្ម ។

ទី៧- ការរៀបចំយន្តការតាមដាន និង វាយតម្លៃ ការកែលម្អបរិយា-កាសធុរកិច្ច និង ការវិនិយោគ ដោយផ្អែកលើការវាយតម្លៃលើភាពងាយស្រួល នៃការធ្វើធុរកិច្ច និង ការវិនិយោគ នៅកម្ពុជា ។

### មុំទី៤. ការពង្រឹងប្រសិទ្ធភាព និង ភាពទាក់ទាញ នៃតំបន់សេដ្ឋកិច្ចពិសេស រួមបញ្ចូលនូវ សួនឧស្សាហកម្ម, សួនកសិ-ឧស្សាហកម្ម និង តំបន់ពាណិជ្ជកម្មសេរីក្នុងស្រុក

គោលដៅជាយុទ្ធសាស្ត្រ គឺការប្រមូលផ្តុំ និង ការអភិវឌ្ឍ បណ្តាញផលិតកម្មឱ្យដើរតួនាទីសំខាន់ ក្នុងការបង្កើនប្រសិទ្ធភាព និង ភាពប្រកួតប្រជែងនៃឧស្សាហកម្មកម្ពុជា សំដៅបង្កើនការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស

និង ក្នុងស្រុក, លើកកម្ពស់ផលិតកម្ម និង ការកែច្នៃ សម្រាប់នាំចេញ, និង ជា-ពិសេស គាំទ្រដល់ការបង្កើតការងារ និង ការលើកស្ទួយជីវភាពប្រជាជននៅទីជនបទ ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

ទី១- ការរៀបចំ និង ការដាក់ឱ្យអនុវត្តច្បាប់ និង លិខិតបទដ្ឋានគតិ-យុត្តនានា ដើម្បីគ្រប់គ្រង និង លើកទឹកចិត្តដល់ការបង្កើត និង ការវិនិយោគ ក្នុងតំបន់សេដ្ឋកិច្ចពិសេស រួមបញ្ចូលនូវ សួនឧស្សាហកម្ម, សួនកសិ-ឧស្សាហកម្ម និង តំបន់ពាណិជ្ជកម្មសេរីក្នុងស្រុក ដើម្បីជំរុញការប្រមូលផ្តុំរោងចក្រសហ-គ្រាស សំដៅលើកកម្ពស់ប្រសិទ្ធភាព និង ភាពងាយស្រួល សម្រាប់គាំទ្រដល់ការអភិវឌ្ឍផលិតផលសក្តានុពល ជាអាទិ៍ កសិកម្ម និង កសិ-ឧស្សាហកម្ម, គ្រឿងបង្គុំអេឡិចត្រូនិក, រថយន្ត, វាយនភណ្ឌ និង/ឬ គ្រឿងសង្ហារិម ។

ទី២- ការសិក្សា និង ការពិនិត្យលទ្ធភាពក្នុងការអភិវឌ្ឍ និង ការប្រើ-ប្រាស់ ដីឯកជនរបស់រដ្ឋ ឱ្យក្លាយជាតំបន់សេដ្ឋកិច្ចពិសេស រួមបញ្ចូលនូវ សួន-ឧស្សាហកម្ម, សួនកសិ-ឧស្សាហកម្ម និង តំបន់ពាណិជ្ជកម្មសេរីក្នុងស្រុក សំដៅជានាការបង្កើតការងារ និង ធ្វើពិពិធកម្មផលិតកម្ម ។

ទី៣- ការបង្កើតតំបន់សេដ្ឋកិច្ចដែលវិនិយោគដោយរដ្ឋ នៅទីតាំងយុទ្ធសាស្ត្រមួយចំនួន សំដៅគាំទ្រដល់ការប្រមូលផ្តុំរោងចក្រ សហគ្រាស, ក្នុងស្រុក និង បរទេស, ដើម្បីផលិត និង កែច្នៃផលិតផល, ក៏ដូចជាសំដៅគាំទ្រវិស័យដែលមានសក្តានុពល ដែលវិស័យឯកជនពុំមានលទ្ធភាពវិនិយោគ ។

ទី៤- ការបន្តពង្រឹង និង ពង្រីកវិនិយោគសាធារណៈ លើការសាង-សង់ហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ ដូចជា ផ្លូវថ្នល់, ប្រព័ន្ធដឹកជញ្ជូន និង ឡូជីស្ទីក, បណ្តាញ អគ្គិសនី, ប្រព័ន្ធទឹកស្អាត និង ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ជាដើម ទៅតំបន់សេដ្ឋកិច្ចពិសេស រួមបញ្ចូលនូវ សួនឧស្សាហកម្ម, សួនកសិ-ឧស្សាហកម្ម, សួនបច្ចេកវិទ្យា និង តំបន់ពាណិជ្ជកម្មសេរីក្នុងស្រុក ។

ទី៥- ការជំរុញការតភ្ជាប់រវាងការវិនិយោគផ្ទាល់ពីបរទេស និង សហគ្រាសធុនមីក្រូ តូច មធ្យម និង ធំ ដែលស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស រួមបញ្ចូលនូវ សួនឧស្សាហកម្ម, សួនកសិ-ឧស្សាហកម្ម និង តំបន់ពាណិជ្ជកម្មសេរីក្នុងស្រុក សំដៅគាំទ្រដល់ការត្រៀមខ្លួនរបស់សហគ្រាសក្នុងស្រុក ចូលរួមក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ តំបន់ និង សកល ។

### មុំទី៥. ការធ្វើនវានុវត្ត យន្តការហិរញ្ញប្បទាន និង ផលិតផលហិរញ្ញវត្ថុ សម្រាប់គាំទ្រដល់ការវិនិយោគ

គោលដៅជាយុទ្ធសាស្ត្រ គឺការរៀបចំ និង ការកែលម្អ ក្របខ័ណ្ឌ និង យន្តការហិរញ្ញប្បទាន, និង ការធ្វើពិពិធកម្មផលិតផល និង សេវាកម្មហិរញ្ញវត្ថុ ដែលជានាបានសន្ទនីយភាព (Liquidity) ក្នុងទីផ្សារ និង ជម្រើសហិរញ្ញប្បទានសម្រាប់ការវិនិយោគ សំដៅរួមចំណែកជំរុញការវិនិយោគ និង ការធ្វើពិពិធកម្មសេដ្ឋកិច្ច ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

ទី១- ការបន្តជំរុញការធ្វើពិពិធកម្មផលិតផល ក្នុងវិស័យមូលបត្រតាមរយៈ ការលើកកម្ពស់ការបោះផ្សាយលក់សញ្ញាបណ្ណបៃតង, សញ្ញាបណ្ណសង្គម, សញ្ញាបណ្ណនិរន្តរភាព និង សញ្ញាបណ្ណផ្សារភ្ជាប់និរន្តរភាព សម្រាប់វិស័យឯកជន, ការដាក់ឱ្យដំណើរការផលិតផលទ្រព្យឌីជីថល, មូលបត្រអនាគត, ការប្តូរមូលបត្រ (SWAP Securities) និង គម្រោងនៃការវិនិយោគរួម (Collective Investment Scheme), និង ការជំរុញការអភិវឌ្ឍយន្តការបរធនបាលកិច្ច ។

ទី២- ការរៀបចំក្របខ័ណ្ឌគតិយុត្ត និង/ឬ ផែនការចង្អុលផ្លូវ ក្នុងការអភិវឌ្ឍផលិតផលហិរញ្ញវត្ថុសាធារណៈ ដូចជា មូលបត្ររដ្ឋ, មូលបត្ររដ្ឋបៃតង, មូលបត្ររដ្ឋអាកាសធាតុ, និង មូលបត្ររដ្ឋសង្គម ជាដើម ដើម្បីលើកកម្ពស់ការវិនិយោគសាធារណៈ និង វិស័យអាទិភាព ។

ទី៣- ការលើកកម្ពស់យន្តការភាពជាដៃគូរវាងរដ្ឋ និង ឯកជន ដើម្បី

គាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រ, គោលនយោបាយ និង របៀបវារៈនានា ក្នុងការ-អភិវឌ្ឍសង្គម-សេដ្ឋកិច្ច តាមរយៈ ការជំរុញការអនុវត្តច្បាប់ស្តីពីភាពជាដៃគូ រវាង រដ្ឋ និង ឯកជន, នីតិវិធីប្រតិបត្តិការ និង ក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធ ។

ទី៤- ការដាក់ចេញក្របខ័ណ្ឌយុទ្ធសាស្ត្រ ក្នុងការគាំទ្រការអភិវឌ្ឍ សហគ្រាសធុនមីក្រូ ធុនតូច មធ្យម និង ធំ តាមរយៈ ការគាំទ្រឱ្យមានការចុះបញ្ជីលក់មូលបត្រ, ការរៀបចំក្របខ័ណ្ឌគតិយុត្ត, និង ការបង្កើតបរិយាកាសអំណោយផល សម្រាប់ដាក់ឱ្យដំណើរការនូវយន្តការ និង ឧបករណ៍ហិរញ្ញវត្ថុថ្មីៗ ។

ទី៥- ការលើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ បង្កើតផលិតផលហិរញ្ញវត្ថុថ្មីៗ ស្របតាមតម្រូវការទីផ្សារ ដូចជា ឥណទានកសិកម្ម ដែលមានជម្រើសក្នុងការទូទាត់សង សមស្របទៅនឹងចំណូលតាមរដូវកាល ជាដើម ព្រមទាំងការជំរុញការនវានុវត្តយន្តការហិរញ្ញប្បទាន ដែលផ្សារភ្ជាប់រវាងហិរញ្ញប្បទានទៅនឹងផលិតផលសេវាជានាប៉ាប់រង, ជាពិសេស ក្នុងវិស័យកសិកម្ម ដើម្បីលើកកម្ពស់បរិយាបន្នហិរញ្ញប្បទាន ។

ទី៦- ការជំរុញការចុះបញ្ជីផ្លូវការរបស់ធុរកិច្ច ជាពិសេស សហគ្រាសធុនមីក្រូ តូច និង មធ្យម ដើម្បីបង្កភាពងាយស្រួលដល់គ្រឹះស្ថានហិរញ្ញវត្ថុ និង ធនាគារ ក្នុងការផ្តល់សេវាឥណទាន ប្រកបដោយសុវត្ថិភាព ក៏ដូចជា អនុញ្ញាតឱ្យធុរកិច្ចទាំងនោះ អាចទទួលបានការលើកទឹកចិត្ត និង ជំនួយអន្តរាគមន៍នានា ។

ទី៧- ការជំរុញការធ្វើពិពិធកម្ម យន្តការ និង សេវាហិរញ្ញវត្ថុ ដែលប្រើប្រាស់បច្ចេកវិទ្យា និង គិតគូរអំពីបរិស្ថាន, សង្គម និង អភិបាលកិច្ច ។

ទី៨- ការរៀបចំក្របខ័ណ្ឌគោលនយោបាយ, យុទ្ធសាស្ត្រ និង ផែនការចង្អុលផ្លូវ ក្នុងការអភិវឌ្ឍយុទ្ធសាស្ត្រហិរញ្ញប្បទានជាតិ ដើម្បីកៀរគរហិរញ្ញ-ប្បទាន និង ស្វែងរកប្រភពធនធានហិរញ្ញប្បទាន សម្រាប់គាំទ្រដល់ការអនុវត្ត

គោលនយោបាយ, យុទ្ធសាស្ត្រ និង របៀបវារៈនានា របស់រាជរដ្ឋាភិបាល ។

ទី៩- ការជំរុញ និង ការរៀបចំយន្តការលើកទឹកចិត្ត ឱ្យប្រជាពលរដ្ឋ និង សហគ្រាសនានា បង្កើនការដាក់សន្សំប្រាក់ក្នុងស្រុក ឱ្យបានច្រើននៅក្នុងប្រព័ន្ធធនាគារ ដើម្បីអនុញ្ញាតឱ្យវិស័យឯកជនមានលទ្ធភាពកៀរគរហិរញ្ញប្បទានសម្រាប់ការវិនិយោគបន្ថែម ។

## បញ្ហាគោលទី៣. ការអភិវឌ្ឍវិស័យឯកជន និង ការងារ

ការអភិវឌ្ឍវិស័យឯកជន និង ការងារ គឺជារបៀបវារៈគោលនយោបាយសំខាន់សម្រាប់ជំរុញកំណើន នៅក្នុងបរិការណ៍នៃដំណើរការបរិវត្តកម្មសង្គម-សេដ្ឋកិច្ចកម្ពុជា នាបច្ចុប្បន្ន និង សម្រាប់រយៈពេល ២៥ ឆ្នាំខាងមុខ ។ រាជរដ្ឋាភិបាលចាត់ទុកវិស័យឯកជន ជាក្បាលម៉ាស៊ីននៃកំណើន និង ជាដៃគូសំខាន់បំផុត ក្នុងការបង្កើតការងារ, ការបង្កើតគំនិត ច្នៃប្រឌិត និង នវានុវត្ត, ការលើកកម្ពស់ផលិតភាព, និង ការពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុងទីផ្សារ តំបន់ និង សកល ។ ឈរលើមូលដ្ឋាននេះ, រាជរដ្ឋាភិបាលផ្តោតលើអាទិភាពចំនួន ៥ : (១). ការអភិវឌ្ឍទីផ្សារការងារ; (២). ការលើកស្ទួយសហគ្រាសធុន មីក្រូ តូច និង មធ្យម, ធុរកិច្ចថ្មី, សហគ្រិនភាព, និង ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ; (៣). ការពង្រឹងភាពជាដៃគូវិស័យសាធារណៈ និង វិស័យឯកជន; (៤). ការពង្រឹងការប្រកួតប្រជែង; និង (៥). ការពង្រឹងប្រព័ន្ធធនាគារ និង វិស័យហិរញ្ញវត្ថុមិនមែនធនាគារ ។

### មុំទី១. ការអភិវឌ្ឍទីផ្សារការងារ

គោលដៅជាយុទ្ធសាស្ត្រ គឺការជំរុញការអភិវឌ្ឍទីផ្សារការងារ តាមរយៈ ការបង្កើត, ការរក្សា, និង ការបង្កើន ការងារដល់កម្មករ-និយោជិត, ទាំងក្នុងប្រព័ន្ធ និង ក្រៅប្រព័ន្ធ, សំដៅ បង្កើនប្រាក់ចំណូល, ទ្រទ្រង់ជីវភាពសមរម្យ និង កាត់បន្ថយភាពក្រីក្រ របស់ប្រជាជន ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្ដោតអាទិភាពលើ ៖

ទី១- ការរៀបចំ ផែនការវិនិយោគបន្ថែម និង យន្តការតាមដាន និង វាយតម្លៃ គ្រឹះស្ថានបណ្ដុះបណ្ដាល; និង ការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធគាំទ្រការបណ្ដុះបណ្ដាលវិទ្យាសាស្ត្រអនុវត្ត និង បច្ចេកវិទ្យា ។

ទី២- ការបន្តបង្កើនឱកាសការងារ, ការពង្រីកសេវាជួយស្វែងរកការងារ ប្រឹក្សាយោបល់ និង មគ្គុទេសក៍ការងារ, ការបន្តរៀបចំវេទិកាការងារ, និង ការរៀបចំឱ្យមានគ្រូបង្គោល និង ជនបង្គោលផ្នែកអាជីពសម្រាប់ជួយស្វែង-រកការងារ នៅតាមគ្រឹះស្ថានសិក្សា ។

ទី៣- ការពង្រឹងអនុលោមភាព និង ប្រសិទ្ធភាព នៃការគ្រប់គ្រងហត្ថពលកម្មបរទេស ស្របតាមបទដ្ឋានអន្តរជាតិ, ការរៀបចំយន្តការផ្ទេរជំនាញមកឱ្យយុវជនខ្មែរ, និង ការបង្ការការជួញដូរកម្លាំងពលកម្មឆ្លងដែនខុសច្បាប់ ។

ទី៤- ការបន្តពង្រឹងការអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង ដោយរួមបញ្ចូល កម្មវិធីហាត់ការ, កម្មសិក្សា, ការបង្កើនជំនាញ និង ការរៀបចំជំនាញឡើងវិញ ដើម្បីលើកកម្ពស់ផលិតភាពការងារ ។

ទី៥- ការបន្តពង្រឹងគុណភាព និង ប្រសិទ្ធភាពអធិការកិច្ចការងារ, ការធ្វើវិជ្ជាជីវូបនីយកម្មអធិការការងារ, និង ការជំរុញ និង ការពង្រឹង យន្តការអធិការកិច្ចអន្តរស្ថាប័ន ។

ទី៦- ការបន្តលើកកម្ពស់ជីវភាពកម្មករ-និយោជិត, ការបន្តដំឡើងប្រាក់ឈ្នួលអប្បបរមា និង អត្ថប្រយោជន៍ផ្សេងៗ, ការពិនិត្យលទ្ធភាពពង្រីកវិសាលភាពប្រាក់ឈ្នួលអប្បបរមាទៅកាន់វិស័យផ្សេងៗ, ការបន្តការតបណ្ដាញអគ្គិសនី និង ទឹកស្អាត ក្នុងថ្លៃសមរម្យ, និង ការជំរុញអនុវត្តច្បាប់ស្ដីពីកតិសន្យាពិសេស ។

ទី៧- ការបន្តការលើកកម្ពស់សុវត្ថិភាព និង សុខភាពការងារ, ការ-រៀបចំច្បាប់ស្ដីពីសុវត្ថិភាព និង សុខភាពការងារ, ការកែលម្អគុណភាពមធ្យោ-

បាយដឹកជញ្ជូន, និង ការជំរុញឱ្យមានទារកដ្ឋាន កន្លែងស្នាក់នៅ កន្លែងបរិភោគអាហារ/អាហារដ្ឋាន ដែលមានថ្លៃសមរម្យ ក្នុងតំបន់ប្រមូលផ្តុំរោងចក្រ និង តំបន់សេដ្ឋកិច្ចពិសេស ។

ទី៨- ការបន្តពង្រឹងសុខដុមនីយកម្មក្នុងទំនាក់ទំនងវិជ្ជាជីវៈ; ការពង្រឹងសមត្ថភាព និង ការធ្វើវិជ្ជាជីវូបនីយកម្មដល់មន្ត្រីផ្សះផ្សាវិវាទការងារ និង បុគ្គល ដែលទទួលផ្នែកបុគ្គលិក; ការពង្រឹងយន្តការដោះស្រាយវិវាទការងារ; ការធានានិរន្តរភាពក្រុមប្រឹក្សាអាជ្ញាកណ្តាល; ការជំរុញដាក់ឱ្យដំណើរការតុលាការការងារ; ការរៀបចំបង្កើតមូលនិធិអភិវឌ្ឍទំនាក់ទំនងវិជ្ជាជីវៈ; និង ការជំរុញយុទ្ធនាការថ្នាក់ជាតិស្តីពី **«សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ »** ។

ទី៩- ការបន្តពង្រីកទីផ្សារការងារនៅក្រៅប្រទេស; ការទប់ស្កាត់ទេសន្តរប្រវេសន៍ការងារខុសច្បាប់; ការបណ្តុះបណ្តាល និង ការលើកកម្ពស់សិទ្ធិ, ផលប្រយោជន៍ និង សេចក្តីថ្លៃថ្នូរ របស់ពលករទេសន្តរប្រវេសន៍ខ្មែរ; ការរៀបចំយន្តការទទួលស្គាល់ជំនាញ; និង ការធ្វើចល័តភាពរបបសន្តិសុខសង្គម ។

### មុំទី២. ការលើកស្ទួយសហគ្រាសធុនមីក្រូ តូច និង មធ្យម, ធុរកិច្ចថ្មី, សហគ្រិនភាព និង ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

គោលដៅជាយុទ្ធសាស្ត្រ គឺការបន្តជំរុញការអភិវឌ្ឍបរិយាកាសអំណោយផលដល់សហគ្រាសធុនមីក្រូ តូច និង មធ្យម និង ធុរកិច្ចថ្មី ឱ្យរីកលូតលាស់, ធន់នឹងវិបត្តិ និង នវានុវត្ត ដែលរួមចំណែកដល់កំណើនសេដ្ឋកិច្ច និង ការបង្កើតការងារ ព្រមទាំងការអភិវឌ្ឍវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធឆ្លងអន្តរកាលចូលទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

ទី១- ការបន្តរៀបចំ និង ការដាក់ឱ្យអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ និង បទប្បញ្ញត្តិនានា; ការធានាកែលម្អអភិបាលកិច្ចសាធារណៈ; ការលើកស្ទួយបរិយាកាសអំណោយផលដល់សហគ្រាសធុន មីក្រូ តូច និង មធ្យម

និង ធុរកិច្ចថ្មី; និង ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ ប្រកបដោយប្រសិទ្ធភាព ដល់គ្រប់តួអង្គ ក្នុងប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព ។

ទី២- ការបន្តលើកកម្ពស់ និង ការលើកទឹកចិត្ត ការបណ្តុះបណ្តាលសមត្ថភាព និង ជំនាញគ្រប់គ្រង ធុរកិច្ច និង សហគ្រិនភាព ដល់ម្ចាស់សហគ្រាសធុនមីក្រូ តូច និង មធ្យម និង ធុរកិច្ចថ្មី; ការគាំទ្រការរៀបចំកម្មវិធីចែករំលែករបស់សហគ្រិនដែលមានបទពិសោធ (Mentorship); និង ការបណ្តុះបណ្តាល សមត្ថភាព និង ជំនាញ របស់បុគ្គលិកបម្រើការ ក្នុងសហគ្រាសធុនមីក្រូ តូច និង មធ្យម និង ធុរកិច្ចថ្មី ។

ទី៣- ការបន្តពង្រឹង និង ការពង្រីកទីផ្សារ ក្នុងស្រុក និង សកលសម្រាប់សហគ្រាសធុនមីក្រូ តូច និង មធ្យម និង ធុរកិច្ចថ្មី តាមរយៈការដាក់ឱ្យអនុវត្តយន្តការគាំទ្ររបស់រដ្ឋនានា និង លទ្ធកម្មសាធារណៈ; ព្រមទាំងការផ្តល់ការគាំទ្រ និង ការលើកទឹកចិត្ត ដល់ការបង្កើតបណ្តាញធុរកិច្ច (Business Networking) ។

ទី៤- ការបង្កើនលទ្ធភាពទទួលបានហិរញ្ញវត្ថុដល់សហគ្រាសធុន មីក្រូ តូច និង មធ្យម និង ធុរកិច្ចថ្មី ដែលមានសក្តានុពល តាមរយៈ ការអភិវឌ្ឍផលិតផលហិរញ្ញវត្ថុថ្មីៗ ក្នុងទីផ្សារឥណទាន និង ទីផ្សារហិរញ្ញវត្ថុ, ការផ្តល់ជំនួយឥតសំណង (Grants) និង ការពិចារណាចូលរួមវិនិយោគក្នុងក្រុមហ៊ុន, ការបន្តពង្រីកមូលនិធិអភិវឌ្ឍសហគ្រិនភាព និង ការលើកទឹកចិត្តដល់វិស័យឯកជន ឱ្យវិនិយោគលើសហគ្រាសធុន មីក្រូ តូច និង មធ្យម និង ធុរកិច្ចថ្មី ។

ទី៥- ការបង្កើនវិនិយោគសាធារណៈ លើថ្នាលបច្ចេកវិទ្យាឌីជីថល ប្រព័ន្ធឡូជីស្ទីក និង ហេដ្ឋារចនាសម្ព័ន្ធ ដើម្បីគាំទ្រដល់សហគ្រាសធុន មីក្រូ តូច និង មធ្យម និង ធុរកិច្ចថ្មី ដែលតភ្ជាប់ និង ស្ថិតក្នុងសួនបណ្តុំសហគ្រាសធុនមីក្រូ តូច និង មធ្យម តំបន់សេដ្ឋកិច្ចពិសេស ឬ ទីតាំងភូមិសាស្ត្រយុទ្ធសាស្ត្រនានា; និង ការលើកទឹកចិត្តវិស័យឯកជន ឱ្យវិនិយោគលើហេដ្ឋារចនា-

សម្ព័ន្ធទាំងនេះ ។

ទី៦- ការរៀបចំ និង ការដាក់ឱ្យអនុវត្ត យន្តការលើកកម្ពស់វប្បធម៌សហគ្រិនភាព និង ធុរកិច្ច តាមរយៈ ការបញ្ជ្រាបការយល់ដឹង និង គុណតម្លៃសហគ្រិនភាព, ការច្នៃប្រឌិត, ការបង្កើតថ្មី និង ការទទួលយកហានិភ័យធុរកិច្ចដល់សាធារណជន ។

ទី៧- ការរៀបចំ និង ការដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ ២០២៣-២០២៨ ។

## មុំទី៣. ការពង្រឹងភាពជាដៃគូវិស័យសាធារណៈ និង វិស័យឯកជន

គោលដៅជាយុទ្ធសាស្ត្រ គឺការបន្តពង្រឹងភាពជាដៃគូរវាងរដ្ឋ និង ឯកជន ដែលជាយន្តការមិនអាចខ្វះបាន និង មានប្រសិទ្ធភាព ក្នុងការគាំទ្រពិពិធកម្ម និង កំណើន, និង ការបន្តពង្រឹងការគ្រប់គ្រងហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ ចំពោះការអនុវត្តគម្រោងការវិនិយោគសាធារណៈ ក្រោមយន្តការភាពជាដៃគូរវាងរដ្ឋ និង ឯកជន ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

ទី១- ការបន្តបញ្ជ្រាបការយល់ដឹង និង ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និង ធនធានមនុស្ស នៅតាមក្រសួង-ស្ថាប័ន ពាក់ព័ន្ធនឹងការរៀបចំ, ការអភិវឌ្ឍ, ការអនុវត្ត និង ការគ្រប់គ្រង គម្រោងវិនិយោគសាធារណៈ តាមយន្តការភាព-ជាដៃគូរវាងរដ្ឋ និង ឯកជន ។

ទី២- ការជំរុញ និង ការអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធគាំទ្រទីផ្សារភាព-ជាដៃគូរវាងរដ្ឋ និង ឯកជន តាមរយៈការរៀបចំបង្កើតយន្តការគាំទ្រហិរញ្ញវត្ថុ និង ការគាំទ្រពីរដ្ឋ ដែលកំណត់ដោយច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និង ឯកជន និង លិខិតបទដ្ឋានគតិយុត្តជាធរមាន ។

ទី៣- ការបន្តអភិវឌ្ឍគម្រោងវិនិយោគសាធារណៈ តាមយន្តការភាព-ជាដៃគូរវាងរដ្ឋ និង ឯកជន ដោយផ្តោតលើគម្រោងផ្តួចផ្តើមដោយរដ្ឋ សម្រាប់

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និង ការផ្តល់សេវាសាធារណៈកាន់តែប្រសើរ សំដៅគាំទ្រដល់កំណើនសេដ្ឋកិច្ច និង ការបន្ថយសម្ពាធថវិកាជាតិ និង បន្ទុកបំណុលសាធារណៈ ។

ទី៤- ការបន្តជំរុញយន្តការសម្របសម្រួលកម្រិតអន្តរស្ថាប័ន ដើម្បីប្រមូលព័ត៌មាន និង ទិន្នន័យគម្រោង សំដៅពង្រឹងការវិភាគ និង ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុសាធារណៈ ។

ទី៥- ការបន្តរៀបចំយន្តការពិនិត្យ និង តាមដាន ការអនុវត្តកាតព្វកិច្ចរបស់រដ្ឋ និង ឯកជន ដោយអនុលោមតាមកិច្ចសន្យាភាពជាដៃគូរវាងរដ្ឋ និង ឯកជន និង លិខិតបទដ្ឋានគតិយុត្តជាធរមាន ។

### មុំទី៤. ការពង្រឹងការប្រកួតប្រជែង

គោលដៅជាយុទ្ធសាស្ត្រ គឺការបន្តជំរុញការប្រកួតប្រជែងស្មើភាពតាមរយៈ ការបន្តបង្កើតបរិយាកាសធ្វើធុរកិច្ចដោយស្មើភាព, គ្មានការរើសអើង, តាមនីតិវិធីដោយយុត្តិធម៌ និង ស្របតាមអភិក្រម "**ជវភាពនៃប្រព័ន្ធតួអង្គតែមួយ**" សំដៅរួមចំណែកដល់ការបង្កើតមុខទំនិញ និង សេវាកម្មថ្មីៗ; និង ការបង្កើនផលិតភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ចកម្ពុជា ។

ក្នុងនីតិកាលទី៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

ទី១- ការបន្តពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែង, ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន; ការការពារកម្មសិទ្ធិឯកជនស្របច្បាប់; និង ការទប់ស្កាត់រាល់ប្រតិបត្តិការ និង សកម្មភាព ធុរកិច្ចទាំងឡាយ ដែលរារាំង, រឹតត្បិត, ឬ បង្ខូចដល់ការប្រកួតប្រជែង ស្មើភាព និង យុត្តិធម៌ ។

ទី២- ការបន្តពង្រឹងសមត្ថភាពស្ថាប័ន, រៀបចំ និង អនុវត្ត គោលនយោបាយ និង និយ័តកម្មទីផ្សារ, និង រៀបចំយន្តការ តាមដាន ត្រួតពិនិត្យ និង វាយតម្លៃ លើចរិតធុរកិច្ច និង លើការរួមបញ្ចូលគ្នានៃធុរកិច្ច របស់សហ-

គ្រោះសដែលមាន ឬ អាចមានកម្មវត្ថុ ឬ អានុភាព រារាំង រឹតត្បិត ឬ បង្ខូច ដល់ការប្រកួតប្រជែង ឬ បង្កើនអំណាចផ្ដាច់មុខក្នុងទីផ្សារ (Monopoly Power) ។

ទី៣- ការរៀបចំ និង ការដាក់ចេញ យន្តការ និង លិខិតបទដ្ឋានគតិយុត្តចាំបាច់ សម្រាប់គ្រប់គ្រង និង ដោះស្រាយ ប្រកបដោយប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាព ចំពោះការបង្កើត ឬ ការព្រមព្រៀង ឬ សកម្មភាព ឃុបឃិតនៃសហគ្រាស (Collusion) ក្នុងការកំណត់ភូមិសាស្ត្រលក់ទំនិញ ឬ សេវាកម្ម, ការរក្សា ឬ ការកំណត់ថ្លៃឱ្យខ្ពស់ជាងថ្លៃទីផ្សារប្រកួតប្រជែង ដែលប៉ះពាល់ដល់ការផលិតទំនិញ និង សេវាថ្មីៗ ។

ទី៤- ការបន្តពង្រឹងការការពារ កម្មសិទ្ធិបញ្ញា និង ទ្រព្យសម្បត្តិឯកជនស្របច្បាប់ ដើម្បីលើកកម្ពស់ការបង្កើតផលិតផល និង សេវាកម្មថ្មីៗ, ការច្នៃប្រឌិត និង ការនវានុវត្ត ក្នុងគោលបំណងជានាឱ្យមានការប្រកួតប្រជែងនៅក្នុងទីផ្សារ ។

ទី៥- ការបន្តជំរុញ ការរៀបចំ, ការអភិវឌ្ឍ, ការធ្វើវិសោធនកម្ម និង ការអនុវត្ត គោលនយោបាយ, ច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងការប្រកួតប្រជែង; និង ការបន្តពង្រឹងសមត្ថភាពគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា, យន្តការដោះស្រាយជម្លោះធុរកិច្ច, និង យន្តការការពារសិទ្ធិអ្នកប្រើប្រាស់ ស្របតាមស្តង់ដា គុណភាព, សុវត្ថិភាព និង សុខភាព ។

ទី៦- ការរៀបចំ និង ការដាក់ចេញ យន្តការការពារសិទ្ធិអ្នកប្រើប្រាស់ឱ្យដើរតួនាទីចម្បងក្នុងការដោះស្រាយបញ្ហាជំនួសអ្នកប្រើប្រាស់ ក្នុងករណីមានវិវាទប្រតិបត្តិការទិញ-លក់ ទំនិញ និង សេវា គ្រប់ប្រភេទ ។

### មុំទី៥. ការពង្រឹងប្រព័ន្ធធនាគារ និង វិស័យហិរញ្ញវត្ថុមិនមែនធនាគារ

គោលដៅជាយុទ្ធសាស្ត្រ គឺការបន្តពង្រឹងប្រព័ន្ធធនាគារ និង វិស័យហិរញ្ញវត្ថុមិនមែនធនាគារ ឱ្យកាន់តែមាន ស័ក្តិសិទ្ធភាព, ភាពធន់នឹងវិបត្តិ, បរិយាបន្ន, ពិពិធភាព និង ភាពទំនើប តាមរយៈ ការបន្តអភិវឌ្ឍក្របខ័ណ្ឌគតិយុត្ត,

ជំរុញភាពស៊ីជម្រៅហិរញ្ញវត្ថុ, ពង្រឹងសមត្ថភាពស្ថាប័ន និង អក្ខរកម្មហិរញ្ញវត្ថុ, និង លើកស្ទួយឌីជីថលូបនីយកម្ម ក្នុងវិស័យហិរញ្ញវត្ថុ ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

ទី១- ការបន្តអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ឆ្នាំ ២០១៦-២០២៥ ព្រមទាំងការធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រនេះ ដើម្បីបន្តអភិវឌ្ឍក្របខ័ណ្ឌគតិយុត្ត, ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ និង យន្តការសម្របសម្រួលនយោបាយ, និង លើកស្ទួយតួនាទីអន្តរការិយកម្មនៃប្រព័ន្ធហិរញ្ញវត្ថុ; ការពង្រឹងសមត្ថភាពស្ថាប័ន និង មូលធនមនុស្ស ក្នុងវិស័យធនាគារ និង ហិរញ្ញវត្ថុមិនមែនធនាគារ; និង ការធ្វើពិពិធកម្មផលិតផលហិរញ្ញវត្ថុ ។

ទី២- ការបន្តធានាស្ថិរភាពហិរញ្ញវត្ថុ តាមរយៈ ការពង្រឹងយន្តការ-គ្រប់គ្រង និង ត្រួតពិនិត្យ វិស័យធនាគារ និង វិស័យហិរញ្ញវត្ថុមិនមែនធនាគារ; ការបន្តប្រឆាំងការសម្អាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម; ការកាត់បន្ថយធនាគារស្រមោល; និង ការជំរុញបន្ថែមដល់ការប្រើប្រាស់ប្រាក់រៀល ។

ទី៣- ការបន្តពង្រឹងអក្ខរកម្មហិរញ្ញវត្ថុ តាមរយៈ ការបន្តយុទ្ធនាការផ្សព្វផ្សាយដល់សាធារណជន, ការរៀបចំ កម្មវិធីសិក្សា និង ការបណ្តុះបណ្តាលការគ្រប់គ្រងហិរញ្ញវត្ថុ ដល់ម្ចាស់ និង អ្នកគ្រប់គ្រងសហគ្រាស ជាពិសេស សហ-គ្រាសធុនមីក្រូ តូច និង មធ្យម; និង ការបន្តជំរុញការអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិកម្ពុជា (CIFRS) ។

ទី៤- ការបន្តអភិវឌ្ឍទីផ្សារមូលបត្រ តាមរយៈ ការជំរុញ និង ការលើក-ទឹកចិត្តដល់ក្រុមហ៊ុនក្នុងស្រុក ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ឱ្យបោះផ្សាយលក់មូលបត្រជាសាធារណៈ; ការបង្កើតយន្តការលើកទឹកចិត្តដល់វិនិយោគិនស្ថាប័ន; ការបង្កើតប្រតិបត្តិករទីផ្សារមូលបត្រអនាគត; និង ការបង្កើតយន្តការគ្រប់គ្រងការជួញដូរទ្រព្យឌីជីថល ។

ទី៥- ការជំរុញការអភិវឌ្ឍទីផ្សារឧបករណ៍និស្សន្ទ ដែលជាថ្នាលលើក

កម្ពស់ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ និង យន្តការកំណត់អត្រាការប្រាក់អនាគត តាមរយៈ ការរៀបចំក្របខ័ណ្ឌគតិយុត្ត, ការរៀបចំហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និង ការទាក់ទាញតួអង្គផ្តល់សន្ទនីយភាព ។

ទី៦- ការបន្តពង្រីកផលិតផលធានារ៉ាប់រង, ជាពិសេស សេវាធានារ៉ាប់រងអាយុជីវិត និង សេវាធានារ៉ាប់រងខ្នាតតូច, តាមរយៈ ការកែសម្រួលក្របខ័ណ្ឌគតិយុត្ត, ការរៀបចំស្តង់ដាចាំបាច់នានា, ការពង្រឹងសមត្ថភាពនិយ័តករធានារ៉ាប់រង, និង ការបង្កើនការចូលរួមក្នុងទីផ្សារធានារ៉ាប់រង ។

ទី៧- ការបន្តពង្រឹងវិស័យអភិវឌ្ឍអចលនវត្ថុ, ជាពិសេស អាជីវកម្មអភិវឌ្ឍលំនៅឋាន និង អាជីវកម្មផ្តល់ សេវាកម្មអចលនវត្ថុ និង វិស័យបញ្ចាំ និង ប្រាតិភោគដោយអនុប្បទាន, តាមរយៈ ការរៀបចំ និង ការកែសម្រួល ក្របខ័ណ្ឌគតិយុត្ត, ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យអចលនទ្រព្យនៅកម្ពុជា, ការពង្រឹង សមត្ថភាពមន្រ្តីជំនាញ និង អ្នកចូលរួមទីផ្សារ ។

ទី៨- ការបន្តអភិវឌ្ឍវិស័យបរធនបាលកិច្ច ដោយជំរុញ និង ពង្រឹងការអនុវត្តច្បាប់; ការលើកកម្ពស់ការយល់ដឹងជាសាធារណៈ; និង ការអភិវឌ្ឍទីផ្សារ, ប្រតិបត្តិករ និង ផលិតផលបរធនបាលកិច្ចថ្មីៗ; ព្រមទាំងការសិក្សា និង ការបង្កើត យន្តការគ្រប់គ្រង និង ប្រតិបត្តិការ តាមការនវានុវត្តបច្ចេកវិទ្យា។

## បញ្ហាកោណទី៤. ការអភិវឌ្ឍប្រកបដោយភាពធន់, ចីរភាព និង បរិយាបន្ន

ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និង បរិយាបន្ន គឺជាអភិក្រមរួម និង ជាមាគ៌ាឆ្ពោះទៅបរិវត្តកម្មសង្គម-សេដ្ឋកិច្ច ដើម្បីធានាឱ្យសង្គមទាំងមូលអាចត្រៀមខ្លួនបានល្អ ក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមចម្រុះ និង ភាពមិនប្រាកដប្រជានៃសកលភាវូបនីយកម្ម, ចីរភាពបរិស្ថាន និង ការប្រែប្រួលអាកាសធាតុ ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលផ្តោតលើអាទិភាពចំនួន ៥ : (១).

ការធ្វើបរមការូបនីយកម្មផលលាភប្រជាសាស្ត្រ, ការពង្រឹងភាពធន់ប្រជាសាស្ត្រ និង ការលើកកម្ពស់សមភាពយេនឌ័រ; (២). ការគ្រប់គ្រងធនធានធម្មជាតិ, បេតិកភណ្ឌ វប្បធម៌ និង ទេសចរណ៍ ប្រកបដោយចីរភាព; (៣). ការលើកស្ទួយកសិកម្ម និង ការអភិវឌ្ឍជនបទ; (៤). ការពង្រឹងការគ្រប់គ្រង និង ការធ្វើទំនើបកម្មនគរូបនីយកម្ម; និង (៥). ការធានាចីរភាពបរិស្ថាន និង ការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងការលើកកម្ពស់សេដ្ឋកិច្ចបៃតង ។

## មុំទី១. ការធ្វើបរមការូបនីយកម្មផលលាភប្រជាសាស្ត្រ, ការពង្រឹងភាពធន់ប្រជាសាស្ត្រ និង ការលើកកម្ពស់សមភាពយេនឌ័រ

គោលដៅជាយុទ្ធសាស្ត្រ គឺការជំរុញការទាញយកអត្ថប្រយោជន៍ ឱ្យបានជាអតិបរមាពីផលលាភប្រជាសាស្ត្រ និង ការពង្រឹងភាពធន់ប្រជាសាស្ត្រ ដោយបន្តជំរុញការអនុវត្តគោលនយោបាយជាតិប្រជាជន និង លើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងការងារដឹកនាំ ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

ទី១- ការបន្តជំរុញពិពិធកម្មការងារ ដើម្បីស្រូបយកកម្លាំងពលកម្មរបស់យុវជន តាមរយៈ ការអភិវឌ្ឍជំនាញបច្ចេកទេស, ការបង្កើនការវិនិយោគ, និង ការអភិវឌ្ឍវិស័យសហគ្រាសធុនមីក្រូ តូច និង មធ្យម ដោយគិតគូរដល់ការអភិវឌ្ឍសហគ្រិនវ័យក្មេង, សមភាពយេនឌ័រ និង ស្វ័យធុរកិច្ច ។

ទី២- ការបន្តពង្រឹង និង ការពង្រីកវិសាលភាពសេវាសុខភាពបន្តពូជ និង សុខភាពផ្លូវភេទរបស់យុវវ័យ, ជាពិសេសស្ត្រី និង ក្មេងស្រី; ការបន្តអនុវត្តកម្មវិធីគាំពារសង្គមដល់ស្ត្រីមានផ្ទៃពោះ និង កុមារនៃគ្រួសារក្រីក្រ; និង ការបន្តលើកកម្ពស់អាហារូបត្ថម្ភដល់ស្ត្រីមានផ្ទៃពោះ និង កុមារ ។

ទី៣- ការបង្កើតយន្តការ និង គម្រោងសន្សំប្រាក់ ដើម្បីកាត់បន្ថយហានិភ័យអសន្តិសុខផ្នែកហិរញ្ញវត្ថុ សម្រាប់វ័យចាស់ និង ដើម្បីជំរុញការវិនិយោគ

នារីវ័យចាស់ ។

ទី៤- ការបង្កើនការវិនិយោគលើយេនឌ័រ និង ការបង្កើនភាពអង់អាចដល់ស្ត្រី និង ក្មេងស្រី នៅក្នុងវិស័យសេដ្ឋកិច្ច, អប់រំ, សុខភាព និង ការដឹកនាំសាធារណៈ ដើម្បីទាញយកអត្ថប្រយោជន៍ពីភាគលាភយេនឌ័រ, បង្កលក្ខណៈអំណោយផលដល់ស្ត្រី ក្នុងការប្រើប្រាស់សិទ្ធិលើការសម្រេចចិត្តអំពីគ្រួសារ និងចំនួនកូន, កាត់បន្ថយភាពងាយរងគ្រោះ ដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រទៅលើស្ត្រី និង ក្មេងស្រី, និង លើកកម្ពស់ទំនាក់ទំនងអន្តរជំនាន់ ។

ទី៥- ការជំរុញការដាក់ចេញនូវវិធានការគោលនយោបាយសមស្រប និង ទាន់ពេល ដោយផ្តោតការគិតគូរដល់បម្រែបម្រួលប្រជាសាស្ត្រ ដែលស្តែងឡើង តាមបម្រែបម្រួលរចនាសម្ព័ន្ធអាយុប្រជាជន សំដៅធានាឱ្យអត្រាកំណើត, អត្រាមរណភាព និង ទេសន្តរប្រវេសន៍ ស្ថិតក្នុងស្ថានភាពអំណោយផល ដោយមានកម្លាំងពលកម្មគ្រប់គ្រាន់ សម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយភាពធន់, ចីរភាព និង បរិយាបន្ន ។

### មុំទី២. ការគ្រប់គ្រងធនធានធម្មជាតិ, បេតិកភណ្ឌវប្បធម៌ និង ទេសចរណ៍ ប្រកបដោយចីរភាព

គោលដៅជាយុទ្ធសាស្ត្រ គឺការផ្តោតលើការអភិរក្សដើម្បីការអភិវឌ្ឍ សំដៅលើកកម្ពស់វិភាគទានកិច្ចការនេះ ចំពោះការអភិវឌ្ឍវិស័យកសិកម្ម, ឧស្សាហកម្ម និង ទេសចរណ៍; ការពង្រឹងការគ្រប់គ្រងធនធានរ៉ែ; ការធានាចីរភាពធនធានព្រៃឈើ, ជលផល និង គុណភាពដី; ព្រមទាំងការការពារ, ការអភិវឌ្ឍ និង ការទាញយកប្រយោជន៍ ឱ្យអស់សក្តានុពល ពីបេតិកភណ្ឌវប្បធម៌ និង ទេសចរណ៍ ប្រកបដោយចីរភាព ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

ទី១- ការបន្តជំរុញការអនុវត្ត "គោលនយោបាយជាតិស្តីពីធនធានរ៉ែ ឆ្នាំ ២០១៨-២០២៨" ដោយបន្តជំរុញការវិនិយោគក្នុងវិស័យឧស្សាហកម្ម

និស្សារណកម្ម និង ឧស្សាហកម្មគាំទ្រ; ការរៀបចំផែនទី និង ការកំណត់តំបន់សក្តានុពលធនធានរ៉ែ និង ប្រេងកាត និង កិច្ចដំណើរការឡើងវិញនូវ អណ្តូងប្រេងកាត; ការបង្កើនប្រសិទ្ធភាពការប្រមូលចំណូលជាតិ; ការលើកកម្ពស់អភិបាលកិច្ច ក្នុងការគ្រប់គ្រងធនធាន និង ការធ្វើអាជីវកម្មរ៉ែ; ការបង្កើនការចូលរួម និង ការលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន និង ការកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់បរិស្ថាន និង សង្គម; និង ការពង្រឹងយន្តការអភិរក្ស និង គ្រប់គ្រងអាជីវកម្មខ្សាច់ ដោយកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ផ្នែកសង្គម និង បរិស្ថាន ជាពិសេស ការបាក់ច្រាំងទន្លេ ។

ទី២- ការពង្រឹងការគ្រប់គ្រង, ការអភិរក្ស, ការការពារ និង ការអភិវឌ្ឍប្រកបដោយសុខដុមនីយកម្ម និង ចីរភាព នូវប្រព័ន្ធអេកូឡូស៊ីសំខាន់ៗរបស់កម្ពុជា តាមរយៈ ការបន្តគ្រប់គ្រងធនធានព្រៃឈើ និង សត្វព្រៃដោយរក្សាគម្របព្រៃឈើឱ្យលើស ៦០% នៃផ្ទៃប្រទេស; ការស្តារព្រៃឈើឡើងវិញ; ការទប់ស្កាត់ និង ការឆ្លើយតបទាន់ពេលទៅនឹងភ្លើងឆេះព្រៃ និង ការអភិរក្សតំបន់ដីមមោក; ការលើកកម្ពស់ការអភិវឌ្ឍចម្ការដែលមានភាតរបរិស្ថាន និង ប្រកបដោយចីរភាព; ការកាត់បន្ថយការពឹងផ្អែកលើការដកហូតអនុផលព្រៃឈើដោយចីរភាព; ការទប់ស្កាត់ការទន្ទ្រានកាន់កាប់ដីព្រៃ និង ដីតំបន់ការពារធម្មជាតិធ្វើជាកម្មសិទ្ធិ; ការលើកកម្ពស់ការអភិរក្សតំបន់ការពារ ធម្មជាតិ, ព្រៃឈើ និង សត្វព្រៃ; និង ការបង្ក្រាបបទល្មើសព្រៃឈើ, ការជួញដូរសត្វព្រៃ និង បទល្មើសធនធានធម្មជាតិ ។

ទី៣- ការលើកកម្ពស់ការគ្រប់គ្រងធនធានជលផល តាមរយៈ ការជំរុញ ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យជលផល; ការបង្កើនវារីវប្បកម្ម; ការពង្រឹងការគ្រប់គ្រង និង ការអភិវឌ្ឍសហគមន៍នេសាទ; ការជំរុញ ការអភិវឌ្ឍសមត្ថភាព និង បច្ចេកវិទ្យា ដើម្បីកែលម្អគុណភាពជលផល; ការអភិវឌ្ឍខ្សែច្រវាក់តម្លៃជលផល និង ការលើកកម្ពស់ការនាំចេញ; និង ការពង្រឹងការអនុវត្ត

ច្បាប់ស្តីពីជលផល ក្នុងការប្រយុទ្ធប្រឆាំងនឹងការនេសាទខុសច្បាប់ ។

ទី៤- ការលើកកម្ពស់ការគ្រប់គ្រងធនធានដីកសិកម្ម តាមរយៈ ការអនុវត្តកម្មវិធីសកម្មភាពជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះនៃគុណភាពដី, ទប់ស្កាត់ការរេចរឹលដី, និង បង្កើនផលិតភាពដី ។

ទី៥- ការជំរុញការប្រើប្រាស់ធនធានដី ប្រកបដោយចីរភាព តាមរយៈ ការពង្រឹងការអនុវត្តផែនការប្រើប្រាស់ដីថ្នាក់ជាតិ; ការបោះបង្គោលព្រំ និង ការកំណត់បែងចែកតំបន់គ្រប់គ្រង; ការចុះបញ្ជីដីតំបន់ការពារធម្មជាតិ; ក៏ដូចជាការរៀបចំផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិនីមួយៗ ស្របតាមផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ និង ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ។

ទី៦- ការជំរុញការថែរក្សាប្រព័ន្ធអេកូឡូស៊ី, ការការពារជីវចម្រុះ និង ការការពារតំបន់ធម្មជាតិ តាមរយៈ ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ; ការធ្វើទំនើបកម្ម និង ឌីជីថលូបនីយកម្មទិន្នន័យព័ត៌មាន និង ភូមិសាស្ត្រតំបន់ការពារធម្មជាតិ; ការលើកទឹកចិត្តឱ្យមានការទូទាត់សេវាកម្មប្រព័ន្ធអេកូឡូស៊ី ដើម្បីជានាន្ទវនិរន្តរភាពហិរញ្ញវត្ថុ ក្នុងការគ្រប់គ្រង និង អភិរក្សធនធានធម្មជាតិ; ការទប់ស្កាត់ និង ការបង្ក្រាបបទល្មើសធនធានធម្មជាតិ; ការប្រើប្រាស់ដំណោះស្រាយតាមបែបធម្មជាតិ; និង ការធ្វើបច្ចុប្បន្នកម្មគម្របព្រៃឈើ, តំបន់ដីសើម, តំបន់ដីមមោក, ព្រៃកោងកាង, ដីលិចទឹកធម្មជាតិ និង ប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ ផ្សេងទៀត ។

ទី៧- ការជំរុញការអភិវឌ្ឍជីវភាពសហគមន៍ ក្នុងតំបន់ការពារធម្មជាតិ ដោយផ្សារភ្ជាប់ទៅនឹងទេសចរណ៍ តាមរយៈ ការប្រែក្លាយតំបន់ការពារធម្មជាតិទៅជាតំបន់ទេសចរណ៍, ការពង្រឹងសមត្ថភាពសហគមន៍ព្រៃឈើ, សហគមន៍តំបន់ការពារធម្មជាតិ និង សហគមន៍នៅក្បែរតំបន់ការពារធម្មជាតិ, និង សមភាពនៃការបែងចែកប្រយោជន៍ ។

ទី៨- ការអនុវត្តអភិក្រមនៃការគ្រប់គ្រងធនធានវប្បធម៌ ដោយរក្សាតុល្យភាពរវាងការអភិវឌ្ឍ និង ការអភិរក្ស, ជាពិសេស ការអភិវឌ្ឍវប្បធម៌មានភាពច្នៃប្រឌិត ដែលមានរួមបញ្ចូលសមាសធាតុនៃវប្បធម៌បែបប្រពៃណី ដោយក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ត្រូវដាក់ចេញនូវគោលការណ៍ណែនាំស្តីពីការ-អភិរក្ស ។

ទី៩- ការបន្តពង្រឹងប្រសិទ្ធភាពនៃការអភិរក្សមរតកវប្បធម៌, ទាំងរូបី និង អរូបី, តាមរយៈ ការជួសជុល, ការថែរក្សានៅទីមានសុវត្ថិភាព, ការសម្អាត, ការចុះបញ្ជីសារពើភណ្ឌ, ការចុះបញ្ជីក្នុងប្រព័ន្ធទិន្នន័យ, និង ការរៀបចំសាលា-កបត្រកាន់កាប់ និង ប្លង់កម្មសិទ្ធិរដ្ឋ; ការរៀបចំស្នើចុះបេតិកភណ្ឌវប្បធម៌ និង ប្រវត្តិសាស្រ្តកម្ពុជា ព្រមទាំងបេតិកភណ្ឌធម្មជាតិ និង ភូគព្ភឧទ្យាន ទៅក្នុងបញ្ជីបេតិកភណ្ឌជាតិ និង បញ្ជីបេតិកភណ្ឌសកលលោក, បញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ, បញ្ជីស្មារតីចងចាំសកលលោក និង បញ្ជីបេតិកភណ្ឌផ្សេងៗទៀត របស់អង្គការយូណេស្កូ និង/ឬ ស្ថាប័នអន្តរជាតិផ្សេងទៀត; ការជំរុញយុទ្ធនាការផ្សព្វផ្សាយបេតិកភណ្ឌវប្បធម៌ទាំងនេះ នៅក្នុងតំបន់ និង សកល-លោក; និង ការបន្តយកចិត្តទុកដាក់ស្តារ និង ពង្រឹងមរតកវប្បធម៌អរូបី ដែលបានបាត់បង់ ឬ កំពុងប្រឈមនឹងការបាត់បង់ ។

ទី១០- ការរៀបចំ និង ការអនុវត្ត គោលនយោបាយអភិវឌ្ឍទេសចរណ៍ធម្មជាតិ និង វប្បធម៌កម្ពុជា សម្រាប់រយៈពេលមធ្យម និង វែង ក្រោមអភិក្រម **"អភិវឌ្ឍដើម្បីអភិរក្ស និង អភិរក្សដើម្បីអភិវឌ្ឍ"** ដើម្បីធ្វើបរមភាវូបនីយកម្ម នៃការទាក់ទាញភ្ញៀវទេសចរ និង រយៈពេលស្នាក់នៅ តាមរយៈទេសចរណ៍ផ្សារភ្ជាប់ទឹក ដី និង ធម្មជាតិ ។

### មុំទី៣. ការលើកស្ទួយកសិកម្ម និង ការអភិវឌ្ឍជនបទ

គោលដៅជាយុទ្ធសាស្រ្ត គឺការបន្តពង្រឹងតួនាទី និង ការអភិវឌ្ឍវិស័យកសិកម្មឱ្យទំនើប, សម្បូរបែប និង មានភាពធន់ ដែលគាំទ្រដល់ការអភិវឌ្ឍ

ជនបទ សំដៅធានាសន្តិសុខ និង សុវត្ថិភាពស្បៀង, បង្កើនតម្លៃបន្ថែមខ្ពស់, ជំរុញភាពប្រកួតប្រជែង, និង លើកកម្ពស់គុណភាពជីវភាពនៅជនបទ ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

ទី១- ការបន្តកសាងក្របខ័ណ្ឌគតិយុត្ត គោលនយោបាយ និង ពង្រឹងស្ថាប័ន ដើម្បីគាំទ្រ និង បង្កបរិយាកាសអំណោយផលសម្រាប់វិស័យកសិកម្ម ។

ទី២- ការជំរុញផលិតកម្មកសិកម្ម ដោយផ្តោតលើការបង្កើនផលិត-ភាព, គុណភាព, សុវត្ថិភាព, ពិពិធភាព, តម្លៃបន្ថែម និង ភាពធន់ តាមរយៈការស្រាវជ្រាវ និង ការអភិវឌ្ឍ ពូជដំណាំ ពូជសត្វ និង វារីវប្បកម្ម ដែលធន់នឹងអាកាសធាតុ និង ឆ្លើយតបនឹងតម្រូវការទីផ្សារ; ការគ្រប់គ្រង និង ការពង្រឹងគុណភាពដី; ការកំណត់តំបន់ដាំដុះ និង ការកសាងផែនទីដាំដុះ; ការបន្តជំរុញសេវាធានារ៉ាប់រងកសិផល; ការពង្រឹងសហគ្រិនភាពនៃសហគមន៍កសិកម្ម; ការ-ដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មនៅមូលដ្ឋាន; និង ការពង្រឹងបច្ចេកទេសកសិកម្មទំនើប, វៃឆ្លាត, ឌីជីថល និង មានសុវត្ថិភាព ។

ទី៣- ការពង្រឹងកិច្ចសហការក្នុងការធ្វើវិចារណកម្មការវិនិយោគលើប្រព័ន្ធធារាសាស្ត្រ ដើម្បីធានាសន្តិសុខទឹក សម្រាប់ វិស័យកសិកម្ម និង ការ-អភិវឌ្ឍជនបទ ។

ទី៤- ការកាត់បន្ថយថ្លៃដើមផលិតកម្ម តាមរយៈការពង្រឹងការយល់ដឹងអំពីការប្រើប្រាស់ធាតុចូល និង ការគ្រប់គ្រងគុណភាពធាតុចូល, ការបន្តផ្តល់ឥណទានការប្រាក់ទាប, និង ការលើកទឹកចិត្តផលិតកម្មធាតុចូលក្នុងស្រុក ។

ទី៥- ការធានាស្ថិរភាពថ្លៃផលិតផលកសិកម្ម តាមរយៈ ការបង្កើត និង ការពង្រឹងនូវយន្តការសម្របសម្រួលតាមដាន និង ត្រួតពិនិត្យ, និង ការ-បន្តពង្រីកវិសាលភាពកញ្ចប់ហិរញ្ញប្បទានពិសេស ដើម្បីរក្សាលំនឹងថ្លៃផលិត-ផលកសិកម្ម និង លើកកម្ពស់ខ្សែច្រវាក់តម្លៃ ក្នុងវិស័យកសិកម្មទាំងមូល ។

ទី៦- ការលើកកម្ពស់ការកែច្នៃផលិតផលកសិកម្ម តាមរយៈ ការធ្វើឱ្យ

ប្រសើរឡើង និង ការធ្វើទំនើបកម្មផ្នែកកសិ-ឧស្សាហកម្ម; ការជំរុញឱ្យមានការ-វិនិយោគលើកសិផលកែច្នៃ; ការសិក្សា និង ការបង្កើត "សួនកសិ-ឧស្សាហកម្មនៅកម្ពុជា" សម្រាប់ប្រមូលផ្តុំសហគ្រាសកែច្នៃ; ការជំរុញស្ថិរភាពនៃការផ្គត់ផ្គង់ផលិតផលកសិកម្ម; និង ការបន្តផ្តល់ហិរញ្ញប្បទានសម្បទានសម្រាប់វិនិយោគ ។

ទី៧- ការបន្តលើកកម្ពស់ការតភ្ជាប់ទីផ្សារក្នុងស្រុក និង ការជំរុញការនាំចេញ តាមរយៈ ការលើកកម្ពស់ការគាំទ្រផលិតផលក្នុងស្រុក ដោយការ-ប្រើប្រាស់ដោយផ្ទាល់ក្នុងចំណោមស្ថាប័នសាធារណៈ និង ប្រជាជនទូទៅ, ការ-ពង្រឹងយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា, ការបង្កើតទីផ្សារបោះដុំ និងចែកចាយផលិតផលកសិកម្មក្នុងស្រុក, ការពង្រឹងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ, និង ការទាញយកប្រយោជន៍ជាអតិបរមាពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ។

ទី៨- ការបន្តអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍជនបទ តាមរយៈ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង គមនាគមន៍ជនបទ; ការលើកកម្រិតគុណភាពហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ, ជាពិសេស ការកសាងផ្លូវជនបទតភ្ជាប់ទៅកសិ-ដ្ឋាន និង ផ្លូវជាតិ ឱ្យក្លាយទៅជាជនបទសមាហរណកម្ម; ការកែលម្អលក្ខខណ្ឌជីវភាពរបស់សហគមន៍ជនបទ; និង ការធ្វើពិពិធកម្មសេដ្ឋកិច្ចជនបទ និង ការ-អភិវឌ្ឍសហគមន៍ជនបទ, ជាពិសេស ការជំរុញការអភិវឌ្ឍចម្រុះ និង ការបន្តអនុវត្ត "**ចលនាភូមិមួយ ផលិតផលមួយ**" និង "**ចលនាភូមិគំរូ**" ។

### មុំទី៤. ការពង្រឹងការគ្រប់គ្រង និង ការធ្វើទំនើបកម្មនគរូបនីយកម្ម

គោលដៅជាយុទ្ធសាស្ត្រ គឺការពង្រីកទីក្រុង និង ការអភិវឌ្ឍទីក្រុងថ្មីៗបន្ថែម នៅតាមបណ្តារាជធានី-ខេត្ត; ការបង្កើតសួនសាធារណៈ និង ឧទ្យានបៃតង; និង ការពង្រឹងការគ្រប់គ្រង និង ការធ្វើទំនើបកម្មនគរូបនីយកម្ម ដើម្បីធានាសុវត្ថិភាព, សោភ័ណភាព, បរិស្ថានល្អ និង សុខុមាលភាព សម្រាប់ការ-រស់នៅ និង ប្រសិទ្ធភាពក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

ទី១- ការបន្តដំណើរការកែទម្រង់ដីធ្លី ដោយជំរុញការចុះបញ្ជី និង ការ-ដោះស្រាយវិវាទដីធ្លី នៅក្រៅប្រព័ន្ធតុលាការ; និង ការកសាងផែនការរៀបចំដែនដី និង នគរូបនីយកម្ម, ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, ក្នុងគោលដៅគ្រប់គ្រង និង អភិវឌ្ឍវិស័យដីធ្លី ឱ្យបានត្រឹមត្រូវ និង កាន់តែមានប្រសិទ្ធភាព ។

ទី២- ការពង្រឹងសមត្ថភាពអនុវត្តការងារនគរូបនីយកម្ម; ការងារកសាងផែនការរៀបចំដែនដី និង នគរូបនីយកម្ម ថ្នាក់ក្រុង-ស្រុក-ខណ្ឌ ឃុំ-សង្កាត់ នៅទូទាំងរាជធានី-ខេត្ត; ការរៀបចំយុទ្ធសាស្ត្រតម្រង់ទិស ក្នុងការ-កំណត់បែងចែកតំបន់ប្រើប្រាស់; និង ការគ្រប់គ្រងលំនៅឋានដោយប្រើប្រាស់បច្ចេកទេសឋានលេខា និង បច្ចេកវិទ្យាព័ត៌មាន ។

ទី៣- ការរៀបចំផែនការមេអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុង និង ទីប្រជុំ-ជនសំខាន់ៗ ប្រកបដោយភាពធន់ និង សោភ័ណភាព; ការជំរុញការប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈក្នុងទីក្រុង; ការគ្រប់គ្រង ទុកដាក់ និង កែច្នៃសំរាម; ការរៀបចំផ្លូវថ្មើរជើង, ទីធ្លាចំណត, ស្លាកសញ្ញា, កាមេរ៉ាសុវត្ថិភាព និង ភ្លើងសញ្ញាចរាចរណ៍; និង ការពង្រីកបណ្តាញអគ្គិសនី, ភ្លើងបំភ្លឺទីក្រុង, បណ្តាញ ទឹកស្អាត, ប្រព័ន្ធលូរំដោះទឹកភ្លៀង, ប្រព័ន្ធចម្រោះ និង ប្រព្រឹត្តកម្មទឹកកខ្វក់, និង ប្រព័ន្ធពន្លត់អគ្គិភ័យទីប្រជុំជន; ការអភិរក្សសំណង់ដែលមានតម្លៃប្រវត្តិសាស្ត្រ; ការស្នើឱ្យមានការគិតគូររៀបចំសួនសាធារណៈប្រចាំរាជធានី-ខេត្ត ឬ តំបន់ដែលមិនទាមទារឱ្យមានចំណាយប្រតិបត្តិការ ឬ ការថែទាំខ្ពស់ ដោយយកលក្ខណៈបែបធម្មជាតិ និង វប្បធម៌ជាគោល ។

ទី៤- ការជំរុញការវិនិយោគស្តារឡើងវិញនូវគម្រោងសាងសង់ ឬសំណង់អគារ ដែលទំនេរមិនដំណើរការ ក្នុងក្រុងព្រះសីហនុ; ការលើកទឹកចិត្តឱ្យប្រែក្លាយមកជាគម្រោងអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ; និង ការផ្តោតលើការអនុវត្តបន្ថែមលើការដាក់ចេញគោលនយោបាយ ដោយស្នើឱ្យមានការគិតគូរលើយន្តការលើកទឹកចិត្តដល់វិស័យឯកជន ឱ្យចូលរួមក្នុងកិច្ចការរៀបចំទីក្រុង,

ជាពិសេស ពាក់ព័ន្ធទៅនឹងការអភិវឌ្ឍទីក្រុងវៃឆ្លាត ឬ ទីក្រុងបៃតង ឬ ទីក្រុងដែលគួរឱ្យចង់រស់នៅ ។

ទី៥- ការសិក្សាលើវិសោធនកម្មក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធនឹងការរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ដែលត្រូវបានដាក់ចេញតាំងពីឆ្នាំ ១៩៩៤ ឱ្យមានការផ្សារភ្ជាប់នគរូបនីយកម្មទៅនឹងស្ថានភាពសង្គម, សេដ្ឋកិច្ច, វប្បធម៌ និង បរិស្ថាន; ការស្តារអាងស្តុកទឹក ឬ ប្រភពទឹក; ការរៀបចំច្បាប់ស្តីពីប្រព័ន្ធទឹកកខ្វក់ សំដៅកាត់បន្ថយការបំពុលទឹក; និង ការសិក្សាពាក់ព័ន្ធការបាក់ប្រាំងអាងទន្លេ សម្រាប់ការអភិវឌ្ឍ និង ការធ្វើទំនើបកម្មនគរូបនីយកម្ម ។

### មុំទី៥. ការធានាចីរភាពបរិស្ថាន និង ការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងការលើកកម្ពស់សេដ្ឋកិច្ចបៃតង

គោលដៅជាយុទ្ធសាស្ត្រ គឺការកាត់បន្ថយការបំពុល និង ផលប៉ះពាល់បរិស្ថានជាអតិបរមា; ការពង្រឹងការគ្រប់គ្រងទឹក និង ការពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ; និង ការចូលរួមចំណែកក្នុងការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុសកល ដើម្បីធានាការអភិវឌ្ឍប្រកបដោយចីរភាព ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

ទី១- ការលើកកម្ពស់ការអភិវឌ្ឍបៃតង និង សេដ្ឋកិច្ចចក្រា តាមរយៈការអនុវត្ត គោលនយោបាយថាមពលស្អាត និង ប្រសិទ្ធភាពថាមពល ដោយបន្តលើកទឹកចិត្ត និង បង្កើនការវិនិយោគលើថាមពលស្អាតដែលមានតម្លៃសមរម្យ, គោលនយោបាយកសិកម្មវៃឆ្លាត និង បៃតង, គោលនយោបាយនវានុវត្តក្នុងដំណើរការឧស្សាហកម្ម និង ការប្រើប្រាស់ផលិតផល, គោលនយោបាយទីក្រុងវៃឆ្លាត និង ការដឹកជញ្ជូនបៃតង, និង គោលនយោបាយគ្រប់គ្រងសំណល់រឹង រាវ ឧស្ម័ន និង សំណល់គ្រោះថ្នាក់; និង ការពង្រឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ចំពោះគម្រោងអភិវឌ្ឍ, ទាំងនៅក្នុងស្រុក និង ឆ្លងដែន, ប្រកបដោយ

ប្រសិទ្ធភាព ។

ទី២- ការបន្តជំរុញ និង កសាងហេដ្ឋារចនាសម្ព័ន្ធទឹក រួមទាំងប្រព័ន្ធប្រព្រឹត្តកម្ម ដើម្បីធានានូវសន្តិសុខទឹក និង ចីរភាពបរិស្ថាន, និង ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ។

ទី៣- ការបន្តបង្កើនការប្រើប្រាស់បច្ចេកវិទ្យា ភាគរបរិស្ថាន និង ភាគរ-អាកាសធាតុ ដូចជា បច្ចេកវិទ្យា, ដំណោះស្រាយតាមបែបធម្មជាតិ, និង ការ-ប្រើប្រាស់ម៉ូដែល និង បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត ទៅក្នុងការគ្រប់គ្រង សុវត្ថិ-ភាព ទឹក និង បរិស្ថាន ជាដើម ។

ទី៤- ការបន្តពង្រឹងក្របខ័ណ្ឌគតិយុត្ត និង គោលនយោបាយពាក់ព័ន្ធបរិស្ថាន ទឹក និង គ្រោះមហន្តរាយធម្មជាតិ ក៏ដូចជា ការងារការទូតបៃតង ដើម្បីធានានិរន្តរភាពប្រព័ន្ធអេកូឡូស៊ី និង ការរួមចំណែកក្នុងការកាត់បន្ថយការប្រែ-ប្រួលអាកាសធាតុ ។

ទី៥- ការបន្តអភិវឌ្ឍ សមត្ថភាពជំនាញ និង ចំណេះដឹងបច្ចេកទេស ព្រមទាំងការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ លើផ្នែកបរិស្ថាន, ការអភិវឌ្ឍបៃតង, សន្តិសុខទឹក, ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់, ការបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ, និង ការប្រើប្រាស់ធនធានធម្មជាតិ ប្រកបដោយចីរភាព; និង ការចងក្រងផលិតឯកសារឧបទេស សម្រាប់ការអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋទូទៅ ដើម្បីជំរុញ និង លើកទឹកចិត្តការចូលរួមអនុវត្ត សាលារៀន និង អារាម ភាគរបរិស្ថាន និង គោលនយោបាយភូមិ-ឃុំ-សង្កាត់ មានសុវត្ថិ-ភាព ប្រកបដោយ អនាម័យ, សោភ័ណភាព និង បរិស្ថានល្អ ។

### បញ្ហាកោណទី៥. ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល

រាជរដ្ឋាភិបាល បានចាត់ទុកបច្ចេកវិទ្យាឌីជីថលជាកាតាលីករថ្មីដ៏មានសារៈសំខាន់ ដែលមានសក្តានុពលភាព និង កាលានុវត្តភាព ក្នុងការជំរុញកំណើនផលិតភាពសេដ្ឋកិច្ច និង សង្គម ក៏ដូចជាប្រសិទ្ធភាពនៃការងាររដ្ឋបាល ។

ក្នុងទិសដៅនេះ, រាជរដ្ឋាភិបាលបានដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយ សេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ និង គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលផ្តោតលើអាទិភាពចំនួន ៥ : (១). ការកសាងរដ្ឋាភិបាលឌីជីថល និង ពលរដ្ឋឌីជីថល; (២). ការអភិវឌ្ឍ សេដ្ឋកិច្ចឌីជីថល, ធុរកិច្ចឌីជីថល, ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និង ប្រព័ន្ធនវានុវត្តឌីជីថល; (៣). ការកសាង និង ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល; (៤). ការកសាងភាពជឿទុកចិត្តលើប្រព័ន្ធ ឌីជីថល; និង (៥). ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ។

### មុំទី១. ការកសាងរដ្ឋាភិបាលឌីជីថល និង ពលរដ្ឋឌីជីថល

គោលដៅជាយុទ្ធសាស្ត្រ គឺការដឹកនាំការធ្វើបរិវត្តកម្មឌីជីថល ដោយរាជរដ្ឋាភិបាលធ្វើជាគំរូ និង ដឹកមុខក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថល តាមរយៈការធ្វើឌីជីថលភាវូបនីយកម្មកិច្ចការសាធារណៈរបស់រដ្ឋ ដើម្បីពង្រឹងប្រសិទ្ធភាពការងារ និង ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ជូនប្រជាជន និង វិស័យឯកជន, និង ការពង្រឹងអភិបាលកិច្ចផ្អែកលើទិន្នន័យ ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

ទី១- ការពង្រឹងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរដ្ឋាភិបាលឌីជីថល ដែលមានស្រាប់ ឱ្យអស់លទ្ធភាព និង ការបន្តពង្រីកហេដ្ឋារចនាសម្ព័ន្ធរដ្ឋាភិបាលឌីជីថល ដែលមានលក្ខណៈចាំបាច់ និង ជាអាទិភាព ។

ទី២- ការបន្តកសាង និង អភិវឌ្ឍប្រព័ន្ធទិន្នន័យគោល ក្នុងរដ្ឋបាលសាធារណៈ ប្រកបដោយគុណភាព និង មានស្តង់ដាបច្ចេកទេសខ្ពស់ ។

ទី៣- ការបន្តពង្រីកការធ្វើឌីជីថលភាវូបនីយកម្មសេវាសាធារណៈ, ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ។

ទី៤- ការអភិវឌ្ឍស្តង់ដាបច្ចេកទេសរួមនៃការផ្តល់សេវាសាធារណៈឌីជីថល, ក្របខ័ណ្ឌអន្តរប្រតិបត្តិការ, ស្តង់ដាសន្តិសុខ និង ស្តង់ដាបច្ចេកទេស-

រួមពាក់ព័ន្ធផ្សេងៗ សម្រាប់ក្រសួង-ស្ថាប័ន ។

ទី៥- ការបន្តកសាង និង អភិវឌ្ឍថ្នាលឌីជីថលគ្រឹះរួម ដែលដើរតួនាទីជាឃ្នាស់ ក្នុងការជំរុញការកសាងប្រព័ន្ធរដ្ឋាភិបាលឌីជីថលជាអង្គតែមួយ ។

ទី៦- ការបន្តពង្រឹងសមត្ថភាពមន្ត្រីលើជំនាញឌីជីថល តាមរយៈ ការ-បណ្តុះបណ្តាលជាប្រចាំ និង ការលើកកម្ពស់ភាពជាអ្នកដឹកនាំឌីជីថល ដល់ថ្នាក់ដឹកនាំ និង មន្ត្រីរាជការ, និង ការពិនិត្យលទ្ធភាពបង្កើតអង្គភាពបរិវត្តកម្មឌីជីថល តាមអង្គភាពការងារនៃក្រសួង-ស្ថាប័ន ។

ទី៧- ការកសាងមូលធនមនុស្សដែលមានជំនាញឌីជីថល តាមរយៈការធ្វើទំនើបកម្ម និង ការធ្វើសុវឌ្ឍិកម្ម កម្មវិធីសិក្សា និង កម្មវិធីបណ្តុះបណ្តាលជំនាញឌីជីថល, និង ការកៀរគរ និង ការទាក់ទាញ ធនធានមនុស្ស ដែលមានទេពកោសល្យឌីជីថលពីបរទេស ។

ទី៨- ការបន្តលើកកម្ពស់អក្ខរកម្មឌីជីថល ក្នុងចំណោមប្រជាពលរដ្ឋទូទៅ ដោយរួមបញ្ចូលទាំងការបញ្ចូលជំនាញឌីជីថលជាមូលដ្ឋានក្នុងកម្មវិធីសិក្សា, និង ការរៀបចំកម្មវិធីបណ្តុះបណ្តាលជំនាញឌីជីថល តាមវិស័យ ។

### មុំទី២. ការអភិវឌ្ឍ សេដ្ឋកិច្ចឌីជីថល, ធុរកិច្ចឌីជីថល, ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និង ប្រព័ន្ធនវានុវត្តឌីជីថល

គោលដៅជាយុទ្ធសាស្ត្រ គឺការជំរុញការធ្វើបរិវត្តកម្មឌីជីថលក្នុងវិស័យសេដ្ឋកិច្ច; ការបង្កើតធុរកិច្ចថ្មីឌីជីថល (Digital Startups); ការជំរុញការធ្វើបរិវត្ត-កម្មឌីជីថលសហគ្រាស; ការជំរុញការអភិវឌ្ឍខ្សែច្រវាក់ឌីជីថល និង ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក; និង ការជំរុញការកសាង និង ការអភិវឌ្ឍប្រព័ន្ធនវា-នុវត្តឌីជីថល ដើម្បីសម្រួលធុរកិច្ច និង ពាណិជ្ជកម្ម សំដៅជំរុញសម្ទុះកំណើនសេដ្ឋកិច្ច ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

ទី១- ការបន្តកសាង និង អភិវឌ្ឍប្រព័ន្ធទិន្នន័យគោល ដែលជាអាទិ-

ភាពក្នុងវិស័យសេដ្ឋកិច្ច និង ធុរកិច្ច ប្រកបដោយគុណភាព និង មានស្តង់ដាបច្ចេកទេសខ្ពស់, និង ការបន្តពង្រីកការធ្វើឌីជីថលភាវូបនីយកម្មសេវាសាធារណៈសម្រាប់គាំទ្រដល់វិស័យសេដ្ឋកិច្ច និង ធុរកិច្ច ។

ទី២- ការបន្តកសាង និង អភិវឌ្ឍផ្ទាលឌីជីថលគ្រឹះរួម និង ផ្ទាលនវានុវត្តឌីជីថល ។

ទី៣- ការលើកកម្ពស់ប្រព័ន្ធអេកូឡូស៊ី ធុរកិច្ចថ្មី, ធុរកិច្ចឌីជីថល និង ពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិកឱ្យកាន់តែរស់រវើក និង បំពេញឱ្យគ្នាតាមរយៈ ការតភ្ជាប់ និង ការពង្រីកទីផ្សារ, ការពង្រីកការវិនិយោគ, ការផ្តល់ហិរញ្ញប្បទាន, និង កម្មវិធីគាំទ្រសំខាន់ដទៃទៀត ។

ទី៤- ការរៀបចំ និង ការដាក់ឱ្យអនុវត្តកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាស ។

ទី៥- ការបង្កើនភាពជឿទុកចិត្ត, ការពង្រឹងអនុលោមភាព និង ការបន្តដោះស្រាយបញ្ហាប្រឈមជាយុទ្ធសាស្ត្រ នៃខ្សែច្រវាក់ក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ។

ទី៦- ការលើកកម្ពស់សហគ្រិនភាព និង ការនវានុវត្ត ដើម្បីបង្កើនសកម្មភាពនៃការធ្វើធុរកិច្ច, ការចាប់ដៃគូ និង ការជំរុញការតភ្ជាប់ក្នុងខ្សែច្រវាក់តម្លៃផលិតកម្ម ។

ទី៧- ការពង្រឹងសមត្ថភាពនវានុវត្តឌីជីថល តាមរយៈ ការអភិវឌ្ឍធនធានមនុស្ស និង បុគ្គលមានទេពកោសល្យ ក្នុងជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា និង ការនវានុវត្ត, ក៏ដូចជា ការអភិវឌ្ឍសមត្ថភាពនៃការស្រាវជ្រាវ, ការអភិវឌ្ឍ និង ការនវានុវត្ត នៅតាមគ្រឹះស្ថានសិក្សា និង បណ្តុះបណ្តាល ។

ទី៨- ការរៀបចំច្បាប់ស្តីពីសេដ្ឋកិច្ចឌីជីថល និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ, និង ការដាក់សេដ្ឋកិច្ចឌីជីថលទៅក្នុងអនុវិស័យនៃប្រព័ន្ធគណនីជាតិ ។

## មុំទី៣. ការកសាង និង ការអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធឌីជីថល

គោលដៅជាយុទ្ធសាស្ត្រ គឺការកសាង និង ការពង្រីកហេដ្ឋារចនាសម្ព័ន្ធឌីជីថល រួមមាន ការតភ្ជាប់ឌីជីថល និង ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ និង ក្លោដ ឬ មជ្ឈមណ្ឌលទិន្នន័យ សំដៅពង្រឹង គុណភាព និង ប្រសិទ្ធភាព នៃ បណ្ដាញតភ្ជាប់ឌីជីថល, ការចែករំលែកព័ត៌មាន និង ការផ្ដល់សេវាទូរគមនាគមន៍ ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្ដោតអាទិភាពលើ ៖

ទី១- ការជំរុញឱ្យក្រុមហ៊ុនផ្ដល់សេវាអ៊ីនធឺណិត និង ទូរគមនាគមន៍ ពង្រឹងគុណភាពនៃសេវាឱ្យបានល្អ និង គ្របដណ្ដប់គ្រប់ទីកន្លែង តាមរយៈ ការវិនិយោគបន្ថែម ដើម្បីពង្រឹងហេដ្ឋារចនាសម្ព័ន្ធរបស់ខ្លួន, ពិសេសនៅតំបន់ដែលមានសក្ដានុពល ។

ទី២- ការបន្ត កសាង និង អភិវឌ្ឍ បណ្ដាញ និង ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ផ្នែកបណ្ដាញឆ្អឹងខ្នង និង បណ្ដាញចែកចាយ; និង ការជំរុញការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធឌីជីថល នៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ។

ទី៣- ការជំរុញការវិនិយោគ និង ការប្រើប្រាស់មូលនិធិកាតព្វកិច្ចសេវាសកល ប្រកបដោយប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាព ដើម្បីកសាង និង ពង្រីកហេដ្ឋារចនាសម្ព័ន្ធ បណ្ដាញទូរគមនាគមន៍ និង ហេដ្ឋារចនាសម្ព័ន្ធគាំទ្រវិស័យទូរគមនាគមន៍ សម្រាប់អ៊ីនធឺណិតលឿន ដើម្បីជួយកាត់បន្ថយគម្លាតឌីជីថល ។

ទី៤- ការពិនិត្យលទ្ធភាព បង្កើនសមត្ថភាពប្រតិបត្តិការ ខ្សែកាបអុបទិកក្រោមបាតសមុទ្រ និង ខ្សែកាបអុបទិកឆ្លងព្រំដែនគោកដែលមានស្រាប់, និង ការពង្រីកការសាងសង់ ខ្សែកាបអុបទិកក្រោមបាតសមុទ្រថ្មី និង ខ្សែកាបអុបទិកឆ្លងព្រំដែនគោកបន្ថែម តាមការចាំបាច់ ។

ទី៥- ការបន្តធ្វើបច្ចុប្បន្នកម្មច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត ពាក់-

ព័ន្ធនឹងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ និង ការគ្រប់គ្រងធនធានវិសាលគមន៍វិទ្យុ ។

ទី៦- ការបន្តជំរុញការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍រួមអនុលោមតាមច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត ជាធរមាន ។

ទី៧- ការរៀបចំក្របខ័ណ្ឌគតិយុត្ត សម្រាប់ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធក្លោដ, តាមវិស័យ និង តាមប្រភេទទិន្នន័យ ។

ទី៨- ការជំរុញការប្រើប្រាស់មជ្ឈមណ្ឌលទិន្នន័យជាតិ សម្រាប់បម្រើដល់ប្រព័ន្ធឌីជីថល របស់ក្រសួង-ស្ថាប័ន ដែលមិនមានមជ្ឈមណ្ឌលទិន្នន័យ, និង ការជំរុញប្រតិបត្តិករឯកជន ឱ្យវិនិយោគលើការកសាងមជ្ឈមណ្ឌលទិន្នន័យ ដោយផ្ដោតលើស្តង់ដា និង សុវត្ថិភាពខ្ពស់ របស់ទិន្នន័យ ។

## មុំទី៤. ការកសាងភាពជឿទុកចិត្តលើប្រព័ន្ធឌីជីថល

គោលដៅជាយុទ្ធសាស្ត្រ គឺការកសាងភាពជឿទុកចិត្តលើប្រព័ន្ធឌីជីថល តាមរយៈ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និង យន្តការស្ថាប័នសន្តិសុខឌីជីថល, និង ការលើកកម្ពស់ការយល់ដឹងអំពីសន្តិសុខឌីជីថល ដើម្បីជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ឱ្យបានទូលំទូលាយ ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្ដោតអាទិភាពលើ ៖

ទី១- ការបន្តកសាង និង ពន្លឿន ការរៀបចំ និង ការអនុម័តសេចក្ដីព្រាងច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

ទី២- ការបង្កើតគណៈកម្មាធិការសន្តិសុខឌីជីថល និង មជ្ឈមណ្ឌលសន្តិសុខឌីជីថលជាតិ, និង ការបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និង ប្រព័ន្ធសន្តិសុខឌីជីថល ។

ទី៣- ការរៀបចំវិធានអនុវត្ត ឬ វិធានប្រតិបត្តិ, ស្តង់ដា, ក្របខ័ណ្ឌបច្ចេកទេស, គោលការណ៍ណែនាំ, ក្រមប្រតិបត្តិ និង នីតិវិធីនៃការឆ្លើយតប ដើម្បីជាមូលដ្ឋាន សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និង ប្រព័ន្ធសន្តិសុខ

ឌីជីថល ។

ទី៤- ការរៀបចំក្របខ័ណ្ឌវាយតម្លៃឡើងវិញនូវចន្លោះប្រហោង និង ការពង្រឹងប្រព័ន្ធសន្តិសុខឌីជីថលសម្រាប់ហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ។

ទី៥- ការបណ្តុះបណ្តាល និង ការបង្កើនការអភិវឌ្ឍ ជំនាញសន្តិសុខឌីជីថល, និង ការលើកកម្ពស់ការយល់ដឹងអំពីបញ្ហាសន្តិសុខឌីជីថល ដើម្បីបញ្ជ្រាបការយល់ដឹងជាសាធារណៈ អំពីបញ្ហាសន្តិសុខឌីជីថល និង កិច្ចការពារខ្លួន និង ការប្រឆាំងបទល្មើសបច្ចេកវិទ្យាព័ត៌មាន ។

ទី៦- ការបង្កើតយន្តការនៃកិច្ចសហការ និង កិច្ចសហប្រតិបត្តិការជាមួយនឹងស្ថាប័នពាក់ព័ន្ធ, ទាំងរដ្ឋ វិស័យឯកជន និង ប្រជាជន, ដើម្បីចូលរួមរាយការណ៍, ទប់ស្កាត់, បំពាក់សុវត្ថិភាពក្នុងប្រព័ន្ធឌីជីថល និង ឈានឆ្ពោះទៅដល់ការបង្ក្រាបទាន់ពេល នូវបទល្មើសបច្ចេកវិទ្យាព័ត៌មាន ។

ទី៧- ការបង្កើតក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ, ទាំងក្នុងតំបន់ និង ជាសកល, ក្នុងការចែករំលែកព័ត៌មាន និង ការគ្រប់គ្រងហានិភ័យពាក់ព័ន្ធនឹងសន្តិសុខឌីជីថល ក្នុងបរិការណ៍តំបន់ និង សកល ។

### មុំទី៥. ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ

គោលដៅជាយុទ្ធសាស្ត្រ គឺការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ដោយចាប់យកកាលានុវត្តភាព និង ទាញយកអត្ថប្រយោជន៍ជាអតិបរមាពីបច្ចេកវិទ្យាឌីជីថល ដើម្បីលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ, រក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ, និង ជំរុញការនវានុវត្តហិរញ្ញវត្ថុ តាមរយៈ ការអនុវត្ត "គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨" ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

ទី១- ការរៀបចំ ការធ្វើវិសោធនកម្ម និង ការពង្រឹងប្រសិទ្ធភាព នៃការអនុវត្តច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីកសាងប្រព័ន្ធអេកូឡូស៊ីគតិយុត្ត សម្រាប់ការធ្វើនិយ័តកម្ម, ការធ្វើសុខដុម-

នីយកម្មមុខងារ, និង ការលើកកម្ពស់ភាពជឿទុកចិត្តពីអ្នកប្រើប្រាស់ ។

ទី២- ការសិក្សា និង ការរៀបចំក្របខ័ណ្ឌនៃការគ្រប់គ្រងហិរញ្ញវត្ថុបើកចំហ សម្រាប់ការចែករំលែក និង ការបើកចំហទិន្នន័យ ដើម្បីផ្តល់កាលានុវត្តភាពថ្មីៗដល់ការអភិវឌ្ឍ និង ការនវានុវត្ត បច្ចេកវិទ្យាហិរញ្ញវត្ថុ សម្រាប់សហគ្រាស និង ធុរកិច្ចថ្មី ដែលធ្វើអាជីវកម្មក្នុងវិស័យពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុ ។

ទី៣- ការបន្តកសាង, ការធ្វើទំនើបកម្ម, និង ការជំរុញ ការចាប់យក និង ការប្រើប្រាស់ថ្នាលឌីជីថលគ្រឹះ ក្នុងបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីជំរុញនវានុវត្តហិរញ្ញវត្ថុ ។

ទី៤- ការជំរុញការធ្វើទំនើបកម្ម និង ការធ្វើសុវុឌ្ឍិកម្ម ប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល ប្រកបដោយបរិយាបន្ន ឈរលើគោលការណ៍អន្តរប្រតិបត្តិការជាប្រព័ន្ធអេកូឡូស៊ី សំដៅជានាអធិបតេយ្យក្នុងប្រព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុជាតិ ។

ទី៥- ការអភិវឌ្ឍបច្ចេកវិទ្យានិយ័តកម្ម និង បច្ចេកវិទ្យាត្រួតពិនិត្យ ដើម្បីជួយសម្រួល និង ពង្រឹងប្រសិទ្ធភាពនៃអនុលោមភាពនិយ័តកម្ម, ព្រមទាំងបង្កើនសមត្ថភាពវិភាគ តាមដាន និង គាំទ្រដល់ដំណើរការនៃការត្រួតពិនិត្យហានិភ័យ ប្រកបដោយបុរេសកម្ម និង ប្រសិទ្ធភាព ។

ទី៦- ការបង្កើនការបណ្តុះបណ្តាលចំណេះដឹង និង ជំនាញ, ការផ្សព្វផ្សាយ, ការធ្វើកិច្ចសហការ, និង ការពង្រីក ការស្រាវជ្រាវ, ការអភិវឌ្ឍ, ការនវានុវត្ត, និង ការប្រើប្រាស់បច្ចេកវិទ្យាចុងក្រោយថ្មីៗ ក្នុងបច្ចេកវិទ្យាហិរញ្ញវត្ថុ ។

ទី៧- ការលើកកម្ពស់ការកសាងប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុឱ្យកាន់តែមានលក្ខណៈសម្បូរបែប និង ការពង្រឹងយន្តការដឹកនាំសម្របសម្រួលឱ្យមានភាពប្រទាក់ក្រឡា និង បំពេញឱ្យគ្នា រវាងបច្ចេកវិទ្យាហិរញ្ញវត្ថុវិស័យធនាគារ និង បច្ចេកវិទ្យាហិរញ្ញវត្ថុវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ។

## ២.៥. កម្មវិធីគោលនយោបាយអាទិភាព ចំនួន ៦ សម្រាប់ចាប់ផ្តើមអនុវត្តភ្លាម ក្នុងឆ្នាំ ២០២៣

បន្ថែមលើយុទ្ធសាស្ត្រអាទិភាពដែលបានដាក់ចេញតាមផ្នែកនីមួយៗនៃបញ្ចកោណ ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលដាក់ចេញកម្មវិធីគោលនយោបាយអាទិភាព ចំនួន ៦ ដែលត្រូវចាប់ផ្តើមអនុវត្តភ្លាមនៅក្នុងឆ្នាំ ២០២៣ ដូចខាងក្រោមៈ

**កម្មវិធីទី១** : **ការផ្តល់ការថែទាំសុខភាពឆ្ពោះទៅកម្មវិធីគ្របដណ្តប់សុខភាពជាសកល** ដោយចាប់ផ្តើមពី (១). ការផ្តល់សេវាថែទាំសុខភាពជូនគ្រួសារងាយរងហានិភ័យប្រមាណជាង ៤៥ ម៉ឺនគ្រួសារ, ស្មើនឹងសមាជិកសរុបជាង ១,៥ លាននាក់ តាមរយៈ ការប្រើប្រាស់មូលនិធិសមធម៌សុខាភិបាល; និង (២). ការពង្រីករបបថែទាំសុខភាពរបស់ ប.ស.ស, ទាំងសម្រាប់កម្មករ-និយោជិត និង សម្រាប់មន្ត្រីសាធារណៈ ដែលគ្របដណ្តប់បន្ថែមដល់សមាជិកគ្រួសារ និង អ្នកនៅក្នុងបន្ទុក ប្រមាណជាង ៣ លាននាក់ តាមគោលការណ៍ស្ម័គ្រចិត្ត ។ ជាសរុប, គម្រោងទាំងពីរនេះ នឹងធ្វើឱ្យប្រជាជនប្រមាណ ៧,៤ លាននាក់ មានលទ្ធភាពទទួលបាននូវរបបសន្តិសុខសង្គមផ្នែកសេវាថែទាំសុខភាព ។

**កម្មវិធីទី២** : **ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និង បច្ចេកទេសជូនដល់យុវជនមកពីគ្រួសារក្រីក្រ និង គ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេស** ដែលមានចំនួនប្រមាណជាង ១,៥ លាននាក់ នៅតាមបណ្តាគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈនានារបស់រដ្ឋ ក្នុងកម្រិតសញ្ញាបត្របច្ចេកទេស និង វិជ្ជា-ជីវៈកម្រិត ១ ដោយមិនបង់ថ្លៃសិក្សា និង ទទួលបាននូវប្រាក់ឧបត្ថម្ភប្រចាំខែ ។

**កម្មវិធីទី៣** : **ការធ្វើស្ថាបនូបនីយកម្មកម្មវិធីជាតិជំនួយសង្គមសម្រាប់គ្រួសារក្រីក្រ, ក្រុមជនងាយរងគ្រោះ នៅក្នុងគ្រួសារក្រីក្រ និង គ្រួសារងាយរងហានិភ័យ នៅក្នុងគ្រាមានវិបត្តិសេដ្ឋកិច្ច និង គ្រាមានគ្រោះអាសន្ន** ដើម្បីជួយទ្រទ្រង់ និង ផ្តល់ការគាំពារទាន់ពេល និង ក្នុងលក្ខណៈជាប្រព័ន្ធជូន

ប្រជាពលរដ្ឋ, ជាពិសេស គ្រួសារក្រីក្រ និង ងាយរងគ្រោះ និង គ្រួសារងាយរងហានិភ័យ, ទៅតាមស្ថានភាពជាក់ស្តែងនៃវិបត្តិ ឬ គ្រោះអាសន្ន នៅតាមគ្រប់ទីតាំងភូមិសាស្ត្រទូទាំងប្រទេស ដែលនឹងគ្របដណ្តប់លើប្រជាជនសរុបប្រមាណ ៤,៣ លាននាក់ ។

**កម្មវិធីទី៤** : **ការដាក់ចេញ និង ការជំរុញអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឱ្យមានលទ្ធភាពចូលរួមក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និង អាចទទួលបានផលប្រយោជន៍ពីប្រព័ន្ធគាំពារសង្គមផ្លូវការ** តាមរយៈ (១). ការផ្តល់នូវការគាំពារ និង ការបង្កើតនូវបរិយាកាសអំណោយផល សម្រាប់ធ្វើធុរកិច្ច និង ពាណិជ្ជកម្ម ព្រមជាមួយនឹងការផ្តល់នូវការបណ្តុះបណ្តាលជំនាញបច្ចេកទេស និង វិជ្ជាជីវៈដល់ក្រុមហ៊ុន, សហគ្រាសធុនមីក្រូ តូច និង មធ្យម; និង (២). ការផ្តល់ការគាំពារសង្គម ដល់បុគ្គលស្វ័យនិយោជន៍ ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដោយផ្តោតការយកចិត្តទុកដាក់ជាបឋម លើការផ្តល់សេវាថែទាំសុខភាពនៅក្រោមមូលនិធិសមធម៌សុខាភិបាល។

**កម្មវិធីទី៥** : **ការដាក់ចេញនូវយន្តការសម្របសម្រួល និង កម្មវិធីហិរញ្ញប្បទាន សំដៅលើកស្ទួយផលិតកម្ម, រកទីផ្សារ និង រក្សាលំនឹងថ្លៃកសិផលសំខាន់ៗ ក្នុងកម្រិតសមរម្យ** តាមរយៈការដាក់ចេញកញ្ចប់ថវិកាជាក់លាក់ ដោយចាប់ផ្តើមពីចំនួន ១០០ លានដុល្លារអាមេរិក និង អាចវិភាជថវិកាបន្ថែម, ប្រសិនបើមានតម្រូវការចាំបាច់, ដើម្បីធ្វើអន្តរាគមន៍ឱ្យបានទាន់ពេល ក្នុងការទិញកសិផលពីប្រជាកសិករ ជាមួយនឹងគោលដៅរក្សាស្ថិរភាពថ្លៃនៅរាល់រដូវប្រមូលផល, ជាពិសេស លើផលិតផលកសិកម្មមួយចំនួន ជាអាទិ៍ ស្រូវ ស្វាយកែវរមៀត មៀនប៉ៃលិន ស្វាយចន្ទី ដំឡូង ពោត និង ផលិតផលផ្សេងទៀត តាមការចាំបាច់ ។

**កម្មវិធីទី៦** : ការដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មទៅគ្រប់ឃុំ-សង្កាត់ ដែលមានសកម្មភាពកសិកម្ម នៅទូទាំងប្រទេស ដើម្បីជំរុញការ-

លើកកម្ពស់ផលិតភាពកសិកម្ម និង ជួយដល់គ្រួសារកសិករ ក្នុងការលើកស្ទួយផលិតផលកសិកម្មរបស់ខ្លួន ។ រាជរដ្ឋាភិបាល នីតិកាលទី ៧ នឹងយកចិត្តទុកដាក់ផងដែរ ទៅលើ **ការរៀបចំឱ្យមានសមាគមកសិករនៅតាមទីជនបទ** ដើម្បីរក្សាកម្លាំងរបស់កសិករក្នុងការផលិត ក៏ដូចជាការតថ្លៃជាមួយអ្នកទទួលទិញ ។

# ផ្នែកទី ៣

ក្នុងការអនុវត្ត **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១**, រាជរដ្ឋាភិបាលយកចិត្តទុកដាក់ខ្ពស់ និង ប្តេជ្ញាបន្តប្រឹងប្រែង, ដោយជំនឿទុកចិត្ត និង ភាពម្ចាស់ការ, ក្នុងស្មារតីអនុវត្តតួនាទីរបស់ខ្លួន ដោយបុរេសកម្ម សកម្ម និង អន្តរសកម្ម បំផុត, ដើម្បីអនុវត្តវិធានការគោលនយោបាយ, ក្នុងតួនាទីជាយុទ្ធសាស្ត្រវិទូ និង មគ្គទ្ទេសក៍, តាមអភិក្រម "**ជវភាពនៃប្រព័ន្ធតួអង្គតែមួយ**" ជាមួយនឹងសហថាមពល, សមត្ថភាព, កិច្ចសម្របសម្រួលខ្ពស់, ការទទួលខុសត្រូវ និង ការចូលរួមពីគ្រប់តួអង្គពាក់ព័ន្ធ ។ ក្នុងស្មារតីនេះ, រាជរដ្ឋាភិបាលដាក់ចេញនូវយន្តការជំរុញការអនុវត្ត; យន្តការដឹកនាំសម្របសម្រួល; និង យន្តការតាមដាន, ត្រួតពិនិត្យ និង វាយតម្លៃ ដូចខាងក្រោម៖

## ៣.១. យន្តការជំរុញការអនុវត្ត

យន្តការជំរុញការអនុវត្តផ្តោតលើសមត្ថភាព ដែលមានភាពប្រទាក់ក្រឡាគ្នា និង បំពេញគ្នា ក្នុងការប្រើប្រាស់រចនាសម្ព័ន្ធ, ការកៀរគរធនធាន, ការផ្សព្វផ្សាយ និង ការលើកកម្ពស់ការយល់ដឹង, ការរៀបចំផែនការសកម្មភាព និង សូចនាករសមិទ្ធកម្ម, និង ការរៀបចំផែនការថវិកា ស្របតាមលទ្ធភាពថវិកាជាតិ និង ដែលមានលក្ខណៈផ្សារភ្ជាប់នឹងវិធានការគោលនយោបាយនៃយុទ្ធសាស្ត្រនេះ ។

ក្រសួង-ស្ថាប័ន គឺជាតួអង្គសំខាន់ និង ស្នូល ក្នុងការអនុវត្តយុទ្ធសាស្ត្រនេះផ្ទាល់ ។ ក្រសួង-ស្ថាប័ន ត្រូវរៀបចំរចនាសម្ព័ន្ធ, បែងចែកធនធាន និង ចាត់តាំងក្រុមមន្ត្រី, ព្រមទាំងសម្របសម្រួលការពង្រឹងសមត្ថភាពស្ថាប័ន និង មន្ត្រីទទួលបន្ទុកការអនុវត្តយុទ្ធសាស្ត្រ ។ ជាមួយនេះ, ក្រសួង-ស្ថាប័នទាំងអស់, នៅក្រោមការសម្របសម្រួលរបស់ស្ថាប័ន ដែលរាជរដ្ឋាភិបាលប្រគល់ភារកិច្ចជាសេនាធិការ សម្រាប់ដឹកនាំសម្របសម្រួលរួម លើការជំរុញការអនុវត្ត, ការតាមដាន, ការត្រួតពិនិត្យ និង ការវាយតម្លៃ យុទ្ធសាស្ត្រនេះ, ត្រូវសហការរៀបចំ និង

អនុវត្តកម្មវិធីផ្សព្វផ្សាយ **យុទ្ធសាស្ត្របញ្ចកោណ** ឱ្យបានទូលំទូលាយ និង ជាប្រចាំ ដល់ស្ថាប័ន និង អង្គភាពរដ្ឋ, ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ; ដៃគូអភិវឌ្ឍន៍; វិស័យឯកជន; និង សាធារណជន; ដើម្បីលើកកម្ពស់ការយល់ដឹង និង ទាក់ទាញការចូលរួមអនុវត្ត ពីគ្រប់កម្លាំងចលករ ។

ទន្ទឹមនេះ, ក្រសួងផែនការត្រូវដឹកនាំសម្របសម្រួលកម្រិតបច្ចេកទេស ក្នុងការរៀបចំផែនការសកម្មភាព និង សូចនាករសមិទ្ធកម្ម គន្លឹះរបស់ក្រសួង-ស្ថាប័ន ព្រមទាំងផ្តួចផ្តើម និង តម្រឹមក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ឆ្នាំ ២០២៤-២០២៨ និង ផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍតាមវិស័យ, ដោយមានការចូលរួម ពីស្ថាប័នគោលនយោបាយ, ស្ថាប័នថវិកា និង ស្ថាប័នជំនាញ ដើម្បីធ្វើឱ្យមានសង្គតិភាព និង ប្រសិទ្ធភាព និង ជានាសហ-ថាមភាពនៃសកម្មភាព ដែលមានលក្ខណៈអន្តរវិស័យ និង ប្រទាក់ក្រឡាគ្នា ។ មួយវិញទៀត, ការរៀបចំគោលនយោបាយ, កម្មវិធី និង គម្រោង របស់ក្រសួង-ស្ថាប័ន ត្រូវឆ្លើយតបដាច់ខាតទៅនឹងវិធានការ គោលនយោបាយនៃយុទ្ធសាស្ត្រ និង បំពេញគ្នាជាមួយផែនការសកម្មភាព ។ បន្ថែមលើនេះ, ក្រសួង-ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកា និង ផែនការថវិកាប្រចាំឆ្នាំ ស្របតាមលទ្ធភាពនៃថវិកាជាតិ និង ដែលផ្សារភ្ជាប់ នឹងវិធានការគោលនយោបាយនៃយុទ្ធសាស្ត្រ, ផែនការសកម្មភាព, កម្មវិធី និង គម្រោង ដោយប្រមូលផ្តុំ និង ប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព, គណនេយ្យភាព និង តម្លាភាព, ពិសេស សម្រាប់ជំរុញការអនុវត្ត វិធានការ ឬ កម្មវិធីគោលនយោបាយអាទិភាព ដែលជាគន្លឹះ ឬ ជាកាតាលីករ ផ្តល់មេគុណខ្ពស់នៃប្រសិទ្ធផលក្នុងកិច្ចអភិវឌ្ឍ ។

### ៣.២. យន្តការដឹកនាំសម្របសម្រួល

ការអនុវត្តយុទ្ធសាស្ត្រប្រកបដោយជោគជ័យ ទាមទារនូវការដឹកនាំដ៏ប៉ិនប្រសប់ និង រស់រវើករបស់រាជរដ្ឋាភិបាល ដែលសកម្មក្នុងការប្រមើល និង បុរេសកម្ម ក្នុងការចាត់វិធានការឆ្លើយតប និង បត់បែនទាន់ពេល តាមការប្រែ-

ប្រួលនៃបរិការណ៍ ព្រមជាមួយនឹងការទទួលខុសត្រូវរួមគ្នាជាអង្គតែមួយនៃរាជរដ្ឋាភិបាលផង និង ការទទួលខុសត្រូវតាមសមត្ថកិច្ចរៀងខ្លួន របស់ក្រសួង-ស្ថាប័ននីមួយៗផង ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលដឹកនាំការអនុវត្តយុទ្ធសាស្ត្រជារួម ដោយផ្ដោតលើការតម្រង់ទិស, ការកែសម្រួលវិធានការគោលនយោបាយនានា និង ការដាក់ចេញនូវវិធានការគោលនយោបាយថ្មីៗតាមការចាំបាច់ ដើម្បីសម្រេចគោលដៅយុទ្ធសាស្ត្រ ។ រាជរដ្ឋាភិបាលចាត់ឱ្យមានស្ថាប័នមួយជាសេនាធិការសម្រាប់ដឹកនាំសម្របសម្រួលរួម លើការរៀបចំផែនការសកម្មភាព និង ការបូកសរុបវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រ, ការតាមដាន, ការត្រួតពិនិត្យ និង ការវាយតម្លៃ ។ ជាមួយនេះ, រាជរដ្ឋាភិបាលកំណត់ឱ្យគណៈកម្មាធិការ អន្តរក្រសួង ឬ ក្រុមប្រឹក្សា ដែលមានសមត្ថកិច្ចពាក់ព័ន្ធ ទទួលបន្ទុកសម្របសម្រួលលើការជំរុញការអនុវត្តការងារអាទិភាព ដែលមានចរិតអន្តរក្រសួង-ស្ថាប័ន ឬ អន្តរវិស័យ, ក្នុងនេះ ការយកចិត្តទុកដាក់ជាពិសេស នឹងត្រូវបានផ្ដោតលើអាទិភាព ដែលមានភាពយឺតយ៉ាវ ឬ មានវឌ្ឍនភាពតិចតួច និង មានទម្រង់ជាអន្តរវិស័យ ឬ អន្តរក្រសួង តាមរយៈ ការលើកកម្ពស់កិច្ចសហការ និង កិច្ចសហប្រតិបត្តិការ ព្រមទាំងការសម្របសម្រួលដោះស្រាយបញ្ហាជាន់ភារកិច្ចគ្នា ដើម្បីធានាឱ្យការអនុវត្ត អាចប្រព្រឹត្តទៅរួមគ្នា, ប្រទាក់ក្រឡាគ្នា និង បំពេញគ្នា ប្រកបដោយប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាព ។

ទន្ទឹមនេះ, ក្រសួង-ស្ថាប័នត្រូវបុរេសកម្ម, សកម្ម និង មានកិច្ចសហការជិតស្និទ្ធជាមួយគ្រប់ភាគីពាក់ព័ន្ធ ក្នុងការរៀបចំផែនការ, ការអនុវត្ត, ការបូកសរុបវឌ្ឍនភាព និង ការវាយតម្លៃ ព្រមទាំងប្រកាន់ខ្ជាប់អភិក្រម "**ឆ្លុះកញ្ចក់, ងូតទឹក, ដុសក្អែល, ព្យាលបាល, និង វះកាត់**" ។ ការណ៍នេះ តម្រូវឱ្យក្រសួង-ស្ថាប័ន ពង្រឹងជាប្រចាំ នូវសមត្ថភាពរបស់មន្ត្រីទទួលបន្ទុកអនុវត្ត, ជាពិសេស តាមរយៈ ការបណ្ដុះបណ្ដាល និង ការតម្រង់ទិស ។ ក្រៅពីនេះ, ការទទួលយកយោបល់, ធាតុចូល និង សំណូមពរផ្សេងៗ ពីអង្គភាពរដ្ឋ, ដៃគូអភិវឌ្ឍន៍, វិស័យ

ឯកជន និង សាធារណជន គឺជាយន្តការបន្ថែមសម្រាប់ ការឆ្លុះបញ្ចាំងពីសកម្មភាពការងារ, ការដោះស្រាយសំណូមពរ និង ការជំរុញការអនុវត្តយុទ្ធសាស្ត្រ ។

## ៣.៣. យន្តការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃ

ការតាមដាន, ការត្រួតពិនិត្យ និង ការវាយតម្លៃ គឺជាឧបករណ៍សម្រាប់តម្រង់ទិស និង កែសម្រួលវិធានការគោលនយោបាយផង និង សម្រាប់តម្រង់ទិស និង កែសម្រួលការអនុវត្តផងដែរ ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលដាក់ចេញនូវយន្តការ តាមដាន ត្រួតពិនិត្យ និង វាយតម្លៃ ដែលផ្អែកលើភស្តុតាង (Evidence-based M&E Framework) ដើម្បីធានាបាននូវប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាពខ្ពស់ ក្នុងការអនុវត្ត **យុទ្ធសាស្ត្របញ្ចកោណ** របស់ខ្លួន ។ ឈរលើគោលការណ៍ណែនាំទូទៅ និង ជាមូលដ្ឋានគោល ដែលនឹងត្រូវបានដាក់ចេញ, ក្រសួង-ស្ថាប័នទាំងអស់ ត្រូវរៀបចំ និង អនុវត្តកម្មវិធី ឬ គោលការណ៍ សម្រាប់ការតាមដាន, ការត្រួតពិនិត្យ និង ការវាយតម្លៃ ផ្ទៃក្នុងរបស់ខ្លួន ដោយជំរុញសកម្មភាពពិភាក្សា ឆ្លុះរក និង ដោះស្រាយបញ្ហាប្រឈម, ដាក់ចេញវិធានការកែតម្រូវ, វាស់វែងពីកិច្ចប្រឹងប្រែង និង វាយតម្លៃប្រសិទ្ធភាពនៃការអនុវត្ត, ក៏ដូចជារៀបចំ និង ចងក្រង សូចនាករ សមិទ្ធកម្មគន្លឹះ ភ្ជាប់ជាមួយនឹងការកំណត់ក្របខ័ណ្ឌពេលដាក់លាក់ ព្រមទាំងគោលដៅ និង វិធីសាស្ត្រវាស់វែងសូចនាករសមិទ្ធកម្មគន្លឹះទាំងឡាយនោះ ផងដែរ ។

នៅក្រោមក្របខ័ណ្ឌនៃយន្តការ តាមដាន ត្រួតពិនិត្យ និង វាយតម្លៃនេះ, ក្រសួង-ស្ថាប័នត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីវឌ្ឍនភាព ក្នុងការ-អនុវត្តយុទ្ធសាស្ត្រ តាមសមត្ថកិច្ចទទួលខុសត្រូវរៀងខ្លួន ។ បន្ទាប់ពីនេះ, ស្ថាប័នទទួលបន្ទុកដឹកនាំសម្របសម្រួលរួម លើការតាមដាន, ការត្រួតពិនិត្យ និង ការ-វាយតម្លៃ ត្រូវបូកសរុបរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងមូលប្រចាំឆ្នាំ ដាក់ជូនកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី និង ធ្វើការផ្សព្វផ្សាយជាសា-

ធារណៈ បន្ទាប់ពីមានការសម្រេចពីរាជរដ្ឋាភិបាល ។ បន្ថែមលើនេះ, រាជរដ្ឋាភិបាលនឹងធ្វើការវាយតម្លៃពាក់កណ្ដាលអាណត្តិ និង ចុងអាណត្តិ អំពីគោលដៅ ឬ កម្មវិបាកលើការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ក្នុងកម្រិតយុទ្ធសាស្ត្រ ដែលជាការវាយតម្លៃគ្រប់ជ្រុងជ្រោយ និង ផ្អែកលើសមិទ្ធកម្មការងារ ដែលសម្រេចបានធៀបទៅនឹង **បាវចនា ៥, គោលដៅ យុទ្ធសាស្ត្រ ៥** និង **អាទិភាពគន្លឹះ ៥** របស់ **យុទ្ធសាស្ត្របញ្ចកោណ** ។ លទ្ធផលនៃការវាយតម្លៃនេះ នឹងត្រូវបានយកទៅប្រើប្រាស់ជាធាតុចូលដ៏សំខាន់ សម្រាប់ការរៀបចំ និង ការដាក់ចេញ **យុទ្ធសាស្ត្របញ្ចកោណ ក្នុងដំណាក់កាលបន្តបន្ទាប់**, ពិសេស សម្រាប់ការតម្រង់ទិស និង ការដាក់ចេញនូវវិធានការចាំបាច់ ដើម្បីដោះស្រាយបញ្ហាប្រឈម និង ជំរុញការអនុវត្ត ឱ្យកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ និង គ្រប់ជ្រុងជ្រោយ ។

# សន្និដ្ឋាន

ក្នុងរយៈពេល ២៥ ឆ្នាំចុងក្រោយ បន្ទាប់ពីការសម្រេចបាននូវ សុខសន្តិភាពពេញលេញ, ឯកភាពជាតិ និង ឯកភាពទឹកដី ទាំងស្រុង តាមរយៈ **នយោបាយឈ្នះ-ឈ្នះ** របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**, រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តប្រកបដោយជោគជ័យនូវ **យុទ្ធសាស្ត្រត្រីកោណ** និង **យុទ្ធសាស្ត្រចតុកោណ ទាំង ៤ ដំណាក់កាល**, ដោយសម្រេចបាននូវសមិទ្ធផលធំៗ លើគ្រប់វិស័យ, ទាំងនយោបាយ, សង្គម, និង សេដ្ឋកិច្ច, ដែលនាំឱ្យកម្ពុជាសម្រេចបាននូវការផ្លាស់ប្តូរមុខមាត់ថ្មី គួរជាទីមោទនៈបំផុត ។ ជាក់ស្តែង, កម្ពុជា, ដែលធ្លាប់ស្ថិតក្នុងសោកនាដកម្មនៃសង្គ្រាម និង ការរួមរឹតដោយភាពក្រីក្រ, បានក្លាយមកជាប្រទេសដែលមានសន្តិភាពពេញលេញ និង រឹងមាំ, ប្រជាជនរាប់លាននាក់ ត្រូវបានរំដោះឱ្យចាកផុតពីភាពក្រីក្រ និង បានក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាប ។ បច្ចុប្បន្ន, កម្ពុជាកំពុងស្ថិតនៅលើមាគ៌ានៃការអភិវឌ្ឍប្រកបដោយ ក្តីសង្ឃឹម, ក្លៀវក្លា, រឹងប៉ឹង, និង កាន់តែជឿជាក់ ។ សម្រាប់រយៈពេល ២៥ ឆ្នាំទៅមុខ ដែលជាវដ្តថ្មីនៃការអភិវឌ្ឍ, កម្ពុជាមានមហិច្ឆតាចង់លើកស្ទួយមោទនភាពជាតិ ឱ្យឈានកាន់តែខ្ពស់ឡើង ដូចសម័យអង្គរ តាមរយៈ ការកសាងជាតិមួយឱ្យរឹងមាំ, រស់រវើក, រុងរឿង និង មានវិបុលភាព ឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ក្លាយជាប្រទេសមានចំណូលខ្ពស់នៅត្រឹមឆ្នាំ ២០៥០ ។

ក្នុងន័យនេះ, ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលដាក់ចេញ **"យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១"** ដើម្បីជំរុញកំណើនសេដ្ឋកិច្ច, បង្កើតការងារ, ជានាសមធម៌, បង្កើនប្រសិទ្ធភាព និង រក្សាចីរភាព ។ ជារួម, **យុទ្ធសាស្ត្របញ្ចកោណ** គឺជាយុទ្ធសាស្ត្រសម្លឹងទៅមុខ សម្រាប់រយៈពេល ២៥ ឆ្នាំ ដែលត្រូវបានគិតគូរដាក់ចេញ និង អនុវត្ត ជា ៥ ដំណាក់កាល បន្តបន្ទាប់ និង ត្រូវបានតម្រង់ និង សម្របសម្រួលទៅតាម **កម្មវិធីនយោបាយរបស់រាជរដ្ឋា-**

**ភិបាល** នៃនីតិកាលនីមួយៗ របស់រដ្ឋសភា ។ បានន័យថា ដំណាក់កាលនីមួយៗ នឹងត្រូវបានកែសម្រួល ដោយផ្អែកលើបរិការណ៍ជាក់ស្តែង នៅក្នុងប្រទេស, តំបន់ និង ពិភពលោក ព្រមទាំងបទពិសោធនៃការអនុវត្តពីដំណាក់កាលមុនៗ ដោយសម្លឹងឆ្ពោះទៅសម្រេចឱ្យបាននូវគោលដៅនៃការកសាងជាតិ ស្របតាម **ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០** ។

**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ ដើម្បី កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និង ចីរភាព** មានបេសកកម្មជាប្រវត្តិសាស្ត្រចម្បងពីរ ។ ***ទីមួយ***, រក្សា និង ថែបំប៉ន សុខសន្តិភាព ដែលសម្រេចបានមកដោយលំបាកជាមួយនឹងការលះបង់មិនអាចកាត់ថ្លៃបាន, និង ពូនជ្រំចលនាការណ៍នៃកំណើនសេដ្ឋកិច្ច និង ការអភិវឌ្ឍ ជារួម; និង ***ទីពីរ,*** កសាង និង ពង្រឹងមូលដ្ឋានគ្រឹះសម្រាប់ជំរុញសន្ទុះនៃការអភិវឌ្ឍប្រទេសជាតិ, ដោយឆ្លងកាត់បង្គោលចរនៃការប្រែក្លាយខ្លួនជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០, ឆ្ពោះទៅសម្រេចបាន **ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០** តាមរយៈការកសាងភាពធន់រឹងមាំនៃវិស័យទាំង ៥ រួមមាន : វិស័យសាធារណៈ, វិស័យសេដ្ឋកិច្ច, វិស័យហិរញ្ញវត្ថុ, វិស័យមូលធនមនុស្ស និង សង្គម, និង វិស័យបរិស្ថាន និង ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ។

**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ត្រូវបានដាក់ឱ្យអនុវត្តស្របតាមអភិក្រម "**ជវភាពនៃប្រព័ន្ធតួអង្គតែមួយ**" ដែលក្រសួង-ស្ថាប័នទាំងអស់ នៅក្រោមរចនាសម្ព័ន្ធរាជរដ្ឋាភិបាល, ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, ធ្វើការនៅក្នុងកិច្ចសហការ និង ការសម្របសម្រួលរស់រវើក ប្រកបដោយសហថាមពល និង ដោយបំពេញឱ្យគ្នាទៅវិញទៅមក ព្រមទាំងដោយបត់បែនតាមការប្រែប្រួលនៃបរិការណ៍ជាក់ស្តែង ដើម្បីសម្រេចបានគោលដៅអាទិភាពដែលត្រូវបានដាក់ចេញ ។ ក្នុងន័យនេះ, **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ឆ្លុះបញ្ចាំងយ៉ាងច្បាស់ នូវ **របៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ចកម្ពុជា**

សម្រាប់អនុវត្ត **កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា** ក្នុងរយៈពេល ៥ ឆ្នាំ ដែលផ្តោតលើ **គោលដៅយុទ្ធសាស្ត្រ ចំនួន ៥** រួមមាន ៖

(១). ធានាឱ្យបានកំណើនសេដ្ឋកិច្ច ក្នុងអត្រាមធ្យមប្រចាំឆ្នាំ ក្នុងរង្វង់ ៧% ប្រកបដោយភាពធន់នឹងវិបត្តិនានា;

(២). បង្កើតការងារឱ្យបានកាន់តែច្រើន, ទាំងបរិមាណ និង គុណ-ភាព, ជូនដល់ប្រជាជនកម្ពុជា, ជាពិសេស សម្រាប់យុវជន;

(៣). សម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ ក្នុងអត្រាទាបជាង ១០% និង បន្តខិតខំទាញទម្លាក់អត្រានៃភាពក្រីក្រ ឱ្យស្ថិតនៅក្នុងកម្រិតជាអប្បបរមា;

(៤). បន្តពង្រឹងសមត្ថភាពអភិបាលកិច្ច និង លើកកម្ពស់គុណភាពស្ថាប័ន, ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពនៃសេវាសាធារណៈ ក៏ដូចជា បន្តពង្រឹងអភិបាលកិច្ចវិស័យឯកជន និង បន្តកិច្ច-ប្រឹងប្រែងលើកកម្ពស់បរិយាកាសអំណោយផល សម្រាប់ធុរកិច្ច, ការវិនិយោគ និង ពាណិជ្ជកម្ម; និង

(៥). ធានាចីរភាពនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និង កសាងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ។

ជាមួយនឹង **បាវចនា ៥** គឺ : **កំណើន, ការងារ, សមធម៌, ប្រសិទ្ធភាព និង ចីរភាព** និង **គោលដៅយុទ្ធសាស្ត្រ ៥** ដូចបានគូសរំលេចខាងលើ, រាជរដ្ឋា-ភិបាលសម្រេចកំណត់យកនូវ **អាទិភាពគន្លឹះ ចំនួន ៥** សម្រាប់ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** គឺ : **មនុស្ស, ផ្លូវ, ទឹក, ភ្លើង និង បច្ចេកវិទ្យា** ដែលត្រូវបានឆ្លុះបញ្ចាំងជាចម្បង តាមរយៈ **បញ្ចកោណយុទ្ធសាស្ត្រ ចំនួន ៥** នៅក្នុងរចនាសម្ព័ន្ធនៃយុទ្ធសាស្ត្រទាំងមូល ដែលមានរួមបញ្ចូលផងដែរ នូវ **ស្នូលនៃយុទ្ធសាស្ត្រ** និង **បរិស្ថានគ្របដណ្តប់** សម្រាប់ធានាបរិយាកាសអំណោយ-ផលដល់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល ។ រួមជាមួយគ្នា, **ស្នូលនៃយុទ្ធសាស្ត្រ**

និង **បរិស្ថានគ្របដណ្តប់** ព្រមទាំង **បញ្ចកោណយុទ្ធសាស្ត្រ** ទាំង ៥ ប្រៀបបាន ទៅនឹងអនុគមន៍ផលិតកម្ម ដែលការអនុវត្តវិធានការប្រទាក់ក្រឡាគ្នា នឹងនាំទៅ ដល់ការបង្កើនផលិតភាពសរុបនៃសេដ្ឋកិច្ច, ការបង្កើនផលិតភាពនៃកម្លាំងពល-កម្ម និង ការបង្កើនការ វិនិយោគ ក៏ដូចជាប្រសិទ្ធភាពនៃការវិនិយោគលើមូល-ធនសេដ្ឋកិច្ច ។ ផលិតភាពសរុប នឹងត្រូវបានបង្កើនតាមរយៈសម្ព័ន្ធនៃវិធានការ ដែលត្រូវបានរៀបចំឡើង, ម៉្យាង, នៅក្នុងស្នូលនៃយុទ្ធសាស្ត្រ ដោយផ្តោតលើ ការកែទម្រង់អភិបាលកិច្ច និង ការពង្រឹងសមត្ថភាពស្ថាប័ន; និងម៉្យាងទៀត, នៅក្នុងបរិស្ថានគ្របដណ្តប់ ដោយផ្តោតលើការបង្កើតបរិយាកាសអំណោយ-ផល សម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។ ចំណែកផលិតភាព ផ្នែកពលកម្ម និង ផ្នែកមូលធន នឹងត្រូវបានបង្កើនតាមរយៈ **បញ្ចកោណយុទ្ធសាស្ត្រ** ចំនួន ៥ រួមមាន (១). ការអភិវឌ្ឍមូលធនមនុស្ស; (២). ការធ្វើពិពិធកម្មសេដ្ឋកិច្ច និង ការបង្កើនភាពប្រកួតប្រជែង; (៣). ការអភិវឌ្ឍវិស័យឯកជន និង ការងារ; (៤). ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និង បរិយាបន្ន; និង (៥). ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល ។

ក្នុងក្របខណ្ឌរួមនេះ, **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ដាក់ចេញទិសដៅការងារអាទិភាពសំខាន់ៗ រួមមានជាអាទិ៍ : ការពង្រឹងអភិ-បាលកិច្ច, ប្រសិទ្ធភាព និង សមត្ថភាព ស្ថាប័ន; ការទ្រទ្រង់កំណើន និង ការធ្វើ ទំនើបកម្មសេដ្ឋកិច្ច; ការបង្កើតការងារ, ទាំងគុណភាព និង បរិមាណ; ការលើក ស្ទួយវិស័យឯកជន និង សហគ្រិនភាព; ការកសាងមូលធនមនុស្ស ដោយផ្តោត ជាពិសេស លើគុណភាពវិស័យអប់រំ, សេវាសុខាភិបាល និង សីលធម៌សង្គម; ការលើកស្ទួយសេវាគាំពារសង្គម និង សុខុមាលភាពប្រជាជន, ជាពិសេស សម្រាប់គ្រួសារងាយរងហានិភ័យ និង ក្រុមជនងាយរងគ្រោះ; ការពង្រឹង គុណភាពនគរូបនីយកម្ម, ជាពិសេស ការកាត់បន្ថយគម្លាតរវាងទីក្រុង និង ជនបទ; ការពង្រឹងចីរភាពបរិស្ថាន និង ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាស-

ធាតុ; ព្រមទាំងការជំរុញធ្វើបរិវត្តកម្មឌីជីថល, ទាំងក្នុងសង្គម និង សេដ្ឋកិច្ច ។

ជាមួយនេះ, **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ក៏ផ្តល់អាទិភាពខ្ពស់ និង បន្ទាន់ លើការជំរុញអនុវត្តកម្មវិធីគោលនយោបាយអាទិភាព ទាំង ៦ នៃ កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា ដោយចាប់អនុវត្ត ក្នុងដំណាច់ឆ្នាំ ២០២៣ នេះតែម្តង រួមមាន ៖

(១). ការពង្រីកសេវាថែទាំសុខភាពឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកល;

(២). ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និង បច្ចេកទេស ជូនដល់យុវជនមកពីគ្រួសារក្រីក្រ និង គ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេស;

(៣). ការធ្វើស្ថាបនូបនីយកម្មកម្មវិធីជាតិជំនួយសង្គម សម្រាប់គ្រួសារក្រីក្រ, ក្រុមជនងាយរងគ្រោះនៅក្នុងគ្រួសារក្រីក្រ និង គ្រួសារងាយរងហានិភ័យ នៅក្នុងគ្រាមានវិបត្តិសេដ្ឋកិច្ច និង គ្រាមានគ្រោះអាសន្ន;

(៤). ការដាក់ចេញ និង ការជំរុញ អនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឱ្យមានលទ្ធភាពចូលរួមក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និង អាចទទួលបានផលប្រយោជន៍ពីប្រព័ន្ធគាំពារសង្គមផ្លូវការ;

(៥). ការដាក់ចេញនូវយន្តការសម្របសម្រួល និង កម្មវិធីហិរញ្ញប្បទាន សំដៅលើកស្ទួយផលិតកម្ម, រកទីផ្សារ និង រក្សាលំនឹងថ្លៃកសិផលសំខាន់ៗ ក្នុងកម្រិតសមរម្យ; និង

(៦). ការដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មទៅគ្រប់ឃុំ-សង្កាត់ដែលមានសកម្មភាពកសិកម្ម នៅទូទាំងប្រទេស និង ការរៀបចំឱ្យមានសមាគមកសិករនៅតាមទីជនបទ ។

បន្ថែមលើនេះ, រាជរដ្ឋាភិបាល ក៏សម្រេចដាក់ចេញផងដែរ នូវយន្តការជំរុញការអនុវត្ត, យន្តការស្ថាប័នដឹកនាំសម្របសម្រួល, និង យន្តការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃ ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពខ្ពស់ ក្នុងការ-

អនុវត្ត **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ។

យន្តការជំរុញការអនុវត្ត ផ្តោតលើសមត្ថភាព ដែលមានភាពប្រទាក់-ក្រឡាគ្នា និង បំពេញគ្នា ក្នុងការប្រើប្រាស់រចនាសម្ព័ន្ធ, ការកៀរគរធនធាន, ការផ្សព្វផ្សាយ និង ការលើកកម្ពស់ការយល់ដឹង, ការរៀបចំផែនការ សកម្មភាព និង សូចនាករសមិទ្ធកម្ម, និង ការរៀបចំផែនកាថវិកា ស្របតាមលទ្ធភាពនៃថវិកាជាតិ និង ដែលមានលក្ខណៈផ្សារភ្ជាប់នឹងគោលនយោបាយនៃយុទ្ធសាស្ត្រនេះ ។ យន្តការស្ថាប័ន ផ្តោតលើតួនាទី និង សមត្ថភាពរបស់ក្រសួង-ស្ថាប័នទទួលបន្ទុកអនុវត្តយុទ្ធសាស្ត្រ ក្រោមការដឹកនាំសម្របសម្រួលរួមរបស់ស្ថាប័នមួយនៃរាជរដ្ឋាភិបាល លើការរៀបចំផែនការសកម្មភាព, ការបូកសរុបវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រ, ការតម្រង់ទិស, ការកែសម្រួលវិធានការនានា និង ការដាក់ចេញនូវវិធានការថ្មីៗ ក៏ដូចជា លើការតាមដាន, ការត្រួតពិនិត្យ និង ការវាយតម្លៃផងដែរ ។ ជាមួយគ្នានេះ, រាជរដ្ឋាភិបាលកំណត់ឱ្យគណៈកម្មា-ធិការអន្តរក្រសួង ឬ ក្រុមប្រឹក្សា ដែលមានសមត្ថកិច្ចពាក់ព័ន្ធទទួលបន្ទុកសម្របសម្រួលលើការជំរុញការអនុវត្តការងារអាទិភាព ដែលមានចរិតអន្តរ-ក្រសួង-ស្ថាប័ន ឬ អន្តរវិស័យ, ក្នុងនេះ ការយកចិត្តទុកដាក់ជាពិសេស នឹងត្រូវបានផ្តោតលើអាទិភាព ដែលមានភាពយឺតយ៉ាវ ឬ មានវឌ្ឍនភាពតិចតួច និង មានទម្រង់ជាអន្តរវិស័យ ឬ អន្តរក្រសួង តាមរយៈ ការលើកកម្ពស់កិច្ចសហការ និង កិច្ចសហប្រតិបត្តិការ ព្រមទាំងការសម្របសម្រួលដោះស្រាយបញ្ហាជាន់ភារកិច្ចគ្នា ដើម្បីជានាឱ្យការអនុវត្ត អាចប្រព្រឹត្តទៅរួមគ្នា, ប្រទាក់ក្រឡាគ្នា និង បំពេញគ្នា ប្រកបដោយប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាព ។

សរុបជារួម, កម្ពុជាពិតជាមានមោទនភាពខ្ពស់បំផុត ជាមួយនឹងការសម្រេចបាននូវ សុខសន្តិភាពដ៏ពេញលេញ និង រឹងមាំ ក្នុងរយៈពេល ២៥ ឆ្នាំកន្លងមក; ហើយនៅក្រោមម្លប់ដ៏ត្រជាក់នៃសុខសន្តិភាពនេះ, កម្ពុជាសម្រេចបាននូវសមិទ្ធផលធំៗ មិនអាចកាត់ថ្លៃបាន និង បានឆ្លងកាត់បរិវត្តកម្មសំខាន់ៗ

ជាប្រវត្តិសាស្ត្រ ដែលបានកែលម្អជីវភាពរបស់ប្រជាជន និង លើកស្ទួយកិត្យានុភាពជាតិ ឱ្យខ្ពស់ត្រដែត លើឆាកតំបន់ និង សកល តាមរយៈ ការដាក់ចេញ និង ការដឹកនាំអនុវត្ត ដោយជោគជ័យនូវ **យុទ្ធសាស្ត្រត្រីកោណ** និង **យុទ្ធសាស្ត្រចតុកោណ ទាំង ៤ ដំណាក់កាល** ។ លើមូលដ្ឋាននៃសមិទ្ធផលដ៏ធំធេងទាំងអស់នេះ ជាមួយនឹងការសម្លឹងទៅមុខ សម្រាប់រយៈពេល ២៥ ឆ្នាំទៀត, រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ដើម្បី **កំណើន, ការងារ, សមធម៌, ប្រសិទ្ធភាព និង ចីរភាព** ជា **របៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច** នៃ **កម្មវិធីនយោបាយ** របស់ខ្លួន សម្រាប់នីតិកាលទី ៧ នៃរដ្ឋសភា សំដៅបន្តជំរុញការរីកចម្រើនជាប់មិនដាច់របស់កម្ពុជា ។

ផ្អែកលើបទពិសោធក្នុងការបំពេញបេសកកម្មដ៏ឧត្តុង្គឧត្តម ក្នុងការសង្គ្រោះ ការការពារ ការកសាង និង ការអភិវឌ្ឍ ប្រទេសជាតិ នាពេលកន្លងមក រួមជាមួយនឹងការប្តេជ្ញាចិត្ត និង ឆន្ទៈដ៏មោះមុតឥតរាថយ និង កិច្ចប្រឹងប្រែងយ៉ាងប្តូរផ្តាច់ ដោយប្រកាន់ខ្ជាប់នូវ ការប្តេជ្ញាថែរក្សា ការពារ និង ពូនជ្រំបន្ថែមទៀត នូវសមិទ្ធផលជាតិ និង ការតម្កល់ប្រយោជន៍ ជាតិ និង ប្រជាជន ជាធំ ព្រមទាំងដោយមានការគាំទ្រ ពី គ្រប់ដៃគូអភិវឌ្ឍន៍ និង តួអង្គពាក់ព័ន្ធ ក៏ដូចជាការចូលរួមយ៉ាងសកម្មពីសំណាក់ប្រជាជនគ្រប់ស្រទាប់ជាន់ថ្នាក់, រាជរដ្ឋាភិបាលមានជំនឿយ៉ាងមុតមាំថា នឹងជម្នះបាននូវបញ្ហាប្រឈម, ឧបសគ្គ និង វិបត្តិទាំងឡាយ ក្នុងការដឹកនាំសង្គមជាតិកម្ពុជា លើវិថីនៃការអភិវឌ្ឍ, វឌ្ឍនភាព, និង វិបុលភាព កាន់តែថ្កើងថ្កានឡើងបន្ថែមទៀត ហើយកសាងបាននូវមូលដ្ឋានគ្រឹះប្រកបដោយភាពធន់ដ៏រឹងមាំ សម្រាប់ការឈានឡើងប្រកបដោយការទុកចិត្ត ឆ្ពោះទៅសម្រេចបាន **ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០** ។

គំនូរបំព្រួញស្តីពី «យុទ្ធសាស្ត្របញ្ចកោណ - ដំណាក់កាលទី ១»
ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និង ចីរភាព : កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០



# សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

## មហាវិទ្យាល័យអប់រំផ្តល់ការបណ្តុះបណ្តាលពីកម្រិតវិញ្ញាបនបត្រ ដល់បណ្ឌិតដូចខាងក្រោម៖

- វិញ្ញាបនបត្រអប់រំកុមារតូច
- វិញ្ញាបនបត្រអប់រំបឋមសិក្សា

- បរិញ្ញាបត្រអប់រំ ឯកទេសសិក្សាអប់រំ
- បរិញ្ញាបត្រអប់រំ ឯកទេសគ្រប់គ្រង និងអភិវឌ្ឍឧត្តមសិក្សា
- បរិញ្ញាបត្រអប់រំ ឯកទេសអប់រំពេញមួយជីវិត
- បរិញ្ញាបត្រអប់រំ វិជ្ជាជីវៈគ្រូបង្រៀន ឯកទេស អក្សរសាស្ត្រខ្មែរ ប្រវត្តិវិទ្យា គណិតវិទ្យា គីមី រូបវិទ្យា និងជីវវិទ្យា
- បរិញ្ញាបត្រអប់រំ ឯកទេសគ្រប់គ្រងអប់រំ
- បរិញ្ញាបត្រអប់រំ ឯកទេសកម្មវិធីសិក្សានិងការបង្រៀនកម្រិតកុមារតូច

- បរិញ្ញាបត្រជាន់ខ្ពស់អប់រំ វិជ្ជាជីវៈគ្រូបង្រៀន ឯកទេស អក្សរសាស្ត្រខ្មែរ ប្រវត្តិវិទ្យា គណិតវិទ្យា គីមី រូបវិទ្យា និងជីវវិទ្យា
- បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសកម្មវិធីសិក្សា និងការបង្រៀន
- បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសសិក្សាអប់រំ
- បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសគ្រប់គ្រង និងអភិវឌ្ឍឧត្តមសិក្សា
- បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសអប់រំពេញមួយជីវិត

- បណ្ឌិតអប់រំ ឯកទេសគ្រប់គ្រងអប់រំ
- បណ្ឌិតអប់រំ ឯកទេសកម្មវិធីសិក្សា និងការបង្រៀន
- បណ្ឌិតអប់រំ ឯកទេសអភិវឌ្ឍការអប់រំ
- បណ្ឌិតអប់រំ ឯកទេសអភិវឌ្ឍធនធានមនុស្ស និងអប់រំពេញមួយជីវិត

**មហាវិទ្យាល័យអប់រំក៏មានផ្តល់សេវាប្រឹក្សាយោបល់ និងស្រាវជ្រាវអប់រំផងដែរ។**

សម្រាប់ព័ត៌មានបន្ថែម សូមស្កេនខាងក្រោម

www.facebook.com/rupp.edu.kh

www.rupp.edu.kh/fed/

Facebook Page
Faculty of Education